ពុទ្ធប្បវត្តិ

ដោយរូបភាព

LIFE OF THE BUDDHA

IN PICTURES

រំលេចរូបភាពដោយ

គុណរត្ន ជយកោធី

ប . វិចក្រមនាយក

សុនិល គមិនិ

ឧបសេន គុណាវធនេណោ

បោះពុម្ពលើកទីមួយ

២៨ ឧសភា ១៩៩១ (ថ្ងៃពេញបូរមី ខែពិសាខ)

បោះពុម្ពលើកទីពីរ

៦ ឧសភា ១៩៩៣ (ថ្ងៃពេញបូរមី ខែពិសាខ)

បោះពុម្ពលើកទីបី

២៥ ឧសភា ១៩៩៤ (ថ្ងៃពេញបូរមី ខែពិសាខ)

បោះពុម្ពនៅសិង្ហបូរី

បោះពុម្ពជាភាសាខ្មែរ

៧ ឧសភា ២០០១ (ថ្ងៃពេញបូរមី ខែពិសាខ)

នៅភ្នំពេញព្រះរាជាណាចក្រកម្ពុជា

ក្របមុខ

ព្រះពុទ្ធរូបៈ ផ្ទាំងគំនូរនៅលើជញ្ជាំងព្រះវិហារ ជយន្តិ

ក្រុងវេរគោទ ប្រទេសស្រីលង្កា

រក្សាសិទ្ធិ
អ្នកនិពន្ធ និង អ្នកបោះពុម្ពផ្សាយ

ព្រះតេជព្រះគុណ **ទេវគោរ សរទ មហាថេរោ**

បកប្រែជាភាសាខ្មែរ
ភិក្ខុ **ញៀម គីម តេង**
យី ធន់

ពិនិត្យផ្ទៀងផ្ទាត់ដោយ
ធម្មបណ្ឌិត **ហេង មណីចិន្តា**

បោះពុម្ពនៅរោងពុម្ពមិត្តភាព-កម្ពុជា ជប៉ុន
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឧសភា ២០០១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
~~~~~

ក្រសួងធម្មការ និងសាសនា

លេខ ៨៦ / ២០០១ / ក.ធ.ស.

លិខិតអនុញ្ញាត

បោះពុម្ពផ្សាយសៀវភៅ "ពុទ្ធប្បវត្តិ-រូបភាព"

(Life of the Buddha in Pictures)

សៀវភៅ "**ពុទ្ធប្បវត្តិ-រូបភាព**" រៀបរៀងដោយព្រះតេជព្រះគុណ **វេរគោទ សរទ** (Ven. Weragoda Sarada) គឺជាសៀវភៅសិក្សាមួយដ៏សំខាន់ សំរាប់អ្នកទាំងឡាយណាដែលជាប់ចិត្ត និងស្រឡាញ់ពុទ្ធសាសនា ពិសេស សំដៅដល់កុលបុត្ត-កុលធីតា នៃប្រជាជនកម្ពុជាគ្រប់ស្រទាប់ ។ តាមរយៈសៀវភៅ "ពុទ្ធប្បវត្តិ-រូបភាព" នេះ, គេប្រាកដជាបានយល់ព្រះពុទ្ធ ដែលជាធម្មទូតដ៏សកម្មបំផុតទីមួយ ក្នុងលោក ។ ព្រះអង្គបានគោចរពីទីមួយ ទៅកាន់ទីមួយទៀត អស់រយៈពេល ៤៥ ឆ្នាំ ដើម្បីផ្សព្វផ្សាយព្រះធម៌ដល់មហាជន និងពួកបញ្ញវន្ត ។ រហូតដល់ខណៈចុងក្រោយ, ព្រះអង្គបានបំរើមនុស្សជាតិ ទាំងតាមគំរូវិរិយភាពរបស់ព្រះអង្គ ទាំងតាមព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ។ សាវ័កដ៏ឆ្នើមៗរបស់ព្រះអង្គ បានយកតម្រាប់តាមគំរូនេះ ។ ថ្វីបើឋិតក្នុងស្ថានភាពក្រខ្សត់ ខ្វះខាតសព្វបែបយ៉ាង, សាវ័កទាំងនោះបាននិមន្តទៅកាន់តំបន់ឆ្ងាយៗ ដើម្បីផ្សព្វផ្សាយព្រះធម៌ ដោយមិនមានបំណងចង់បានអ្វីត្រឡប់វិញឡើយ ។

ក្រសួងធម្មការ និងសាសនា បានចាត់បញ្ចូលសៀវភៅនេះ ក្នុងពពួកសៀវភៅនៃមុខវិជ្ជាអប់រំសីលធម៌ និងអភិសមាចារសង្គមខ្មែរ ហើយអនុញ្ញាតឱ្យអង្គការសន្តិស្មគ្រចិត្តជប៉ុន ប្រចាំនៅកម្ពុជា (Santi Volunteer Association " SVA ", Cambodia) បោះពុម្ព និងចែកផ្សាយសៀវភៅនេះ ឱ្យបានទូលំទូលាយ ទាំងនៅក្នុងស្ថាប័នសិក្សាអប់រំ ទាំងនៅក្នុងស្ថាប័នរដ្ឋ ។

ភ្នំពេញ ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០០១

រដ្ឋមន្ត្រី

ក្រសួងធម្មការ និងសាសនា

ជា_សារឿន
~~~~~

ពុទ្ធប្បវត្តិ

ដោយរូបភាព

LIFE OF THE BUDDHA

IN PICTURES

THE SINGAPORE BUDDHIST MEDITATION CENTRE
342-D PASIR PANJANG ROAD
SINGAPORE 0511
TEL: 7783330 FAX: 7730150

អំពីអ្នកនិពន្ធ



ព្រះភិក្ខុ វេរគោទ សរទ មហាថេរោ ទ្រង់ប្រសូត្រនៅឆ្នាំ១៩៤១នៅកោះស្រីលង្កា ។ ព្រះអង្គបានសាងផ្នួសជាភិក្ខុ នៅក្នុងឆ្នាំ១៩៥៣ ។ ព្រះអង្គបានសិក្សា និងទទួលសញ្ញាប័ត្រពីសកលវិទ្យា-ល័យវិទ្យោទ័យនៃប្រទេសស្រីលង្កាក្នុងឆ្នាំ១៩៦៤ ។ ដោយមានជំនាញខាងភាសាបាលី ភាសាសំស្ក្រឹត និងវិជ្ជាពុទ្ធសាសនា ព្រះអង្គធ្លាប់បានធ្វើជានាយកនៃមហាវិទ្យាល័យឥន្ទ្រូបថ្វិល ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៦៧ និងជានាយកនៃមហាវិទ្យាល័យសុទម៉ារាម ពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៦៩ផងដែរ ។ ព្រះភិក្ខុ សរទ បាននិមន្តចាកចេញពីប្រទេស ស្រីលង្កា ក្នុងឆ្នាំ១៩៦៩ទៅគង់នៅប៉េណាំង ប្រទេសមាឡេស៊ី ដែលនៅទីនោះព្រះអង្គបានទទួល តំណែងជានាយកនៃសាលាបាលីរបស់វត្ត មិហិន្ទារាម រហូតដល់ឆ្នាំ១៩៧៩ ។

ព្រះអង្គបាននិមន្តទៅប្រទេសសិង្ហបូរីនៅឆ្នាំ១៩៧៩ និងបានបង្កើតមជ្ឈមណ្ឌលវិបស្សនាសិង្ហបូរី ដែលនៅទីនោះព្រះអង្គជាប្រធានសង្ឃរហូតមក ។ ព្រះអង្គជាស្ថាបនិកមួយអង្គ ក្នុងចំណោមស្ថាបនិកទាំងឡាយនៃសមាគមពុទ្ធសាសនិកស្រីលង្កា អាមេរិកនៅ ក្រុងញូវយ៉ក ដែលព្រះអង្គមានឋានៈជាប្រធានរហូតដល់សព្វថ្ងៃ ។ ព្រះអង្គជាប្រធានស្ថាបនិកនៃមជ្ឈមណ្ឌលពុទ្ធសាសនាស្រីលង្កា ជប៉ុន ដែលសព្វថ្ងៃព្រះអង្គទទួលបន្ទុកជាអគ្គលេខាធិការ ។ នៅក្នុងប្រទេសស្រីលង្កា ព្រះអង្គជាចៅអធិការនៃវត្តជយន្តីវិហារ ខេត្តវេរគោទ ។

កិច្ចការចំបងរបស់ព្រះភិក្ខុសរទ ក្នុងការបំរើព្រះពុទ្ធសាសនា គឺការបោះពុម្ពផ្សាយសៀវភៅស្តីអំពីព្រះពុទ្ធសាសនា ហើយដែលបានចែកផ្សាយដោយឥតគិតថ្លៃរួចហើយអស់ប្រហែលមួយលានច្បាប់ នៅទូទាំងពិភពលោក ។ រហូតមកដល់បច្ចុប្បន្ននេះ ព្រះអង្គបានបោះពុម្ពសៀវភៅបានចំនួន៦៨ចំណងជើង ដែលក្នុងចំណោមនោះមាន៦ចំណងជើងជាស្នាព្រះហស្តផ្ទាល់របស់ព្រះអង្គនោះគឺៈ *ហេតុអ្វីបានជាខ្លាចសេចក្តីស្លាប់? ព្រះពុទ្ធវចនៈ, សមាធិអំពីមេត្តាករុណា, វិធីធ្វើសមាធិបែបពុទ្ធសាសនា, ពុទ្ធសាសនាសំរាប់អ្នករៀនថ្នាក់ដំបូង និងពុទ្ធប្បវត្តិដោយរូបភាព* ដែលជាសៀវភៅដ៏ល្បីល្បាញរបស់ព្រះអង្គ ។ សៀវភៅដែលនឹងចេញផ្សាយរបស់ព្រះអង្គ គឺជាស្នាដៃដ៏សម្បើមមួយឈ្មោះ *រតនាគារនៃសច្ចធម៌* ដែលមានរំលេចដោយផ្ទាំងគំនូរផាត់ពណ៌យ៉ាងប្រណីត ចំពោះគាថាទាំង៤២៣ នៃគម្ពីរធម្មបទ ។

ពុទ្ធប្បវត្តិ

ដោយរូបភាព

LIFE OF THE BUDDHA
IN PICTURES

ដោយ

ព្រះតេជព្រះគុណ **វេរគោឌ សរទ មហាថេរោ**

by
Ven. Weragoda Sarada Maha Thero

Advisory Board

Ven. Banagala Upatissa Maha Nayaka Thero
Ven. Malimbada Mangala Thero
Ven. Muwagama Gnanaseeha Thero
Ven. Tiniyawala Palita Thero
Ven. Zenyu Noguchi (Japan)
Ven. Budhasasanajotako J. Osada (Japan)
Rev. Eiyu Ishii (Japan)
Rev. Daijyo Nakajima (Japan)
Rev. Ando Shodo (Japan)
Miss Lee Foong Ming
Mr. Ee Fook Choy
Mr. Daya Satarasinghe
Mr. Upul Rodrigo
Mr. Edwin Ariyadasa
Mr. Dennis Wang Khee Pong

ព្រះពុទ្ធរូបធំជាងគេបំផុត

វត្តមតរ វេហេរហេន, មតរ, ស្រីលង្កា

Largest Buddha Image
Matara Veherahena Temple, Matara, Sri Lanka

ព្រះពុទ្ធ

«បុគ្គលឯក កាលកើតឡើងក្នុងលោក
ក៏រមែងកើតឡើងដើម្បីជាគុណដល់ជនច្រើន
ដើម្បីសេចក្ដីសុខដល់ជនច្រើន
ដើម្បីអនុគ្រោះដល់សត្វលោក
ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ
ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ
បុគ្គលឯក តើ គឺនរណា គឺព្រះតថាគត អរហន្ត សម្មាសម្ពុទ្ធ»

អង្គុត្តរនិកាយ

THE BUDDHA

"A unique being, an
extraordinary man arises in this
world for the benefit of the
many, for the happiness of the
many, out of compassion for
the world, for the good, benefit,
and happiness of gods and
men. Who is this unique being?
He is the Tathāgata, the Exalted,
Fully Enlightened One."

Anguttara Nikāya,

សេចក្ដីសង្ខេបនៃ «**ចតុរារក្ខភាវនា**»

នមាមិ ពុទ្ធំ គុណសាគរន្តំ
សត្តា សទា ហោន្តុ សុខី អវេរា
កាយោ ជិគុច្ឆោ សកលោ ទុគន្ធោ
គច្ឆន្តិ សព្វេ មរណំ អហំ ច ។

ខ្ញុំព្រះករុណា សូមថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ដ៏ជាមហាសមុទ្រនៃគុណធម៌ ។
សូមឱ្យសត្វលោកទាំងអស់បានសុខ និងរួចរំដោះផុតពីពៀរវេរា ។
រូបកាយជាវត្ថុគួរឱ្យខ្ពើម និងពោរពេញទៅដោយក្លិនអសោច ។
សព្វសត្វទាំងឡាយ រួមទាំងខ្ញុំព្រះករុណា សុទ្ធតែស្លាប់ទៅវិញទាំងអស់គ្នា ។

(កំណត់សម្គាល់៖ ឃ្លាទីមួយសំដៅ ពុទ្ធានុស្សតិ ។ ឃ្លាទីពីរសំដៅ មេត្តានុស្សតិ ។ ឃ្លាទីបីសំដៅ កាយានុស្សតិ ។ ឃ្លាទីបួនសំដៅ មរណានុស្សតិ ។ ចំពោះជនណាដែលចង់បានការណែនាំជាវិជ្ជមាននោះ ព្រះពុទ្ធសាសនាបានផ្ដល់នូវ ទស្សនៈសម្រាប់ការពារបួនយ៉ាងនេះ ។ ទស្សនៈទាំងនេះគ្រាន់តែជាប្រធានបទបួន ឬកម្មវត្ថុបួននៃការចម្រើនភាវនា និងធ្វើសមាធិ ប៉ុន្តែការជ្រើសរើសយកប្រធានបទទាំងនេះចេញពីប្រជុំនៃប្រធានបទទាំងឡាយ ដែលម្នាក់ៗអាចធ្វើសមាធិក្នុងពេលដែលគេប៉ុនប៉ងធ្វើឱ្យសុក្រឹតនូវការហាត់ពត់ខាងផ្លូវចិត្តនោះ គឺជាការបរិយាយដោយសរសើរអំពីសុខុមញ្ញាណនៃការប្រតិបត្តិរបស់ព្រះពុទ្ធ ។)

The Buddha Statue in the Image House of Jayanthi Viharaya, Weragoda, Meetiyagoda, Sri Lanka, erected on 3 June, 1953. It is inarguably the most beautiful and serene-looking image of the Buddha ever sculptured. The Author wishes to transfer all the merits that he has accrued in printing Buddhist literature and propagating Buddhism to his late Teacher the **Venerable Pandit-Yatalmatte Wajiranana Maha Nayaka Thero** who was the late Chief Monk of Jayanti Viharaya, Weragoda, Meetiyagoda, Sri Lanka. It was his unending efforts that saw to the successful erection of the Statue.

កាលាមសុត្ត

អលំ ហិ វោ កាលាមា កង្ខិតុំ អលំ វិចិកិច្ឆិតុំ កង្ខានិយេ ច[១] បន វោ ឋានេ វិចិកិច្ឆា ឧប្បន្នា ។ ឯថ តុម្ហេ កាលាមា មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ ។ យទា តុម្ហេ កាលាមា អត្តនា វ ជានេយ្យាថ ឥមេ ធម្មា អកុសលា ឥមេ ធម្មា សាវជ្ជា ឥមេ ធម្មា វិញ្ញុគរហិតា ឥមេ ធម្មា សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តីតិ អថ តុម្ហេ កាលាមា បជហេយ្យាថ ។

ម្នាលកាលាមក្សត្រិយ៍ គួរអ្នកទាំងឡាយងឿងឆ្ងល់ដែរ គួរសង្ស័យដែរ ព្រោះការងឿងឆ្ងល់និងការសង្ស័យកើតឡើងដល់អ្នកទាំងឡាយក្នុងទីនេះហើយ ។ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់តម្រូវផ្សេងៗ[២] កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថាសមណៈ (នេះ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះបុគ្គលបានសមាទានពេញលេញហើយរមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយក្នុងកាលនោះ អ្នកទាំងឡាយត្រូវលះបង់ចោលចេញ ។

អង្គុត្តរនិកាយ ទុតិយភាគ (ក្បាលទី៤១) ទំព័រ ២១៨-២១៩
(ទុតិយបណ្ណាសក មហាវគ្គ)

ព្រះសម្មាសម្ពុទ្ធ

(១) តាមគម្ពីរព្រះត្រៃបិដកខ្មែរថាៈ កង្ខានិយេវ
(២) គម្ពីរព្រះត្រៃបិដកខ្មែរថាៈ កាត់ជំរួយផ្សេងៗ

កាលាមសូត្រ

កុំជឿលើអ្វី ដោយគ្រាន់តែអ្នកបានឮ

កុំជឿតាមពាក្យបរម្បរា ដោយសារតែវា ជាប្រពៃណីដែលគេធ្លាប់ជឿរាប់តំណមកហើយ

កុំជឿលើអ្វី ដោយសារតែ មានគេនិយាយ និងជាពាក្យចចាមអារ៉ាមតៗគ្នា

កុំជឿលើអ្វី ដោយគ្រាន់តែឃើញថា មានសរសេរនៅក្នុងគម្ពីរសាសនារបស់អ្នក

កុំជឿលើអ្វី ដោយសារតែវា ជាពាក្យប្រៀនប្រដៅរបស់គ្រូអ្នក និងចាស់ទុំរបស់អ្នក

ប៉ុន្តែក្រោយពេលបានសង្កេតនិងវិភាគល្អិតល្អន់ និងនៅពេលដែលអ្នកយល់ឃើញថា ធម៌ទាំងនោះវាសមស្របនឹងវិចារណញ្ញាណ និងដែលនាំមកនូវគុណប្រយោជន៍ចំពោះមនុស្សទូទៅហើយ ពេលនោះសូមទទួលយក និងជឿតាមចុះ ។

ព្រះសម្មាសម្ពុទ្ធ



បណ្ឌិត យតលមត្តេ ស្រី វចិស្សរៈ មហាថេរោ ជាព្រះឧបជ្ឈាយ៍
និងជាព្រះគ្រូរបស់ព្រះភិក្ខុ វេរគោទ សរទ មហាថេរោ

වේරගොඩ ජයන්ති විහාරාධිපති ***පණ්ඩිත යටලමත්තේ සිරි වාචිස්සර***
ජිනරතන වජිරඤාණාභිධාන ගාල්ල කෝරළයේ ප්‍රධාන සංඝනායක හිමිපාණෝ

යො මාං ප්‍රව්‍රාජයිත්වා ජනක ඉවමුද මෙ'හිවෘද්ධිං ව්‍යධත්ත
ශ්‍රී වජ්‍රඥානනාමා යටලමතුරිති ග්‍රාමජාතො යතීන්ද්‍රඃ
ග්‍රන්ථං තස්මා ඉදං මෙ භවතු ච ගුරවෙ දක්ෂිණාවත් ප්‍රශස්තං
පුණ්‍යෙනෛතෙන භූයාත් පරම මමෘතදං ශ්‍රෙයසඥචාපිතයෙම
"මා පැවිදි කරවා පියකු මෙන් සතුටින් මගේ දියුණුව සිදු කළ යටලමත්තේ ශ්‍රී වජිරඤාණ
ගුරුදේව ස්වාමීන්ද්‍රයන් වහන්සේට මේ මහහු ග්‍රන්ථය පූජාවක් වේවා. මේ පිනෙන්
උන්වහන්සේට අමාමහ නිවන් සැප ලැබේවා"

රචනය පණ්ඩිත දවුල්දෙන ඤාණිස්සර නායක ස්වාමීන්ද්‍රයන් වහන්සේ

ពិធីបុណ្យឆ្លង និង ប្រគល់សៀវភៅ
រតនាគារនៃសច្ចធម៌- ធម្មបទដោយរូបភាព

អ្នកនិពន្ធ:

ព្រះតេជព្រះគុណ វេរគោទ សរទ មហាថេរោ ប្រគេន
រតនាគារនៃសច្ចធម៌- ធម្មបទដោយរូបភាព
ចំពោះព្រះតេជព្រះគុណ សេក ហ្វាត់ គួន

អ្នកនិពន្ធ:

ព្រះតេជព្រះគុណ វេរគោទ សរទ មហាថេរោ ប្រគេន
រតនាគារនៃសច្ចធម៌- ធម្មបទដោយរូបភាព
ចំពោះប្រធានគណសង្ឃនៃប្រទេស សីរីលង្កា
(និកាយ កុត្ត)

អ្នកនិពន្ធ:

ព្រះតេជព្រះគុណ វេរគោទ សរទ មហាថេរោ
ជាមួយនឹងគណកម្មការនិពន្ធ និង ក្រុមអ្នកទ្រទ្រង់
ក្នុងឱកាសបុណ្យឆ្លង និង ប្រគល់សៀវភៅ

អ្នកនិពន្ធ:

ព្រះតេជព្រះគុណ វេរគោទ សរទ មហាថេរោ
ថ្លែងសុន្ទរកថា ក្នុងពេលបុណ្យ

ខ្ញុំសូមគោរពអ្នកយ៉ាងជ្រាលជ្រៅ ។ ខ្ញុំមិនស្អប់អ្នកទេ ។ ហេតុអ្វីបានជាដូច្នេះ? ពីព្រោះតែអ្នកអាចប្រតិបត្តិតាមមាគ៌ារបស់ព្រះពោធិសត្វបាននិងអាចក្លាយទៅជាព្រះពុទ្ធបានទៅអនាគត ។

ដកស្រង់ចេញពីគម្ពីរ បុណ្ឌរីកសូត្រ

I respect you deeply. I do not despise you. Why is it? It is because you will be able to practise the Way of Bodhisattvas and to become Buddhas.

From The Lotus Sutra

ពីឆ្វេងទៅស្តាំៈ ព្រះតេជព្រះគុណ **ស៊ីប៊្វីយ៉ា កូជូ** , ព្រះតេជព្រះគុណ **ណាកាជិមា ដាយជ្យូ** ,
ព្រះតេជ ព្រះគុណ **អន់ជូ សូជូ** , ព្រះតេជព្រះគុណ **វេរគោទ សរទ មហាថេរោ** (អ្នកនិពន្ធ),
ព្រះតេជព្រះគុណ **មលិម្ពទ មង្គល** , ព្រះតេជព្រះគុណ **អ៊ីស៊ីអ៊ី អេអ៊ីយុ**
និងព្រះតេជព្រះគុណ **អូសាកា កូយុ** ។

LOTUS BUDDHISM INTERNATIONAL SOCIETY	6-9, EBARA 7 SHINAGAWAKU TOKYO, JAPAN	PHONE :81337855576 FAX :81337864577 ZIP :142

ដោយបានថែរក្សាខ្ញុំនៅក្នុងផ្ទៃអស់ពេលដប់ខែ និងដោយបានចិញ្ចឹមបីបាច់រក្សាខ្ញុំឱ្យល្អរហូតដល់ធំ
ខ្ញុំសូមថ្វាយបង្គំបាតជើងរបស់ម្តាយខ្ញុំ និងជូនពរគាត់ សូមឱ្យមានអាយុយឺនយូរដល់រយវស្សា ។

វុឌ្ឍិការោ អលិង្គិត្វា ចុម្ពិត្វា បិយា បុត្តកំ
រាជ មជ្ឈំ សុបតិដ្ឋំ បិតុ បាទំ នមាមហំ

ខ្ញុំថ្វាយបង្គំបាតជើងរបស់ឪពុកខ្ញុំ ដែលគាត់បានថើប និងបបោសអង្អែលខ្ញុំ និងស្រឡាញ់ថ្នាក់ថ្នម
ខ្ញុំមិនឱ្យមានហ្មង ទុកដូចជាមហាក្សត្រមួយព្រះអង្គ នៅក្នុងដួងចិត្តរបស់គាត់ ។

**For protecting me within the womb for ten months and for bringing me up well,
I worship the feet of my mother, wishing her a life of a hundred years.**

*Vuddhikāro alingitvā · Chumbitvā piya puttakaṃ
Rāja majjhaṃ supatiṭṭaṃ · Pitu pādam namā maham*

**I worship the feet of my father who kissed and caressed me and placed me
among kings with my welfare at heart.**

ខ្ញុំពុំមានពាក្យនឹងរ៉ាយរ៉ាប់ឡើងវិញអំពីទុក្ខវេទនា ដែលឪពុកខ្ញុំបានទទួលដោយសារតែរូបខ្ញុំ ចាប់តាំងពីថ្ងៃដែលខ្ញុំកើតមកទេ ។ លោកឪពុក ខ្ញុំសូមគោរពលោកឪពុកដោយវិធីយ៉ាងនេះ ដើម្បីលាងឱ្យអស់នូវបាបកម្មទាំងឡាយ ។

ពេលខ្ញុំយំ លោកលួងខ្ញុំឱ្យដេកលក់ ដោយសេចក្តីស្នេហានិងស្រឡាញ់ ។ លោកជូតទឹកលាងសំអាតខ្ញុំ ។ សូមឱ្យលោកឪពុករបស់ ខ្ញុំបានត្រាស់ជាព្រះពុទ្ធទៅថ្ងៃអនាគត ។

ខ្ញុំពុំមានពាក្យនឹងរ៉ាយរ៉ាប់ឡើងវិញអំពីទុក្ខវេទនា ដែលម្តាយខ្ញុំបានទទួលដោយសារតែរូបខ្ញុំ ចាប់តាំងពីថ្ងៃដែលខ្ញុំកើតមកទេ ។ អ្នកម្តាយ ខ្ញុំសូមគោរពអ្នកម្តាយ ដោយវិធីយ៉ាងនេះ ដើម្បីលាងឱ្យអស់នូវបាបកម្មទាំងឡាយ ។

ពេលខ្ញុំយំ អ្នកលួងខ្ញុំឱ្យដេកលក់ ដោយសេចក្តីស្នេហានិងស្រឡាញ់ ។ អ្នកជូតទឹកលាងសំអាតខ្ញុំ ។ សូមឱ្យអ្នកម្តាយរបស់ខ្ញុំបានត្រាស់ ជាព្រះពុទ្ធទៅថ្ងៃអនាគត ។

I have no words to recount the suffering my father underwent, on my behalf, from the day I was born. I worship you this way, O my father, to expiate my sins.

When I cried, you lulled me to sleep, with love and affection. You washed me and cleaned me. My father, may you attain Buddhahood in a future day.

I have no words to recount the suffering my mother underwent, on my behalf, from the day I was born. I worship you this way, O my mother, to expiate my sins.

When I cried, you lulled me to sleep, with love and affection. You washed me and cleaned me. My mother, may you attain Buddhahood in a future day.


Wickrama

19

មាតិកា
CONTENTS

បុព្វកថា Introduction	I - VI
ពុទ្ធប្បវត្តិ Life of the Buddha	01 - 217
លោវាទ សង្គារវៈ ព្រះសូត្រដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ Lowada Sangarava For the Benefit of Mankind	218 - 249
ប្រសិនបើគេកើតជាសត្វតិរច្ឆាន If one is born as an Animal	219
ប្រសិនបើគេជាប្រេតអសុរកាយ If persons are born as manes-evil spirits	220
សូម្បីអណ្តើកងើបពីបាតមហាសមុទ្រ Even if a Turtle emerging from the depth of the Ocean	221
ជនប្រព្រឹត្តបាបកម្ម៥យ៉ាងនៅក្នុងជាតិនេះ People commit five-fold sins during this Birth	222
ជនដែលមានភ្លើងឆេះសក់ A person whose hair is on fire	223
មារៈ (សេចក្តីស្លាប់) រង់ចាំមនុស្សជានិច្ចនិងនៅគ្រប់ទីកន្លែង Mara (Death) awaits man always, in all places	224
ដូចជាសុនខ លិតឆ្អឹងទទេដូច្នោះ Just as a dog licking a dry bone	225
សត្វស្ទាំង កំពុងពាំសាច់មួយដុំ A Hawk carrying a lump of flesh	226
សត្វក្តាមនៅក្នុងឆ្នាំង សប្បាយរហូតដល់ភ្លើងឆេះពីក្រោមវា The Crab in the pot is joyous until the fire is lit under it	227
ស្មៅស្ងួតត្រូវភ្លើងឆេះ The burning dry grass	228
ចោរត្រូវទោសប្រហារជីវិត The Bandit condemned to death	229
ចោរត្រូវប្រហារជីវិត ដោយច្រានទម្លាក់ពីលើចំណោតភ្នំ The Bandit hurled down a precipice to his death	230
បុរសទាំងឡាយត្រូវលះបង់ Men must renounce	231
ជនដែលចូលចិត្តបរិភោគអាហារឆ្ងាញ់ People who enjoy delicious food	232
ថ្វីបើយើងពេញចិត្តនឹងសេចក្តីរីករាយ ដែលយើងមាន Though we are proud of the pleasures we enjoy	233
នៅពេលដែលផ្ទះអ្នកជិតខាងត្រូវចោរប្លន់ When a neighbour's house is burgled	234
ក្អែកល្មោភស៊ីសាកសពដំរី The greedy Crow feeding on the carcass of an Elephant	235
បុរសម្នាក់លង់ទឹកទន្លេដោយគ្មានគេជួយ A Man taken helplessly down the river	236

ជនដែលប្រើសម្តីអេចអូច ជាអាវុធប្រល័យជីវិត
People use the deadly weapon of tale-bearing 237

សត្វកង្កែបនៅពេលវាកំពុងធ្លាក់ជាចំណីនៃសត្វពស់
The frog while being a prey to snakes 238

រឿងស្ត្រីម្នាក់កាត់កពពែញី
Once, a woman cut off the head of a she-goat 239

រឿងបុរសម្នាក់លួចសំលៀកបំពាក់សម្លាញ់របស់ខ្លួនលេងជាល្បែង
Once, a man stole his friend's clothes for fun 240

ជនមានបាប ដោយលួចប្រពន្ធអ្នកដទៃ
A Sinner who coveted the wife of another 241

ព្រះរាជាសម័យបុរាណមួយអង្គ បាត់បង់មហិទ្ធិឫទ្ធិ
An ancient King lost His psychic powers 242

ជនដែលញុះញង់ឱ្យភិក្ខុពីរអង្គទាស់ទែងគ្នា
A person who created dissension between two Bhikkhus 243

រឿងតាបសតិះដៀលព្រះសង្ឃ
Once an Ascetic scolded the Sangha 244

ការបីបាច់រក្សាភិក្ខុសង្ឃ មាតាបិតា គ្រូអាចារ្យ ចាស់ជរា និងជនពិការ
The care of Bhikkhus, Parents, Teachers, the Old, the Infirm 245

រឿងសូមយាចកម្នាក់ គ្រាន់តែដាក់បាត្របាយមួយស្លាបព្រាចំពោះព្រះអនុរុទ្ធថេរ
Once a Beggar gave just a spoonful of Rice to Anuruddha Thero 246

ស្ត្រីម្នាក់ដែលបានកាន់សីលដ៏បរិសុទ្ធ បានតែមួយថ្ងៃប៉ុណ្ណោះ
A Woman who observed virtuous Sila just one day 247

សត្វកង្កែបកំពុងស្តាប់ធម៌របស់ព្រះពុទ្ធ
A Frog listening to the Word of the Buddha 248

ជនទុរគតម្នាក់បានបូជាផ្កាព្រលិតមួយទង ចំពោះព្រះចេតិយ
A poor person offered a humble water-flower to a Stupa 249

ទសបារមី
Ten Perfections 250

ទានបារមី វេស្សន្តរជាតក
The Perfection of Generosity (Dana) Vessantara Jātaka Story (Birth Story) 251

សីលបារមី ឆទ្ទន្តជាតក
Perfection of Morality (Sīla) Chaddanta Jātaka Story 253

នេក្ខម្មបារមី មឃទេវជាតក
Perfection of Renunciation (Nekkhamma) Makhadeva Jātaka Story 255

បញ្ញាបារមី សត្តុភត្តជាតក (សាធុភទ្ទជាតក)
Perfection of Equanimity (Upekkha) Lomahamsa Jātaka Story 257

វិរិយបារមី ព្រះអង្គម្ចាស់ បញ្ចាយុធជាតក
Perfection of Effort (Vīriya) Prince Panchāyudha Jātaka Story 260

ខន្តីបារមី (ខន្តិវាទិជាតក)
Perfection of Patience (Khanti) Khantivādi Jātaka Story 262

សច្ចៈបារមី សុតសោមជាតក
Perfection of Truth (Satya) Sutasoma Jātaka Story 264

អធិដ្ឋានបារមី តេមិយជាតក
Perfection of Determination (Addhitthāna) Themiya Jātaka Story 266

មេត្តាបារមី សាមជាតក (សុវណ្ណសាមជាតក)
Perfection of Loving-Kindness (Mettā) Sāma Jātaka Story 268

ឧបេក្ខាបារមី លោមហង្សជាតក
Perfection of Wisdom (Pañña) Sattubhatta Jātaka Story 270

បរាភវសូត្រ ព្រះសូត្រស្ដីអំពីប្រភពនៃសេចក្ដីវិនាស
Parābhava Sutta Discourse on Downfall 272

ការមិនចូលចិត្តស្ដាប់ព្រះធម៌
Disinclination to the Doctrine 273

ការពេញចិត្តសេពគប់ជនអសប្បុរស មិនចូលចិត្តចំពោះពួកសប្បុរស
Preference of the depraved dislike of the virtuous 274

ភាពជាអ្នកខ្ជិលច្រអូស
Sloth 275

ភាពជាអ្នកចូលចិត្តនិយាយពាក្យឥតប្រយោជន៍
Talkativeness 276

ការបណ្ដោយឱ្យចិត្តក្ដៅក្រហាយមិនចេះចប់
Unceasing irritation 277

ការមិនចិញ្ចឹមមាតាបិតាដែលចាស់ជរា
Not supporting parents 278

ការរកបានប្រាក់ដោយទុច្ចរិត
Obtaining money fraudulently 279

ការមិនចែករំលែកចំណីអាហារ ដែលមានរសជាតិឆ្ងាញ់ដល់អ្នកដទៃ
Non-sharing of good food 280

ការមិនជួយដល់ញាតិក្រីក្រ
Disregarding poor relatives 281

ការងប់នឹងស្រី
Over-fondness for women 282

ការញៀននឹងគ្រឿងស្រវឹង
Desire for intoxicating drinks 283

ការញៀននឹងល្បែងស៊ីសង
Desire for gambling 284

ការចាយទ្រព្យមរតកដោយខ្ជះខ្ជាយ
Wasting inhrieted Wealth 285

ការងប់នឹងស្ត្រីពេស្យា
Seeking the company of Prostitutes 286

បុរសវ័យចាស់រៀបការជាមួយស្ត្រីក្មេង
Marrying very young women when one is old 287

ការភូតកុហកចំពោះសមណព្រាហ្មណ៍
Lying to clergy 288

ការមិនថ្វាយទានដល់សង្ឃ និងអ្នកមានសីល ដែលនិមន្តមកបិណ្ឌបាតក្នុងពេលទទួលទានអាហារ
Not offering alms to Priests who arrive at meal-time 289

ការគ្មានហិរិ និងឱត្តប្បៈ
Lack of shame and fear 290

សេចក្ដីក្រោធខឹង និងសេចក្ដីលោភ
Deception due to anger and greed. 291

ការប្រមាថតិះដៀលព្រះពុទ្ធ និងសាវ័កព្រះអង្គ
Insulting the Buddha & His disciples 292

និវេទនកថា

ដោយបានទទួលសំណូមពរពីព្រះតេជព្រះគុណ **មុចាគី សិក្ស** ប្រធានអង្គការអ្នកស្ម័គ្រចិត្តអន្តរជាតិ សូតូស៊ូ វត្ត **ហ៊ិយុ សិនជី** និងព្រះតេជព្រះគុណ **អ៊ីស៊ី ហ៊ីជីអុ** ប្រធានអង្គការទំនាក់ទំនងព្រះពុទ្ធសាសនាអន្តរជាតិ **ហុកកេ** ឱ្យខ្ញុំជួយបកប្រែសៀវភៅពុទ្ធប្បវត្តិដោយរូបភាពនេះ ពីភាសាអង់គ្លេសមកជាភាសាខ្មែរ ដើម្បីបោះពុម្ពផ្សាយជាប្រយោជន៍ចំពោះពុទ្ធសាសនិកជនកម្ពុជា ខ្ញុំក៏បានទទួលយល់ព្រមបំពេញកិច្ចការនេះដោយស្មោះស្ម័គ្រ ព្រោះដោយយល់ឃើញថា ម្យ៉ាងនៅប្រទេសកម្ពុជា ពីមុនមកពុំធ្លាប់បានបោះពុម្ពផ្សាយសៀវភៅប្រភេទនោះទេគឺមានតែសៀវភៅពុទ្ធប្បវត្តិជាអត្ថបទសុទ្ធ ។ ចំពោះពុទ្ធប្បវត្តិជារូបភាពវិញ យើងមានតែគំនូរនៅតាមជញ្ជាំងព្រះវិហារតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតសៀវភៅពុទ្ធប្បវត្តិ ដែលបានបោះពុម្ពកន្លងមកសម្រាប់តែបំរើការអានរបស់ព្រះភិក្ខុសង្ឃ ដែលសិក្សារៀនសូត្រអំពីព្រះពុទ្ធសាសនាបានច្រើនបង្គួរហើយ ដូច្នេះកុមារនិងយុវជនយើង ដែលមិនធ្លាប់បានរៀនអំពីវិជ្ជាពុទ្ធសាសនានេះមានការលំបាកច្រើនក្នុងការអានសៀវភៅទាំងនោះ ។ ខ្ញុំយល់ថា សៀវភៅពុទ្ធប្បវត្តិដោយរូបភាពនេះមាន ប្រយោជន៍ខ្លាំងណាស់សម្រាប់កុមារ និងយុវជនយើងដែលទើបចាប់ផ្តើមរៀនសូត្រអំពីវិជ្ជាព្រះពុទ្ធសាសនា ក៏ដូចជាចំពោះពុទ្ធសាសនិកជនដែលមិនចេះអក្សរផងដែរ ។

នៅក្នុងការបកប្រែសៀវភៅនេះ ខ្ញុំបានពិគ្រោះយោបល់ជាច្រើនលើកច្រើនសា ជាមួយសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** ព្រមទាំងបានផ្ទៀងផ្ទាត់ជាមួយសៀវភៅ និងឯកសារជាច្រើន ទាំងភាសាខ្មែរ ទាំងភាសាបាលី មានគម្ពីរព្រះត្រៃបិដកភាសាខ្មែរ និងភាសាអង់គ្លេស សៀវភៅពុទ្ធប្បវត្តិកថា សៀវភៅពុទ្ធប្បវត្តិទូរេនិទាន អវិទូរេនិទាននិងពុទ្ធប្បវត្តិសន្តិកេនិទានជាដើម ព្រមទាំងបានពិគ្រោះជាមួយព្រះតេជព្រះគុណបណ្ឌិត **បញ្ញាតិស្ស:** ដែលជាព្រះសង្ឃស្រីលង្កាមួយអង្គមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះភិក្ខុ **ទេរគោឌ សរទ មហាថេរោ** ដែលជាអ្នកនិពន្ធសៀវភៅនេះផងដែរ ក្នុងគោលបំណងធ្វើឱ្យអត្ថបទបកប្រែមានន័យសេចក្តីខិតមកជិតដំណើររឿង ដែលប្រជាជនខ្មែរយើងធ្លាប់បានស្តាប់ បានអានពីបុរាណរៀងមក ។ ហេតុដូច្នេះ បានជាជួនកាលអត្ថបទភាសាខ្មែរ មិនដូចអត្ថបទភាសាអង់គ្លេសទាំងស្រុងទេ ។ ប៉ុន្តែក៏មិនឱ្យឃ្លាតចាកឆ្ងាយពីអត្ថបទដើមពេកដែរ ។ ហេតុដូច្នេះ ខ្ញុំសូមអភ័យទោសជាមុន ចំពោះការខុសឆ្គងទាំងឡាយដែលអាចកើតមានជាយថាហេតុ និងដោយអចេតនា ទាំងនៅក្នុងការបកប្រែ ទាំងក្នុងការរៀបរៀង និងសូមលោកអ្នកទាំងឡាយមេត្តាជួយកែតម្រូវឱ្យទានផង ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះសម្តេចព្រះធម្មលិខិត ដែលបានជួយផ្ទៀងផ្ទាត់អត្ថបទជាភាសាបាលី និងជួយកែលំអឃ្លាប្រយោគដែលប្រែមកជាភាសាខ្មែរទៀតផង ។ ទន្ទឹមនឹងនេះដែរ ខ្ញុំសូមថ្លែងនូវអំណរព្រះគុណយ៉ាងជ្រាលជ្រៅចំពោះព្រះតេជព្រះគុណ **ញៀម គឹមតេង** ប្រធានអង្គការសន្តិសេនាខេត្តស្វាយរៀង ដែលព្រះអង្គបានឆ្លៀតឱកាសជួយបកប្រែសៀវភៅនេះត្រង់ផ្នែកទសបារមី និងបរាភវសូត្រ និងចំពោះព្រះតេជព្រះគុណបណ្ឌិត **បញ្ញាតិស្ស:** ដែលបានជួយបំភ្លឺសេចក្តីក្នុងអត្ថបទខ្លះដែលទាក់ទងទៅនឹងប្រពៃណីទំនៀម ទម្លាប់អ្នកកោះស្រីលង្កា ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះលោកធម្មបណ្ឌិត **ហេង មណីចិន្តា** ដែលបានជួយពិនិត្យផ្ទៀងផ្ទាត់ចំពោះការបកប្រែ និងជួយរៀបរៀងអត្ថបទទៅតាមលំនាំរឿងរបស់ខ្មែរយើង ។

ខ្ញុំសូមអរគុណដោយស្មោះអស់ពីដួងចិត្តចំពោះលោក **ហាម ទិចិត្រ** ជាបុគ្គលិករបស់អង្គការសន្តិស្ម័គ្រចិត្ត ដែលបានចំណាយពេលយ៉ាងច្រើនក្នុងការចម្លងអត្ថបទធ្វើជាគំរូដើមសម្រាប់បោះពុម្ព ដែលប្រសិនបើគ្មានការព្យាយាមយ៉ាងស្វិតស្វាញរបស់គាត់ទេនោះ សៀវភៅនេះនឹងមិនអាចបោះពុម្ពទាន់ពេលវេលាបានទេ ។

នៅទីបញ្ចប់នេះ ខ្ញុំសូមឧទ្ទិសផលានិសង្ស ដែលបានមកពីការបកប្រែ និងការបោះពុម្ពផ្សាយសៀវភៅពុទ្ធប្បវត្តិនេះចំពោះការរីកចំរើនរុងរឿងរបស់ព្រះពុទ្ធសាសនា និងសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជនកម្ពុជា ។ សូមសន្តិភាពកើតមានចំពោះមនុស្សម្នាទាំងអស់នៅលើសកលលោក ។

ភ្នំពេញ, ថ្ងៃទី៧ ខែមករា ឆ្នាំ២០០១

យី ធន់

អតីតទីប្រឹក្សាអមក្រសួងធម្មការនិងសាសនា



បុព្វកថា

ពេលដែលខ្ញុំព្រះករុណា អាត្មាភាពបានទទួលសៀវភៅពុទ្ធប្បវត្តិនេះ ពីសំណាក់ព្រះចៅអធិការ **អ៊ីស៊ី ហ៊ីដិអុ** ប្រធានអង្គការទំនាក់ទំនងព្រះពុទ្ធសាសនាអន្តរជាតិ **ហុកកេ** ជាលើកដំបូង ខ្ញុំព្រះករុណា អាត្មាភាពមានសេចក្តីរំភើបយ៉ាងខ្លាំងដោយឃើញភាពប្រណីតរបស់សៀវភៅនេះ ។ ពេលនោះខ្ញុំព្រះករុណា អាត្មាភាព ក៏នឹកភ្លាមថា ខ្ញុំព្រះករុណា អាត្មាភាពចង់ឱ្យប្រជាជនកម្ពុជាបានមើល និងអានសៀវភៅនេះផងដែរ ។

ប្រទេសកម្ពុជា ជាប្រទេសដែលគោរពប្រតិបត្តិព្រះពុទ្ធសាសនាតាំងពីបុរាណកាលមក ។ ដូច្នេះខ្ញុំព្រះករុណា អាត្មាភាពគិតថាប្រជាជនកម្ពុជាមានការយល់ដឹងច្រើនអំពីពុទ្ធប្បវត្តិ ប៉ុន្តែដោយសារតែប្រទេសកម្ពុជាជួបប្រទះនឹងសង្គ្រាម ប្រកបដោយសោកនាដកម្មដែលមិនធ្លាប់មាន ខ្ញុំព្រះករុណា អាត្មាភាពគិតថាប្រហែលឯកសារទាំងឡាយត្រូវបាត់បង់ ដូច្នេះខ្ញុំព្រះករុណា អាត្មាភាព ក៏បានប្រគល់សៀវភៅនោះដល់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងវត្តអារាមមួយចំនួន ។

ពេលធ្វើការប្រគល់សៀវភៅនោះ ខ្ញុំព្រះករុណា អាត្មាភាព បានទទួលសំណូមពរសូមឱ្យជួយបោះពុម្ពសៀវភៅនេះដោយប្តូរអត្ថបទពី ភាសាជប៉ុននិងអង់គ្លេស មកភាសាខ្មែរនិងអង់គ្លេសវិញ ។

絵でみる釈尊の生涯の刊行にあたって

この「絵でみる釈尊の生涯」を法華仏教国際交流協会会長の石井英雄上人からいただいたとき、大変よくできているので感動しました。すぐ頭に浮かんだことは、カンボジアの人々にも見て、読んでいただきたいという思いでした。

もとよりカンボジアは仏教国です。カンボジアの人々は、仏陀の生涯について熟知していると思いましたが、古今未曾有の悲劇を体験したあとですので、もしやと思い仏教研究所並びに、いくつかのお寺に贈呈させていただきました。

間もなく、日本語と英語の対訳版のその本をカンボジア語と英語の対訳版にして出版していただきたいという要望が届きました。

ពេលនោះ ខ្ញុំព្រះករុណាអាត្មាភាពបានពាំនាំសំណូមពរនោះទៅប្រគេនព្រះចៅអធិការ ប្រធានអង្គការទំនាក់ទំនងព្រះពុទ្ធសាសនាអន្តរជាតិ **ហុកកេ** ហើយយើងក៏សម្រេចចិត្តធ្វើសហប្រតិបត្តិការ រវាងអង្គការទំនាក់ទំនងព្រះពុទ្ធសាសនាអន្តរជាតិ **ហុកកេ** និងអង្គការអ្នកស្ម័គ្រចិត្តអន្តរជាតិសូតូស៊ូ វត្ត**ហ្វ៊ុឃុសិនជី** ដើម្បីបោះពុម្ពសៀវភៅនេះជាភាសាខ្មែរឡើងហើយប្រគល់ជូនប្រទេសកម្ពុជា ។

ខ្ញុំព្រះករុណា អាត្មាភាពក៏ សូមថ្លែងនូវអំណរព្រះគុណចំពោះព្រះតេជព្រះគុណ **សរទ មហាថេរោ** នៃប្រទេសស្រីលង្កា ដែលបានជួយជ្រោមជ្រែងយ៉ាងអស់ពីព្រះហឫទ័យ ក្នុងការបោះពុម្ពសៀវភៅជាភាសាខ្មែរនេះ ។

ខ្ញុំព្រះករុណា អាត្មាភាពទាំងអស់ជាពុទ្ធសាសនិកជនជប៉ុន មានបំណងសូមប្រគេន និងផ្ញើសៀវភៅនេះជូនប្រទេសកម្ពុជា ដើម្បីឱ្យបានជាគម្ពីរសម្រាប់ប្រទេសដែលគោរពប្រតិបត្តិព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

ខ្ញុំព្រះករុណា អាត្មាភាពជឿជាក់ថា ព្រះពុទ្ធសាសនាគឺជាសាសនាដែលអាចធានារកសន្តិភាព និងសុភមង្គលជូនពិភពលោកបាន ។

ខែធ្នូ ឆ្នាំ២០០០
អង្គការអ្នកស្ម័គ្រចិត្តអន្តរជាតិ សូតូស៊ូ វត្ត**ហ្វ៊ុឃុសិនជី**
ប្រធាន
មុចាគី សីក្យូ

そこで法華仏教国際交流協会の会長さんにその旨伝え、曹洞宗福泉寺国際ボランティア会と共同でカンボジア語版を刊行して、カンボジアに贈ることにしました。

カンボジア語版の製作に快く応えてくださったスリランカ僧、サラダ大僧正に心からお礼申し上げます。

私たち日本の仏教徒は、カンボジアが仏教国の典型になることを希望してこの本を贈らせていただくのです。

仏教こそが世界に平和と幸福を約束する宗教だと信じているからです。

曹洞宗福泉寺国際ボランティア会
代表　無着　成恭

ព្រះតេជព្រះគុណ **អ៊ីស៊ី ហ៊ីដិអុ** (គង់ជួរមុខទីពីរពីស្តាំ)
និងសប្បុរសជន ដែលឧបត្ថម្ភចំពោះការបោះពុម្ពសៀវភៅនេះ

បុព្វកថា

នៅក្នុងឱកាសនេះ ខ្ញុំព្រះករុណា អាត្មាភាព មានសេចក្តីសប្បាយរីករាយ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះចៅអធិការវត្ត **ហ៊្វុឃុសិនជី** ព្រះនាម **មូចាគី សីក្យូ** និងឧបាសិកា **តូគី** ព្រមទាំងអង្គការសន្តិស្មគ្រចិត្តដែលព្រះអង្គ និងអស់លោកទាំងអស់ បានធ្វើសហប្រតិបត្តិការណ៍ក្នុងការបោះពុម្ព និងចែកចាយសៀវភៅពុទ្ធប្បវត្តិនេះ ។

សៀវភៅនេះ ជាគំនិតផ្តួចផ្តើមដំបូងរបស់ព្រះតេជព្រះគុណ **វេរគោឌ សរឌ មហាថេរោ** ហើយនៅក្នុងការងារបោះពុម្ពសៀវភៅលើកនេះ ព្រះមហាថេរោបានសំណូមពរឱ្យមានកិច្ចសហប្រតិបត្តិការណ៍គ្រប់ផ្នែក ដោយចាត់ទុកថា «សិទ្ធិនៃការបោះពុម្ពផ្សាយ គឺស្ថិតនៅលើព្រះពុទ្ធ» ។ ម្យ៉ាងទៀត នៅក្នុងកិច្ចការបកប្រែនេះទៀតសោតលោក **យី ធន់** ដែលជាអតីតមន្ត្រីក្រសួងធម្មការនិងសាសនា បានខំប្រឹងប្រែងអស់ពីលទ្ធភាពជាមួយនេះបណ្ឌាពុទ្ធបរិស័ទជាច្រើន ដែលមានសទ្ធាដ៏បរិសុទ្ធក៏បានក្លាយជាកម្លាំងជាមូលដ្ឋាន នៅក្នុងការបោះពុម្ពផ្សាយនាគ្រានេះផងដែរ ។

សតវត្សទី២១ បានឈានចូលមកដល់ហើយ ។ ប៉ុន្តែកាលពីនៅក្នុងសតវត្សទី២០ ទន្ទឹងនឹងការអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រ

この度、クメール語訳仏伝絵本LIFE OF THE BUDDHA を、福泉寺ご住職無着成恭師並びにご内室とき様、そして、SVAの皆様方との共同で出版、贈呈の運びとなりました事を、心より喜び、感謝申し上げる次第であります。

この絵本は、スリランカ僧侶ウェラゴダ．サラダ上人の発願によるものであり、今回の出版に際しても、サラダ師は「この本の版権は釈尊にあります」として、全面的な協力を申し出てくださいました。また翻訳に当っては、元カンボジア宗教省 YI THON氏が大変なご努力をされるなど、多くの方々の信仰心と、真心が今回の出版への原動力となりました。

時はまさに２１世紀と言う新たな世紀を迎えました。２０世紀は科学の発展と共に、人類史上

នៅក្នុងប្រវត្តិសាស្ត្រមនុស្សលោកក៏បានបញ្ជាក់ថា ជាសតវត្ស ដែលបានសម្លាប់រង្គាលយ៉ាងព្រៃផ្សៃ តាមរយៈការធ្វើសង្គ្រាម ។

ជាពិសេសនៅក្នុងប្រទេសកម្ពុជា តាមរយៈសង្គ្រាមផ្ទៃក្នុងមិនត្រឹមអាយុជីវិតមនុស្សជាច្រើនប៉ុណ្ណោះទេ ដែលត្រូវបានបំផ្លាញ ប៉ុន្តែសង្គ្រាមនេះថែមទាំងបានបំផ្លាញសម្បត្តិវប្បធម៌ដ៏មានតម្លៃជាច្រើនទៀតផង ។ គម្ពីរព្រះពុទ្ធសាសនាសំខាន់ៗក៏ត្រូវបានដុតកំទេច ។ ប៉ុន្តែជាសំណាងល្អដោយសារការខិតខំប្រឹងប្រែងរបស់ព្រះតេជព្រះគុណ **មុចាគី** គម្ពីរព្រះត្រៃបិដកត្រូវបានបោះពុម្ពឡើងវិញ ហើយបានត្រឡប់មកប្រទេសកម្ពុជាវិញ ។ ប៉ុន្តែចំពោះការស្តារវិស័យព្រះពុទ្ធសាសនាទាំងមូលនោះ គឺទើបតែចាប់ផ្តើមប៉ុណ្ណោះ ។

សូមឱ្យសៀវភៅពុទ្ធប្បវត្តិនេះ បានដល់ដៃប្រជាជនជាច្រើន ពិសេសបានជាឯកសារសម្រាប់កុមារ ដែលជាសរសរទ្រូងរបស់សង្គមជាតិបានអាន និងសូមឱ្យមានការថែរក្សាដល់ជីវិតទាំងអស់មានការជួយសង្គ្រោះគ្នាទៅវិញទៅមក ហើយក្រេបយកការប្រៀនប្រដៅរបស់ព្រះពុទ្ធមកដាក់ក្នុងចិត្ត និងសូមឱ្យអាចកសាងបាននូវពិភពលោក ដែលពោរពេញទៅដោយសន្តិភាព ។ ដើម្បីឱ្យក្លាយទៅជាការពិតបាន សំខាន់បំផុតយើងត្រូវតែចាប់ដៃគ្នា និងពង្រឹងកិច្ចសហប្រតិបត្តិការណ៍គ្នាទៅវិញទៅមក ។ ការបោះពុម្ពសៀវភៅលើកនេះ បានរៀបចំឡើងដើម្បីជាពិសោធន៍សម្រាប់សម្រេចគោលបំណងនេះ ។

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណា អាត្មាភាព សូមឧទ្ទិសអត្ថមនុញ្ញផល ដែលកើតឡើងដោយសារការបោះពុម្ពសៀវភៅនេះចំពោះសន្តិភាពនិងកិច្ចអភិវឌ្ឍន៍នៅប្រទេសកម្ពុជា និងសូមបួងសួងសុំឱ្យទំនាក់ទំនងមិត្តភាពកម្ពុជាជប៉ុន បានរីកចំរើនរឹងមាំព្រមជាមួយនោះដែរ សូមឱ្យសង្គ្រាមក្នុងស្រុក នៅប្រទេសស្រីលង្កាបានចប់នៅក្នុងពេលដ៏ឆាប់នេះ ។

«ប្រសិនបើអាច បួងសួងបានតាមរយៈផលានិស្សងនេះ អាត្មាភាពសូមបួងសួងឱ្យយើងទាំងអស់គ្នា និងមនុស្សម្នាទាំងអស់នៅក្នុងពិភពលោកនេះ អាចចូលទៅដល់ផ្លូវព្រះធម៌របស់ព្រះពុទ្ធបានទាំងអស់គ្នា »

ខែមករា ឆ្នាំ២០០១

អង្គការទំនាក់ទំនងព្រះពុទ្ធសាសនាអន្តរជាតិ **ហុកកេ**

ប្រធាន

អ៊ីស៊ី ហ៊ីដិអុ

最も多くの戦争による虐殺が行なわれた世紀でもありました。

特に，カンボジアでは内戦によって、多くの尊い人名が失われたばかりでなく、貴重な文化遺産も失われ。大切な仏教経典も全て焼失しました。幸い「トリピタカ」は、無着師等のご尽力により復刻され、カンボジアに戻ってきましたが、本格的な仏教の復興はまだ緒についたばかりであります。

この、仏伝絵本がカンボジアの多くの人々、特に未来を担う子供たちの目に触れ、すべての生きとし生けるものを尊び、互いに生かしあう、釈尊のみ教えが人々の心に宿り、争いの無い、平和な世界が築かれます様、祈念するものであります。そして、その実現の為には，世界中の人々が手を携えて互いに協力して行く事の重要性がますます高まっています。今回の仏伝絵本はその試みの一つとして、出来上がりました。

この功徳によって、カンボジアの平和と発展、そして、日本とカンボジアの友好並びにスリランカに於ける内戦の早期終結等々、様々な願いを込めて、出版のご挨拶とさせて頂きます。

「願わくばこの功徳を以って普く一切に及ぼし、我等と衆生と皆共に仏道を成ぜん」

２００１年1月

法華仏教国際交流協会会長

石　井　英　雄

អារម្ភបទ

អាត្មាភាពមានសេចក្ដីរីករាយណាស់ នឹងប្រគល់ជូននូវស្នាដៃ ដែលមានចំណងជើងថា «ពុទ្ធប្បវត្តិដោយរូបភាព» នេះចំពោះលោកអ្នកទាំងឡាយណា ដែលគោរពយ៉ាងខ្ពស់ចំពោះតម្លៃនៃជីវិតនៅលើសកលលោកទាំងមូល ។ សៀវភៅនេះ គឺជាលទ្ធផលនៃសេចក្ដីប្រឹងប្រែងដ៏ខ្លាំងក្លានៃការធ្វើដំណើរទៅច្រើនកន្លែង និងការប្រជុំនិងកិច្ចពិភាក្សារាប់ពាន់ដង ។ អាត្មាភាពបានប្ដេជ្ញាថានឹងចេញ ផ្សាយស្នាដៃនេះនៅថ្ងៃពេញបូរមី ខែពិសាខ ឆ្នាំ១៩៩១ ។ អាត្មាភាពធ្វើបានសម្រេចតាមគោលបំណងដែលបានគ្រោងទុកជាអាទិ៍ដោយ សារមានជំនួយឧបត្ថម្ភ និងកិច្ចសហប្រតិបត្តិការជាឯកជនពីសំណាក់អ្នកមានសទ្ធាយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

សៀវភៅនេះមានលក្ខណៈប្លែកច្រើន ។ ជាសៀវភៅបោះផ្សាយជាពហុភាសាដោយសារមានអត្ថបទជាភាសាសិង្ហលផង អង់គ្លេសផង ចិនផង កូរ៉េផងនិងជប៉ុនផង ។ ភាសាដទៃទៀតក៏អាចនឹងបន្ថែមបានជាយថាហេតុ ប្រសិនបើនិងនៅពេលណាដែលគេចង់បាន ។ រូបភាពដែលរំលេចស្នាដៃនេះ ដោយភាគច្រើនសុទ្ធតែរចនាឡើងជាពិសេសសំរាប់តែប្រើក្នុងសៀវភៅនេះ ។

ពីបុរាណ មុនពេលមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទំនើបជឿនលឿនដូចសព្វថ្ងៃ ពុទ្ធវចនៈត្រូវបានគេបង្រៀនតាមរយៈផ្ទាំងគំនូរ នៅលើជញ្ជាំងវិហារតាមវត្តអារាម និងតាមរយៈពាក្យសំដីរបស់ភិក្ខុសង្ឃទាំងឡាយ ។

បច្ចុប្បន្ននេះ ឧបករណ៍ផ្សព្វផ្សាយសោតទស្សន៍ជឿនលឿនដ៏ក្រៃលែង បានបញ្ជូនទាំងអត្ថបទ ទាំងរូបភាពទៅដល់ដៃមហាជន ។ ប៉ុន្តែឥឡូវនេះពាក្យពេចន៍និងរូបភាពទាំងនោះ ត្រូវបានគេចម្លងឡើងវិញតាមមធ្យោបាយដែលមានបច្ចេកវិទ្យាខ្ពស់ រីឯអ្នកទទួលវិញ គឺអាចទទួលបាននៅគ្រប់ទិសទីនៅលើសកលលោក ផ្ទុយពីសម័យបុរាណដែលអ្នកស្ដាប់ អ្នកអានមានកំរិតតែត្រឹមអ្នកនៅក្នុងភូមិនីមួយៗតែប៉ុណ្ណោះ ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបច្ចុប្បន្ន បានប្រើប្រាស់ពាក្យពេចន៍និងរូបភាពដោយកំរិតប៉ិនប្រសប់ខ្ពស់ ។ រីឯគ្រឿងម៉ាស៊ីនបោះពុម្ព ក៏ឈានដល់កំរិតរីកចំរើនហួសនិស្ស័យនៃពិភពលោកសម័យទំនើប ។

បច្ចេកទេសជឿនលឿនខាងការបោះពុម្ព អាចធ្វើឱ្យការថតចម្លងអត្ថបទឯកសារទាំងឡាយបានចំនួនច្រើនសន្ធឹកសន្ធាប់ និងក្នុងល្បឿនយ៉ាងលឿនដោយរក្សាបាននូវគុណភាពល្អដូចរូបភាពដើមពិតៗ ។

ដោយហេតុនេះ ការបង្ហាញរូបភាពនិងអត្ថបទមានលក្ខណៈប្រជាប្រិយណាស់ ចំពោះអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសម័យបច្ចុប្បន្ននៅគ្រប់ទិសទីលើពិភពលោក ។

ស្នាដៃនេះ បានប្រើប្រាស់នូវបច្ចេកទេសដ៏ទំនើបជឿនលឿនទាំងឡាយនោះដើម្បីផ្សាយឱ្យបានដឹងអំពីអនន្តពុទ្ធិ ដែលទាក់ទងទៅនឹងជីវិត និងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

ប្រសិនបើសៀវភៅ អាចបង្កឱ្យកើតប្រយោជន៍ខ្ពង់ខ្ពស់នៅក្នុងជីវិត និងចំពោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធយ៉ាងហោចក៏ចំពោះអ្នកអានមួយចំនួនតូច ដែលក្នុងនោះមានអ្នកអានទាំងឡាយនៃសៀវភៅនេះ ក៏អាត្មាភាពចាត់ទុកថា នោះជាការសម្រេចនូវគោលបំណងរបស់ អាត្មាភាពហើយ ។

អាត្មាភាព សូមសម្ដែងនូវកតញ្ញុតា និងអំណរគុណដោយស្មោះ ចំពោះលោកអ្នកទាំងឡាយ ដែលមានចំនួនដ៏ច្រើនពុំអាចរៀបរាប់ឈ្មោះអស់ ដែលបានជួយអាត្មាភាពនៅក្នុងកិច្ចការនេះ តាមរបៀបច្រើនបែបយ៉ាង ។

សូមលោកអ្នកទាំងឡាយនោះ បានសម្រេចនូវបរមសុខនៃនិព្វាន ។

ភិក្ខុ **ទេរគោន សរេន**

ពុទ្ធប្បវត្តិ
LIFE OF THE BUDDHA



India before the Buddha's Day.
ប្រទេសឥណ្ឌាមុនពុទ្ធកាល

ប្រទេសឥណ្ឌាមុនពុទ្ធកាលមានឈ្មោះថា ជម្ពូទ្វីប ។ ប្រទេសនេះ រួមមានព្រះរាជាណាចក្រតូចធំជាច្រើន ។ ក្នុងចំណោម រាជាណាចក្រទាំងនោះ មានខ្លះជារាជាធិបតេយ្យ ខ្លះទៀតគ្រប់គ្រងដោយសន្តតិវង្សច្រើនរួមគ្នា ។

India, before the days of the Buddha, was known as Jambudvipa. It consisted of minor and major Kingdoms. Of these, some were Monarchies, some others were ruled jointly by several Dynasties.

The minor Kingdom of Kapiavastu on River Tapti.
កបិលពស្តុជាព្រះរាជាណាចក្រតូចមួយស្ថិតនៅតាមដងទន្លេតប្តិ

កបិលពស្តុ កាលពីបុរាណជាព្រះរាជាណាចក្រតូចមួយក្នុងចំណោមព្រះរាជាណាចក្រតូចៗទាំងឡាយ ។ ព្រះរាជាណាចក្រនេះស្ថិតនៅក្នុងតំបន់ជើងភ្នំហេមពាន្ត ប៉ែកខាងជើងទន្លេតប្តិ ។ អ្នកគ្រប់គ្រងព្រះរាជាណាចក្រនេះ គឺព្រះបាទសុទ្ធោទនៈ នៃត្រកូលសក្យៈ ។ ត្រកូលរបស់ព្រះអង្គមាននាមថា គោតម ។ ព្រះរាជអគ្គមហេសីរបស់ព្រះអង្គព្រះនាមមហាមាយា ។

Kapilavastu, was one of those minor Kingdoms. It was located at the foothills of the Himalayas, to the North of River Tapti. The Ruler of this Kingdom was King Suddhodana of the Sakya clan. His Clan-name was Gotama. His consort was Queen Maha Maya.

King Suddhodhana and Queen Maha Maya.
ព្រះបាទសុទ្ធោទនៈ និងព្រះរាជអគ្គមហេសី មហាមាយា

ព្រះមហាក្សត្រ និងព្រះរាជអគ្គមហេសី ទ្រង់បានសោយរាជ្យសម្បត្តិយ៉ាងសុខក្សេមក្សាន្ត តាំងពីទ្រង់បានទទួលរាជាភិសេកជាមួយគ្នាមក ។ ពេលវេលាបានកន្លងទៅ ព្រះរាជអគ្គមហេសី មហាមាយា ក៏ទ្រង់គភ៌ ។ នៅពេលដែលថ្ងៃប្រសូត្របុត្រជិតចូលមកដល់ ព្រះនាងបានសុំព្រះរាជានុញ្ញាតពីព្រះមហាក្សត្រ ដើម្បីយាងទៅនគរទេវទហៈ ដែលជាស្រុកកំណើតរបស់ព្រះនាង ។ ព្រះបាទសុទ្ធោទនៈ ក៏ទ្រង់សព្វព្រះរាជហឫទ័យអនុញ្ញាតតាមសំណូមពរ ។ ព្រះអង្គទ្រង់ត្រាស់ ព្រះរាជបញ្ជាឱ្យរាជអាមាត្យត្រៀមរៀបចំគ្រឿងប្រដាប់ចាំបាច់សម្រាប់ធ្វើដំណើរ និងឱ្យសំអាតផ្លូវ និងតុបតែងលំអតាមពេលកំណត់ ។

The King and the Queen led a happy married life together. In the course of time Queen Maha Maya conceived. When child-birth was near, the Queen requested permission from the King, to go to the city of Devadaha – her native city. King Suddhodana was quite pleased. He ordered his officials, to make the necessary arrangements for the journey and to have the roads cleaned and duly decked.

Lumbini Pleasure Park.
សួនឧទ្យានលុម្ពិនី

នៅពាក់កណ្ដាលផ្លូវពីក្រុងកបិលពស្ដុ ទៅទេវទហៈ មានសួនឧទ្យានមួយឈ្មោះ លុម្ពិនី ។ នៅរាល់រដូវក្ដៅ មនុស្សម្នានៅក្នុងនគរតែងទៅជួបជុំគ្នានៅក្នុងសួនឧទ្យាន ដើម្បីសម្រាក និងកំសាន្តនៅក្រោមម្លប់ដើមសាលព្រឹក្ស ។ ពួកគេគាប់ ចិត្តនឹងបានគយគន់ដើមសាលព្រឹក្សកំពុងចេញផ្កា និងសម្លេងខ្សៀវខ្សារនៃសត្វបក្សាបក្សី និងសូរទ្រហឹងនៃសត្វឃ្មុំ ។

Mid-way between the cities of Kapilavastu and Devadaha, there stood a Pleasure Park called Lumbini. Each summer people of the cities foregathered in this Park for rest and recreation in the shade of Sala trees. They enjoyed the sight of the trees in bloom, the warbling of birds and the hum of bees.

Prince Siddhartha, walks on Seven Lotuses immediately after His birth.
ព្រះសិទ្ធត្ថ យាងប្រាំពីរជំហានលើផ្កាឈូកបន្ទាប់ពីព្រះអង្គទ្រង់ប្រសូត្រភ្លាម

ព្រះនាងមហាមាយា បានយាងទៅដល់សួនឧទ្យានលុម្ពិនី នៅថ្ងៃសុក្រ ទី១៥ ខែមិថុនា ដែលជាថ្ងៃពេញបូរមី (នេះតាមប្រពៃណីរបស់ប្រទេសថៃ) ។ តាមប្រតិទិនសុរិយគតិ ថ្ងៃនោះត្រូវនឹងថ្ងៃពេញបូរមី ខែឧសភា ។ ដោយសារកំដៅ ថ្ងៃកាន់តែក្តៅឡើងៗ ព្រះនាងមហាមាយា បានបញ្ជាឱ្យរាជអាមាត្យផ្អាកដំណើរ ដើម្បីព្រះនាងបានសម្រាកព្រះកាយមួយស្របក់នៅក្រោមដើមសាលព្រឹក្ស ។ រំពេចនោះ ព្រះនាងទ្រង់បានប្រសូត្របុត្រមួយព្រះអង្គ ។ ព្រះពោធិសត្វ បានទ្រង់យាងប្រាំពីរជំហានលើផ្កាឈូក បន្ទាប់ពីព្រះអង្គបានប្រសូត្រចាកព្រះឧទរព្រះមាតាភ្លាម ។

Queen Maya arrived at Lumbini Pleasure Park, on Friday the 15th of June – the Full Moon Day. (This is according to the Thai tradition). In terms of the Solar Calendar, this Day is identical with the Full-Moon Day of the month of May. As the heat of the day began to increase, Queen Maya ordered the Officials to break journey to enable Her to rest awhile in the shade of trees. Soon, the Queen gave birth to a son. The Bodhisatta Prince walked upon Seven Lotuses immediately after he has born.



The return of Queen Maha Maya to Kapilavastu, after the Birth of Bodhisatta.
ការយាងត្រឡប់នៃព្រះនាងមហាមាយា ទៅនគរកបិលពស្ដុវិញ បន្ទាប់ពីការប្រសូត្រនៃព្រះពោធិសត្វ

ព្រះនាងមហាមាយា បានប្រសូត្រព្រះរាជបុត្រមួយព្រះអង្គ នៅក្នុងឧទ្យានលុម្ពិនី ។ ពួករាជអាមាត្យ មន្ត្រីចាប់ផ្ដើមការពារព្រះនាង និងព្រះរាជឱរសរបស់ព្រះនាង ។ ពួកស្រ្ដីស្នំនៅទីនោះ បានទទូចអង្វរសុំឱ្យព្រះនាងយាងត្រឡប់ទៅ កាន់ក្រុងកបិលពស្ដុវិញ ។ ព្រះបាទសិរីសុទ្ធោទនៈ មានបិតិសោមនស្សក្រៃលែងដោយបានទតឃើញព្រះរាជឱរស ។ ព្រះរាជាបានចាត់ចែងឱ្យមានការការពារជាពិសេស ចំពោះព្រះជាយា និងព្រះរាជឱរស ។

In the Pleasure Park of Lumbini. Queen Maya gave birth to a Son. The Royal Officials set about protecting Queen Maya and Her infant Son. The ladies in attendance entreated the Queen to return to Kapilavastu. King Suddhodana was exceedingly happy to see the infant Prince. The King arranged special protection for the Queen and the Son.

Sage Asita, dwelling in a mountain, near Kapilavastu.
អសីតតាបស រស់នៅឯភ្នំមួយជិតក្រុងកបិលពស្តុ

មានតាបសជាច្រើនរស់នៅតាមភ្នំជិតៗក្រុងកបិលពស្តុ ។ ក្នុងចំណោមតាបសទាំងនោះ មានអសីតជាតាបសដែលមានអាយុច្រើន និងបានទទួលសេចក្តីកោតសរសើរ និងគោរពពីសំណាក់ព្រះបាទសុទ្ធោទនៈ ។ កាលបើបានឮថា ព្រះបាទសុទ្ធោទនៈ ទ្រង់ទទួលបានព្រះរាជបុត្រ តាបសអសីតក៏ធ្វើដំណើរទៅកាន់ព្រះរាជវាំង ដើម្បីពិនិត្យមើលលក្ខណៈសម្បត្តិនៃរាងកាយរបស់ព្រះរាជឱរស ។

Many an ascetic lived in the hills around the city of Kapilavastu. Among them was the aged ascetic Asita, who had won the admiration and respect of King Suddhodana. Hearing that King Suddhodana was blessed with a Son, Ascetic Asita paid a visit to the Palace, to examine the bodily characteristics of the infant Prince.



Sage Asila visits King Suddhodhana's Palace.
អសីតតាបស និមន្តទៅកាន់សំណាក់ព្រះបាទសិរីសុទ្ធោទនៈ

នៅពេលអសីតតាបស បាននិមន្តទៅដល់ព្រះរាជវាំង ព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យព្រះរាជបរិពារនាំព្រះរាជឱរសមក ដើម្បីឱ្យថ្វាយបង្គំតាបសផង និងដើម្បីទទួលពរសព្ទសាធុការពីតាបសផង ។ តាបសបានពិនិត្យពិច័យព្រះរាជឱរស យ៉ាងយកចិត្តទុកដាក់បំផុត ហើយបានរកឃើញថា ព្រះរាជឱរសមានលក្ខណៈសម្បត្តិ សម្គាល់ច្បាស់ថានឹងបានជាមហាបុរស ។

When Ascetic Asita arrived at the Palace, the King ordered the Courtiers to fetch the Infant Prince, both as a mark of respect for the Ascetic and for the infant Prince to receive the Blessings of the Ascetic. The Ascetic scrutinised the infant Prince with great earnestness, and found that the infant Prince had the bodily markings of a Supreme Being.



Sage Astia, begins to cry after seeing the Bodhisatta Prince.
អសិតតាបសយំ បន្ទាប់ពីបានឃើញព្រះពោធិសត្វ

ពេលនោះតាបស មានសេចក្ដីរីករាយយ៉ាងខ្លាំង ។ គាត់ញញឹម ហើយត្រឡប់ជាយំវិញ ។ ព្រះបាទសុទ្ធោទនៈ មានសេចក្ដីងឿងឆ្ងល់ ក៏សួរទៅតាបសវិញអំពីហេតុដែលគាត់យំ ។ តាបសឆ្លើយតបវិញដូច្នេះថា «ព្រះរាជឱរសប្រកបដោយមហាបុរិសលក្ខណៈ ។ ថ្ងៃណាមួយព្រះរាជកុមារនេះ នឹងបានសម្រេចនូវគុណធម៌ខ្ពស់បំផុត ។ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ និងជួយដោះលែងមនុស្សលោកឱ្យរួចផុតពីសេចក្ដីទុក្ខរបស់ខ្លួន ។ ប៉ុន្តែ អាត្មាមិនអាចរស់នៅទាន់ពេលព្រះអង្គបានត្រាស់ជាព្រះពុទ្ធទេ» ។ ពោលដូច្នេះបណ្ដើរ តាបសលុតជង្គង់នៅចំពោះព្រះរាជកុមារបណ្ដើរ ហើយថ្វាយបង្គំព្រះរាជកុមារ ។ ទតឃើញតាបសធ្វើដូច្នោះ ព្រះរាជាក៏លុតជង្គង់ ហើយថ្វាយបង្គំព្រះរាជកុមារដែរ ។

The Ascetic was immensely pleased. He smiled, but in a trice, tears came into his eyes.

King Suddhodana found it difficult to understand what this meant. The King asked the Ascetic the reason for the tears. The Ascetic responded thus: "The Infant Prince possesses the bodily marks of a super Human-being. This infant will one day achieve the highest in Virtue and Righteousness. He will attain Enlightenment and will release worldlings from their suffering. But, I will not be alive when this happens." So saying, he knelt before the Infant Prince and worshipped Him. Seeing this, the King too knelt down and worshipped the Infant Prince.



The Infant Prince is named 'Siddhartha' by the learned men, who assembled at the Palace five days after the Prince's Birth.
ប្រាំថ្ងៃបន្ទាប់ពីព្រះរាជកុមារទ្រង់ប្រសូត្រព្រះអង្គត្រូវបានប្រទាននាមថា «សិទ្ធត្ថ» ដោយក្រុមព្រាហ្មណ៍បណ្ឌិត្យជាច្រើនដែលបានអញ្ជើញមកប្រជុំគ្នានៅក្នុងព្រះរាជវាំង

ប្រាំថ្ងៃ បន្ទាប់ពីព្រះរាជកុមារទ្រង់ប្រសូត្រមក ព្រះបាទសិរីសុទ្ធោទនៈ បានអញ្ជើញព្រាហ្មណ៍បុរោហិតជាច្រើន ដើម្បីសុំឱ្យជួយជ្រើសរើសរកព្រះនាមឱ្យស័ក្តិសមសម្រាប់ប្រទានចំពោះរាជកុមារ ។ ពួកតាបសធ្វើការពិភាក្សាគ្នា រួចសម្រេចជ្រើសយកនាម «សិទ្ធត្ថ» ដែលជាព្រះនាមដ៏ស័ក្តិសមបំផុតចំពោះព្រះរាជកុមារ ។ ព្រះនាមនេះមានន័យថា «អ្នកសម្រេចប្រយោជន៍តាមបំណង» ។

Five days after the birth of the Infant Prince, King Suddhodana invited many Sages and requested them to select a fitting name for the Prince. The Sages held a discussion and selected the name 'Siddhartha' as the most suitable for the Infant Prince. The name means "Fulfilled Wish".

Brahmin Sage Kondanna asserts that the infant Prince will undoubtedly become The Enlightened One.
កោណ្ឌញ្ញព្រាហ្មណ៍ពោលអះអាងថា ព្រះរាជកុមារនេះនឹងបានត្រាស់ជាព្រះពុទ្ធ ឥតសង្ស័យឡើយ

ពួកព្រាហ្មណ៍ដែលបានមកជួបជុំគ្នាដើម្បីជ្រើសរើសព្រះនាមថ្វាយព្រះរាជកុមារ បានពិនិត្យឃើញនូវបុព្វលក្ខណ៍នៅលើព្រះភក្ត្រ របស់ព្រះអង្គ ។ ព្រាហ្មណ៍ខ្លះទាយថា ព្រះរាជកុមារនឹងឡើងសោយរាជបន្ទាប់ពីព្រះបាទសុទ្ធោទនៈ បន្ទាប់មកនឹងក្លាយជាស្ដេចចក្រពត្តិ ។ ចំណែកឯកោណ្ឌញ្ញព្រាហ្មណ៍ ដែលក្មេងជាងគេក្នុងចំណោមព្រាហ្មណ៍ទាំងឡាយ បានអះអាងយ៉ាងម៉ឺងម៉ាត់ថា «ព្រះរាជកុមារសិទ្ធត្ថ នឹងបោះបង់ចោលជីវិតជាគ្រហស្ថ និងរាជបល្ល័ង្កនៅក្នុងយុវវ័យរបស់ព្រះអង្គ ។ ព្រះអង្គនឹងយាងទៅស្វែងរកបរមសុខមួយ ដែលខ្ពស់លើសបរមសុខលោកិយ ។ ព្រះអង្គនឹងបានសម្រេចពុទ្ធភាព រួចនឹងពិតជាបានត្រាស់ជាព្រះពុទ្ធ ។ ព្រះអង្គនឹងទៅជាបរមសាស្ដាចារ្យ ដែលនៅលើលោកនេះមិនដែលមានទាល់តែសោះ» ។

The Sages who gathered to select a name for the Prince, were able to observe the auspicious marks on His face. Some of the Sages said that the Prince will succeed to the Throne after King Suddhodana, and will later become a Universal Monarch. But Kondanna a youthful savant among the Sages firmly stated thus : "This Prince Siddhartha will renounce the household life and the Throne in His youth. He will embark upon a quest for the bliss that transcends all worldly bliss. He will attain Buddhahood, and will become The Enlightened One. He will be the greatest Teacher world has ever known.



King Suddhodhana and the masses wish the Infant Prince to be a Universal Monarch.
ព្រះបាទសិរីសុទ្ធោទនៈ និងមហាជនមានបំណងចង់ឱយព្រះរាជកុមារក្លាយជាស្តេចចក្រពត្តិ

សេចក្តីសប្បាយរីករាយដ៏ធំបំផុតរបស់ប្រជារាស្ត្រទាំងនគរ និងពួកព្រាហ្មណ៍ទាំងឡាយនោះ គឺចង់ឃើញព្រះរាជកុមារក្លាយជាស្តេចចក្រពត្តិនៅពេលព្រះអង្គចំរើនវ័យវឌ្ឍនាការ ។ នោះក៏គឺជាព្រះរាជបំណងរបស់ព្រះបាទសិរីសុទ្ធោទនៈផងដែរ ។ ព្រះរាជាមិនបានសព្វព្រះរាជហឫទ័យចំពោះគំនិតដែលថា ព្រះរាជកុមារនឹងលះបង់ជីវិតគ្រហស្ថ ដើម្បីក្លាយជាសាស្តាចារ្យទេ ។ សេចក្តីសង្ឃឹមរបស់ព្រះអង្គ គឺថាព្រះរាជកុមារសិទ្ធត្ថ ក៏ដូចជាព្រះរាជកុមារដទៃឯទៀតដែរ គប្បីចំរើនវ័យវឌ្ឍនាការដល់ពេញវ័យគប្បីទទួលរាជាភិសេក និងឡើងសោយរាជ្យសម្បត្តិបន្ទាប់ពីព្រះអង្គ ។

The greatest joy of the people of the land and all the Sages was to see that the Prince should become a Universal King when He grew up. That was the wish of King Suddhodana as well. The King did not at all like the idea of the Prince renouncing lay life to become a Teacher. His hope was that, Prince Siddhartha too, just as other Princes, should grow up, get married and should succeed to His Throne after him.



Queen Maha Maya passes away Seven Days after the Birth of Prince Siddhartha.
ព្រះនាងសិរីមហាមាយា ទ្រង់សោយព្រះទិវង្គត បន្ទាប់ពីព្រះសិទ្ធត្ថទ្រង់ប្រសូត្របានប្រាំពីរថ្ងៃ

ពីរថ្ងៃបន្ទាប់ពីពិធីប្រទាននាមចំពោះព្រះរាជកុមារមក ព្រះនាងសិរីមហាមាយាទ្រង់ចាប់ប្រឈួនរួចក៏សោយព្រះទិវង្គតទៅ ។ សេចក្តីទុក្ខក្រៀមក្រំយ៉ាងធំធេងកើតមានឡើងចំពោះមនុស្សគ្រប់ៗគ្នា ។ សេចក្តីទុក្ខរបស់ព្រះបាទសុទ្ធោទនៈ មានកំរិតធំធេងបំផុត ។ ព្រះនាងសិរីមហាមាយា គឺជាក្សត្រីដែលមានចរិយាសម្បត្តិប្រកបដោយគុណធម៌មួយអង្គនៃព្រះរាជសន្តតិវង្សដ៏ខ្ពង់ខ្ពស់ ។ ដោយហេតុនោះហើយ ទើបធ្វើឱ្យព្រះរាជាមានសេចក្តីសោកស្តាយយ៉ាងជ្រាលជ្រៅ ។

Two days after the naming ceremony of the Prince, Queen Maya took ill and passed away. All were plunged into sorrow. King Suddhodana's sorrow was the greatest. Queen Maya was a virtuous Lady of a noble Royal Dynasty. This was the reason for the King's deep sorrow.



Queen Maha Prajapati Gotami brings up the little Prince Siddhartha.
ព្រះនាងមហាបជាបតិគោតមី ទ្រង់បីបាច់រក្សាព្រះរាជកុមារ សិទ្ធត្ថ

បន្ទាប់ពីព្រះនាងសិរីមហាមាយាទ្រង់សោយព្រះវិលាល័យទៅ ព្រះរាជាទ្រង់ផ្ទុកផ្ដាក់ការចិញ្ចឹមបីបាច់ព្រះរាជកុមារ ទៅឱ្យព្រះនាងមហាបជាបតិគោតមី ដែលជាព្រះស្នំមួយអង្គក្នុងចំណោមព្រះស្នំទាំងឡាយរបស់ព្រះអង្គ និងជាមេនំបំបៅព្រះរាជកុមារសិទ្ធត្ថផ្ទាល់ ។ ព្រះនាងបានបីបាច់ព្រះរាជកុមារដូចជាព្រះរាជបុត្របង្កើតរបស់ព្រះនាង ។ ដោយហេតុនោះ ទើបព្រះរាជកុមារសិទ្ធត្ថពុំបានដឹងថា ព្រះមាតាបច្ចុប្បន្នរបស់ព្រះអង្គជានរណាឡើយ ។

After the death of Queen Maya, the King entrusted the bringing up of the Prince to Queen Maha Prajapati Gotami – one of His Consorts and Prince Siddhartha's own step-mother. She looked after the Prince as her own child. In consequence, Prince Siddhartha did not know who His actual mother was.



Prince Siddhartha at Studies.
ព្រះរាជកុមារសិទ្ធត្ថ ក្នុងពេលសិក្សា

ព្រះរាជកុមារសិទ្ធត្ថ បានរីកចំរើនវ័យវឌ្ឍនាការឡើងក្រោមការបីបាច់រក្សាយ៉ាងល្អបំផុតរបស់ព្រះនាងមហាបជាបតិគោតមី ។ ព្រះអង្គទ្រង់មានរូបសម្ផស្សល្អស្រស់ និងមានសុខភាពល្អឥតខ្ចោះ ។ នរណាៗ ក៏ស្រឡាញ់ពេញចិត្តនឹងព្រះអង្គគ្រប់ៗគ្នា ។ នៅពេលព្រះអង្គមានព្រះជន្មប្រាំបីវស្សា ព្រះរាជាបានអញ្ជើញសាស្ត្រាចារ្យជំនាញក្នុងវិស័យផ្សេងៗ ឱ្យមកបង្ហាត់បង្រៀនព្រះរាជកុមារអំពីសិល្បៈ សិល្បសាស្ត្រ និងវិទ្យាសាស្ត្រនានា ។

Prince Siddhartha grew up under the kind eye of Maha Prajapati Gotami. He was comely and was in perfectly good health. He won the hearts of all. When the Prince was eight, The King got the services of experts in various fields, to instruct Him in the Arts, the Crafts and the Sciences.

Prince Siddhartha being trained in Archery.
ព្រះរាជកុមារសិទ្ធត្ថ កំពុងហាត់ វិជ្ជាបាញ់ធ្នូ

ដោយសារសាស្ត្រាចារ្យទាំងអស់របស់ព្រះអង្គសុទ្ធតែជាអ្នកមានជំនាញនោះ ព្រះរាជកុមារអាចរៀនចេះស្ទាត់បានយ៉ាងឆាប់រហ័ស និងប្លែកពីគេផង ។ វាជារឿងប្រត្យក្សណាស់ ដែលព្រះរាជកុមារសិទ្ធត្ថរៀនពូកែដាច់គេក្នុងចំណោមរាជកុមារទាំងឡាយ ។ ភាពស្ទាត់ជំនាញក្នុងការសិក្សារបស់ព្រះអង្គពោរពេញទៅដោយសេចក្ដីស្ងើចស្ងប់ស្ងែង ជាពិសេសពីសំណាក់ព្រះរាជា និងព្រះនាងមេដោះរបស់ព្រះអង្គ ។ ព្រះអង្គរៀនសិល្បសាស្ត្រថ្មីចេះចាំបានយ៉ាងឆាប់រហ័ស និងមិនដែលភ្លេចទាល់តែសោះនូវអ្វីដែលព្រះអង្គបានរៀនរួចហើយ ។

Since His Teachers were all experts, the Prince was able to learn quickly and with distinction. It became quite evident, that Prince Siddhartha stood heads and shoulders above all other Princes. His adeptness in studies filled all with wonder, especially the King and the Prince's step-mother. He acquired new art with alacrity and never forgot what was taught him.

Prince Siddhartha salutes His Teachers.
ព្រះរាជកុមារសិទ្ធត្ថ ថ្វាយបង្គំព្រះរាជគ្រូរបស់ព្រះអង្គ

ថ្វីត្បិតតែព្រះអង្គជាសិស្សពូកែឈ្លាសវៃមួយអង្គនិងជារជ្ជទាយាទរបស់នគរ ព្រះរាជកុមារសិទ្ធត្ថមិនដែលភ្លេចសម្តែងសេចក្តីគោរពចំពោះព្រះរាជគ្រូរបស់ព្រះអង្គទេ ។ ព្រះរាជកុមារសិទ្ធត្ថទ្រង់មានជំនឿជឿជាក់ថា កិត្តិយសដ៏ខ្ពង់ខ្ពស់នៅក្នុងការសិក្សា នឹងអាចទទួលបានក៏អាស្រ័យដោយសារតែមានការអប់រំណែនាំរបស់លោកសាស្ត្រាចារ្យតែប៉ុណ្ណោះ ។ ការសម្តែងការគួរសមចំពោះអ្នកដទៃ និងធ្វើឱ្យអ្នកផងសប្បាយចិត្ត គឺជាលក្ខណៈធម្មជាតិរបស់ព្រះអង្គ ។

Although He was a clever student and was the Crown Prince of the Land, Prince Siddhartha, never failed to pay due respect to His Teachers. Prince Siddhartha was convinced that high distinction in learning could be obtained, only in terms of the instructions given by the Teachers. It was the Prince's nature to be courteous and pleasant to all.

Prince Siddhartha handles a war-chariot skilfully.
ព្រះរាជកុមារសិទ្ធត្ថ បររទេះចម្បាំងយ៉ាងស្ទាត់ជំនាញ

ភាពជាអ្នកកីឡារបស់ព្រះរាជកុមារសិទ្ធត្ថ គឺការប្រកាន់ខ្ជាប់នូវគុណធម៌ដ៏ខ្ពង់ខ្ពស់ និងចរិតថ្លៃថ្នូររបស់ព្រះអង្គ ។ ចាប់តាំងពីកុមារភាពរហូតមក ព្រះអង្គបានរៀនធ្វើជាអ្នកដឹកនាំត្រកូលដ៏អង់អាចក្លាហានម្នាក់ ។ ព្រះអង្គជាអ្នកបររទេះចម្បាំងយ៉ាងស្ទាត់ជំនាញ ។

Prince Siddhartha's sportsmanship was quite in keeping with His high virtue and noble character. From childhood on! He learnt to be a fearless clan-leader. He was an adept at charioteering.



Prince Siddhartha breaks an unruly horse.
ព្រះរាជកុមារសិទ្ធត្ថ បានធ្វើឱ្យសេះកាចក្លាយជាសេះស្លូត

ព្រះអង្គបានទទួលជ័យជំនះក្នុងការប្រណាំងរទេះចម្បាំង ដោយធ្វើឱ្យជើងឯកដ៏ល្បីៗបំផុតនៅក្នុងប្រទេសទាំងមូលទទួលបរាជ័យ ។ នៅក្នុងពេលប្រកួតប្រជែងដ៏ខ្លាំងក្លានោះ ព្រះអង្គសម្ដែងនូវសេចក្ដីស្រឡាញ់ខ្លាំងណាស់ចំពោះសេះរបស់ព្រះអង្គខុសពីអ្នកប្រកួតឯទៀត ដែលវាយធ្វើបាបសេះរបស់ខ្លួនយ៉ាងឃោរឃៅ ។ សេះក៏ដឹងនូវអំពើល្អនោះ ហើយខំប្រឹងពេញទំហឹងរបស់ខ្លួន ដើម្បីធ្វើឱ្យព្រះរាជកុមារទទួលបានជ័យជំនះដាច់គេ ។

He won the chariot race defeating the most formidable champion of the whole land. In the course of the fierce competition, the prince was extremely kind to His horse, unlike the other contenders who treated their horses cruelly. The horse too appreciated this and tried his utmost to make the Prince the winner.

Prince Siddhartha shows kindness to animals.
ព្រះរាជកុមារ សម្តែងសេចក្តីសប្បុរសចំពោះសត្វ

ព្រះរាជកុមារទ្រង់មានព្រះទ័យសប្បុរសចំពោះសព្វសត្វទាំងឡាយ ។ ក្នុងឋានៈជាអ្នកស្នងរាជ្យ ព្រះអង្គមិនដែលស្គាល់ដូចម្តេចដែលហៅថាខ្វះខាតនោះទេ ។ ព្រះអង្គទ្រង់បានទទួលការពន្យល់ទូន្មានថា មនុស្សក្តី សត្វក្តី សុទ្ធតែរីករាយខ្លាំងណាស់ពេលបានរស់នៅបានសុខស្រួល និងមិនចង់ជួបសេចក្តីឈឺចាប់ និងទុក្ខសោកដូចគ្នា ។

The Prince was kind to all animals. As the Heir to the Throne, He did not suffer any privation. He was convinced that both men and animals alike delight in comfort, and shun pain and suffering.

Prince Siddhartha prevents a serpent being harassed.
ព្រះរាជកុមារសិទ្ធត្ថ សង្គ្រោះសត្វពស់ដែលគេកំពុងយាយី

ចាប់តាំងពីព្រះអង្គមានព្រះជន្មប្រាំបីវស្សារហូតមក ចរិតប្រកបដោយមេត្តាធម៌របស់ព្រះរាជកុមារ គឺជាគុណធម៌ដ៏ខ្ពស់លើសលប់ ។ ព្រះអង្គមិនដែលប៉ះពាល់ដល់ជីវិតសត្វតូចធំគ្រប់រូបភាពសោះឡើយ ។ ព្រះអង្គទ្រង់ត្រៀមខ្លួនជានិច្ច ដើម្បីជួយសព្វសត្វទាំងឡាយឱ្យរួចរំដោះផុតពីសេចក្ដីទុក្ខនិងការឈឺចាប់ ។ មានម្ដងនោះ ព្រះអង្គបានទតឃើញបំរើរបស់ព្រះអង្គម្នាក់ កំពុងវាយប្រហារសត្វពស់ដោយលំពែង ព្រះអង្គទ្រង់ឃាងយ៉ាងប្រញាប់ទៅឃាត់បំរើនោះ កុំឱ្យវាយសត្វពស់ទៀត ។

From the age of eight on, the compassionate qualities of the Prince's character became quite predominant. He never hurt any animal or any form of life. He was ever ready to help animals to overcome their suffering and pain. Once the Prince observed one of His men attacking a serpent with a spear. He quickly intervened and got him to refrain from attacking the serpent.

Prince Siddhartha and Prince Devadatta at play together.
ព្រះរាជកុមារសិទ្ធត្ថ និងរាជកុមារទេវទត្ត ទ្រង់ក្រសាលកំសាន្តជាមួយគ្នា

ថ្ងៃមួយ ព្រះរាជកុមារសិទ្ធត្ថ កំពុងក្រសាលកំសាន្តនៅក្នុងឧទ្យាន ជាមួយនឹងរាជកុមារដែលមានវ័យស្របាលនឹងព្រះអង្គ ។ នៅក្នុងចំណោមគ្នូកនរបស់ព្រះអង្គនោះ ក៏មានរាជកុមារទេវទត្តមួយអង្គដែរ ។ រាជកុមារទេវទត្ត មានចរិតផ្ទុយស្រឡះពីរាជកុមារសិទ្ធត្ថ ទោះបីត្រូវជាបងប្អូនជីដូនមួយនឹងព្រះអង្គក៏ដោយ ។

One day, Prince Siddhartha was playing in the Pleasure Park with His Peers. Among the companions was Prince Devadatta, who was a total contrast in character to Prince Siddhartha, though His cousin.

Prince Siddhartha nurses a Swan wounded by Prince Devadatta's arrow.
ព្រះរាជកុមារសិទ្ធត្ថ ព្យាបាលរបួសឱ្យសត្វក្ងាន ដែលរបួសដោយព្រួញរបស់រាជកុមារទេវទត្ត

ព្រះរាជកុមារសិទ្ធត្ថ ទ្រង់ជាតួយ៉ាងនៃសេចក្ដីមេត្តា និងសេចក្ដីស្រឡាញ់ ។ ព្រះអង្គមិនដែលធ្វើឱ្យនរណាម្នាក់ឈឺចាប់ឡើយ មានតែជួយអ្នកដទៃឱ្យរួចរំដោះពីសេចក្ដីទុក្ខ ។ ផ្ទុយទៅវិញព្រះរាជកុមារទេវទត្ត ចូលចិត្តខាងច្រណែនគេ និងសប្បាយខ្លាំងណាស់ក្នុងការបាញ់សត្វ ។ ថ្ងៃមួយ រាជកុមារបានតម្រង់ព្រួញបាញ់សំដៅទៅលើហ្វូងក្ងានដែលកំពុងហើរ ។ ក្ងានមួយក្បាលបានត្រូវរបួសយ៉ាងធ្ងន់ ហើយព្រះរាជកុមារសិទ្ធត្ថទ្រង់សម្គាល់ឃើញថា សត្វក្ងាននោះមានការឈឺចាប់ខ្លាំងណាស់ ។

Prince Siddhartha was the epitome of compassion and love. He never hurt anyone but helped to relieve the suffering of others. On the other hand Prince Devadatta was given to jealousy and took delight in hunting animals. One day Prince Devadatta aimed His arrows at flying Swans. One of the Swans was grievously hurt and Prince Siddhartha noted that the Swan was in great pain.

Prince Siddhartha's kindness towrads the Swan.
ព្រះទ័យមេត្តាអាណិតអាសូររបស់ព្រះរាជកុមារសិទ្ធត្ថ ចំពោះសត្វក្ងាន

ព្រះរាជកុមារសិទ្ធត្ថ បានរត់យ៉ាងលឿនទៅរកសត្វក្ងាន ព្រះអង្គបានដកព្រួញចេញ ហើយបបោសអង្អែលវា ។ ព្រះរាជកុមារទេវទត្ត ទ្រង់រត់ទៅរកព្រះរាជកុមារសិទ្ធត្ថដោយក្ដីពិរោធ ក្នុងបំណងដណ្ដើមយកសត្វក្ងានទៅវិញ ។ ទ្រង់បាន ស្រែកដោយក្ដីក្រោធទៅរកព្រះរាជកុមារសិទ្ធត្ថ និងសុំយកសត្វក្ងានពីព្រះអង្គ ។

Prince Siddhartha rushed to the Swan took off the arrow that pierced it and caressed it. Prince Devadatta angrily rushed towards Prince Siddhartha to grab the Swan. Angrily he shouted at Prince Siddhartha and demanded the Swan.

The dispute about the ownership of the Swan.

ជម្លោះដណ្ដើមសត្វក្ងានជារបស់ផងខ្លួន

ព្រះរាជកុមារសិទ្ធត្ថ ទ្រង់បដិសេធដាច់ខាត និងមានបន្ទូលថា ព្រះអង្គនឹងមិនប្រគល់សត្វក្ងាននោះទៅរាជកុមារទេវទត្តទេ ។ ព្រះរាជកុមារមានព្រះបន្ទូលថា «ប្រសិនបើសត្វក្ងាននេះ បានស្លាប់ដោយព្រួញនោះ វាគួរតែបានទៅជនដែលបានបាញ់វា ប៉ុន្តែនៅពេលដែលវានៅមានជីវិតនៅឡើយ វាត្រូវបានទៅជនដែលជួយសង្គ្រោះជីវិតវា» ។ ប៉ុន្តែ ព្រះរាជកុមារទេវទត្ត នៅតែទទូចទាមទារយកសត្វក្ងាន ។ ព្រះរាជកុមារសិទ្ធត្ថបានស្នើថា ការដោះស្រាយបញ្ហានេះ គួរតែទុកឱ្យអង្គប្រជុំនៃអ្នកប្រាជ្ញរាជបណ្ឌិត្យក្នុងនគរជាអ្នកធ្វើការវិនិច្ឆ័យ ។ ព្រះរាជកុមារទេវទត្តក៏យល់ព្រម ។

Prince Siddhartha was adamant and said that He will never give back the swan to him. "If the Swan died by the arrow it would belong to the person who shot it. But, when it is alive, it belongs to the person who saved its life", Prince Siddhartha said. But, Prince Devadatta kept on demanding it. Prince Siddhartha proposed that the issue should be put to an Assembly of learned people of the Land for Judgement. Prince Devadatta agreed.

Assembly of learned men arbitrates the dispute about the ownership of the Swan.
អង្គប្រជុំនៃពួកអ្នកប្រាជ្ញ វិនិច្ឆ័យជម្លោះនៃការដណ្ដើមសត្វក្ងាន

សមាជិកទាំងឡាយនៃអង្គប្រជុំអ្នកប្រាជ្ញ មានទស្សនៈផ្សេងៗគ្នាចំពោះដំណោះស្រាយរឿងសត្វក្ងាននេះ ។ អ្នកខ្លះយល់ព្រមតាមមតិដែលថា សត្វក្ងានត្រូវបានទៅព្រះរាជកុមារសិទ្ធត្ថ ដោយហេតុថាព្រះអង្គជាអ្នកជួយសង្គ្រោះជីវិតវា ។ ប៉ុន្តែមានអ្នកខ្លះថា ព្រះរាជកុមារទេវទត្ត គប្បីជាអ្នកទទួលសត្វក្ងានដោយសារព្រះអង្គជាអ្នកបាញ់ទម្លាក់វា ។ ក្រុមនីមួយៗ ខំលើកហេតុផលតែរៀងខ្លួន ដើម្បីបញ្ជាក់ពីគោលគំនិតរបស់ខ្លួន ។

Members of the Assembly of Learned Men held differing views about the Swan issue. Some were of the opinion that Prince Siddhartha, should be given the Swan, since the prince saved its life, but some others said that Prince Devadatta should get the Swan, as he shot it down. Each group adduced its own reasons for the view it held.



A young Savant, gives the ownership of the Swan to Prince Siddhartha.
អ្នកប្រាជ្ញដ៏ក្មេងម្នាក់ សម្រេចថ្វាយសត្វក្ងានទៅព្រះរាជកុមារសិទ្ធត្ថ

នៅទីបញ្ចប់នៃការពិភាក្សា សមាជិកដ៏ក្មេងម្នាក់នៃអង្គប្រជុំបណ្ឌិត បានក្រោកឈរឡើងហើយពោលថា ជីវិតទាំងអស់ជារបស់អ្នកដែលការពារវា ព្រោះហេតុនោះ សត្វក្ងានត្រូវបានទៅព្រះរាជកុមារសិទ្ធត្ថ ។

Towards the end of the debate a young Member of the Assembly of Pundits stood up and said that, all life belongs to those who protect it and, in consequence, Prince Siddhartha should get this Swan.

The healed Swan flies away into freedom.
សត្វក្ងានបានហើរទៅរកសេរីភាព បន្ទាប់ពីជារបួស

សមាជិកទាំងអស់នៃអង្គប្រជុំអ្នកប្រាជ្ញយល់ព្រមតាមសំណូមពរនេះ ។ ព្រះរាជកុមារសិទ្ធត្ថ បានព្យាបាលសត្វក្ងានរហូតដល់ជារបួស និងមានសុខភាពល្អដូចធម្មតាវិញ ។ ព្រះរាជកុមារបានលែងសត្វក្ងានឱ្យមានសេរីភាពវិញ ធ្វើឱ្យវាអាចទៅរស់នៅដោយសេរីជាមួយសត្វក្ងានគ្នាវា ។

ចាប់តាំងពីពេលនោះមក ព្រះរាជកុមារទេវទត្ត បានចាប់ផ្ដើមស្អប់ព្រះរាជកុមារសិទ្ធត្ថ ។ ព្រះរាជកុមារទេវទត្ត សម្រេចចិត្តថានឹងលបព្យាបាទព្រះរាជកុមារសិទ្ធត្ថឱ្យបាន ។

All the Members of the Learned Assembly agreed to this suggestion. Prince Siddhartha nursed the injured Swan into perfect normal health. The Prince, then released the Swan into freedom, enabling it to live a life of perfect liberty with its kind.

From then on Prince Devadatta began to hate Prince Siddhartha. Prince Devadatta decided to plot against Prince Siddhartha.



Getting ready for the Ploughing Ceremony.

ការត្រៀមធ្វើពិធីបុណ្យច្រត់ព្រះនង្គ័ល

ចំពោះប្រជាជនឥណ្ឌានៅក្នុងសម័យបុរាណ សកម្មភាពខាងកសិកម្មមានសារសំខាន់ជាអាទិភាព ។ ព្រះរាជាព្រះអង្គឯងទ្រង់នាំមុខប្រជារាស្ត្ររបស់ព្រះអង្គនៅក្នុងសកម្មភាពភ្ជួររាស់ និងសាបព្រោះក្នុងការធ្វើស្រែចំការតាមរដូវ ។ កាយវិការគំរូរបស់ព្រះរាជាបានធ្វើឱ្យការភ្ជួររាស់ និងសាបព្រោះក្លាយជាសកម្មភាពដ៏ថ្លៃថ្នូរ ។

To the people of India in those ancient days, agricultural pursuits were of primary importance. The King himself, led His people in the seasonal agricultural activities of ploughing and sowing. The King's example made ploughing and sowing noble pursuits.



The Ploughing Ceremony held in Kapilavastu.
ពិធីបុណ្យច្រត់ព្រះនង្គ័ល នៅក្រុងកបិលពស្តុ

នៅចុងរដូវក្តៅគឺជារដូវភ្ជួររាស់នៅក្នុងនគរកបិលពស្តុ ។ ព្រះបាទសិរីសុទ្ធោទនៈបានដឹកនាំពិធីច្រត់ព្រះនង្គ័លនៅទីជិតៗក្រុង ។ ប្រជាជនបាននាំគ្នាច្រើនកុះករទៅមើលពិធីបុណ្យនោះ ។ ទាំងព្រះរាជកុមារសិទ្ធត្ថ ក៏យាងដង្ហែព្រះបិតាព្រះអង្គ ទៅធ្វើពិធីបុណ្យច្រត់ព្រះនង្គ័លដែរ ។

At the end of summer, it was the season for ploughing in Kapilavastu. King Suddhodana took the lead in ploughing ceremonies, in the vicinity of the city. The people gathered to witness the ceremony. Prince Siddhartha too accompanied His father to the ploughing ceremonies.

King Suddhodhana participates in the Ploughing Ceremony.
ព្រះបាទសិរីសុទ្ធោទនៈ ប្រារព្ធពិធីច្រត់ព្រះនង្គ័ល

ព្រះរាជាទ្រង់ផ្ដួចផ្ដើមធ្វើពិធីបុណ្យច្រត់ព្រះនង្គ័ល ។ ព្រះអង្គទ្រង់កាន់នង្គ័លមាស និងតុបតែងយ៉ាងស្អាតដោយព្រះទ័យសប្បាយរីករាយ ។ ពួកនាហ្មឺនសព្វមុខមន្ត្រី ភ្ជួរដោយនង្គ័លប្រាក់ ។ ពួកកសិករនាំគ្នាភ្ជួរតាមក្រោយពួកមន្ត្រី ។ ដីស្រែត្រូវបានត្រៀមជាស្រេចដើម្បីសាប ។

The King initiated the Ploughing Ceremony. He wielded the gaily decorated golden plough. The Royal Officials used silver ploughs. The other cultivators followed them. The fields were now ready for sowing.



The Oxen being treated in an unkind manner at the Ploughing Ceremony.
សត្វគោត្រូវគេវាយធ្វើបាប ក្នុងពិធីបុណ្យច្រត់ព្រះនង្គ័ល

ប៉ុន្តែគោឈ្មោលហាក់ដូចជាមិនបានសប្បាយទាល់តែសោះ ។ ការភ្ជួរដីធ្វើឱ្យគោឈ្មោលទាំងនោះហេវហត់ក្រៃលែង និងដកដង្ហើមដោយដង្ហក់ឥតឈប់ឈរ ។ ឯមនុស្សវិញ គិតតែពីសម្តែងសេចក្តីសប្បាយរីករាយ ។ គោឈ្មោលធ្វើការហត់នឿយខ្លាំងណាស់ ។ នៅពេលគោមិនអាចធ្វើការធ្ងន់ធ្ងរបាន ម្ចាស់វាវាយធ្វើបាបវាយ៉ាងឃោរឃៅ ។

But the oxen do not seem to be happy at all. Ploughing has left these oxen extremely exhausted and panting for breath ceaselessly. Men exult. The bulls do the hard work. When the bulls fail to work hard their Masters punish them cruelly.

A Snake swallows a lizard and a Hawk attempts to take the Snake as prey.
សត្វពស់កំពុងលេបសត្វថ្លែន ហើយសត្វស្ទាំងកំពុងប៉ុនប៉ងចាប់សត្វពស់ធ្វើចំណី

ព្រះរាជកុមារសិទ្ធត្ថ បានកត់សម្គាល់នូវរបៀបរកស៊ីរបស់សត្វនានាជុំវិញព្រះអង្គ ។ ព្រះអង្គទតឃើញសត្វថ្លែនលេបស្រមោច ។ មួយសន្ទុះក្រោយមក សត្វពស់មួយក្បាលមកលេបសត្វថ្លែន ។ ភ្លាមនោះដែរសត្វស្ទាំងឆាបពីលើមេឃចុះមកចាប់សត្វពស់យកទៅស៊ីបាត់ ។ ទាំងអស់នេះធ្វើឱ្យព្រះរាជកុមារតក់ស្លុតយ៉ាងខ្លាំង ។

Prince Siddhartha noted the ways of other animals around Him. He saw a lizard swallowing ants. A moment later a serpent swallowed up the lizard. Instantly a hawk swooped down from the sky, caught the serpent and ate him up. All this shocked the Prince.

Prince Siddhartha in deep meditation while the Ploughing Ceremony is going on.
ព្រះរាជកុមារ បានធ្វើសមាធិយ៉ាងស្លុងអារម្មណ៍ ក្នុងពេលគេកំពុងធ្វើបុណ្យច្រត់ព្រះនង្គ័ល

នៅពេលសម្រាកដើម្បីហូបបាយថ្ងៃត្រង់ ពួករាជបំរើបាននាំគ្នាទៅបរិភោគអាហារ ទុកព្រះរាជកុមារសិទ្ធត្ថឱ្យនៅម្នាក់ឯង ។ ព្រះរាជកុមារទ្រង់យាងទៅរកគល់ព្រីងមួយដើម និងដោយមានអារម្មណ៍យ៉ាងស្ងប់ ទ្រង់ចាប់ផ្តើមចំរើនសមាធិកម្មដ្ឋាន ។ ទាំងព្រះរាជា ទាំងរាជអាមាត្យ និងម្ចាស់កសិដ្ឋានទាំងឡាយ នាំគ្នាសោយក្រយា និងទទួលទានអាហារយ៉ាងរីករាយ ។

During the recess for the mid-day meal, the Royal attendants went to partake of the feast, leaving the Prince alone. Prince Siddhartha, went across to the foot of a rose-apple tree and with tranquil mind started contemplating thus. The King, the Royal Officials and farmers are happily at their meals.

Prince Siddhartha reaches the first stage of Higher Meditation.

ព្រះរាជកុមារសិទ្ធត្ថ បានសម្រេចបឋមជ្ឈាន

នៅក្នុងពេលចំរើនសមាធិ ព្រះរាជកុមារចាប់ផ្ដើមសួរខ្លួនព្រះអង្គថា «អ្វីៗ វាដូច្នេះ តើមិនមែនទេឬ ដែលភាពអាក្រក់វានៅពួនពីក្រោយ អាការល្អតែសំបកក្រៅនៃជីវិត» ។ នៅទីបញ្ចប់ព្រះអង្គរកឃើញថា ទោះបីមនុស្ស និងសត្វមានសេចក្ដីសប្បាយម្ដងម្កាល តែមិនអាចចៀសផុតពីសេចក្ដីទុក្ខដែលគេត្រូវតែទទួលទេ ។ ព្រះអង្គអាចប្រមើលមើលសព្វសត្វដោយសតិអារម្មណ៍ស្ងប់ស្ងាត់ ។ ព្រះអង្គទ្រង់បានសម្រេចបឋមជ្ឈាន ។

In deep contemplation the Prince started questioning Himself thus "As things are, does not ugliness lurk behind the facade of beauty of life? Though men and beasts are momentarily happy, they suffer unconquered sorrow". He realized this at the end. He was able to view everything with an even mind. He reached the first stage of higher meditation.



On His way to the Palace, Prince Siddhartha contemplates the fate of animals.
នៅតាមផ្លូវត្រឡប់ទៅព្រះបរមរាជវាំង ព្រះរាជកុមារសិទ្ធត្ថបានសញ្ជឹងគិតទៅដល់វាសនានៃសត្វទាំងឡាយ

នៅពេលចប់ពិធីបុណ្យ ពួកមេនំត្រឡប់ទៅរកព្រះរាជកុមារវិញ ។ ពួកគេបានឃើញព្រះរាជកុមារស្ថិតនៅក្រោមដើមព្រីងគង់ផ្ចង់ព្រះភ្នែននឹងស្ងួកដូចជាបដិមាធ្វើអំពីថ្ម ។ ពួកគេនាំគ្នាដាស់ព្រះរាជកុមារឱ្យតើនឡើង ។ ពួកមេនំទូលព្រះអង្គថា ព្រះរាជាទ្រង់រៀបព្រះដំណើរត្រឡប់ទៅព្រះរាជវាំងវិញហើយ ។ នៅពេលព្រះរាជកុមារ ទ្រង់បានយល់ដឹងច្បាស់ថា សត្វលោកទាំងអស់ត្រូវតែប្រយុទ្ធតស៊ូនឹងសេចក្ដីឈឺចាប់និងសេចក្ដីទុក្ខ ព្រះអង្គទ្រង់មានចិត្តអាណិតអាសូរ ចំពោះសព្វសត្វទាំងអស់រហូតមក ។

At the end of the feasting, the Royal attendants thought about their charge – The Prince. They saw the Prince under the rose-apple tree, seated steadily like a stone-image. They awakened the Prince. They said that the King was ready to go back to the Palace. When He realized that all beings have to fight against pain and suffering, His mind became compassionate towards all beings.

King Suddhodhana instructs that new Palaces should be built.
ព្រះបាទសិរីសុទ្ធោទនៈ បង្គាប់ឱ្យសង់ប្រាសាទថ្មី

នៅពេលដែលព្រះបាទសិរីសុទ្ធោទនៈទ្រង់ជ្រាបថា ព្រះរាជកុមារកំពុងស្វែងរកសេចក្តីពិត ព្រះអង្គទ្រង់មានព្រះទ័យខ្វល់ខ្វាយខ្លាំងណាស់ ។ ព្រះអង្គទ្រង់ជ្រាបថា ប្រសិនបើគំនិតនេះមិនត្រូវបានបំបាត់ចោលទាំងស្រុងទេនោះ ព្រះរាជកុមារច្បាស់ជាបោះបង់ជីវិតជាគ្រហស្ថពុំខានឡើយ ។ ព្រះរាជាពុំមាននរណាស្នងរាជ្យព្រះអង្គឡើយ ។ គំនិតនេះធ្វើឱ្យព្រះរាជាភ័យខ្លាំងណាស់ ។ ព្រះរាជាទ្រង់ជ្រាបថា វិធីដ៏ល្អបំផុតក្នុងការប្តូរគំនិតព្រះរាជកុមារ គឺបង្កើនផាសុកភាព និងប្រណីតភាពនៅក្នុងព្រះរាជវាំងឱ្យបានពីរដង ឬបីដង ។ ជំហានទីមួយឆ្ពោះទៅរកបំណងនេះ គឺការសាងសង់ប្រាសាទដ៏ល្អប្រណីតចំនួនបី ។

When King Suddhodana realized that the Prince was on a quest for truth, He became troubled. He knew that if these thoughts were not totally eradicated, He would leave the household life. He will not have anyone to succeed Him. These thoughts filled the King with fear. He knew that the best way to change the Prince's mind was to double and treble the comforts and luxurires in the Royal Palace. The first step towards this was erecting three luxurious Palaces.

The first Palace is built of fragrant Timber.
ប្រាសាទទីមួយសង់អំពីឈើក្រអូប

ប្រាសាទទីមួយ ត្រូវបានសង់ឡើងអំពីឈើក្រអូប ។ នៅខាងក្នុងមានភាពកក់ក្តៅ និងសម្រាប់ជានិវាសដ្ឋាននៅរដូវរងា ។ ប្រាសាទទីពីរ សង់អំពីថ្មើមថ្មរលោង សម្រាប់ប្រើនៅរដូវក្តៅ ។ ប្រាសាទទីបី សង់អំពីឥដ្ឋ និងដំបូលពណ៌បៃតង ។ ប្រាសាទនេះទុកសម្រាប់ប្រើក្នុងរដូវភ្លៀង ។ ព្រះរាជាបានទ្រង់ត្រាស់បញ្ជាឱ្យធ្វើសួនច្បារយ៉ាងល្អនៅជុំវិញប្រាសាទទាំងនោះ មានទាំងស្រះបោក្ខរណីប្រកបដោយផ្កាឈូកពណ៌ផ្សេងៗ ។ នៅក្នុងសួននេះ ព្រះរាជកុមារអាចយាងដោយព្រះបាទ ឬដោយជិះសេះតាមព្រះអង្គសព្វព្រះទ័យ ។

The first Palace was built of fragrant Timber. It was warm inside and was the Residence for the Winter season. The second was built of polished Marble to be used during Summer. The third was a Brick Building with a green roof. This was for the rainy season. The King ordered beautiful gardens to be laid out around these Palaces. There were ponds with Lotuses of different hues. He could walk or ride just as He wished in these Gardens.

King Suddhodhana, makes and effort to keep Prince Siddhartha happy.
ព្រះបាទសិរីសុទ្ធោទនៈ ខិតខំប្រឹងប្រែងធ្វើឱ្យព្រះរាជកុមារសប្បាយព្រះទ័យជានិច្ច

ព្រះរាជកុមារបានចំរើនវ័យវឌ្ឍនាការជាយថាហេតុ ។ សំរាប់ព្រះរាជកុមារ ព្រះអង្គបានពិចារណាឃើញយ៉ាងច្បាស់ថា រាល់ភាពសុខស្រួលលោកិយនេះពុំមានប្រយោជន៍អ្វីសម្រាប់ព្រះអង្គទេ ។ ព្រះរាជាទ្រង់ជ្រាបថា សេចក្តីប្រឹងប្រែងរបស់ព្រះអង្គ ដើម្បីធ្វើឱ្យព្រះរាជកុមារីរីករាយទាំងប៉ុន្មានឥតបានការទេ ។

Eventually He grew up into a youth. To the Prince, because of His contemplative mind, all these worldly comforts were of no use. The King discovered that all His efforts to please Him were of no avail.

King Suddhodhana enquires Courtiers about further ways to make Prince Siddhartha happy.
ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ត្រាស់សួរយោបល់ព្រះរាជអាមាត្យ អំពីផ្លូវផ្សេងតទៅទៀត ដើម្បីធ្វើឱ្យព្រះរាជកុមារសប្បាយព្រះទ័យ

ព្រះរាជាត្រាស់សួរទៅនាហ្មឺនសព្វមុខមន្ត្រី ក្រែងមានផ្លូវណាផ្សេងទៀតដែលអាចរារាំងព្រះរាជកុមារកុំឱ្យក្លាយជាសាស្តាចារ្យ ។ ក្រុមមន្ត្រីប្រទានយោបល់ថា «ផ្លូវតែមួយគត់ដែលចងព្រះរាជកុមារឱ្យជាប់នឹងជីវិតជាគ្រហស្ថ គឺប្រទានស្រីក្រមុំដែលមានរូបឆោមស្រស់ស្អាតទៅព្រះអង្គ ដើម្បីធ្វើជាមហេសី ។ នៅពេលដែលព្រះអង្គបានស្គាល់រសជាតិនៃសេចក្តីសប្បាយនៃជីវិតលោកិយហើយ ពេលនោះអារម្មណ៍របស់ព្រះអង្គច្បាស់ជាមិនផ្លាស់ប្តូរទៅជាប្រការផ្សេងឡើយ ។ ដូច្នេះព្រះអង្គនឹងឡើងស្នងរាជ្យតាមព្រះរាជបំណងរបស់ព្រះរាជាមិនខានឡើយ » ។

The King asked the Assembly of Ministers if there was some way by which the Prince could be prevented from becoming a Teacher. The Ministers advised thus. "The only way to keep Prince Siddartha bound to the household life is to provide Him with a comely Maiden as Consort. Once He relishes the delights of worldly life, His mind will not turn to other matters. He will then succeed to the throne as you wish.

They decide to find a comely Princess as bride for Prince Siddhartha.
ព្រះរាជានិងរាជអាមាត្យសម្រេចជ្រើសរើសរាជធីតាដ៏ស្រស់ស្អាតមួយអង្គ យកមករៀបអភិសេកថ្វាយព្រះរាជកុមារសិទ្ធត្ថ

ព្រះរាជាទ្រង់ប្រកាសធ្វើការជ្រើសរើសរកនាងកញ្ញា ដែលមានរូបឆោមលោមពណ៌ល្អដាច់គេនៅក្នុងនគរតាមសំណូមពររបស់ពួករាជអាមាត្យ ។ នាងកញ្ញាដ៏ល្អឆើតៗ ត្រូវបានគេអញ្ជើញឱ្យមកជួបជុំគ្នាក្នុងទីក្រុងនៅថ្ងៃដែលបានកំណត់ ។ នាងកញ្ញាទាំងនោះត្រូវចេញទៅបង្ហាញខ្លួននៅមុខព្រះភក្ត្ររាជកុមារម្តងម្នាក់ៗ និងទទួលអំណោយពីព្រះអង្គ ។ ព្រះរាជាទ្រង់ត្រាស់ឱ្យមន្ត្រីរាជបណ្ឌិត្យមួយក្រុមពិនិត្យមើលក្បួនបង្ហាញឆោមនាងធីតាទាំងនោះ និងកត់សម្គាល់នូវធីតាណាដែលធ្វើឱ្យរាជកុមារពេញព្រះហឫទ័យជាងគេ ។

Accepting the suggestion of the Ministers, the King set out to select the most beautiful damsel of the whole land. All beauties were requested to assemble in the City on a given day. Each Beauty came before the Prince and received a gift from Him.The King asked a team of very wise Royal Officials to watch the proceedings and to observe the beauty who won the Prince's heart most.



The Parade of Beauties.
ក្បួនបង្ហាញបវរកញ្ញា

នាងធីតាប្រកបដោយរូបសម្ផស្សល្អឆើតមកពីគ្រប់ទិសទីនៃព្រះនគរ បានមកបង្ហាញខ្លួននៅចំពោះព្រះភក្ត្ររាជកុមារសិទ្ធត្ថ និងទទួលអំណោយមួយម្នាក់ពីព្រះអង្គ ។ ធីតាទាំងអស់សុទ្ធតែមានសម្រស់ល្អក្រៃលែង ។ ពួកគេរីករាយនឹងបានទទួលអំណោយពីរាជកុមារ ប៉ុន្តែ បារម្ភខ្លាចមិនល្អដល់កំរិតដែលព្រះរាជកុមារត្រូវជ្រើសរើស ។

The Beauties from all over the land appeared before Prince Siddartha, and obtained a gift from Him. All were exceedingly comely. They were happy to receive gifts from the Prince, but were afraid that they were not that beautiful.

Prince Siddhartha gives presents to all Beauties, who pass in front of Him.
រាជកុមារសិទ្ធត្ថទ្រង់ប្រទានអំណោយដល់បវរកញ្ញាទាំងអស់ ដែលបានមកបង្ហាញខ្លួនចំពោះព្រះភក្ត្រព្រះអង្គ

ធីតាដ៏សោភាទាំងនោះមានអារម្មណ៍ដូច្នេះ ពីព្រោះពួកគេសង្កេតឃើញថា រាជកុមារពុំសូវយកព្រះទ័យទុកដាក់ចំពោះរូបសម្ផស្សរបស់ពួកគេទេ តែទោះបីយ៉ាងណាក៏ព្រះរាជកុមារបានប្រទានអំណោយទៅធីតាទាំងនោះគ្រប់ៗគ្នា ។ ធីតាទាំងឡាយមានអារម្មណ៍ថា រាជកុមារមិនមែនជាមនុស្សធម្មតាទេ ប៉ុន្តែគឺជាទេវៈមួយអង្គ ។

They felt that way because the Prince was not very much concerned with their physical beauty, though He gave gifts to all of them. The Beauties felt that He was not an ordinary human being but a Divine person.



An extremely beautiful Princess appears before the Prince suddenly at the last moment.
នៅទីបំផុតស្រាប់តែមានខត្តិយកញ្ញាដ៏ល្អសោភាក្រៃលែងមួយអង្គ បានយាងមកចំពោះព្រះភក្ត្ររាជកុមារ

បវរកញ្ញាចុងក្រោយបង្អស់បានចេញផុតទៅ រីឯវត្ថុជាអំណោយក៏អស់ដែរ ។ គេទាំងអស់គ្នាគិតថា បវរកញ្ញាទាំងឡាយសុទ្ធតែបានទទួលអំណោយទាំងអស់គ្នា ហើយក្បួនបង្ហាញរូបសម្ផស្សក៏បានចប់ត្រឹមនោះដែរ ។ ប៉ុន្តែ រំពេចនោះស្រាប់តែមានខត្តិយកញ្ញាមួយអង្គយាងចេញមក ។ ព្រះនាងបានយាងមកយឺតជាងគេ ។

The last of the Beauties was gone and so were the gifts. Everybody thought all Beauties had obtained gifts and the parade was over. But suddenly a beautiful Princess appeared. She came late.



Prince Siddhartha presents her a golden necklace.
ព្រះរាជកុមារប្រទានខ្សែកមាសទៅខត្តិយកញ្ញា

ពួកអ្នកចាំសង្កេតមើលព្រឹត្តិការណ៍ដឹងថា អាការខាងក្រៅរបស់រាជធីតានេះ ធ្វើឱ្យរាជកុមារចាប់អារម្មណ៍ ។ ព្រះនាងទ្រង់យាងពីមុខព្រះភក្ត្ររាជកុមារហួសទៅ រួចត្រឡប់មកវិញ ហើយទូលសួររាជកុមារដោយញញឹមក្រែងរាជកុមារមានសល់អំណោយសម្រាប់ព្រះនាង ។ ព្រះរាជកុមារតបទៅវិញថា ពិធីចែកអំណោយបានចប់អស់ហើយ ។ ប៉ុន្តែ ខ្ញុំមានអំណោយនេះសម្រាប់នាង សូមនាងទទួលយកវាចុះ ។ ទ្រង់មានបន្ទូលដូច្នេះ ហើយទ្រង់ក៏ប្រទានខ្សែកមាសដ៏មានតម្លៃ ដែលព្រះអង្គពាក់ជាប់នឹងខ្លួន ។

The obesrvers felt, that her appearance surprised the Prince. She walked in front of the Prince, turned back and asked the Prince with a smile if He had a gift for her as well. The Prince said, that the gift-giving was over."But I have this Gift for you. Please take it." So saying He gave her the valuable golden necklace He wore.



Proposal of marriage between Prince Siddhartha and·Princess Yasodhara.
សំណើសុំរាជាភិសេកព្រះរាជកុមារសិទ្ធត្ថ និងព្រះនាងយសោធរា

ពួកអ្នកសង្កេតការណ៍ដែលតែងតាំងដោយព្រះរាជាមានសេចក្ដីត្រេតអរណាស់ចំពោះរឿងនេះ ។ ក្រោយមកទើបពួកគេបានដឹងថា រាជធីតាដែលយាងមកក្រោយគេបំផុតនោះ គឺព្រះនាងយសោធរា បុត្រីរបស់ព្រះបាទសុប្បពុទ្ធ ។ ព្រះបាទសិរីសុទ្ធោទនៈទ្រង់បញ្ជូនព្រះរាជតំណាងទៅគាល់ព្រះបាទសុប្បពុទ្ធ ដើម្បីឱ្យព្រះអង្គប្រទានបុត្រី ទៅរៀបអភិសេកជាមួយព្រះរាជបុត្ររបស់ព្រះអង្គ គឺរាជកុមារសិទ្ធត្ថ ។

The observers deployed by the King were very happy at this. They learnt later, that the princess who came last, was princess Yasodhara, the daughter of King Suprabuddha. King Suddhodana sent emissaries to King Suprabuddha requesting Him to give His Daughter in marriage to His Son Prince Siddhartha.



Display of horsemanship at Kapilavastu.
ពិធីសម្តែងសិល្បៈជិះសេះ នៅក្រុងកបិលពស្តុ

ជនទាំងឡាយដែលរស់នៅតាមជើងភ្នំហេមពាន្ត សុទ្ធជាជនអង់អាចក្លាហាន ។ តាមប្រពៃណីរបស់ត្រកូលសក្យៈ យុវក្សត្រនៅពេលបំរុងនឹងរៀបអភិសេក គប្បីសម្តែងឱ្យគេឃើញជាសាធារណៈនូវសិល្បៈជិះសេះ បាញ់ធ្នូ និងគុណដាវរបស់ខ្លួន ។ ដោយគោរពតាមប្រពៃណីនេះ ព្រះរាជកុមារសិទ្ធត្ថ ទ្រង់ប្រកួតជាមួយពួកកម្លោះដែលក្លាហាន និងពូកែៗទាំងអស់ ដើម្បីបង្ហាញឱ្យឃើញថា ព្រះអង្គពូកែជាងគេនៅក្នុងការសម្តែងជាសាធារណៈ ។

Those who lived at the foothills of the Himalayas were brave people. According to the traditions of the Sakya Clan, a young person, when he is about to get married should publicly display his skills in horsemanship, archery and swordsmanship. Respecting this tradition, Prince Siddhartha challenged all the brave and clever young men of Kapilavastu to better Him at a public display.



The breaking of the untamed horse at the Contest.
ការបង្ក្រាបសេះមិនទាន់ផ្សាំងនៅក្នុងពេលប្រកួត

កម្លោះៗទាំងអស់សុទ្ធតែពូកែស្ទាត់ក្នុងជំនាញរបស់ខ្លួន ។ ពួកគេសម្តែងម្តងម្នាក់ៗ នៅចំពោះព្រះភក្ត្រព្រះរាជា និងសេវកាមាត្យ ។ រាជកុមារសិទ្ធត្ថជិះសេះសរបស់ព្រះអង្គឈ្មោះ កណ្ឋកៈ និងបង្ហាញឱ្យឃើញច្បាស់ថា ព្រះអង្គជាអ្នកជិះសេះពូកែបំផុត ។ រាជកុមារសិទ្ធត្ថ បាញ់ធ្នូបានពូកែជាងរាជកុមារទេវទត្តទៅទៀត ទោះបីរាជកុមារទេវទត្តមានឈ្មោះល្បីថាជាខ្មាន់ធ្នូពូកែជាងគេក៏ដោយ ។

All these young men were adepts in their skills. They displayed, in turn, their skills, in the presence of the King and the Courtiers. Prince Siddhartha rode His white Horse Kanthaka, and proved that He was the most skilful horseman. Prince Siddhartha, bettered Prince Devadatta in archery, though Prince Devadatta was reputed as the greatest in archery.

Prince Siddhartha becomes winner at Fencing.
រាជកុមារសិទ្ធត្ថ ទទួលជ័យជំនះក្នុងកីឡាកាប់ដាវ

ក្នុងការសម្តែងសិល្បៈកាប់ដាវ ព្រះរាជកុមារសិទ្ធត្ថបានកាប់ផ្តាច់ដើមឈើមួយដើមតែមួយដាវ ។ ឈើដែលបានកាត់ហើយនោះពុំបានរលំទេ ។ ទស្សនិកជនគិតស្មានថា ព្រះរាជកុមារពុំអាចកាត់ដើមឈើនោះដាច់ទេ ។ ប៉ុន្តែ នៅពេលខ្យល់បក់មក ដើមឈើក៏រលំយឺតៗរហូតដល់ដី ។ វាហាក់ដូចជាមុខដាវរត់កាត់វត្ថុអ្វីមួយដ៏សែនទន់ ។ នៅក្នុងសិល្បៈកាប់ដាវ គឺព្រះរាជកុមារទទួលបានជ័យជំនះដាច់គេទៀត ។ ពេលមុននោះ គឺព្រះរាជកុមារនន្ទ ដែលជាបងប្អូនជីដូនមួយរបស់ព្រះអង្គទេ ជាអ្នកដែលគេទទួលស្គាល់ថាជាជើងឯកខាងកាប់ដាវ ។

Displaying His swordsmanship, Prince Siddhartha cut down a tree with one stroke of his sword. The tree did not fall though cut with the sword. The spectators thought that the Prince had not been able to cut down the tree. But when the wind blew the tree fell slowly. It was as if the blade of the sword went through something exceedingly soft. In swordsmanship too, the Prince won with distinction. Earlier, it was Prince Nanda, a cousin of Prince Siddhartha who had been acclaimed the champion swordsman.

Prince Siddhartha wins in Horse-riding.
រាជកុមារសិទ្ធត្ថ ឈ្នះគេក្នុងការប្រណាំងសេះ

វិញ្ញាសាបន្ទាប់មក គឺការប្រណាំងសេះ ។ សេះសឈ្មោះកណ្ឋកៈរបស់រាជកុមារសិទ្ធត្ថ បានរត់លឿនជាងសេះដទៃ ។ ពួកអ្នកចូលរួមប្រកួតតវ៉ាថា រាជកុមារសិទ្ធត្ថឈ្នះគេក៏ព្រោះតែព្រះអង្គជិះសេះកណ្ឋកៈ ។ ពួកគេពោលថា «អ្នកណាក៏ដោយឱ្យតែជិះសេះកណ្ឋកៈសុទ្ធតែឈ្នះគេ ឯអ្នកជិះសេះខ្មៅសុទ្ធតែទទួលបរាជ័យតែទាំងអស់គ្នាហ្នឹង» ។

Next came horse-racing. Prince Siddhartha's white Horse Kanthaka – outran all the other horses. The other competitors complained that Prince Siddhartha scored an easy victory because he mounted Kanthaka. "Anyone riding Kanthaka will win. Anyone riding the black horse will get defeated" they said.



Taming an unruly Horse.
ការផ្សាំងសេះដែលគេមិនអាចបង្ក្រាបបាន

ក្រោយមក រាជកុមារទាំងឡាយបានប្ដូរសេះគ្នា ។ អ្នកដែលល្បងឡើងជិះសេះខ្មៅសុទ្ធតែត្រូវសេះនេះទម្លាក់ពីលើខ្នង ។ រាជកុមារអនុរុទ្ធ ដែលគេចាត់ទុកថាជាអ្នកជិះសេះពូកែបំផុតនៅក្នុងនគរ ឡើងជិះសេះខ្មៅបានមួយរយៈដ៏ខ្លី ដោយវាយសេះនោះផង ។

Then they changed horses. All the riders who tried to mount the black horse were dislodged by the black horse. Prince Anuruddha, who was considered the cleverest horseman in the land managed to ride him for a few moments by whipping the horse.

Display of horsemanship
ការសម្តែងសិល្បៈជិះសេះ

ប៉ុន្តែនៅពេលដែលព្រះរាជកុមារអនុរុទ្ធ គង់ភ្លេចខ្លួនមួយភ្លែត សេះខ្មៅកំណាចនោះបានផាយទម្លាក់ព្រះអង្គពីលើខ្នង ។ ពួកអ្នកការពារនាំគ្នារត់ប្រញាប់ប្រញាល់ទៅជួយការពារព្រះអង្គ កុំឱ្យសេះធ្វើឃាត ។

But, when Prince Anuruddha stood still for an instant, the unbroken black horse threw him off, the guardians rushed forward and prevented the horse killing Prince Anuruddha.



Prince Siddhartha tames a ferocious Horse.
ព្រះរាជកុមារសិទ្ធត្ថ ផ្សាំងសេះកំណាច

បន្ទាប់មកដល់វេនព្រះរាជកុមារសិទ្ធត្ថម្តង ពួកគេព្រួយបារម្ភគ្រប់ៗគ្នា ព្រោះថាអ្នកជិះសេះដ៏ឆ្នើមបំផុតនៅក្នុងនគរទៅហើយ ក៏ស្ទើរតែនឹងបាត់បង់ជីវិត ។ ប៉ុន្តែ រាជកុមារសិទ្ធត្ថយាងទៅជិតសេះកំណាចយ៉ាងទន់ភ្លន់ ។ ទ្រង់អង្អែលសេះ រួចទះខ្នងវាថ្នមៗ ដោយមានបន្ទូលពិរោះទៅរកវា ។

Then came Prince Siddhartha's turn. All were anxious because the cleverest horseman in the land could save His life only by a hair's breadth. But Prince Siddhartha approached the untamed black horse gently. He caressed the horse and patted his back speaking to him kindly.



Prince Siddhartha rides a ferocious black Horse.
ព្រះរាជកុមារសិទ្ធត្ថជិះសេះកំណាច

សេះខ្មៅកំណាចប្រគល់ខ្លួន ឱ្យរាជកុមារឡើងជិះតាមរាជបំណង ។ មនុស្សម្នាទាំងអស់គ្នាឃើញច្បាស់ថា សេះខ្មៅកំណាចបានស្តាប់បង្គាប់តាមបំណងរបស់ព្រះរាជកុមារសិទ្ធត្ថទាំងអស់ ។ គឺចាប់ពីក្រោយពេលនោះមកហើយ ដែលអ្នកដទៃឯទៀតចូលទៅផ្សាំងវា ដោយពុំបានវាយធ្វើបាបវាទៀតឡើយ ។

The ferocious black horse yielded to the Prince's wishes. Allowed the Prince to mount him. Everybody saw that the untamed black horse obeyed the wishes of Prince Siddhartha. It was only after that others came forward to tame it without whipping it.



Marriage between Prince Siddhartha and Princess Yasodhara is confirmed.
ព្រះរាជពិធីអភិសេករវាងព្រះរាជកុមារសិទ្ធត្ថ និងព្រះនាងយសោធរា ត្រូវបានយល់ព្រម

នៅទីបញ្ចប់ ទាំងអស់គ្នាបានទទួលស្គាល់ថា ព្រះរាជកុមារសិទ្ធត្ថគឺជាអ្នកពូកែជិះសេះជាងគេបំផុតនៅក្នុងព្រះនគរ និងជាអ្នកកម្លោះដ៏ប្រពៃបំផុតដែលត្រូវធ្វើជាស្វាមីរបស់ព្រះនាងយសោធរា ។ ព្រះរាជាសុប្បពុទ្ធ ទ្រង់ក៏យល់ព្រមថ្វាយបុត្រីជាទីស្រឡាញ់របស់ព្រះអង្គទៅរាជកុមារដ៏ក្លាហាន ដើម្បីរៀបអភិសេកជាមហេសីដែរ ។

At the end all were agreed that Prince Siddhartha was the cleverest horseman in the land, and was the best young person to be the husband of Princess Yasodhara. King Suprabuddha too agreed to give his dear daughter in marriage to the courageous Prince.



The Wedding Ceremony between Prince Siddhartha and Princess Yasodhara.
ពិធីរាជាភិសេករវាងព្រះរាជកុមារសិទ្ធត្ថ និងព្រះនាងយសោធរា

ពិធីរាជាភិសេករវាងព្រះរាជកុមារសិទ្ធត្ថ និងព្រះនាងយសោធរា គឺជាឱកាសដ៏សប្បាយរីករាយសម្រាប់មនុស្សម្នាទាំងអស់ក្នុងនគរ ។ គូស្វាមីភរិយាដែលទើបរៀបការហើយនេះរស់នៅក្នុងប្រាសាទមួយដែលព្រះបាទសិរីសុទ្ធោទនៈសង់ឡើងជាពិសេសសម្រាប់ថ្វាយចំពោះរាជកុមារនិងមហេសី ។ នោះគឺជាប្រាសាទដ៏ល្អប្រណីតពោរពេញទៅដោយផាសុកភាពគ្រប់យ៉ាងនៃជីវិត។ ព្រះបាទសិរីសុទ្ធោទនៈទ្រង់មានអារម្មណ៍ស្ងប់ដោយមានជំនឿថា ព្រះរាជកុមារនឹងពុំបោះបង់ចោលជីវិតជាគ្រហស្ថឡើយ ។

The wedding of Prince Siddhartha and Princess Yasodhara was a joyous occasion for all the people of the land. The newly-weds lived in a Palace especially built for them by King Suddhodana. It was a luxurious Residence, full of all comforts of life. King Suddhodana lived in a relaxed state of mind, convinced that the prince will not renounce the lay life.



Dancing in front of Prince Siddhartha.
របាំថ្វាយព្រះរាជកុមារ

ដើម្បីការពារកុំឱ្យព្រះរាជកុមារលះបង់ជីវិតជាគ្រហស្ថ ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ត្រាស់ហាមដាច់ខាតមិនឱ្យនរណាម្នាក់និយាយឱ្យព្រះរាជកុមារឮអំពីសេចក្ដីទុក្ខ ចាស់ជរា រោគាព្យាធិ និងសេចក្ដីស្លាប់ឡើយ ។ ពួកបំរើនៅក្នុង ព្រះរាជវាំងត្រូវគេបង្គាប់ឱ្យច្រៀងរាំប្រគុំតន្ត្រីជាប់មិនដាច់ និងដោយមិនឱ្យបង្ហាញឱ្យឃើញភាពហត់នឿយអស់កម្លាំង នៅចំពោះព្រះភក្ត្ររាជកុមារឡើយ ។

To prevent the Prince from renouncing the lay life, King Suddhodana decreed that no one should speak in the Prince's hearing about suffering, ageing, illness, disease and death. The employees of the Royal household had been ordered to sing, dance and to perform music constantly and not to appear tired and exhausted in the Prince's presence.

High Walls are erected for the protection of Prince Siddhartha.
គេសង់កំពែងយ៉ាងខ្ពស់ដើម្បីការពារព្រះរាជកុមារសិទ្ធត្ថ

ព្រះបាទសិរីសុទ្ធោទនៈ ទ្រង់ត្រាស់បញ្ជាឱ្យគេសង់កំពែងយ៉ាងខ្ពស់ព័ទ្ធជុំវិញព្រះរាជវាំង និងឱ្យធ្វើសួនឧទ្យានយ៉ាងល្អព័ទ្ធជុំវិញមួយជាន់ទៀត ។ មានតែស្ត្រីក្រមុំស្អាតៗទេ ដែលគេអនុញ្ញាតឱ្យចូលទៅក្នុងរាជវាំង និងសួនច្បារបាន ។ ជនណាដែលមានរបួសដោយធ្លាក់ពីលើកំពែង ត្រូវនាំចេញជាបន្ទាន់ ។ ជននោះអាចនឹងចូលទៅក្នុងបរិវេណវាំងជាថ្មីទៀតបាន លុះត្រាតែរបួសជាស្រួលបួលដូចដើម ។ ទ្វារចូលវាំងត្រូវដាក់ឱ្យយាមកាមយ៉ាងហ្មត់ចត់បំផុត សូម្បីព្រះរាជកុមារក៏មិនអាចយាងចេញបានដែរ បើគ្មានព្រះរាជានុញ្ញាតពីព្រះរាជា ។

King Suddhodana ordered high walls erected around the Palace and to have beautiful parks right round it. Only beautiful young women were allowed to enter the Palace and the gardens. Anyone injured falling off the walls, was to be taken out instantly. He could not enter into the premises again until he was fully recovered. Garden gates were strictly guarded so that the Prince could leave only with the King's permission.



Prince Siddhartha's desire to see the World outside.
ព្រះរាជកុមារសិទ្ធត្ថ មានព្រះទ័យនឹកភ្នកចង់ឃើញជីវិតនៅខាងក្រៅវាំង

ទោះបីព្រះរាជាបានចាត់ចែងសព្វបែបយ៉ាង ដើម្បីធ្វើឱ្យរាជកុមារបានសប្បាយរីករាយឥតអាក់ក៏ដោយ ក៏ព្រះរាជកុមារមិនបានសប្បាយព្រះទ័យដូចដែលព្រះរាជាសង្ឃឹមទុកនោះទេ ។ ព្រះរាជកុមារមានប្រាថ្នាដ៏ខ្លាំងក្លាចង់ឃើញនូវអ្វីដែលកើតមាននៅខាងក្រៅកំពែងវាំង ។ ព្រះរាជកុមារចង់ដឹងអំពីជីវិតរស់នៅរបស់ប្រជាជនធម្មតាជាងចង់ដឹងអំពីជីវិតរបស់ព្រះរាជបុត្រា បុត្រី ព្រះអង្គម្ចាស់ និងនាហ្មឺនសព្វមុខមន្ត្រី ។ ជាញឹកញាប់ព្រះរាជកុមារបានទទូចសុំអង្វរព្រះរាជាថា ព្រះអង្គពុំអាចមានសេចក្ដីសុខក្នុងជីវិតទេ បើព្រះអង្គពុំបានដឹងអំពីអ្វីដែលបានកើតឡើងនៅខាងក្រៅព្រះបរមរាជវាំង ។

In spite of all the precautions taken by the King to see that the Prince was perpetually happy, the Prince was not as happy as the King expected Him to be. The Prince was keen to see what was going on outside the Palace walls. The Prince was keen to know about the life of ordinary masses than about the sons and daughters of Kings, Princes and high officials. From time to time He entreated to the King that He can never lead a happy life without knowing what went on in the world outside.

Preparations for Prince Siddhartha's visit to the Pleasure Park.
ការរៀបចំដំណើរក្រសាលឧទ្យានថ្វាយព្រះរាជកុមារសិទ្ធត្ថ

ដោយមិនអាចបដិសេធបំណងប្រាថ្នារបស់រាជកុមារ ដែលចង់យាងចេញក្រៅព្រះរាជវាំងម្តងម្កាលនោះ ព្រះបាទសិរីសុទ្ធោទនៈទ្រង់ក៏បានព្រះរាជានុញ្ញាតតាមសំណូមពររបស់រាជកុមារ ។ ព្រះរាជាទ្រង់ត្រាស់បញ្ជាថា នៅពេលរាជកុមារធ្វើដំណើរចេញក្រៅព្រះរាជវាំងនោះ គ្រប់ផ្ទះត្រូវរៀបចំឱ្យបានស្អាតបាត និងតុបតែងលំអដោយទង់ជ្វាលា ។ មិនឱ្យកម្មករដើរអែនអនតាមផ្លូវ ។ មនុស្សខ្វាក់ ជនមានការឈឺចាប់ មនុស្សចាស់ និងមនុស្សកើតឃ្លង់ ត្រូវនៅក្នុងផ្ទះរហូតដល់ព្រះរាជកុមារយាងទៅផុត ។

No longer able to disregard the Prince's wish to go out of the Palace occasionally, King Suddhodana allowed His request. The King ordered that when the Prince travels outside the Palace, all houses should be in neat trim and should be gaily decorated with flags and banners. No workers should linger on the road. Blind people, the afflicted, old people and lepers should stay indoors until the Prince has passed.



Prince Siddhartha sets out for the Pleasure Park.
រាជកុមារសិទ្ធត្ថ យាងចេញទៅក្រសាលឧទ្យាន

អ្វីៗទាំងអស់ត្រូវបានរៀបចំរួចស្រេចសម្រាប់ដំណើរយាងចេញក្រៅរបស់រាជកុមារ ។ ព្រះរាជកុមារសិទ្ធត្ថ ទ្រង់គង់លើរាជរថដែលតុបតែងយ៉ាងល្អស្អាត បរប្រទក្សិណជុំវិញទីក្រុង ។ ព្រះអង្គទតឃើញមានប្រជាជនជាច្រើនរង់ចាំមើលព្រះអង្គយ៉ាងសប្បាយរីករាយ ។ មហាជនបានទះដៃអបអរសាទររាជកុមារ និងថ្វាយព្រះពរឱ្យព្រះអង្គមានព្រះជន្មយឺនយូរ ។ រាជរថបរទៅឆ្ងាយលើកម្រាលផ្កាដែលមហាជនបានបាចតាមដងផ្លូវ ដើម្បីសម្តែងសេចក្តីស្រឡាញ់ចំពោះរាជកុមារ ។

Everything was ready for the Prince's outing. Prince Siddhartha in a decorated chariot, rode around the City. The Prince observed the people waiting joyously to see Him. The masses gave the Prince an ovation and wished Him long life. The Chariot travelled for some distance on the flowers strewn on the road by the adoring masses.

Prince Siddhartha sees an old man.

រាជកុមារសិទ្ធត្ថ ទតឃើញមនុស្សជរាម្នាក់

រំពេចនោះស្រាប់តែមានមនុស្សជរាម្នាក់ សក់ស្កូវស្លៀកពាក់រហែករយ៉ៃចេញពីផ្ទះដោយដំណើរញ៉ររទេទ្រើក ដោយគ្មាននរណាម្នាក់ឃាត់ទាន់ ។ មុខជ្រីវជ្រួញរបស់គាត់មានសុទ្ធតែប្រជ្រុយ ។ ភ្នែកទាំងពីរងងឹតមិនអាចមើលអ្វីឃើញ ។ គាត់មានសល់តែធ្មេញមួយគត់នៅក្នុងមាត់ ។ គាត់មានខ្នងកោង និងដើរបានដោយសារពឹងឈើច្រត់ ។ គាត់បានសុំទានអាហារដោយសម្រក់ទឹកភ្នែក និងទ្រហោរយំ ហើយប្រសិនបើគាត់សុំទានអាហារមិនបាន សូម្បីតែមួយថ្ងៃក៏ដោយក៏គាត់ប្រាកដជាស្លាប់ព្រោះគ្មានអ្វីបរិភោគ ។

Suddenly a grey-haired old man in rags, came out of a house limping, before anyone could stop him. His wrinkled face was marked with moles. Eyes were bereft of sight. He had only one tooth left in his dry mouth. He was hunched and walked about assisted by a stick. He begged for food, weeping and wailing and if he missed his food even one day he would have certainly died of starvation.

Attempt to prevent Prince Siddhartha from seeing the old man.
ការប៉ុនប៉ងទប់ស្កាត់កុំឱ្យរាជកុមារទតឃើញមនុស្សចាស់ជរា

នេះគឺជាដំណើរកំសាន្តលើកទីមួយរបស់រាជកុមារ ។ មនុស្សម្នាទាំងអស់ភ្ញាក់ផ្អើលខ្លាំងណាស់ ពេលឃើញមនុស្សទុព្វលភាពចេញមក ជាពិសេសដោយសារព្រះរាជាបានបញ្ជាពួកគេឱ្យឃាត់កុំឱ្យមនុស្សចាស់ និងមនុស្សឈឺចូលមកជិតក្បួន ។ ពួកគេប៉ុនប៉ងដេញមនុស្សចាស់ឱ្យចេញទៅឆ្ងាយ ដើម្បីកុំឱ្យរាជកុមារទតឃើញ ។ ប៉ុន្តែ ហួសពេលទៅហើយ ។ រាជកុមារបានទតឃើញមនុស្សជរារួចស្រេចទៅហើយ ។

This was the Prince's first pleasure tour. The people were alarmed by the appearance of this decrepit old man, especially because the King had ordered them to keep away the old people and sick ones. The people tried to send the old man away so that the Prince will not see him. But, it was too late. The Prince had seen him already, by then.

rince Siddhartha's surprise at seeing the old man.
ាជកុមារសិទ្ធត្ថ មានព្រះរាជហឫទ័យសង្វេគពេលឃើញមនុស្សជរា

ការទតឃើញមនុស្សជរា ធ្វើឱ្យរាជកុមារមានសេចក្តីសង្វេគយ៉ាងខ្លាំង ។ ព្រះអង្គពុំដែលបានដឹងថា មានមនុស្សជរាទេ ។ ព្រះអង្គបានសួរទៅនាយសារថីរបស់ព្រះអង្គឈ្មោះឆន្នថា «ម្នាលឆន្នអាមាត្យ តើនោះជាអ្វីទៅ? ជាមនុស្សមែនទេ? បើគេជាមនុស្ស ហេតុអ្វីបានជាខ្នងគាត់កោង? ហេតុអ្វីក៏គាត់ញ័រទទ្រើកយ៉ាងនេះ? ហេតុអ្វីក៏សក់គាត់ស្កូវ? ចុះភ្នែកគាត់កើតអ្វី? ហេតុអ្វីបានជាគាត់គ្មានធ្មេញអញ្ចឹង? តើមាននរណាខ្លះដែលកើតមកដូចគាត់? ម្នាលឆន្នអាមាត្យ ចូរអ្នកពន្យល់អ្វីៗទាំងអស់នេះឱ្យយើងបានដឹងផង» ។

The sight of the old man, surprised the Prince very much. He did not know what kind of person that was. He asked His charioteer, Channa "Channa, whatever is that? A man? If that is a man how did his back become hunched? Why is he shaking and trembling? How has his hair turned grey? What has happened to his eyes? Why is it that he has no teeth? Are some born that way? Channa please explain all this to me."



Channa explains old age to Prince Siddhartha.
ឆន្នអាមាត្យ ពន្យល់អំពីជរាភាព ថ្វាយរាជកុមារសិទ្ធត្ថ

ឆន្នអាមាត្យទូលតបថា «ក្រាបទូលព្រះអង្គ នេះគឺជាមនុស្សជរាម្នាក់ ។ ពីមុនមកគាត់មិនមែនមានអាការដូច្នេះទេ ។ ពេលកើតមកគាត់មានលក្ខណៈដូចជាមនុស្សដទៃឯទៀតដែរ ។ ដំបូងគាត់ជាយុវជនមានកាយពលមាំមួនម្នាក់ដោយមានសក់ខ្មៅ ។ ក្រោយមកពេលគាត់រស់បានយូរបន្តិចរាងកាយគាត់ក៏ប្រែប្រួល ។ ក្រាបទូលព្រះអង្គម្ចាស់ សូមព្រះអង្គកុំយកព្រះទ័យទុកដាក់ចំពោះរឿងនេះអី ។ រឿងនេះវាមានតែចំពោះមនុស្សជរាម្នាក់នោះឯង» ។ ព្រះរាជកុមារបន្តជជីកសួរទៅឆន្នអាមាត្យថា «ម្នាលឆន្ន តើឯងចង់និយាយថាដូចម្តេចចំពោះរឿងនេះ? តើឯងចង់និយាយថា នេះជារឿងធម្មតាមែនទេ?» ។ ឆន្នអាមាត្យតបថា «ក្រាបទូលព្រះអង្គ តើព្រះអង្គចង់ដឹងថាមនុស្សទាំងអស់សុទ្ធតែជរាដូចគ្នាមែនឬទេ? មនុស្សទាំងអស់ដល់ពេលចាស់ទៅ សុទ្ធតែប្រែរូបរាងទៅជាយ៉ាងនេះដូចគ្នា ។ គ្មាននរណាអាចហាមឃាត់មិនឱ្យចាស់បានទេ» ។

Channa answered: "O Lord, this is an old man. He has not been that way. At birth he was similar to other human beings. At first he was a sturdy, strong young man, with black hair. After he lived for a long while his form changed. O Lord,do not trouble yourself about it. .This has to do only with that old man".

"Channa what do you mean by that? Do you imply that it is an ordinary matter?" the Prince continued to question Channa that way. Channa replied: "O Lord do you enquire whether all people are subject to this ageing? When people grow old, they change this way. It cannot be prevented."

Channa tells the Prince that ageing cannot be avoided.
ឆន្នអាមាត្យ ទូលរាជកុមារថាជរាភាពមិនអាចចៀសបានទេ

«ម្នាលឆន្នអាមាត្យ តើអ្នកចង់និយាយថា យើងទាំងអស់គ្នា ទាំងអ្នក ទាំងយើង ទាំងអ្នកដទៃឯទៀត សុទ្ធតែជរាដូច្នេះមែនទេ? តើព្រះបិតា និងមហេសីយើងក៏ជរាដូចគ្នាដែរមែនទេ? ថ្ងៃណាមួយយើងទាំងអស់គ្នា នឹងដើរកាន់ឈើច្រត់ ខ្នងកោង បាក់ធ្មេញ សក់ស្កូវ មែនទេ?» ឆន្នអាមាត្យតបទៅវិញថា «ក្រាបទូល ពិតជាដូច្នោះមែនហើយ» ។ «បន្តិចទៀតទៅមនុស្សទាំងអស់ក្លាយទៅជាចាស់ដូចជននោះទាំងអស់គ្នា ។ គ្មាននរណាអាចគេចផុតបានទេ» ។

"Channa do you really mean that we all you, I and others become old this way? Is it the same for my Father and my wife?'One day will all of us have to walk about with the aid of a stick, our body bent, without teeth, with the hair grown grey?" "It is indeed so my Lord" Channa replied. "After some time all people become old like this man. No one can prevent it."



Prince Siddhartha's quick return to the Palace.
រាជកុមារសិទ្ធត្ថ ត្រឡប់ទៅព្រះរាជវាំងវិញជាប្រញាប់

រាជកុមារមិនបានសប្បាយព្រះទ័យនឹងបន្តដំណើរក្រសាលសួនឧទ្យានជុំវិញទីក្រុងទេ ។ ព្រះអង្គទ្រង់បញ្ជាឱ្យឆន្នអាមាត្យត្រឡប់ក្រោយវិលទៅព្រះរាជវាំងវិញ ។ រាជកុមារសិទ្ធត្ថ មានបំណងគង់តែម្នាក់ឯង ដើម្បីពិចារណាឱ្យបានជ្រាលជ្រៅអំពីបញ្ហាដែលធ្វើឱ្យព្រះអង្គខ្វាយខ្វល់ ។ ព្រះអង្គទ្រង់ដឹងច្បាស់ថា ទោះបីព្រះអង្គក្ដី និងរាជបរិវាររបស់ព្រះអង្គក្ដីសុទ្ធតែត្រូវបាត់នូវអ្វីៗដែលខ្លួនមានទាំងអស់នៅថ្ងៃណាមួយមិនខាន ។ ថ្ងៃណាមួយព្រះអង្គនឹងបាត់បង់នូវប្រណីតភាព និងផាសុកភាព ពីព្រោះពុំមានវិធីណាអាចហាមឃាត់មិនឱ្យចាស់បានទេ ។ ទាំងអ្នកមាន ទាំងអ្នកក្រ ទាំងអ្នកមានអំណាច សុទ្ធតែចាស់ដូចគ្នា ។ មនុស្សទាំងអស់ នឹងប្រឈមមុខចំពោះស្ថានភាពនេះដូចគ្នា ។

The Prince did not relish the idea of continuing his tour of the City. He asked Channa to turn back and return to the Palace. Prince Siddhartha wanted to be alone to contemplate deeply about this disturbing problem He faced. He realized that though a Crown Prince He and His loyal retinue will all one day be bereft of everything. He will one day lose all his luxuries and comforts, because there was no way in which old age could be prevented. It does not make a difference whether one is rich or poor or powerful. Everybody will face this situation.



Prince Siddhartha sleeplessly contemplates this event.
រាជកុមារផ្ទុំមិនលក់ ដោយសារការពិចារណាចំពោះព្រឹត្តិការណ៍នេះ

យប់នោះ រាជកុមារសិទ្ធត្ថពុំអាចផ្ទុំលក់ទេ ។ នៅពេលដែលទ្រង់គិតថា ថ្ងៃណាមួយព្រះអង្គក្តី មហេសីព្រះអង្គក្តី សុទ្ធតែក្លាយទៅជាចាស់ជរាដូចមនុស្សដែលព្រះអង្គបានទតឃើញ ព្រះអង្គកាន់តែមានសេចក្តីខ្វាយខ្វល់ខ្លាំងឡើង ។ ព្រះអង្គទ្រង់សង្ស័យក្រែងមាននរណាម្នាក់នៅលើលោកនេះ បានរកឃើញនូវវិធីណាមួយ ដែលអាចចៀសផុតពីសេចក្តីទុក្ខ ដែលកើតអំពីជរាភាព ឬអាចបង្ការកុំឱ្យមានជរាភាពបាន ។ ប្រសិនបើអាត្មាអញបំភ្លេចចោលនូវអ្វីៗផ្សេងៗទៀត ហើយប្រមូលផ្តុំពិចារណាតែទៅលើរឿងមួយនេះ តើអាត្មាអញអាចរកផ្លូវណាមួយសម្រាប់ជួយស្រោចស្រង់ខ្លួនឯង និងអ្នកឯទៀតបានឬទេ? ។

That night Prince Siddhartha could not sleep. When He thought that He and His wife will one day grow old just like the old man He saw, He was quite troubled. He doubted if anyone in the whole world had searched for a way to prevent the suffering of old age, or to prevent old age. If I set aside all else and concentrate only on this, could I find a way to help Myself and others?



The Prince decides to visit the Pleasure Park once again.
ព្រះរាជកុមារសម្រេចព្រះទ័យ នឹងយាងទៅទតឧទ្យានម្តងទៀត

មានគេទូលព្រះរាជាអំពីព្រឹត្តិការណ៍ដែលបានកើតឡើង ក្នុងពេលក្រសាលឧទ្យាន ។ ព្រះរាជាទ្រង់ខ្វាយខ្វល់ព្រះទ័យក្រៃលែង ដោយសាររឿងនេះ ។ ព្រះអង្គទ្រង់បញ្ជាឱ្យរកវិធីផ្សេងៗទៀត ដើម្បីបង្វែររាជកុមារចេញពីសេចក្តីខ្វាយខ្វល់ដែលព្រះអង្គបានជួប ។ ប៉ុន្តែការខិតខំប្រឹងប្រែងទាំងប៉ុន្មានពុំមានប្រយោជន៍ទេ ។ រាជកុមារកាន់តែព្រួយ និងអស់សង្ឃឹម ។ ព្រះអង្គទ្រង់សុំព្រះរាជានុញ្ញាតពីព្រះរាជា ដើម្បីយាងទៅទស្សនាទីក្រុងដោយមិនឱ្យនរណាដឹង ដើម្បីព្រះអង្គអាចនឹងទតឃើញគ្រប់ទិដ្ឋភាពនៃជីវិត ។

Someone informed the King about what happened during the pleasure tour. The King was exceedingly moved by this. The King ordered that ways be found to divert the mind of the Prince from this troubling experience. But all the efforts were of no avail. The Prince was depressed. He asked the King for permission to tour the city unannounced so that He could see all sides of life.



Prince Siddhartha plans to obtain permission to visit the Pleasure Park.
ព្រះរាជកុមារសិទ្ធត្ថ រៀបគម្រោងដើម្បីសុំអនុញ្ញាតយាងទៅក្រសាលឧទ្យាន

ព្រះរាជាពុំមានព្រះទ័យចង់ឱ្យរាជកុមារធ្វើដំណើរចេញក្រៅវាំងទេ ។ ព្រះរាជាសង្ស័យថា រាជកុមារពុំមែនយាងទៅសួរសុខទុក្ខ មន្ត្រីរាជការ និងវរជននោះទេ ប៉ុន្តែគឺទៅជួបនឹងប្រជាជនសាមញ្ញ ដែលធ្វើការបង្ហូរញើសរាល់ៗល្ងាច ។ ព្រះរាជាទ្រង់ខ្វល់ខ្វាយក្នុងព្រះទ័យខ្លាំងណាស់ខ្លាចក្រែងរឿងរ៉ាវដែលពួកតាបសបានទស្សន៍ទាយនោះ កំពុងក្លាយជារឿងពិតក្នុងពេលនេះ ។ ប៉ុន្តែដោយសារសេចក្តី ស្រឡាញ់របស់ព្រះអង្គចំពោះរាជបុត្រ ទ្រង់ក៏យល់ព្រមអនុញ្ញាតឱ្យព្រះរាជបុត្រតាមព្រះរាជបំណង ។

The King was in no mood to permit the Prince to travel outside the Palace. The King suspected that the Prince will see not the courtiers and the elite but the ordinary folk who sweated the whole day. The King was perturbed whether what the old recluse had forecast would actually come to pass. But, because of His love and affection for his Son, he consented to grant Him His wish.



Prince Siddhartha tours the City in disguise.
រាជកុមារសិទ្ធត្ថបន្លំចេញទៅទស្សនាទីក្រុង

ម្តងនេះព្រះរាជកុមារសិទ្ធត្ថ ទ្រង់យាងដោយព្រះបាទ ។ ព្រះអង្គទ្រង់ក្លែងខ្លួនធ្វើជាកូនរបស់គ្រួសារវរជនម្នាក់ ។ ឆន្នអាមាត្យដែលដើរតាមក្រោយព្រះអង្គក៏ក្លែងខ្លួនមិនឱ្យគេស្គាល់ដែរ ។ ដោយវិធីនេះ រាជកុមារបានទតជាលើកទីមួយហើយនូវអ្វីដែលកើតមាននៅក្នុងព្រះរាជាណាចក្រព្រះអង្គ ។ មនុស្សជាច្រើនប្រកបរបរតាមវិជ្ជាជីវៈ ។ ជាងដែកធ្វើនង្គ័ល និងកាំបិត ។ ពួកគេប្រើញញួរដំដុំដែកឱ្យមានរាងដើម្បីធ្វើកង់រទេះ ។

This time Prince Siddhartha walked on foot. He disguised Himself like the son of an elitist family. Channa who walked behind Him was also unrecognizably disguised. This way the Prince saw for the first time what was taking place in His Kingdom. Many were engaged in various vocations. Blacksmiths made ploughs and knives. They hammered bits of iron into shape to make cart wheels.

Prince Siddhartha observes the street scene.
រាជកុមារសិទ្ធត្ថពិនិត្យមើលជីវិតនៅតាមដងផ្លូវក្នុងទីក្រុង

នៅសងខាងផ្លូវមានសុទ្ធតែហាងទំនិញរបស់ឈ្មួញធំៗ ។ ក្រុមជាងទង កំពុងធ្វើគ្រឿងអលង្ការសម្រាប់នារី ។ នៅកន្លែងជ្រលក់សំពត់អាវ គេឃើញមានសំពត់អាវគ្រប់ពណ៌ ។ អ្នកដុតនំកំពុងលក់បង្អែមផ្សេងៗឱ្យប្រជាជន ។ រាជកុមារសប្បាយព្រះទ័យណាស់ដោយបានទតឃើញលក្ខណៈជីវភាពរបស់កម្មករ ដែលខំប្រឹងប្រែងធ្វើការ ។

On either side of the road were the shops of rich merchants. Jewellers were making various ornaments for women. Places where clothes were dyed were full of colourful clothes. Bakers sold varieties of sweetmeat to people. The Prince was happy observing the condition of the workers who laboured hard.

Prince Siddhartha sees an afflicted person trembling and wailing in pain.
ព្រះរាជកុមារទតឃើញមនុស្សមានព្យាធិម្នាក់ កំពុងបំរះនឿល និងស្រែកថ្ងូរដោយសេចក្ដីឈឺចាប់

ប៉ុន្តែ រំពេចនោះស្រាប់តែមានរឿងមិនសប្បាយមួយបានកើតឡើង ។ នៅពេលព្រះរាជកុមារកំពុងយាងលំហែតាមផ្លូវ ស្រាប់តែព្រះអង្គឮសម្លេងថ្ងូរហាក់ដូចមាននរណាម្នាក់ស្រែកឱ្យជួយ ។ រាជកុមារសង្កេតឃើញមានមនុស្សម្នាក់ដេកផ្ទាល់នៅលើដី ។ ខ្លួនប្រាណរបស់គាត់រមួលដោយការឈឺចាប់ ។ រាងកាយ និងមុខមាត់គាត់ស្លេកស្លាំងខុសគេ ។ ភ្នែកគាត់បើកធំៗ ។ ពេលគាត់ខំត្រដររក្រោក គាត់តែងតែដួលទៅវិញរាល់ដង ។

But, suddenly something unpleasant began to happen. When the Prince was walking along leisurely, He suddenly heard a groan as if someone were crying for help. The Prince observed that there was a person lying on the ground. His body was twisted with pain. His body and face were disgustingly pale. Eyes were wide open. Each time he tried to get up he fell back.

Prince Siddhartha enquires Channa about that man's identity.

ព្រះរាជកុមារសួរឆន្នអាមាត្យអំពីអត្តសញ្ញាណរបស់មនុស្សនោះ

ដោយសាររាជកុមារមានព្រះទ័យសប្បុរសអាណិតអាសូរចំពោះអ្នកដទៃ ព្រះអង្គទ្រង់យាងទៅជិត ហើយលើកជននោះឡើង ។ ទ្រង់លើកក្បាលជននោះដាក់លើជង្គង់របស់ព្រះអង្គ ។ ទ្រង់សួរជននោះអំពីមូលហេតុនៃជម្ងឺរបស់គាត់ ហើយហេតុអ្វីបានជាគាត់ក្រោកឈរមិនរួច ។ តែទោះបីខំប្រឹងយ៉ាងណា ក៏ជននោះពុំអាចនិយាយរួចឡើយ ។ ឆន្នអាមាត្យ រត់យ៉ាងលឿនទៅជិតព្រះរាជកុមារ ។ រាជកុមារសួរគាត់ថា «ម្នាលឆន្នអាមាត្យ ហេតុអ្វីក៏មនុស្សនេះមានការឈឺចាប់យ៉ាងនេះ? សូមអ្នកនិយាយប្រាប់យើងមើល ។ អ្នកឃើញរបៀបគាត់ដកដង្ហើមទេ? ហេតុអ្វីទៅបានជាគាត់មិនឆ្លើយនឹងយើង?» ។

As he was very kind hearted the Prince got near him and raised him. He kept His head on his knees. He asked him what the cause of his pain was and why he could not get up on his feet. Though he tried the man could not speak. Channa rushed to the Prince: the Prince asked him: "Channa why is this man in this sore state? Please tell me. See how he breathes. Why does he not answer me?"



Channa explains that he is an afflicted person and warns the Prince against touching him.

ឆន្នអាមាត្យពន្យល់ថា គាត់ជាមនុស្សមានព្យាធិ រួចហាមកុំឱ្យព្រះរាជកុមារប៉ះពាល់ជននោះ

ឆន្នអាមាត្យស្រែកដោយភ្ញាក់ផ្អើលថា «ក្រាបទូលព្រះអង្គម្ចាស់ សូមកុំប៉ះជននោះ ។ គាត់កំពុងមានជម្ងឺ ។ ជាតិពុលកំពុងរត់ក្នុងសរសៃឈាមរបស់គាត់ ធ្វើឱ្យគាត់ក្តៅក្រហល់ក្រហាយក្នុងខ្លួន ។ នៅទីបំផុតគាត់នឹងផុតដង្ហើម» ។ ព្រះរាជកុមារសួរថា «តើរឿងបែបនេះ កើតមានចំពោះមនុស្សដទៃឯទៀតឬទេ? តើចំពោះយើងក៏មានរឿងបែបនេះដែរឬ?» ។ ឆន្នអាមាត្យឆ្លើយថា «ក្រាបទូលប្រសិនបើនរណាប៉ះពាល់ជិតស្និទ្ធជាមួយគាត់ ជននោះនឹងទទួលការឈឺចាប់ដូចគ្នា ។ សូមព្រះអង្គទុកឱ្យគាត់ដេកទៅវិញទៅ ។ សូមព្រះអង្គកុំប៉ះពាល់គាត់ ពីព្រោះជាតិពុលដែលនៅក្នុងខ្លួនគាត់អាចឆ្លងមកព្រះអង្គដែរ ។ សូមព្រះអង្គកុំពាល់គាត់ បើព្រះអង្គពាល់គាត់ព្រះអង្គនឹងទទួលការឈឺចាប់ដូចគាត់ដែរ» ។

Channa shouted in alarm. "O Lord please do not touch this man. He is sick. Poison travels through his veins, burning him inside. At the end he will cease breathing." "Does this happen to others as well? Will this happen to me too" the Prince enquired.

Channa replied thus: "If anyone has close contact with him, he too is likely to suffer this way. Please let him lie down. Please do not touch him because his poison might contaminate you too. Please do not touch him. If you touched him you will get affected like him."



The Prince enquires from Channa, why people fall sick.
ព្រះរាជកុមារសួរឆន្នអាមាត្យ អំពីហេតុដែលនាំឱ្យមនុស្សមានព្យាធិ

«ម្នាលឆន្ន តើនៅមានជម្ងឺធ្ងន់ៗ ក្រៅពីនេះទៀតទេ?» «ក្រាបទូល មានជម្ងឺផ្សេងៗទៀតច្រើនណាស់ ។ ជម្ងឺទាំងនោះក៏នាំឱ្យឈឺចាប់ដូចគ្នាដែរ» ។«តើមាននរណាម្នាក់ អាចជួយជនទាំងនោះបានទេ? ហេតុអ្វីក៏មនុស្សមិនអាចដណ្តើមជ័យជំនះលើជម្ងឺបាន កាលណាគេមានព្យាធិ?» ។ «ជម្ងឺទាំងនោះ វាកើតជាធម្មតាសម្រាប់យើងទាំងអស់គ្នា ។ ជនណាក៏អាចធ្លាក់ខ្លួនឈឺបាននៅគ្រប់ពេល និងគ្រប់ទីកន្លែង ។ គ្មាននរណាអាចដឹងបានថា គេនឹងធ្លាក់ខ្លួនឈឺនៅពេលណាទេ» ។«ឆន្នអាមាត្យ តើនេះជាការពិតមែនទេ? តើយើងក្តី ក្សត្រាជទៃងទៀតក្តីនិងមនុស្សទាំងអស់សុទ្ធតែធ្លាក់ខ្លួនឈឺមែនទេ?» ។«ក្រាបទូល ពិតមែនហើយទាំងទូលបង្គំក៏អាចធ្លាក់ខ្លួនឈឺដែរ» ។

"Channa are there other dire diseases beside this?" "Yes there are many other diseases. They too are equally painful". "Is there no one who could help these people? Why cannot people conquer disease when afflicted?" "These diseases are common to all. One can fall ill anytime, anywhere. No one knows when one is likely to fall ill." "Channa, is that true? Do I, other royals and all people fall ill?" "Yes, O Lord I too may get afflicted."

Channa explains that all beings get afflicted by sickness.
ឆន្នអាមាត្យពន្យល់ថា មនុស្សលោកទាំងអស់សុទ្ធតែមានព្យាធិ ដោយរោគា

«ប្រសិនបើនេះជារឿងដែលមនុស្សកើតមក ហើយត្រូវទទួលគ្រប់គ្នា នោះវាជារឿងគួរឱ្យភ័យរន្ធត់ណាស់ ពីព្រោះមនុស្សម្នាក់ដែលចូលទៅដេកនៅពេលយប់មិនអាចដឹងបានថា ខ្លួនជាអ្នកមានជម្ងឺនៅព្រឹកស្អែកនោះទេ មិនមែនដូច្នោះទេឬ ឆន្ន?» ។

«ក្រាបទូល វាពិតជាដូច្នោះមែនហើយ ។ គ្មាននរណាម្នាក់នៅលើផែនដីយើងនេះ អាចដឹងច្បាស់ថាកាលណាទៅខ្លួនមានរោគាព្យាធិ និងកាលណាទៅដែលខ្លួនមានការឈឺចាប់ និងកាលណាទៅដែលមរណភាពនឹងចូលមកដល់រូបគេទេ» ។

«មរណភាព? តើវាជាអ្វីទៅឆន្ន? ពាក្យនេះខ្ញុំមិនដែលយល់សោះ ។ តើមរណភាពជាអ្វីទៅ?» ។ «ក្រាបទូល សូមព្រះអង្គទតតាមទិសនោះទៅ» ។

"If this is how things are in human existence, it is truly frightening, because a person going to bed in the night would not know if he would be a sick person next morning. Isn't that so, Channa?"

"Yes, that is so my Lord. No one on Earth can be sure when he will be afflicted with disease and when suffering and death will come to him."

"Death?, what's that Channa? This baffles me. What is Death?" "My Lord, please look in that direction."

The Prince sees a dead body being carried in a bier.
ព្រះរាជកុមារទតឃើញមនុស្សស្លាប់ ដែលគេកំពុងសែងនឹងទ្រៀស

រាជកុមារទ្រង់សម្លឹងទៅរកទិស ដែលឆន្នអាមាត្យចង្អុលបង្ហាញ ។ ទ្រង់ទតឃើញមនុស្សមួយក្រុមកំពុងធ្វើដំណើរដោយស្រែកទ្រហ៊ូយំ ។ ព្រះអង្គទតឃើញមនុស្សបួននាក់សែងរាងកាយសាកសពដែលដាក់លើទ្រៀស ។ រាងកាយនោះគួរឱ្យខ្ពើមណាស់ ។ មាត់គាត់ចំហ ថ្ពាល់គាត់ខួង ហើយរាងកាយនោះស្លាប់ទៅហើយ ។ ពួកភ្នាក់សែងទ្រៀសនោះទីងណាត់ទីងណែងគ្មានខ្វល់អ្វីទាំងអស់ ។ មនុស្សដែលដេកលើទ្រៀស គ្មាននិយាយអ្វីមួយម៉ាត់ ។ ព្រះរាជកុមារទតឃើញហ្វូងមនុស្សដើរពីក្រោយទ្រៀស ។ រាជកុមារឆ្ងល់ណាស់ថា ហេតុអ្វីក៏មនុស្សដែលដើរជាមួយដោយទ្រហ៊ូផងយំផង ម្តេចមិនប្រាប់អ្នកសែងទ្រៀសឱ្យយកចិត្តទុកដាក់សែងឱ្យបានល្អផង ។

The Prince looked in the direction pointed out by Channa. The Prince saw a group of people walking along, lamenting and weeping. He saw four people carrying a body placed in a bier. The body was unpleasant. His mouth was agape, cheeks were hollow and the body was lifeless. Those who carried the bier took it along with harsh unconcern. The man lying on the bier did not speak one word. The Prince saw the crowds that followed the bier. The Prince was surprised that those who walked along weeping and lamenting did not instruct those who carried the bier to be more careful with it.

Prince Siddhartha sees how a dead body is cremated.
រាជកុមារទតឃើញគេបូជាមនុស្សស្លាប់

គេយកសាកសពទៅដាក់លើគំនរឧស្សរួចដុតភ្លើង ។ ព្រះរាជកុមារទ្រង់រន្ធត់យ៉ាងខ្លាំង រហូតដល់ព្រឺរោមក្រញាង ។ អណ្ដាតភ្លើងគ្របដណ្ដប់តាំងពីសក់ដល់ចុងជើង ប៉ុន្តែសាកសពនោះនៅតែដេកតទៅទៀតយ៉ាងស្ងៀមស្ងាត់ ។ រាជកុមារសួរដោយសម្លេងញ័រថា «ហេតុអ្វី ក៏ជនកំពុងដេកនោះបណ្ដោយឱ្យគេដុតគាត់ដូច្នេះ?» ។

«ក្រាបទូល មនុស្សនោះស្លាប់ហើយ ។ គាត់មិនអាចដើរបានទេ ទោះបីគាត់មានជើងក៏ដោយ ។ គាត់គ្មានវិញ្ញាណទេ ។ គាត់មិនអាចដឹងថាក្ដៅឬត្រជាក់ទេ ។ គាត់ស្លាប់បាត់ទៅហើយ» ។

They took the body along, put it on a heap of fire-wood and burnt it. The Prince was startled. Hair on the Prince's body stood erect. The fire enveloped the man's hair and his feet but he continued his silent sleep. With trembling voice the Prince asked: "Why does that sleeping man allow himself to be burnt thus?"

"O Lord, that man is dead. He cannot walk, though he has feet. He does not feel anything. He can feel neither cold nor snow. He is now dead."

Prince Siddhartha enquires, Channa about death.
រាជកុមារសិទ្ធត្ថ សួរឆន្នអាមាត្យអំពីសេចក្ដីស្លាប់

«ស្លាប់? ម្នាលឆន្ន នេះឬសេចក្ដីស្លាប់? តើយើងជាបុត្ររបស់ព្រះមហាក្សត្រ នឹងស្លាប់ដូចមនុស្សនោះដែរឬ? តើព្រះបិតា ព្រះនាងយសោធរា និងមនុស្សដទៃដែលយើងស្គាល់ ត្រូវគេយកទៅដុតដូចមនុស្សនោះដែរឬ?» ។

«ក្រាបទូល សត្វមានជីវិតទាំងអស់ សុទ្ធតែស្លាប់នៅថ្ងៃណាមួយមិនខាន គ្មានផ្លូវណាអាចចៀសផុតបានទេ ។ គ្មាននរណាអាចរស់រហូតមិនចេះស្លាប់ទេ ។ មនុស្សលោកមិនអាចគេចផុតពីសេចក្ដីស្លាប់ទេ» ។

ព្រះរាជកុមារទ្រង់នៅស្ងៀម ។ ព្រះអង្គពុំមានបន្ទូលមួយម៉ាត់សោះ ។ ព្រះអង្គទ្រង់ជ្រាបច្បាស់ថា សេចក្ដីស្លាប់គួរឱ្យភ័យរន្ធត់ណាស់ សេចក្ដីស្លាប់មិនអាចចៀសផុតបានទេ សត្វមានជីវិតទាំងអស់សុទ្ធតែត្រូវធ្លាក់ទៅក្នុងអន្ទាក់នៃសេចក្ដីស្លាប់ ។

"Dead? Channa so this is death? Will I, the son of the King, die like this man? Will my father, Yasodhara and all the people I know, be placed on a heap of firewood like that man?"

"All living beings will die one day. In no way can it be avoided. No one can live for ever. Human beings cannot avoid Death".

The Prince was silent. He did not utter one word. He realized how frightening was this Death, that can never be avoided and that will ensnare all beings.



Returning to the Palace, the Prince contemplates in silence.
ត្រឡប់មកដល់ព្រះរាជវាំងវិញ ព្រះរាជកុមារទ្រង់ពិចារណាយ៉ាងស្ងៀមស្ងាត់

រាជកុមារទ្រង់យាងត្រឡប់មកព្រះរាជវាំងវិញយ៉ាងស្ងៀមស្ងាត់ ។ ព្រះអង្គគង់ក្នុងបន្ទប់តែមួយអង្គឯង ហើយពិចារណាយ៉ាងជ្រាលជ្រៅអំពីរឿងអ្វីដែលព្រះអង្គបានទតឃើញ ។ នៅទីបំផុត ព្រះអង្គមានបន្ទូលទៅរកព្រះអង្គឯងថា «តើគួរឱ្យភ័យរន្ធត់ទេ ដែលមនុស្សទាំងអស់ត្រូវតែស្លាប់នៅថ្ងៃណាមួយនោះ ។ វាគួរឱ្យភ័យរន្ធត់ដូចគ្នា ដែលយើងមិនអាចចៀសផុតពីសេចក្ដីស្លាប់បាននោះ ។ វាត្រូវតែមានវិធីដើម្បីចៀសឱ្យផុតពីសេចក្ដីស្លាប់ ។ អាត្មាអញនឹងធ្វើនូវអ្វីដែលអាចធ្វើបាន ដើម្បីរកឱ្យឃើញនូវផ្លូវមួយដែលអាចជួយស្រោចស្រង់ព្រះបិតា ព្រះនាងយសោធរា អាត្មាអញផ្ទាល់ និងអ្នកដទៃឯទៀត ឱ្យផុតពីជរាភាព និងសេចក្ដីស្លាប់ ។ អាត្មាអញនឹងខំប្រឹងឱ្យខ្លាំង និងរកឱ្យឃើញនូវវិធីមួយឱ្យខាងតែបាន» ។

He returned to the Palace in silence. He sat in His chamber all alone and contemplated deeply upon what He witnessed. At the end He said to Himself: "It is frightening that all human beings should die one day. It is equally frightening that Death cannot be avoided. There should be some way of avoiding this. I will do whatever I can to discover a way by which I can save my Father, Yasodhara, Myself and all others from old age and from Death. I will strive hard and discover a way".



Prince Siddhartha sees an Ascetic.
ព្រះរាជកុមារសិទ្ធត្ថទតឃើញបព្វជិត

ចំណេរកាលតពីនោះមក នៅពេលដែលព្រះអង្គគង់លើខ្នងសេះដើម្បីក្រសាលឧទ្យាន ព្រះអង្គទតឃើញបព្វជិតមួយអង្គដណ្តប់រាងកាយដោយសំពត់ពណ៌លឿង ។ ពេលបានទតឃើញបព្វជិតនោះ ព្រះអង្គមានព្រះទ័យស្ងប់និងពោរពេញទៅដោយសេចក្តីសុខក្រៃលែង ។ ព្រះរាជកុមារទ្រង់សម្លឹងទៅបព្វជិតនោះដោយយកព្រះទ័យទុកដាក់ ។ បន្ទាប់មក ព្រះអង្គសួរទៅឆន្នអាមាត្យថា «តើជីវភាពរស់នៅរបស់បព្វជិតនេះយ៉ាងដូចម្តេចទៅ?» ឆន្នអាមាត្យឆ្លើយថា «ក្រាបទូល បព្វជិតនេះបានលះបង់ជីវិតជាគ្រហស្ថហើយ និងកំពុងចំរើនគុណធម៌ ។ បព្វជិតនេះកំពុងស្វែងរកវិធីរំលត់ទុក្ខ ដែលកំពុងរំខានពិភពលោក» ។ ពាក្យបព្វជិតបានធ្វើឱ្យព្រះរាជកុមាររីករាយក្នុងព្រះហឫទ័យ ។

On another occasion when the Prince was riding horse-back in the Pleasure Park He observed an ascetic in yellow robes. Seeing that he was tranquil and was filled with bliss, the Prince looked at Him attentively. Then He questioned Channa: "What is the life-style of such an ascetic?" Channa replied: "This ascetic has given up lay life and practising virtue, is on a quest to overcome the suffering, that troubles the world". The word ascetic made the Prince happy.

Prince Siddhartha thinks about the Ascetic all day long.
ព្រះរាជកុមារសិទ្ធត្ថ ទ្រង់គិតទៅដល់ភេទជាបព្វជិតពេញមួយថ្ងៃ

ព្រះរាជកុមារទ្រង់ក្រសាលសប្បាយក្នុងឧទ្យានពេញមួយថ្ងៃ ។ គំនិតចង់ក្លាយជាបព្វជិត បានដណ្តើមជ័យជំនះលើព្រះទ័យរបស់ព្រះរាជកុមារ ។ នៅវេលានោះ មានគេនាំដំណឹងមកថា ព្រះនាងពិម្ពាយសោធរាទ្រង់ប្រសូត្រព្រះរាជបុត្រមួយព្រះអង្គយ៉ាងស្រស់ស្អាត ។ កំពុងស្ពុងគំនិត ព្រះរាជកុមារពុំបានសម្តែងនូវសេចក្តីរីករាយនឹងដំណឹងនោះទេ បែរជាមានបន្ទូលថា «រាហូចាប់ហើយតើ ចំណងកើតហើយតើ» ។ ដោយហេតុដែលព្រះរាជកុមារលាន់ព្រះឱស្ឋថា «រាហូចាប់ហើយតើ» ដូច្នេះ ទើបព្រះរាជបុត្ររបស់ព្រះអង្គត្រូវបានប្រទាននាមថា «រាហុល» ។

The Prince spent the whole day in the Pleasure Park filled with joy. He was overwhelmed by the idea of being an ascetic. At this moment someone brought the news that Princess Yasodhara had given birth to a comely little Prince. Immersed in thought, the Prince instead of expressing His joy at the news said: "I am caught up in a bondage". Because of this the infant Prince was named 'Rahula'".

A bevy of dancing girls is displayed to distract the Prince's mind.
ស្ត្រីរបាំមួយក្រុម សម្តែងរបាំថ្វាយព្រះរាជកុមារ

នៅក្នុងព្រះរាជវាំងនរណាក៏ដឹងច្បាស់ដែរថា ព្រះរាជកុមារសិទ្ធត្ថមានការប្រែប្រួលយ៉ាងខ្លាំង ចាប់តាំងពីថ្ងៃដែលព្រះរាជបុត្រ រាហុលទ្រង់ប្រសូត្រមក ។ ព្រះអង្គកាន់តែស្ងប់ស្ងៀមឡើងនិងកាន់តែសញ្ជឹងគិតច្រើនជាងពីពេលមុន ។ ព្រះបាទសិរីសុទ្ធោទនៈមាន ព្រះទ័យខ្វល់ខ្វាយខ្លាំងណាស់ចំពោះអាកប្បកិរិយារបស់រាជកុមារ ។ ក្នុងគោលបំណងអូសទាញព្រះរាជបុត្រឱ្យត្រឡប់ទៅរកជីវិតនៃ សេចក្តីសប្បាយរីករាយវិញ ព្រះបាទសិរីសុទ្ធោទនៈទ្រង់ប្រឹងប្រែងជ្រើសរើសពួកស្រីរបាំដែលមានរូបឆោមលោមពណ៌ដ៏ល្អស្រស់ឆើត ឆាយពីគ្រប់ទិសទីនៃព្រះនគរ ។ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឱ្យស្រីរបាំទាំងនោះនៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជវាំងរបស់ព្រះរាជកុមារ ។ អ្នក សម្តែងសិល្បៈទាំងនោះត្រូវបានគេបង្គាប់ឱ្យច្រៀងរាំយ៉ាងណា ដែលអាចទាក់ទាញអារម្មណ៍ព្រះរាជកុមារបាន ។ ដោយបានរៀបចំយ៉ាង នេះព្រះរាជាទ្រង់មានសេចក្តីសង្ឃឹមថានឹងបានឃើញព្រះរាជកុមារយកព្រះទ័យទុកដាក់ជាថ្មីចំពោះជីវិតលោកិយ ។

It was clear to all in the Palace, that Prince Siddhartha underwent a change from the day the little Prince Rahula was born. He was more tranquil and more contemplative than before. King Suddhodana was greatly troubled by the Prince's behaviour. In order to bring the Prince back to the life of pleasure and gaiety. King Suddhodana made an effort to recruit wise and beautiful Dancing women from all over the country. He made the Dancing women live permanently in the Prince's Palace. These performers were instructed to sing and dance in a manner that would win the Prince's mind. The King expected by this arrangement to see that the Princu took a keen and renewed interest in worldly matters.



Prince Siddhartha falls asleep unimpressed by the performance of dancing girls.
ព្រះរាជកុមារសិទ្ធត្ថ ទ្រង់ផ្ទុំដោយពុំបានចាប់អារម្មណ៍ចំពោះការសម្ដែងរបស់ស្រីរបាំទេ

ជាដំបូង ព្រះរាជកុមារទ្រង់យកព្រះទ័យទុកដាក់ចំពោះការសម្ដែងរបស់ពួកស្រីរបាំទាំងនោះដែរ ដើម្បីធ្វើឱ្យព្រះបិតាព្រះអង្គសប្បាយព្រះទ័យ ។ ប៉ុន្តែ ព្រះអង្គយកចិត្តទុកដាក់យ៉ាងតិចតួចបំផុត ព្រោះព្រះអង្គរវល់ក្នុងការត្រិះរិះបញ្ហាផ្សេងៗ ។ ព្រះអង្គទ្រង់ប្រមូលផ្ដុំអារម្មណ៍ទៅលើបញ្ហាតែមួយគត់ «តើធ្វើយ៉ាងណា ដើម្បីឱ្យខ្លួនព្រះអង្គនិងមនុស្សដទៃឯទៀត អាចរំដោះទាំងស្រុងឱ្យរួចផុតពីជរាព្យាធិ និងមរណៈ?» ។ នៅទីបំផុត ដោយអស់ព្រះកាយពលព្រះអង្គក៏ផ្ទុំលក់ទៅ ។ ស្រីរបាំទាំងនោះ លុះដឹងថាព្រះរាជកុមារផ្ទុំលក់ស៊ប់ហើយក៏នាំគ្នាបោះបង់គ្រឿងល្បែងហើយដេកលក់ទៅដែរ ។

At first the Prince paid heed to the performances of the dancing women, to make His father happy. But, the Prince paid only scant attention to these because He was pre-occupied with other thoughts. He concentrated on only one question. "How can Himself and all other beings be totally saved from old age and Death?" At last, exhausted He fell asleep. This gave a respite to the Dancing women.



The Prince is depressed seeing the ungainly attitudes of the sleeping dancing girls.
ព្រះរាជកុមារទ្រង់មានព្រះហឫទ័យសង្វេគ នឿយណាយយ៉ាងខ្លាំងដោយបានទតឃើញវិប្បការៈនៃស្រីរបាំកំពុងដេកលក់

មួយសន្ទុះក្រោយមក ព្រះរាជកុមារទ្រង់តើនឡើង ។ ទ្រង់ទតឃើញស្រីរបាំទាំងនោះកំពុងដេកលក់ដោយអស់កម្លាំង ។ ពួកស្រីរបាំទាំងនោះ ដេកដោយគ្មានយកចិត្តទុកដាក់ដល់អារម្មណ៍ផ្សេងៗ ដែលអាចកើតមានឡើងចំពោះអ្នកដែលបានឃើញនាងសោះ ។ ដំណេករបស់ពួកគេមើលទៅគួរឱ្យខ្ពើម ។ ខ្លះដេកហាមាត់ ខ្លះដេកហៀរទឹកមាត់ ធ្វើឱ្យរលាយម្សៅនៅលើមុខ ។ ខ្លះដេកសង្កៀតធ្មេញដូចយក្សកំណាច ។ ពួកនាងទាំងអស់នោះ គួរឱ្យខ្ពើមរអើមជាទីបំផុត ។ ព្រះរាជកុមារទ្រង់សង្វេគយ៉ាងខ្លាំងដោយឃើញថា ស្រីដែលព្រះអង្គ សព្វព្រះរាជហឫទ័យយ៉ាងខ្លាំង ប្រែក្លាយទៅជាដូច្នេះ ។

In a short while the Prince awoke. He saw that the dancing women were asleep, exhausted. They slept with no regard whatsoever for the feelings that would be evoked in those who saw them. They looked unpleasant in their sleep. From the open mouth of some, saliva issued, discolouring their make-up. Some ground their teeth like enraged demons. All of them seemed disgusting. The Prince was surprised that the women He liked so much were transformed this way.



Deciding to renounce the lay life, the Prince leaves the bed chamber.
ដោយប្ដេជ្ញាក្នុងព្រះទ័យថា នឹងបោះបង់ចោលជីវិតជាគ្រហស្ថ ព្រះរាជកុមារទ្រង់យាងចេញពីក្រឡាបន្ទំ

ការទតឃើញដំណេករបស់ស្រីរបាំ ដែលមុននេះជាប្រភពនៃសេចក្ដីសប្បាយរីករាយរបស់ព្រះរាជកុមារ ប៉ុន្តែពេលនេះគួរឱ្យខ្ពើមរអើមក្រៃលែង ។ នោះគឺជាទស្សនីយភាពគួរស្អប់ខ្ពើមជាទីបំផុត ដែលព្រះអង្គបានទតឃើញ ។ ព្រះអង្គសម្រេចព្រះទ័យថា នឹងបោះបង់ចោលនូវអ្វីៗទាំងអស់ ដែលធ្វើឱ្យព្រះអង្គមានកង្វល់ និងចេញទៅស្វែងរកសច្ចៈ ។ ព្រះអង្គទ្រង់ប្ដេជ្ញាថា នឹងបញ្ចប់សេចក្ដីទុក្ខទាំងអស់ ។ ព្រះរាជកុមារសិទ្ធត្ថ បានយាងចេញចាកទីសយនាដោយមិនធ្វើឱ្យរំខានដល់ពួកស្រីរបាំ ដែលកំពុងលង់លក់ក្នុងដំណេកឡើយ ។ ស្ដេចយាងទៅដាស់ឆន្នអាមាត្យ ឱ្យទៅយកសេះកណ្ឋកៈមករៀបចំគ្រឿងប្រដាប់ឱ្យហើយស្រេច ។

The sight of sleeping dancing women, was once a source of pleasure for the Prince. But, now it was exceedingly disgusting. It was one of the most loathesome sights that the Prince had witnessed. He decided to be rid of everything that troubled His mind and to embark upon a quest for truth. He was determined to end all suffering. Prince Siddhartha got up without disturbing the sleeping women and left the bed-chamber. He summoned Channa and ordered him to get horse Kanthaka ready.



He looks at His new-born Son before leaving the Palace to become an Ascetic.
ព្រះអង្គទ្រង់ទតព្រះរាជឱរសដែលទើបនឹងប្រសូត្រ មុននឹងយាងចេញពីព្រះរាជវាំង ដើម្បីទៅបួសជាបព្វជិត

នៅពេលឆន្នអាមាត្យទៅយកសេះ ព្រះរាជកុមារគិតថានឹងយាងទៅលើកបីព្រះរាជឱរស ដែលទើបតែប្រសូត្ររបស់ព្រះអង្គ ។ ព្រះអង្គស្តេចយាងចូលទៅក្នុងបន្ទប់ជាទីបន្ទំនៃព្រះមហេសី ។ ព្រះនាងទ្រង់ផ្ទុំដាក់ព្រះហស្តគងលើព្រះរាជឱរស ។ ព្រះអង្គទ្រង់ព្រះចិន្តាថា «បើអាត្មាអញនឹងលើកដៃព្រះនាងទេវីចេញ ព្រះនាងទេវីមុខជានឹងភ្ញាក់ដឹងខ្លួន ។ បើព្រះនាងទេវីភ្ញាក់នោះ ព្រះនាងទេវីនឹងឃាត់មិនឱ្យអញចេញទៅបួសបានឡើយ ។ ប៉ុន្តែ អាត្មាអញត្រូវចេញទៅក្នុងពេលនេះ ។ ណ្ហើយចុះ ចាំអាត្មាអញរកឃើញសច្ចធម៌ហើយ សឹមត្រឡប់មកជួបព្រះនាងនិងបុត្រនេះវិញ » ។

While Channa was getting the horse the Prince thought that He will take a look at His new-born son. He stepped into the Princess' bed-chamber. The Princess was sleeping with her hand on the infant Prince. Prince Siddhartha thought thus: "If I took her hand away, she will wake up. If she awoke she will prevent my renunciation. But I must leave soon. Once I have realized the absolute Truth I will come back to see the Princess and my son."

Prince Siddhartha leaves the Palace accompanied by the horse Kanthaka and Charioteer Channa.
ព្រះរាជកុមារសិទ្ធត្ថ យាងចេញពីព្រះរាជវាំងដោយមានសេះកណ្ឋកៈ និងនាយសារថីឆន្នអាមាត្យជូនដំណើរ

នៅក្នុងយប់ដ៏ស្ងាត់នោះ ព្រះរាជកុមារសិទ្ធត្ថបានយាងចេញពីព្រះរាជវាំងដោយពុំបានធ្វើឱ្យនរណាម្នាក់ភ្ញាក់ពីដំណេកឡើយ ។ ព្រះអង្គទ្រង់យាងចេញពីទីក្រុង ដោយគង់លើខ្នងសេះកណ្ឋកៈ ។ មានតែឆន្នអាមាត្យម្នាក់គត់ដែលធ្វើដំណើរទៅជាមួយព្រះអង្គ ។ គ្មាននរណាម្នាក់មករារាំងដំណើរព្រះអង្គឡើយ ។ លុះស្ដេចយាងចេញឃ្លាតផុតពីព្រះនគរបន្តិចទៅ ព្រះរាជកុមារសិទ្ធត្ថទ្រង់បញ្ឈប់សេះ ហើយបែរព្រះភ័ក្ត្រជាចុងក្រោយ ទតឆ្ពោះមកនគរកបិលពស្ដុ ដែលកំពុងនិទ្រាលង់លក់ក្រោមពន្លឺព្រះចន្ទ ។ ប៉ុន្តែព្រះអង្គទ្រង់ពុំបោះបង់សេចក្ដីសម្រេចព្រះទ័យ ដើម្បីបួសជាបព្វជិតឡើយ ។

In that still night Prince Siddhartha left the Palace without awakening anyone. The Prince left the City on the wise horse Kanthaka. Only Channa accompanied them. No one obstructed them. After riding for a while Prince Siddhartha stopped and turned around for a last look at the city of Kapilavastu, bathed in moonlight. But He never wavered in His decision to renounce the worldly life.

Crossing River Anoma, He shaves His head, deciding to become an Ascetic.
ឆ្លងផុតស្ទឹងអនោមា ព្រះអង្គទ្រង់កោរព្រះកេសបួសជាបព្វជិត

នៅពេលទៀបភ្លឺ ព្រះរាជកុមារសិទ្ធត្ថ បានយាងលើខ្នងសេះទៅដល់ឆ្នេរស្ទឹងអនោមា ។ ព្រះអង្គទ្រង់យាងចុះពីលើខ្នងសេះ និង ដោះគ្រឿងសម្លៀកបំពាក់ពីព្រះកាយ ហុចទៅឱ្យឆន្នអាមាត្យ ។ ព្រះអង្គទ្រង់ត្រាស់ឱ្យឆន្នអាមាត្យយកវត្ថុទាំងនោះ ព្រមទាំងសេះកណ្ឋកៈ ត្រឡប់ទៅព្រះនគរវិញ ហើយថ្វាយវត្ថុទាំងនោះទៅព្រះរាជា ដោយទូលថ្វាយព្រះអង្គទ្រង់ជ្រាបអំពីរឿងរ៉ាវគ្រប់យ៉ាងផង ។ នៅក្នុងពេល នោះ ព្រះរាជកុមារសិទ្ធត្ថមានព្រះជន្មគម្រប់២៩វស្សា ។ ព្រះអង្គចាកចេញពីព្រះរាជត្រកូល និងព្រះរាជនគរ ដើម្បីទៅបួសតែមួយ ព្រះអង្គឯង ព្រោះព្រះអង្គបានសម្រេចព្រះទ័យថា នឹងដណ្តើមយកជ័យជំនះលើសេចក្តីទុក្ខទាំងអស់នៃមនុស្សជាតិឱ្យបាន ។

At dawn, Prince Siddhartha reached the bank of the River Anoma on horse-back. he got off the horse and took off the fine garments he wore. He gave them all to Channa. He asked Channa to take those and the horse Kanthaka back to the city and to hand them over to the King, explaining all that happened. Prince Siddhartha was twenty nine at that time. He left His Royal family and His Kingdom to become an ascetic solely because He was determined to overcome all the suffering of the whole of mankind.

Prince Siddhartha as an Ascetic, begs for Alms in the city of Rajagaha.
ព្រះរាជកុមារសិទ្ធត្ថជាបព្វជិតមួយអង្គ ទ្រង់យាងទៅបិណ្ឌបាតនៅក្នុងនគររាជគ្រឹះ

បន្ទាប់ពីឆន្នអាមាត្យនាំយកគ្រឿងសម្លៀកបំពាក់ និងសេះកណ្ឋកៈរបស់ព្រះអង្គវិលទៅនគរកបិលពស្ដុវិញ ព្រះរាជកុមារទ្រង់គង់នៅលើឆ្នេរស្ទឹងអនោមាក្នុងព្រៃស្វាយ ឈ្មោះអនុប្បិយ អស់៧ថ្ងៃ ។ ចាប់ពីទីនោះទៅ ព្រះអង្គទ្រង់យាងឆ្ពោះទៅទិសខាងត្បូង ហើយយាងចូលទៅក្នុងទីក្រុងរាជគ្រឹះ ជារាជធានីនៃនគរមគធៈ ដែលជាព្រះរាជាណាចក្ររបស់ព្រះបាទ ពិម្ពិសារ ។ លុះព្រឹកឡើង ព្រះអង្គទ្រង់ជម្រះកាយនៅក្នុងស្ទឹងដែលនៅជិតទីក្រុង ។ បន្ទាប់មក ព្រះអង្គទ្រង់យាងចូលទៅក្នុងទីក្រុង ដើម្បីបិណ្ឌបាតតាមទម្លាប់របស់អ្នកបួស ។ ដោយមានសេចក្ដីរំភើបចំពោះបុគ្គលិកលក្ខណៈរបស់ព្រះរាជកុមារសិទ្ធត្ថ មនុស្សម្នានៅក្នុងទីក្រុងនាំគ្នាសិរិតសំរាំងម្ហូបអាហារល្អៗទៅដាក់បាត្រព្រះអង្គ ។

After Channa went back to the City of Kapilavastu with the Prince's garments and His Horse Kanthaka, Prince Siddhartha dwelt upon the bank of Anoma in the mango-grove Anupiya for seven days. From there He travelled South and entered Rajagaha, the capital city of Magadha, the Kingdom of King Bimbisara. In the morning He bathed in the river in the vicinity of the city. He then entered the city to beg for alms as is the practice of other ascetics. Impressed by the personality of Prince Siddhartha, the people of the City offered Him the choicest of foods.

He walks towards Pandava mountain to partake of the meal.
ព្រះអង្គទ្រង់យាងទៅកាន់បណ្ឌវបពិត ដើម្បីឆាន់ចង្ហាន់

បន្ទាប់ពីដំណើរបិណ្ឌបាតបានល្មមមួយចំអែតហើយ ព្រះរាជកុមារសិទ្ធត្ថទ្រង់ស្ដេចយាងចេញពីនគររាជគ្រឹះសំដៅទៅភ្នំបណ្ឌវៈ ប្រារព្ធនឹងសោយនូវអាហារ ។ ពេលព្រះអង្គស្ដេចយាងបិណ្ឌបាតជាលើកទីមួយនៅក្នុងទីក្រុង ដំណឹងដែលថាមានបព្វជិតមួយអង្គប្រកបដោយរូបសម្បត្តិគួរឱ្យចាប់អារម្មណ៍ ថ្លៃថ្នូរ និងមានអាការខាងក្រៅបង្ហាញឱ្យឃើញនូវភាពជាអ្នកមានត្រកូលខ្ពង់ខ្ពស់ និមន្តចូលក្នុងទីក្រុងបានលេចឮខ្ចរខ្ចាយយ៉ាងឆាប់ទៅពាសពេញទីក្រុង ។ ព្រះបាទពិម្ពិសារ ក៏ទ្រង់ទទួលដំណឹងនេះដែរ ព្រះអង្គទ្រង់ត្រាស់បញ្ជូនព្រះរាជបុត្ររបស់ព្រះអង្គឱ្យយាងតាមឃ្លាំមើលដំណើររបស់ព្រះរាជកុមារសិទ្ធត្ថ ។ ព្រះបាទពិម្ពិសារ ទ្រង់ទទួលដំណឹងថា បព្វជិតនោះជារជ្ជទាយាទនៃនគរកបិលពស្ដុ ដែលបានលះបង់ចោលនូវរាជសម្បត្តិដ៏ប្រណីតគ្រប់យ៉ាង ដើម្បីស្វែងរកមាគ៌ាជួយស្រោចស្រង់មនុស្សជាតិឱ្យរួចរំដោះអំពីសេចក្ដីទុក្ខ ដែលកើតមកអំពីជរា ព្យាធិ និងមរណៈ ។

After the alms-round, Prince Siddhartha left the City of Rajagaha and went towards the Pandava mountains to take His meals. When the Prince went on His alms round for the first time in the City, the news that an ascetic of impressive personality, noble and elitist in appearance has come to the City, spread around fast. King Bimbisara too heard this and sent his son to enquire into this. He learnt that the ascetic was the Crown Prince of the Kingdom of Kapilavastu and that He has renounced all royal luxuries to embark upon a quest to find out a way of rescuing mankind from the suffering of old age, sickness and death.

The conversation with King Bimbisara, when Ascetic Siddhartha met him.

ការសន្ទនាជាមួយព្រះបាទពិម្ពិសារ នៅពេលដែលបព្វជិតសិទ្ធត្ថបានជួបព្រះអង្គ

ដោយបានទ្រង់ជ្រាបអំពីព័ត៌មាននេះ ព្រះបាទពិម្ពិសារទ្រង់ស្តេចយាងចេញទៅកាន់សំណាក់ព្រះសិទ្ធត្ថនៅជើងភ្នំបណ្ឌវៈ និងសុំយាងព្រះសិទ្ធត្ថទៅគង់នៅក្នុងនគររបស់ព្រះអង្គ ដោយសន្យាថានឹងថ្វាយចំពោះព្រះអង្គនូវអ្វីៗសព្វសារពើ ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ។ ព្រះរាជកុមារសិទ្ធត្ថ ទ្រង់បដិសេធដោយសេចក្តីគួរសម ចំពោះព្រះរាជបំណងរបស់ព្រះបាទពិម្ពិសារ រួចទ្រង់មានព្រះរាជបន្ទូលថា «អាត្មាភាព មិនអាចគង់នៅស្មៀមមួយកន្លែងជាអចិន្ត្រៃយ៍បានទេ ដរាបណាអាត្មាភាពមិនទាន់បានសម្រេចគោលដៅ និងបំណងប្រាថ្នារបស់អាត្មាភាព» ។ ព្រះបាទពិម្ពិសារ ក៏ទូលសុំព្រះរាជកុមារនូវពាក្យសន្យាថា កាលណាបើព្រះអង្គបានសម្រេចគោលដៅក្នុងការត្រាស់ដឹងជាព្រះពុទ្ធពិតប្រាកដហើយ សូមទ្រង់ស្តេចយាងមកកាន់នគររាជគ្រឹះវិញ ដើម្បីប្រទានឱវាទចំពោះព្រះអង្គ និងប្រជារាស្ត្ររបស់ព្រះអង្គផង ។

Hearing this King Bimbisara visited Prince Siddhartha at Pandava mountain and invited the Prince to dwell in his capital city, promising to provide all the Prince's requisites. Prince Siddhartha courteously refused the offer and said: "I cannot reside in one place permanently until I fulfil my purpose and wish." King Bimbisara got the Prince to promise that once He has fulfilled His purpose of attaining Enlightement, He will visit the city of Rajagaha to advise King Bimbisara and his subjects.

On His way to Pandava, Ascetic Siddhartha sees an innocent Lamb.
នៅតាមផ្លូវឆ្ពោះទៅកាន់ភ្នំបណ្ឌវៈ បព្វជិតសិទ្ធត្ថទ្រង់ទតឃើញកូនចៀមមួយក្បាលគួរឱ្យអាណិត

ថ្ងៃមួយ បព្វជិតសិទ្ធត្ថបានយាងចេញពីនគររាជគ្រឹះ ឆ្ពោះទៅជើងភ្នំជាទីសំណាក់នៃពពួកអ្នកបួស និងតាបសទាំងឡាយ ។ ព្រះអង្គទ្រង់ទតឃើញហ្វូងចៀម និងពពែមួយហ្វូងកំពុងដើរក្នុងផ្សែងធូលីហុយទ្រលោម ។ សត្វទាំងនោះកំពុងត្រូវគេដេញសំដៅទៅទីក្រុង ដោយឥតមាននរណាជួយ ។ ព្រះរាជកុមារសិទ្ធត្ថ ទ្រង់ទតឃើញកូនចៀមឃ្លាតចេញពីហ្វូងមួយក្បាលដើរខ្ញើចៗ ដោយឈឺចាប់ ។ កូនចៀមមានឈាមហូរចេញពីរបួសនៅជើងវា ។ ព្រះរាជកុមារ ទ្រង់មានករុណាធម៌យ៉ាងធំធេងចំពោះកូនចៀម និងមេចៀមដែលកំពុងសម្លឹងដោយសេចក្ដីអាណិតអាសូរចំពោះកូនវា ។

One day Prince Siddhartha the ascetic, left the city of Rajagaha to go to the foot-hills of the mountains where many ascetics and sages dwelt. He saw herds of sheep and goats in a cloud of dust. They were being helplessly driven towards the city. Prince Siddhartha saw a limping lamb painfully straying from the main herd. The lamb was bleeding from an injury to its leg. The Prince was filled with great compassion towards the lamb and its mother ewe, looking piteously at its young one.

Ascetic Siddhartha takes the Lamb in His arms.
បព្វជិតសិទ្ធត្ថបីកូនចៀមក្នុងព្រះហស្តព្រះអង្គ

ព្រះរាជកុមារសិទ្ធត្ថ ទ្រង់បីកូនចៀមហើយយាងតាមពីក្រោយហ្វូង និងបបោសអង្អែលថ្នាក់ថ្នមវាបណ្តើរ ។ នៅពេលព្រះអង្គជួបនឹងពួកគង្វាលចៀម ព្រះអង្គទ្រង់សួរទៅពួកគេថា «តើអ្នកនាំចៀមទាំងនេះទៅណា? ។ តាមធម្មតាគេគៀងចៀមតែនៅពេលល្ងាចជិតយប់ទេ ហេតុអ្វីបានជាអ្នកឯងគៀងចៀមទាំងថ្ងៃយ៉ាងនេះ?» ។ ពួកគង្វាលចៀមឆ្លើយតបថា «ព្រះរាជាទ្រង់ប្រារព្ធពិធីយញ្ញធំណាស់នៅថ្ងៃនេះ គេបានសុំឱ្យពួកយើងផ្តល់ចៀមមួយរយក្បាល និងពពែមួយរយក្បាលឱ្យបានទាំងថ្ងៃ» ។ បព្វសិទ្ធត្ថទ្រង់មានបន្ទូលថា «បើដូច្នេះ អាត្មាភាពនឹងទៅជាមួយពួកអ្នកទាំងអស់គ្នាដែរ» ។ ព្រះអង្គទ្រង់បីកូនចៀមយាងឆ្ពោះទៅទីក្រុង ។

Prince Siddhartha took the lamb into His arms and walked behind the herd, caressing it. When He met the shepherds He asked them: "Where do you take these sheep? Generally it is in the evening that they are herded. Why do you herd them during Day-time?" The shepherds replied, "The King performs a gigantic sacrifice today. We have been asked to provide a hundred goats and a hundred sheep during daytime." Prince Siddhartha the ascetic said: "I will come along with you." He carried the lamb to the city.



Ascetic Siddhartha arrives at the place where an animal sacrifice is to take place.
បព្វជិតសិទ្ធត្ថ បានយាងទៅដល់ព្រះរាជវាំងជាទីដែលគេយកសត្វទៅធ្វើពិធីបូជាយញ្ញ

បព្វជិតសិទ្ធត្ថទ្រង់បានយាងទៅដល់ទីក្រុងពីក្រោយហ្វូងសត្វ ។ ព្រះអង្គទ្រង់យាងចូលទៅក្នុងព្រះរាជវាំងជាទីដែលគេប្រារព្ធធ្វើពិធីបូជាយញ្ញ ។ គេបានបំពក់ភ្លើងយ៉ាងសន្ធោសន្ធៅនៅលើអាសនៈសម្រាប់បូជា ។ ពួករាជព្រាហ្មណាចារ្យដែលធ្វើពិធីបូជាចំពោះព្រះអគ្គីកំពុងសូត្រធម៌ត្រៀមបម្រុងនឹងសម្លាប់សត្វចៀម ដើម្បីបូជាយញ្ញ ។ នៅពេលប្រធាននៃព្រាហ្មណាចារ្យលើកដាវឡើងបម្រុងនឹងសម្លាប់សត្វចៀមមួយក្បាលមុនគេនោះ ព្រះរាជកុមារសិទ្ធត្ថទ្រង់យាងចូលទៅដល់ ហើយទ្រង់បញ្ឈប់កុំឱ្យសម្លាប់ ។

Prince Siddhartha the ascetic reached the City behind the herd. From there He went to the Palace, where the sacrifice was being performed. On the altar a huge bonfire was burning. King's Priests who offered homage to Fire God were chanting religious prayers getting ready to kill the sheep for the sacrifice. When the leading Priest raised the sword to kill the first sheep, ascetic Siddhartha stepped in and stopped him.

The Ascetic argues against animal sacrifice.
បព្វជិតសិទ្ធត្ថ ទ្រង់មានបន្ទូលប្រឆាំងនឹងការយកសត្វមកធ្វើពិធីយញ្ញ

បព្វជិតសិទ្ធត្ថទ្រង់ធ្វើអន្តរាគមន៍យ៉ាងអង់អាច និងបង្អាក់នូវអំពើឥតករុណាធម៌របស់ពួកអ្នកគោរពបូជាព្រះអគ្គី ។ ព្រះអង្គទ្រង់សុំឱ្យអ្នកចូលរួមទាំងអស់បញ្ឈប់ពិធីបូជានោះ ។ បព្វជិតសិទ្ធត្ថទ្រង់មានព្រះបន្ទូលទៅកាន់ព្រះបាទពិម្ពិសារដូច្នេះថា «បពិត្រ មហារាជ សូមព្រះអង្គកុំបណ្តោយឱ្យសត្វដែលមិនបង្កឱ្យមានទុក្ខទោសទាំងនេះ ត្រូវគេយកទៅសម្លាប់ ដើម្បីបំពេញព្រះទ័យព្រះអគ្គីធ្វើអ្វីក្រាបទូល» ។ «ជីវិតមានតម្លៃណាស់ មិនអាចពណ៌នាបានទេ ។ ជនដែលយកជីវិតគេ ត្រូវយល់ថាជីវិតមួយ កាលណាបាត់បង់ហើយ នោះមិនអាចរកមកវិញបានទេ» ។ ព្រះបព្វជិតសិទ្ធត្ថទ្រង់មានបន្ទូលទៅរកអ្នកចូលរួមក្នុងពិធីយញ្ញថា «សត្វមានជីវិតទាំងអស់ សុទ្ធតែស្រឡាញ់ជីវិតរបស់ខ្លួនដូចជាមនុស្សដូច្នេះដែរ ហេតុអ្វីបានជាមនុស្សប្រព្រឹត្តចំពោះសត្វយ៉ាងឃោរឃៅដូច្នេះ? ។ តាមធម្មជាតិ ជីវិតរបស់ពួកគេមានកើតចាស់ ឈឺ ស្លាប់ដូចគ្នា» ។

Authoritatively, ascetic Siddhartha intervened and prevented the unkind act of the Fire Priest. Ascetic Siddhartha asked the participants to stop this ceremony. The Ascetic addressed King Bimbisara thus: "O King, please do not allow these harmless animals to be sacrificed to propitiate the Fire God. Life is inexpressibly precious. Those who take it must understand that a life once destroyed cannot be regained." Ascetic Siddhartha addressed those who had come to witness the ceremony: "All beings love their lives just as human beings. Why do human beings treat these animals so cruelly? By nature, birth, old age, sickness and death affect their lives."

He explains why animal sacrifices are bad.
ព្រះអង្គទ្រង់ពន្យល់ថា ហេតុអ្វីបានជាការយកសត្វមកបូជាយញ្ញ ជាអំពើអាក្រក់

ព្រះរាជកុមារសិទ្ធត្ថទ្រង់មានបន្ទូលបន្តថា «ប្រសិនបើមនុស្សយើងមានបំណងចង់បានសេចក្តីស្រឡាញ់ និងអាណិតអាសូរនោះ មនុស្សគប្បីបង្ហាញឱ្យឃើញនូវសេចក្តីស្រឡាញ់ និងអាណិតអាសូរចំពោះអ្នកដទៃវិញ ។ បើតាមហេតុ និងបច្ច័យធម៌ សេចក្តីស្លាប់នឹងមានដល់អ្នកដែលសម្លាប់គេ ។ និយាយឱ្យខ្លី ប្រសិនបើយើងប្រាថ្នាចង់បានសេចក្តីសុខសុភមង្គលទៅអនាគត យើងមិនគប្បីប្រព្រឹត្តអំពើឃោរឃៅចំពោះសត្វមានជីវិត ទោះបីក្នុងករណីណាក៏ដោយ ។ ប្រសិនបើជនណាម្នាក់បានធ្វើឱ្យជនឯទៀតមានទុក្ខសោក និងឈឺចាប់ខាងផ្លូវចិត្ត ជននោះឯងក៏នឹងទទួលផលពីអំពើដែលខ្លួនបានធ្វើដូចគ្នា» ។

Ascetic Siddhartha continued His address: "If people expect to get love and sympathy, they in turn should show love and sympathy towards others. Accrding to the Law of Cause and Effect, Death comes to those who kill others. In short, if we wish future happiness we should not treat any being cruelly in any way. If a person were to give sorrow and pain of mind, to others, he too will certainly reap them."

King Bimbisara requests Ascetic Siddhartha to reside in his kingdom.
ព្រះបាទពិម្ពិសារ សុំយាងព្រះបព្វជិតសិទ្ធត្ថឱ្យគង់នៅក្នុងព្រះនគររបស់ព្រះអង្គ

ការដែលព្រះសិទ្ធត្ថបព្វជិត មានបន្ទូលចំពោះពួកអ្នកគោរពបូជាព្រះអគ្គី បានបង្ហាញនូវលក្ខណៈស្ងប់ស្ងាត់ រម្យទម និងប្រកបដោយមេត្តាធម៌ ។ ព្រះអង្គទ្រង់បានធ្វើឱ្យព្រះរាជា និងអ្នកគោរពបូជាព្រះអគ្គី ប្រែប្រួលព្រះហឫទ័យ និងឥរិយាបថទាំងស្រុង ។ ព្រះរាជាទ្រង់ទទួចអង្វរសុំឱ្យព្រះរាជកុមារគង់នៅក្នុងព្រះនគររបស់ព្រះអង្គ ។ ប៉ុន្តែ ព្រះសិទ្ធត្ថបព្វជិតទ្រង់បដិសេធថា ព្រះអង្គមិនទាន់បានត្រាស់ជាព្រះពុទ្ធទេ ហើយការត្រាស់ដឹងនោះ គឺជាវត្ថុបំណងតែមួយគត់របស់ព្រះអង្គ ។

The way, Ascetic Siddhartha addressed His words to the worshippers of the Fire-God was characterized by calmness, courtesy and compassion. He transformed totally the thoughts and attitudes of the King and the worshippers of the Fire-God. The King entreated the Ascetic to remain in His Kingdom. But Ascetic Siddhartha declined as He has not being able to attain Enlightenment, which was His sole aim.

Leaving Rajagaha, He arrives in the Hermitage of Sage, Alara Kalama.

ចេញពីនគររាជគ្រឹះ ព្រះអង្គទ្រង់ស្តេចយាងទៅដល់សំណាក់នៃតាបស អាឡារកាឡាម

ព្រះសិទ្ធត្ថបព្វជិត ទ្រង់យាងចេញពីនគររាជគ្រឹះ ឆ្ពោះទៅទីសំណាក់នៃតាបសអាឡារកាឡាម ។ អាឡារកាឡាម ជាតាបសដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងការបង្រៀនមុខវិជ្ជាផ្សេងៗ ។ បព្វជិតសិទ្ធត្ថបានគង់នៅក្នុងសំណាក់តាបសនោះ និងខំប្រឹងរៀនសូត្រពីគាត់យ៉ាងយកចិត្តទុកដាក់បំផុត ។ ក្នុងមួយរយៈខ្លីនៃការសិក្សា ព្រះអង្គទ្រង់មានចំណេះដឹងស្មើនឹងអាឡារកាឡាមតាបស ។ តាបសមានសេចក្តីត្រេតអរក្រៃលែង ចំពោះលទ្ធផលដែលសិស្សរបស់គាត់ទទួលបាន ។

From Rajagaha, Ascetic Siddhartha travelled to the hermitage of Sage Alara-Kalama. Alara-Kalama was a well-known Sage who taught a variety of subjects. Ascetic Siddhartha dwelt in His hermitage and studied under him with keen interest. In a short while He was on a par in knowledge with Sage Alara-Kalama. The Sage was extremely happy about His disciple's attainments.



Conversation between Alara Kalama and Ascetic Siddhartha.
ការសន្ទនារវាងអាឡារកាឡាមតាបសនិងបព្វជិតសិទ្ធត្ថ

ថ្ងៃមួយ អាឡារកាឡាមតាបសទូលសួរទៅព្រះសិទ្ធត្ថបព្វជិតថា «ឥឡូវនេះ ព្រះអង្គបានដឹងអំពីអ្វីៗទាំងអស់ ដែលទូលព្រះបង្គំបានចេះហើយ ។ ព្រះអង្គអាចនឹងបង្រៀនពូកែដូចទូលបង្គំដែរ ហេតុដូច្នេះ សូមព្រះអង្គទ្រង់គង់នៅទីនេះជាមួយទូលព្រះបង្គំ និងជួយទូលព្រះបង្គំក្នុងការបង្រៀនសិស្សឯទៀត» ។ ព្រះសិទ្ធត្ថបព្វជិត ទូលសួរតាបសវិញថា «តើតាបសនៅមានសល់អ្វីនឹងបង្រៀនអាត្មាភាពទៀតទេ? តើតាបសមិនអាចនិយាយប្រាប់អាត្មាភាពអំពីផ្លូវដែលនាំទៅរកជ័យជំនះលើភាពចាស់ជរា ព្យាធិ និងមរណៈបានទេឬ?» ។ តាបសនៅស្ងៀម ពីព្រោះគាត់បានបង្រៀនព្រះរាជកុមារអស់ចំណេះដែលគាត់មានទៅហើយ ។

One day, Sage Alara-Kalama addressed Ascetic Siddhartha thus "You now know everything I am aware of. You can teach as efficiently as I, therefore stay with me and assist me to instruct the disciples." Ascetic Siddhartha questioned Him thus: "Have you anything else to teach me? Could you not tell me a way to overcome old age, sickness and death?" The Sage remained silent, because he had taught Him all he knew.

Ascetic Siddhartha leaves Hermitage because He is not able to get what He needs from Sage, Alara Kalama.
បព្វជិតសិទ្ធត្ថចាកចេញពីសំណាក់តាបសអាឡារកាឡាម ពីព្រោះមិនអាចទទួលនូវអ្វីដែលព្រះអង្គចង់បានពីគាត់

តាបសអាឡារកាឡាម ច្រើនតែបង្ហាត់បព្វជិតសិទ្ធត្ថអំពីការធ្វើសមាធិ ។ នោះគឺជាបច្ចេកទេសដើម្បីរក្សាអារម្មណ៍ឱ្យស្ងប់ស្ងាត់ ។ ប៉ុន្តែ នោះមិនមែនជាបញ្ញាចុងបំផុត ឬជាកំពូលវិជ្ជាទេ ។ ព្រះសិទ្ធត្ថបព្វជិត ទ្រង់មិនពេញព្រះហឫទ័យចំពោះចំណេះនោះឡើយ ក៏ព្រោះតែវាពុំអាចផ្ដល់ចម្លើយចំពោះបញ្ហាដែលធ្វើឱ្យព្រះអង្គខ្វល់ខ្វាយអស់ពេលជាយូរមកហើយនោះ ។ ដោយហេតុនោះ ទើបព្រះអង្គទ្រង់ចាកចេញពីតាបសអាឡារកាឡាម ក្នុងបំណងស្វែងរកអាចារ្យណាម្នាក់ទៀត ដែលមានបញ្ញាខ្ពស់ជាងនេះ ។

Sage Alara-Kalama, instructed Ascetic Siddhartha mainly in Meditation. It was the technique to keep the mind tranquil. But this was not final wisdom or ultimate knowledge. Ascetic Siddhartha was not satisfied with that knowledge only, because it did not provide an answer to the question that had troubled Him for a long time. In consequence, He left Sage Alara-Kalama in search of a Teacher who possessed higher wisdom.



Ascetic Siddhartha goes to Sage, Uddaka Ramaputra.
ព្រះសមណសិទ្ធត្ថ យាងទៅជួបមុនីតាបស ឧទ្ទករាមបុត្រ

ព្រះអង្គបានឮគេដំណាលអំពីមុនីតាបស ឈ្មោះឧទ្ទករាមបុត្រ ។ គាត់មានវ័យចាស់ជាងគេ មានគតិបណ្ឌិតខ្ពស់ជាងគេ និងមានចំណេះវិជ្ជាអាចយល់ដឹងជ្រៅដល់ខាងក្នុងនៃផ្លូវចិត្ត ។ ព្រះអង្គបានយាងទៅជួបមុនីតាបសនោះ និងសូមរៀនសូត្រក្នុងសំណាក់គាត់ដោយព្រះទ័យទុកដាក់យ៉ាងជ្រាលជ្រៅ ។ ក្នុងរយៈពេលដ៏ខ្លី សមណសិទ្ធត្ថទ្រង់មានចំណេះដឹងស្មើនឹងមុនីតាបសនោះ ។ មុនីតាបស ឧទ្ទករាមបុត្រ បានសុំឱ្យសមណសិទ្ធត្ថស្នាក់នៅក្នុងសំណាក់របស់គាត់ ដើម្បីបានជួយគាត់ក្នុងការបង្ហាត់បង្រៀនសាវ័ករបស់គាត់ ។

He heard of a Sage called Uddakaramaputra. He was older, wiser and was known to possess deep insights. He went to Him and studied under Him with great devotion. Soon He achieved the same level of knowledge as the Sage. Sage Uddakaramaputra, requested Ascetic Siddhartha to remain in His hermitage, assisting Him to teach His disciples.

He is disillusioned with the teaching of Uddaka Ramaputra.
ព្រះសមណសិទ្ធត្ថ ទ្រង់ស្រងាកព្រះទ័យយ៉ាងខ្លាំងចំពោះការបង្ហាត់បង្រៀនរបស់មុនីតាបសឧទ្ទកពាមបុត្រ

ព្រះសមណសិទ្ធត្ថ ទ្រង់ពុំសព្វព្រះរាជហឫទ័យទាំងស្រុង ចំពោះពាក្យប្រៀនប្រដៅរបស់មុនីតាបសឧទ្ទករាមបុត្រទេ ។ មុនីតាបសឧទ្ទករាមបុត្រ បានបង្រៀនព្រះអង្គនូវវិជ្ជានៃការតម្កល់សតិឱ្យនឹងថ្កល់ កុំឱ្យគិតអ្វីទាំងអស់ ។ តែមុនីតាបសនោះក៏មិនអាចបង្ហាញឱ្យព្រះសមណសិទ្ធត្ថរកឃើញនូវដំណោះស្រាយចំពោះបញ្ហាស្មុគ្រស្មាញទាក់ទងនឹងជរា ព្យាធិ និងមរណៈ ដែលជាបញ្ហាគ្មានទីបញ្ចប់នៃជីវិតបានដែរ ។ ព្រះសមណសិទ្ធិត្ថបានចាកចេញពីសំណាក់តាបសនោះ ដោយប្តេជ្ញាថានឹងរកឱ្យបាននូវការត្រាស់ដឹងតាមរយៈការខំប្រឹងប្រែងដោយខ្លួនព្រះអង្គឯង និងឥតត្រូវការពឹងពាក់ជំនួយពីអ្នកដទៃឡើយ ។

Ascetic Siddhartha was not totally satisfied with the teachings of Sage Uddakaramaputra. He taught Him the discipline of keeping the mind totally still, devoid of thoughts. He too could not give Ascetic Siddhartha a solution to the riddles of old age, sickness and death, which were the unceasing problems of life. Ascetic Siddhartha left Him, determined to achieve Enlightenment through self-effort and without seeking the assistance of others.

Most Ascetics of the day inflicted self-mortification as a means to end suffering.
ពួកតាបសភាគច្រើននាសម័យនោះ នាំគ្នាប្រព្រឹត្តធម៌ដោយការធ្វើបាបខ្លួនឯង ថាជាមធ្យោបាយឆ្ពោះទៅរកការរំលត់ទុក្ខ

នៅសម័យនោះ ក៏ដូចជានៅបច្ចុប្បន្ននេះដែរ មានពួកតាបសគ្រប់ប្រភេទដែលបានបំពេញតបកម្មយ៉ាងតឹងរ៉ឹង ។ តាបសខ្លះជឿថា ពួកគេនឹងបានទៅកើតនៅឋានសួគ៌ បន្ទាប់ពីគេស្លាប់ទៅ ប្រសិនបើពួកគេអត់អាហារ និងទទួលការឈឺចាប់អំពីការធ្វើទុក្ករកិរិយា ។ ជំនឿរបស់ពួកគេគឺថា ពួកគេនឹងទទួលបានសេចក្ដីសុខនិងសុភមង្គលនៅក្នុងជាតិខាងមុខ តិចឬច្រើនស្របទៅតាមការឈឺចាប់ដែលគេបានទទួលនៅក្នុងជាតិនេះ ។ នោះហើយជាហេតុដែលនាំឱ្យពួកគេខំប្រឹងធ្វើទុក្ករកិរិយាយ៉ាងតឹងរ៉ឹងនោះ ។

In those day too, just as today, there were all kinds of ascetics given to severe austerities. Some believed that they will be born in Heaven after Death if they fasted and suffered physical mortification. Their belief was that they could enjoy comforts and happiness during the next birth in proportion to the suffering they underwent during the present life-time. This was the reason for their severe austerities.

Some resorted to Fasting.
តាបសខ្លះងាកទៅរកវិធីអត់អាហារ

តាបសខ្លះក្លាយជាស្គមស្គាំងនៅសល់តែស្បែកដណ្តប់ឆ្អឹង ពីព្រោះពួកគេបានតមពុំឆាន់ចង្ហាន់ ។ តាបសខ្លះបានឈរលើជើងតែមួយ ។ ខ្លះលើកដៃម្ខាងឡើងទៅលើរហូតដល់ឈាមលែងហូរទៅដល់ ហើយអវៈយវៈទាំងនោះក៏ចុះខ្សោយ ។ ខ្លះក្តាប់ដៃចូលគ្នាអស់ពេលដ៏យូរ រហូតដល់ក្រចកដុះយ៉ាងវែង ។ ខ្លះទៀតដេកនៅលើគ្រែដែកគោល ។

Some had been reduced to skin and bone, because they had refrained from taking food. Some stood on one foot. Some kept one hand raised until blood stopped flowing into it and the limb became weak. Some had kept their hands clasped together for so long, that nails had grown extremely long. Some slept on nail-beds.

Ascetic Siddhartha arrives in Uruvela settlement.
ព្រះសមណសិទ្ធត្ថ បានយាងទៅដល់តំបន់ឈ្មោះ ឧរុវេល

ព្រះសមណសិទ្ធត្ថ ក៏ដូចគ្នានឹងតាបសឯទៀតដែរ ទ្រង់បានចំរើនតបកម្មទាំងនោះ ដែលព្រះអង្គទ្រង់បានគិតថា ជាផ្លូវពិតដែលនាំទៅរកការត្រាស់ដឹងបាន ។ នៅក្នុងដំណើរឆ្ពោះទៅនគរមគធៈ ព្រះអង្គទ្រង់បានយាងទៅដល់តំបន់ឧរុវេល ។ នៅទីនោះព្រះអង្គបានទតឃើញកន្លែងដ៏ស្ងប់មួយនៅលើច្រាំងទន្លេ ។ ព្រះអង្គទ្រង់ព្រះតម្រិះថា ប្រសិនបើព្រះអង្គទ្រង់ស្នាក់នៅទីនេះ ព្រះអង្គអាចយាងទៅបិណ្ឌបាតនៅសេនានិគមដែលស្ថិតនៅជិតទីនោះដែរ ។ ព្រះអង្គក៏ទ្រង់សម្រេចព្រះទ័យថានឹងចំរើនតបធម៌ពិសេសនៅទីនោះ ។

Ascetic Siddhartha too resolved to practice such austerities; that, he thought, was the sure path to Enlightenment. On His way to Magadha He arrived in Uruvela. There He saw a tranquil spot on the banks of a river. He thought that if He dwelt there, He would be able to go for alms in the neighbouring village of Senani. He made up His mind to practise special austerities at that place.

Here, the five Ascetics, Kondanna, Bhaddiya, Vappa, Mahanama and Assaji, come to meet Ascetic Siddhartha.
នៅទីនេះ ភិក្ខុទាំងប្រាំអង្គគឺ កោណ្ឌញ្ញ ភទ្ទិយៈ វប្បៈ មហានាម និងអស្សជិ បានមកជួបនឹងព្រះសមណសិទ្ធត្ថ

នៅក្នុងពេលនោះ បញ្ចវគ្គិយ៍ទាំង៥អង្គគឺ កោណ្ឌញ្ញ ភទ្ទិយៈ វប្បៈ មហានាម និង អស្សជិ បាននិមន្តមកដល់តំបន់ឧរុវេល ក្នុងដំណើរស្វែងរកជួបព្រះសមណសិទ្ធត្ថ ។ ពួកបញ្ចវគ្គិយ៍ភិក្ខុទាំង៥អង្គនោះ មានជំនឿយ៉ាងមុតមាំទៅលើព្រះសមណសិទ្ធត្ថ ដែលបានចំរើនតបធម៌ដោយខ្លាំងក្លា និងការយកចិត្តទុកដាក់យ៉ាងនេះ ថាប្រាកដជានឹងបានត្រាស់ដឹងជាព្រះពុទ្ធ ហើយនឹងបានបង្រៀនពួកគេ អំពីមាគ៌ា ឆ្ពោះទៅរកការត្រាស់ដឹងជាពុំខាន ។

At that time, the five Ascetics Kondanna, Vappa, Bhaddiya, Mahanama and Assaji arrived in Uruvela, in search of Ascetic Siddhartha. These five Ascetics believed firmly that Ascetic Siddhartha, practising austerities with such devotion and earnestness, will finally attain Enlightenment and will in turn teach them The Way.

Ascetic Siddhartha is extremely emaciated due to excessive fasting.
ព្រះសមណសិទ្ធត្ថ ទ្រង់មានព្រះកាយស្គមស្គាំងហួសប្រមាណ ដោយសារតែទ្រង់តមមិនឆាន់អាហារហួសកំរិត

ព្រះសមណសិទ្ធត្ថ ទ្រង់ចំរើនតបធម៌រហូតឈានទៅដល់ដំណាក់កាលដែលព្រះអង្គតមមិនសោយអាហារសោះ ។ ព្រះកាយព្រះអង្គបានក្លាយទៅជាស្គាំងស្គមក្រៃលែង រហូតដល់មើលឃើញសុទ្ធតែឆ្អឹង ។ ប៉ុន្តែ ព្រះអង្គនៅតែតាំងព្រះទ័យបន្តចំរើនតបធម៌តទៅទៀត ។ ថ្ងៃមួយ នៅពេលដែលព្រះអង្គកំពុងចំរើនសមាធិ ព្រះអង្គទ្រង់ដួលសន្លប់បាត់ស្មារតីស្ដូកស្ដឹងដោយសារការអស់កម្លាំងហួសប្រមាណ ។ អ្នកជិតខាងទាំងឡាយបានដឹងថា ព្រះសមណទ្រង់អត់មិនសោយអាហារអស់ជាច្រើនថ្ងៃមកហើយ ព្រោះហេតុនោះក្មេងគង្វាលពពែម្នាក់បានគិតថា ព្រះសមណកំពុងតែឈានទៅរកសេចក្ដីស្លាប់ហើយ ។

Ascetic Siddhartha practised austerities and progressed to the stage of totally refraining from food. He became so emaciated that the bones of His body became visible. But, He continued with His resolve. One day, when He was meditating, He fainted due to extreme exhaustion. All the neighbours knew that this noble Ascetic had fasted for several days. Therefore, a young goat-herd thought that the Ascetic was dying.



When Ascetic Siddhartha faints due to physical weakness, a goatherd revives Him with goat's milk.

នៅពេលព្រះសមណសិទ្ធត្ថ ទ្រង់សន្លប់ស្តូកស្តឹងដោយសារភាពទន់ខ្សោយនៃកាយពលនោះ មានក្មេងគង្វាលពពែម្នាក់បានធ្វើឱ្យព្រះអង្គដឹងស្មារតីឡើងវិញ ដោយសារទឹកដោះពពែ

ក្មេងគង្វាលនោះ បានដឹកពពែញីមួយក្បាលទៅកាន់កន្លែងដែលព្រះសមណសិទ្ធត្ថកំពុងសន្លប់ស្តូកស្តឹង រួចបានថ្វាយទឹកដោះពពែទៅព្រះសមណសោយ ។ ព្រះសមណទ្រង់មានព្រះស្មារតីឡើងវិញ រួចចាប់ផ្តើមពិចារណាអំពីអ្វីដែលបានកើតឡើងចំពោះព្រះអង្គកន្លងមក ។ ព្រះសមណទ្រង់សន្និដ្ឋានថា ប្រសិនបើក្មេងគង្វាលពពែនេះមិនបានថ្វាយទឹកដោះចំពោះព្រះអង្គទាន់ពេលទេ ប្រហែលជាព្រះអង្គទ្រង់សោយទិវង្គតដោយពុំបានត្រាស់ដឹងជាព្រះពុទ្ធទេ ។

He pulled along a she goat to the fainted Ascetic and gave Him goat's milk to drink. The Ascetic came to, and started thinking about what happened to Him. The Ascetic concluded that had this young goat-herd not given Him milk in time, He would have died without attaining Enlightenment.



Ascetic Siddhartha hears the music of a group of young women.
ព្រះសមណសិទ្ធត្ថ ទ្រង់ព្រះសណ្តាប់តន្ត្រីរបស់នារីមួយក្រុម

ក្មេងគង្វាលនោះ មានសេចក្តីសប្បាយរីករាយក្រៃលែង ដែលបានជួយសង្គ្រោះព្រះសមណ ដែលមានគុណធម៌ខ្ពស់យ៉ាងនេះ ។
ព្រះសមណទ្រង់ចំរើនសមាធិបន្តទៅទៀត នៅជិតគល់ឈើមួយដើម ។ នៅពេលល្ងាច ព្រះអង្គទ្រង់ព្រះសណ្តាប់ឮសូរក្មេងស្រីមួយក្រុម ពេលពួកគេត្រឡប់ទៅលំនៅដ្ឋានវិញ នាំគ្នាច្រៀងថា «ពេលខ្សែពិណធូរ សម្លេងវាធូរ ស្តាប់មិនពិរោះ ពេលរឹតតឹងពេក វាដាច់ខ្សែអស់ សម្លេងពិរោះ លុះតែរឹតល្មម» ។

The goat-herd was extremely happy that he was able to help the virtuous, Ascetic, he held in such high esteem. Ascetic Siddhartha, continued His meditation at the foot of a tree. In the evening He heard a group of girls returning home, singing. "When the strings of the violin are loose, its notes are sour. When the strings are over-tightened they break. The violin provides pleasant music when the strings are neither loose nor over-tight".

Learning lesson from that music Ascetic Siddhartha gives up his rigid and extreme penances and gradually starts taking food again.

ដោយបានឮសម្លេងតន្ត្រីនោះ ព្រះសមណសិទ្ធត្ថទ្រង់បានបោះបង់ចោលនូវសេចក្តីព្យាយាមធ្វើទារុណកម្មយ៉ាងតឹងរ៉ឹងចំពោះខ្លួនឯង ហើយទ្រង់ ចាប់ផ្តើមសោយអាហារបន្តិចម្តងៗ ឡើងវិញ

ព្រះសមណសិទ្ធត្ថ ទ្រង់ពិចារណាថាព្រះអង្គបានរឹតបន្តឹងខ្សែជីវិតរបស់ព្រះអង្គហួសកំរិតហើយ ។ ព្រះអង្គទ្រង់ពិចារណាដូច្នេះថា «ប្រសិនបើ អាត្មាអញធ្វើមរណកាលមុនពេលអាត្មាអញ បានត្រាស់ដឹងជាព្រះពុទ្ធនោះ ទុក្ករកិរិយាដែលអាត្មាអញបានធ្វើនោះ វាក្លាយជាអសារបង់ឥតប្រយោជន៍អ្វីឡើយ ។ ការធ្វើទារុណកម្មចំពោះខ្លួនឯងយ៉ាងនេះ មិនមែនជាផ្លូវនាំឱ្យបានត្រាស់ដឹងទេ» ។ ព្រោះហេតុនោះ ព្រះអង្គទ្រង់បោះបង់ចោលនូវសេចក្តីព្យាយាមធ្វើទារុណកម្មចំពោះខ្លួនឯង ហើយទ្រង់បន្តស្វែងរកសច្ចៈធម៌ដោយសេចក្តីក្លាហានដដែល ។ ចាប់តាំងពីពេលនោះមក ព្រះអង្គទ្រង់ត្រាច់ចរទៅបិណ្ឌបាតជារៀងរាល់ព្រឹក ។

He had over-tightened the strings of His life, Ascetic Siddhartha thought. He thought thus: "If I died before I attained Enlightenment all these austerities are in vain. Self-mortification is not the right path to the Absolute Truth". Therefore He decided to give up austerities and to continue the search for truth with sustained courage. From then on, the Ascetic went out on His alms round every morning.

The five Ascetics leave Him due to this.
បញ្ចវគ្គិយ៍ទាំងប្រាំអង្គ បាននិមន្តចេញចោលព្រះសមណ ដោយសារតែព្រះអង្គទ្រង់សោយអាហារឡើងវិញ

ដោយសារព្រះសមណសិទ្ធត្ថ សោយអាហារតាមធម្មតាវិញ ព្រះរាជសុខភាពរបស់ព្រះអង្គក៏ស្រស់បស់ល្អពេញលេញឡើងវិញ ដូចប្រក្រតី ។ សម្បុរព្រះកាយព្រះអង្គក៏ត្រឡប់ជាមានពណ៌ដូចមាសឡើងវិញ ដូចកាលដែលព្រះអង្គទ្រង់គង់នៅក្នុងព្រះរាជវាំងដូច្នោះដែរ ។ ព្រះសមណ ទ្រង់ពិចារណាថា ការស្វែងរកសម្មោធិញ្ញាណតាមរយៈការធ្វើទុក្ករកិរិយាគឺ ជាការព្យាយាមឥតប្រយោជន៍ មិនខុសពីការប៉ុនប៉ងវិញខ្សែពួរដោយប្រើដីខ្សាច់ឡើយ ។ ប៉ុន្តែបញ្ចវគ្គិយ៍ភិក្ខុទាំង៥អង្គយល់ខុសចំពោះរឿងនេះ ។ ពួកគេនៅតែប្រកាន់ទស្សនៈថា ទុក្ករកិរិយាជាមាគ៌ាតែមួយគត់ដែលនាំទៅរកការត្រាស់ដឹងជាព្រះពុទ្ធ ។ នៅពេលដែលព្រះសមណសិទ្ធត្ថ ទ្រង់បោះបង់ចោលនូវការព្យាយាមធ្វើទុក្ករកិរិយា ហើយទ្រង់ចាប់ផ្ដើមសោយអាហារតាមប្រក្រតីឡើងវិញ បញ្ចវគ្គិយ៍ភិក្ខុទាំងនោះគិតថា ព្រះសមណជាជនល្មោភឆាន់ រួចពួកគេក៏នាំគ្នាធ្វើដំណើរចាកចោលព្រះអង្គទៅ ។

Due to this, Ascetic Siddhartha, recovered His normal health. His complexion was once again of golden hue, as in the days when He lived in the Palace. Seeking Enlightenment through austerities, He thought was as vain an effort as attempting to weave a rope out of sand. But, the five Ascetics misunderstood this. They stil held the view that austerities were the only path to Englightenment. When Ascetic Siddhartha gave up austerities and started taking food in the normal way the five Ascetics thought Him greedy and left Him.

Sujatha offers Him milk-rice.
ព្រះនាងសុជាតា ថ្វាយមធុបាយាស ចំពោះព្រះសមណសិទ្ធត្ថ

នាព្រឹកមួយ មានព្រះអង្គម្ចាស់ក្សត្រីមួយព្រះអង្គព្រះនាម សុជាតា មកពីភូមិមួយនៅជិតទីនោះ បានចំអិនមធុបាយាសធ្វើអំពីបាយលាយទឹកដោះយ៉ាងឆ្ងាញ់ រួចនាំយកទៅថ្វាយព្រះសមណសិទ្ធត្ថ ។ ព្រះនាងមានបន្ទូលថា «សេចក្ដីប្រាថ្នារបស់នាងខ្ញុំបានសម្រេចហើយ ហេតុនេះសូមឱ្យសេចក្ដីប្រាថ្នារបស់ព្រះអង្គបានសម្រេចដូចគ្នាដែរ» ។ ព្រះនាងសុជាតា បានប្ដេជ្ញាថាប្រសិនបើព្រះនាងទ្រង់បានកូនប្រុស ព្រះនាងនឹងថ្វាយចង្ហាន់បិណ្ឌបាតចំពោះព្រះសមណសិទ្ធត្ថ ។

One morning a Princess named Sujatha, from a neighbouring village cooked some delicious milk-rice and took it to the Ascetic Siddhartha. She said, "Just as my wish was fulfilled, may your wish too get fulfilled"

Princess Sujatha had vowed that if she had a child, she would offer alms to Ascetic Siddhartha.

Ascetic Siddhartha goes to river Neranja to bathe.

ព្រះសមណសិទ្ធត្ថ ទ្រង់យាងទៅកាន់ស្ទឹងនេរញ្ជរា ដើម្បីស្រង់ទឹក

នៅក្នុងថ្ងៃដដែលនោះ ព្រះសមណសិទ្ធត្ថ ទ្រង់យាងទៅកាន់ស្ទឹងនេរញ្ជរា ដើម្បីស្រង់ទឹកជំរះព្រះសរីរកាយ ។ បន្ទាប់ពីជំរះព្រះកាយស្រេចហើយ ព្រះអង្គទ្រង់យាងទៅគង់នៅទៀបគល់ដើមសាលព្រឹក្សមួយដើម រួចដោយសារពុំមាននរណាម្នាក់នៅជិតព្រះអង្គនោះទ្រង់ក៏ចាប់ផ្តើមធ្វើសមាធិដោយប្រាថ្នាចង់ឱ្យសម្រេចនូវសម្មាសម្ពោធិញ្ញាណនៅវេលាយប់នោះឯង ។ ប៉ុន្តែព្រះអង្គយាងចេញពីដើមសាលព្រឹក្សនោះ ឆ្ពោះទៅកាន់ដើមពោធិព្រឹក្សមួយដើមយ៉ាងធំ ដែលជាកន្លែងល្អសមនឹងការធ្វើសមាធិ ។ ព្រះអង្គទ្រង់រៀបចំទីអាសនៈដោយពង្រាយស្មៅស្គាដែលទ្រង់ទទួលពីសោត្ថិយព្រាហ្មណ៍រួចទ្រង់គង់នៅលើអាសនៈនោះដោយបែរព្រះភក្ត្រឆ្ពោះទៅទិសខាងកើត ។

The same day, Ascetic Siddhartha, went to River Neranjana for a bath. After the bath, He sat at the foot of a Sala tree, and since there was no one around, set about meditating with the intention of attaining Enlightenment during that still night. But He left the Sala tree, and went over to the foot of a large Bodhi Tree as the fitting place for meditation. He prepared a seat spreading the 'Kusa' grass He had received from Brahmin Sotthiya and sat on it facing the East.

Ascetic Siddhartha sits at the foot of the Bodhi Tree, determined to attain Enlightenment.
ព្រះសមណសិទ្ធត្ថ ទ្រង់គង់នៅទៀបគល់ពោធិព្រឹក្ស ដោយប្ដេជ្ញាថានឹងសម្រេចឱ្យបាននូវការត្រាស់ដឹងជាព្រះពុទ្ធ

គង់នៅក្រោមដើមពោធិព្រឹក្ស ព្រះសមណសិទ្ធត្ថ ទ្រង់តាំងព្រះទ័យប្ដូរផ្ដាច់ថា «ទោះបីសាច់ និងឈាមរបស់អាត្មាអញរីងស្ងួតទៅនៅសល់តែស្បែក និងឆ្អឹងក៏ដោយ ក៏អាត្មាអញនឹងមិនចាកចេញពីទីអាសនៈនេះឡើយ ដរាបណាអាត្មាអញរកមិនឃើញនូវមាគ៌ាមួយដើម្បីរំដោះអាត្មាអញផ្ទាល់ និងមនុស្សជាតិទាំងអស់ឱ្យផុតពីសេចក្ដីទុក្ខនៃជាតិជរា និងមរណៈ ទេនោះ ។

Seated at the foot of the Bo tree, Ascetic Siddhartha resolved thus : "Even if all my flesh and blood were to dry up, leaving behind only skin and bone, I will not rise from this seat until I discover for myself and for mankind a way of final liberation from the suffering of birth, decay and death".

Ascetic Siddhartha in Meditation at the foot of the Bodhi Tree.
ព្រះសមណសិទ្ធត្ថ ទ្រង់ចំរើនសមាធិនៅទៀបគល់ពោធិព្រឹក្ស

ចាប់តាំងពីពេលនោះមក ព្រះអង្គទ្រង់ចំរើនសមាធិដោយផ្ដោតព្រះហឫទ័យទៅលើការបន្សុទ្ធចិត្តឱ្យចាកផុតនីវរណធម៌ ដែលកើតចេញពីធម្មជាតិ និងពីសេចក្ដីរីករាយដែលឡកលួងរបស់អតីតកាល ។ គំនិតបានកើតឡើងចំពោះព្រះអង្គថា៖ «តើសេចក្ដីទុក្ខទាំងឡាយនោះ វាកើតឡើងដូចម្ដេច? តើយើងអាចរំដោះខ្លួនយើងឱ្យរួចផុតពីសេចក្ដីទុក្ខទាំងនោះដោយរបៀបណា? ទោះជាយ៉ាងណាក្ដី ដោយហេតុថាព្រះសមណទ្រង់នៅជាយុវជនមួយព្រះអង្គដែលទើបមានព្រះជន្ម៣៥ព្រះវស្សានៅឡើយនោះ ព្រះអង្គទ្រង់នៅតែនឹកភ្នកទៅដល់ប្រណីតភាព និងផាសុខភាពទាំងឡាយដែលព្រះរាជបិតារបស់ព្រះអង្គបានរៀបចំថ្វាយ កាលព្រះអង្គគង់នៅក្នុងព្រះរាជវាំងនៅឡើយ ។

From then on He concentrated His mind on ridding the mind of all ills that issue from Nature and of the illusory pleasure of the past. These thoughts occurred to Him. "How do all these sufferings arise? How can we free ourselves from these sufferings?". As Ascetic Siddhartha was still a young man of 35, He still remembered the luxuries and comforts provided by His father when He was in the Palace.



Ascetic Siddhartha, preserves the tranquility of mind in spite of all mental obstacles.
ព្រះសមណសិទ្ធត្ថ ទ្រង់តម្កល់ព្រះហឫទ័យឱ្យនៅនឹងថ្កល់ ទោះបីមានឧបសគ្គខាងអារម្មណ៍ក៏ដោយ

កិលេសភូតទាំងឡាយបានប៉ុនប៉ងអូសទាញការផ្ចង់ស្មារតីព្រះអង្គទៅរកប្រការផ្សេងៗ ។ ភូតទាំងនោះសកម្មខ្លាំងណាស់ក្នុងការអន្ទងព្រះអង្គឱ្យនឹកឃើញដល់កាមតណ្ហា ដែលព្រះអង្គធ្លាប់ក្រសាលនៅក្នុងព្រះរាជវាំង និងធ្វើឱ្យព្រះអង្គមានតម្រេកចំពោះកាមទាំងនោះ ។ ប៉ុន្តែតាមរយៈការធ្វើសមាធិភាវនា ព្រះអង្គទ្រង់អាចតម្កល់ព្រះហឫទ័យឱ្យនៅនឹងថ្កល់ដដែល ហើយគំនិតរវើរវាយដែលមករារាំងព្រះអង្គបានរលាយបាត់បង់អស់ទៅ ។ ព្រះហឫទ័យព្រះអង្គ ស្ងប់នឹងថ្កល់ប្រៀបដូចទឹកស្រះពេលគ្មានខ្យល់បក់ ។ ព្រះហឫទ័យរបស់ព្រះអង្គបានឈានចូលទៅក្នុងសមាធិយ៉ាងជ្រាលជ្រៅ ។

Demons of defilement tried to draw His attention to some other matters. They were active persuading Him to remember the sensual pleasures He enjoyed in the Palace and making Him desire those. But through determination He was able to remain without being tempted. At the end all illusory thoughts that obstructed Him were driven away. His mind was as tranquil as the water in a pond on a day when the air is still. His mind went into deep meditation.

Ascetic Siddhartha attains such stages of Higher Meditation as 'ability to recall past births.'
ព្រះសមណសិទ្ធត្ថ ទ្រង់សម្រេចបាននូវឈានដ៏ខ្ពស់បំផុតគឺ ប្រាជ្ញាអាចរលឹកឃើញនូវអតីតជាតិ ដែលបានកន្លងទៅហើយ

ព្រះសមណសិទ្ធត្ថ ទ្រង់ប៉ុនប៉ងរកឱ្យឃើញនូវដើមចមនៃជីវិត ។ ព្រះអង្គទ្រង់ទទួលបាននូវពលានុភាពដ៏ខ្លាំង ដែលអាចនាំឱ្យព្រះអង្គរលឹកឃើញនូវអតីតជាតិទាំងអស់របស់ព្រះអង្គ ។ ដោយសេចក្ដីប្រឹងប្រែងព្យាយាមថែមទៀត ព្រះអង្គទ្រង់ទទួលបាននូវទិព្វចក្ខុ ដែលអាចប្រមើលឃើញនូវអនាគតនៃសត្វទាំងឡាយ ។ ព្រះអង្គទ្រង់ជ្រាបច្បាស់ថាវដ្តសង្សារ គឺដំណើរវិលចុះឡើងនៃការកើតស្លាប់នោះ កើតឡើងដោយសារតែកម្មរបស់បុគ្គលម្នាក់ៗ ពីព្រោះដោយសារអំពើល្អរបស់ខ្លួនក្នុងជាតិនេះ សត្វខ្លះអាចមានជីវិតប្រសើរជាងនៅក្នុងជាតិខាងមុខ ។ បាបកម្មដែលខ្លួនសាងនៅក្នុងជាតិនេះនឹងនាំឱ្យពួកសត្វទាំងនោះទទួលទុក្ខវេទនាយ៉ាងក្រៃលែងនៅក្នុងជាតិខាងមុខ ។

Ascetic Siddhartha attempted to seek the beginning of life. He acquired the power to recall the past births. With more effort, He was able to obtain the divine eye that revealed the future of all beings. He realized that the cycle of births and deaths occurred due to an individual's Karma, because of good deeds done during the present birth, some can have a better life during the next birth. Sins committed during this birth will make one suffer exceedingly during the next birth.

Ascetic Siddhartha realizes the Four Noble Truiths of Suffering, Cause of Suffering, Ending of Suffering and Path to the End of Suffering.
ព្រះសមណសិទ្ធត្ថទ្រង់ត្រាស់ដឹងអំពីអរិយសច្ចៈទាំង៤ គឺសេចក្តីទុក្ខ ហេតុដែលនាំឱ្យកើតសេចក្តីទុក្ខ ការរំលត់ទុក្ខ និងមាគ៌ានាំទៅរកការរំលត់ទុក្ខ

នៅទីបំផុត ព្រះអង្គត្រាស់ដឹងថា មូលហេតុនៃដំណើរវិលឥតមានទីបញ្ចប់នៃការកើតស្លាប់ ស្លាប់កើតៗ នៅក្នុងមហាសាគរនៃវដ្តសង្សារ គឺអវិជ្ជា និងតណ្ហាចំពោះសេចក្តីសុខលោកិយ ។ ចំពោះអ្នកដែលមានប្រាថ្នាចង់រលាស់ខ្លួនឱ្យចេញផុតពីវដ្តសង្សារ គេមានមាគ៌ាមួយគឺ ការបំបាត់តណ្ហាឱ្យអស់ទាំងស្រុង ។ ព្រះសមណសិទ្ធត្ថ ទ្រង់ជ្រាបច្បាស់ថា ព្រះអង្គទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណ ដោយរកឃើញនូវហេតុដែលនាំឱ្យមានទុក្ខ និងមាគ៌ាដែលនាំទៅរកការរំលត់ទុក្ខនោះហើយ ។ នោះគឺជាព្រឹត្តិការណ៍ដ៏អស្ចារ្យដែលកើតឡើងនៅពេលទៀបភ្លឺនៃថ្ងៃពេញបូរមីក្នុងខែពិសាខ ។ ព្រះសមណសិទ្ធត្ថនៃសក្យត្រកូលបានត្រាស់ដឹងជាព្រះពុទ្ធ នៅក្រោមដើមពោធិព្រឹក្សនាដែនគយាក្នុងព្រះជន្មាយុ៣៥ព្រះវស្សា ។ ចាប់ពីពេលនោះមក ពិភពលោកទាំងមូលបានទទួលនូវប្រទីបមួយប្រកបដោយពន្លឺចិញ្ចាចចិញ្ចែង ។

Finally He realized, that the cause of the endless round of birth, death and rebirth in the ocean of Sansara is ignorance and the craving for the ever-changing, illusory comforts. There is a way of escape for those who desire release from Sansara: that is the total eradication of craving. Ascetic Siddhartha realized that He has attained Enlightenment by discovering the Cause of Suffering and the way to end suffering. This was the great event that occurred at the dawn of Vesak Full-moon Day. Ascetic Siddhartha of the Sakya Clan attained Enlightenment at the foot of the Bodhi Tree at Gaya, at the age of 35. From then on the World received a bright Lamp.

A Brahmin comes to Ascetic Siddhartha,
មានព្រាហ្មណ៍ម្នាក់ បានចូលមកថ្វាយបង្គំព្រះសមណសិទ្ធត្ថ

ព្រះសម្មាសម្ពុទ្ធទ្រង់បានសោយវិមុត្តិសុខនៃនិព្វាន ។ ពេលក្រោយនោះបន្តិចមក ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្រោមដើមពោធិ មានព្រាហ្មណ៍ម្នាក់បានចូលទៅជិតព្រះអង្គ រួចថ្វាយបង្គំព្រះអង្គដោយសេចក្តីគួរសម ហើយទូលសួរព្រះអង្គថា «ព្រះគោតមដ៏ចំរើន តើអ្វីទៅដែលជាគុណសម្បត្តិនិងគុណធម៌ចាំបាច់សម្រាប់បុគ្គលម្នាក់ ដើម្បីឱ្យក្លាយទៅជាព្រាហ្មណ៍ដ៏ពិតប្រាកដ?»។

The Enlightened One dwelt savouring the Bliss of Nibbana. Later on when He was at the foot of a Banyan Tree, a certain Brahmin approached Him, and saluting Him courteously asked Him: "O Gotama, what are the qualities and virtues necessary for a person to be a true Brahman?"

The Buddha explains the true meaning of the word 'Brahmin'.
ព្រះសម្មាសម្ពុទ្ធទ្រង់ពន្យល់អំពីអត្ថន័យពិតនៃពាក្យ "ព្រាហ្មណ៍"

ដោយមិនរវល់ចំពោះសម្ដីឥតគួរសមរបស់ព្រាហ្មណ៍ ដែលបានហៅព្រះអង្គដោយប្រើគោត្តនាម ព្រះសម្មាសម្ពុទ្ធទ្រង់ឆ្លើយតបទៅព្រាហ្មណ៍ដូច្នេះថា «ព្រាហ្មណ៍ពិតប្រាកដត្រូវតែចៀសឱ្យផុតពីអំពើបាប និងមោទនភាព ។ ព្រាហ្មណ៍ត្រូវតែជាអ្នកមើលឃើញវែងឆ្ងាយ បរិសុទ្ធ និងមានការអប់រំខ្ពស់ ។ ព្រាហ្មណ៍ត្រូវតែប្រព្រឹត្តនូវព្រហ្មចរិយាធម៌ ។ របៀបរស់នៅត្រូវតែខុសប្លែកពីការរស់នៅរបស់មនុស្សសាមញ្ញទូទៅឱ្យសមនឹងទទួលការគោរពថាជាព្រាហ្មណ៍» ។ ព្រាហ្មណ៍នោះបានថ្វាយបង្គំលាព្រះសម្មាសម្ពុទ្ធទៅវិញ ដោយនិយាយម្នាក់ឯងថា «ព្រះសមណគោតម ពិតជាអាចមើលធ្លុះដល់ចិត្តរបស់អញមែន» ។

Disregarding the discourtesy of addressing Him by the clan-name, the Englightened One replied him thus : "A true Brahmin must shun sin and pride. He must be far-sighted, pure and highly educated. He must lead a pure life. His way of life must be different from that of the ordinary folk, deserving to be addressed as Brahman". The Brahmin left Him saying to himself that "Ascetic Gotama can really see through my mind".



The merchant brothers, Tapassu and Bhalluka come to the Enlightened One.

ឈ្មួញពីរនាក់បងប្អូន តបស្សុ និងភល្លុកៈ ចូលមកថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ

ថ្ងៃមួយ ពេលដែលព្រះសម្មាសម្ពុទ្ធកំពុងសម្រាកនៅក្រោមបិប្ផលិព្រឹក្ស (ដើមល្វៀប) មានឈ្មួញពីរនាក់បានធ្វើដំណើរកាត់ទីនោះ ។ ដោយចាប់អារម្មណ៍ចំពោះភាពស្ងប់ស្ងៀមខាងផ្លូវកាយ និងផ្លូវចិត្ត ដែលព្រះអង្គបានបង្ហាញឱ្យឃើញ ពួកគេបានថ្វាយចង្ហាន់យ៉ាងឆ្ងាញ់ពិសាចំពោះព្រះសម្មាសម្ពុទ្ធដោយសេចក្តីគោរពបំផុត ។ ពួកគេបានសុំអង្វរព្រះអង្គឱ្យទទួលយកគេទាំងពីរនាក់ធ្វើជាសាវ័ក ។ ឈ្មួញទាំងពីរនាក់នោះគឺ តបស្សុ និងភល្លុកៈ ។ អ្នកទាំងពីរនាក់នោះគឺជាអ្នកបូជាចំពោះព្រះសម្មាសម្ពុទ្ធមុនគេបង្អស់ ។

One day, when the Buddha was resting under a Pipphali tree, two merchants went past that spot. Impressed by His tranquility and the inner peace He exuded, they offered the Buddha delicious food, very respectfuly. They begged the Buddha to accept them as His disciples. The two merchants were Tapassu and Bhalluka. These were the first devotees of the Buddha.

The Enlightened One decides to teach to others the Truths He has realized.
ព្រះសម្មាសម្ពុទ្ធទ្រង់សម្រេចព្រះទ័យថា នឹងបង្រៀនអ្នកដទៃអំពី សច្ចៈធម៌ ដែលព្រះអង្គត្រាស់ដឹង

ជាបឋមព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះតម្រិះថា សច្ចៈធម៌ ដែលព្រះអង្គត្រាស់ដឹងនេះ មានភាពពិបាកយល់ណាស់សម្រាប់មនុស្សភាគច្រើន ។ ប៉ុន្តែ ក្រោយមកព្រះអង្គសម្រេចព្រះទ័យថា ទ្រង់គប្បីទេសនាអំពីធម៌របស់ព្រះអង្គតាមរបៀបមួយដែលអ្នកផងទាំងឡាយអាចយល់ដឹងបាន ។

At first the Buddha thought that the Truths He realized are too difficult for most people to understand. But later on He decided that He should preach His Doctrine in a manner that could be realized by all.

The Enlightened One visits Migadaya near Benares to preach the First Sermon.
ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅកាន់ព្រៃមិគទាយៈ ជិតក្រុងពារាណសី ដើម្បីសម្ដែងបឋមទេសនា

ព្រះអង្គទ្រង់ព្រះតម្រិះទៅដល់បុគ្គលម្នាក់ដែលអាចស្ដាប់ព្រះធម៌របស់ព្រះអង្គមុនគេ ។ ព្រះអង្គនឹកឃើញទៅដល់សាស្ត្រាចារ្យដំបូងបង្អស់របស់ព្រះអង្គគឺអាចារ្យ អាឡារកាឡាម ។ រំពេចនោះ ព្រះអង្គបានដឹងថា អាឡារកាឡាមតាបសបានធ្វើមរណកាលទៅហើយ ។ សាស្ត្រាចារ្យទីពីររបស់ព្រះអង្គគឺ ឧទ្ទករាមតាបស ក៏ធ្វើមរណកាលទៅហើយដែរ ។ បន្ទាប់មក ព្រះសម្មាសម្ពុទ្ធទ្រង់បរិវិតក្កនឹកដល់បញ្ចវគ្គិយ៍ភិក្ខុ ដែលបានតាមបំរើព្រះអង្គកាលព្រះអង្គទ្រង់គង់នៅតំបន់ឧរុវេល ។ ដោយទ្រង់ជ្រាបថា បញ្ចវគ្គិយ៍ ទៅគង់នៅក្នុងព្រៃមិគទាយវ័នទៀបនគរពារាណសី ព្រះសម្មាសម្ពុទ្ធទ្រង់ក៏យាងចាកចេញពីតំបន់ឧរុវេល ដើម្បីទៅជួបបញ្ចវគ្គិយ៍ភិក្ខុនៅទីនោះ ។

He thought of a person who should hear His Doctrine first. His first Teacher, Alara-Kalama came into His mind. In a trice He knew that he was dead. His second Teacher Uddakarama too was dead by them. Next the five-fold Ascetics, who followed Him when He was at Uruvela, came into His mind. Being aware that they resided at Migadaya, near Benares, the Buddha went to see them, leaving Uruvela.

The decision of the five Ascetics at Migadaya.
សេចក្ដីសម្រេចព្រះទ័យរបស់បញ្ចវគ្គិយ៍ភិក្ខុនៅព្រៃមិគទាយវ័ន

ដោយបានឃើញព្រះសម្មាសម្ពុទ្ធពីចម្ងាយ បញ្ចវគ្គិយ៍ភិក្ខុបានធ្វើការពិគ្រោះគ្នាថា «ម្នាលគ្នាយើង ព្រះសមណគោតម កំពុងធ្វើដំណើរមកទីនេះហើយ ។ ព្រះអង្គបានបោះបង់ចោលនូវការប្រតិបត្តិតបកម្មហើយត្រឡប់ទៅឆាន់អាហារវិញ ។ ចូរពួកយើងកុំនិយាយរកព្រះអង្គពេលព្រះអង្គមកដល់ទីនេះ ។ ពួកយើងកុំថ្វាយបង្គំ និងកុំក្រោកទទួលព្រះអង្គជាភ្ញៀវរបស់យើង ។ យើងគ្រាន់តែក្រាលអាសនៈទុកប្រគេនព្រះអង្គបានហើយ ។ បើព្រះអង្គចង់អង្គុយ ឬឈរតាមព្រះទ័យរបស់ព្រះអង្គចុះ ។ តើមាននរណាចង់គួរសមចំពោះបុគ្គលដែលផ្លាស់ប្ដូរព្រះទ័យបែបនេះ?» ។

Seeing the Buddha in the distance, the five Ascetics had a discussion. "There, Ascetic Gotama is heading this way. He gave up austerities and became greedy of food. We will not talk to Him when He comes here. We will not salute Him and will not treat Him as guest. We will only give Him a seat. Let Him sit or stand as He wishes. Who wants to be courteous to a fickle person?"

The manner, the five Ascetics received the Enlightened One, when He approached them.
របៀបដែលពួកបញ្ចវគ្គិយ៍ភិក្ខុ ទទួលព្រះសម្មាសម្ពុទ្ធ ពេលព្រះអង្គយាងទៅជិតពួកគេ

នៅពេលព្រះសម្មាសម្ពុទ្ធ យាងកាន់តែជិតទៅៗ ពួកបញ្ចវគ្គិយ៍ភិក្ខុបានឃើញច្បាស់ថា ព្រះអង្គពុំមែនជាបុគ្គលដូចដែល ពួកគេបានគិតពីមុននោះទេ ។ ព្រះរាជបុគ្គលិកលក្ខណៈរបស់ព្រះអង្គគួរឱ្យចាប់អារម្មណ៍ណាស់ ព្រមទាំងមានរង្សីនៅជុំវិញព្រះកាយផង ។ ពួកបញ្ចវគ្គិយ៍ភិក្ខុ ភ្ញាក់យ៉ាងខ្លាំងចំពោះអ្វីដែលពួកគេបានឃើញ រហូតដល់ភ្លេចអស់នូវសេចក្តីសម្រេចចិត្តពីដំបូងរបស់ពួកគេ ។ ភិក្ខុខ្លះចូលទៅថ្វាយបង្គំព្រះអង្គ ខ្លះជួយទទួលបាត្រចីវរ ។ ភិក្ខុខ្លះរៀបចំអាសនៈថ្វាយព្រះអង្គ ខ្លះទៀតទៅយកទឹកមកលាងព្រះបាទព្រះអង្គ ។

As the Buddha approached nearer, the five Ascetics realized that He was not the kind of person they thought He was. His personality was impressive and He had a Halo around Him. They were so thoroughly surprised by this that they forgot their earlier decisions. Some went and saluted Him; others relieved Him of His burdens. Some prepared a seat for Him. Some brought water to wash His feet.

The Enlightened One declares to the five Ascetics at Migadaya, that He has attained Enlightenment, ridding Himself of all the Defilements.
ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសចំពោះបញ្ចវគ្គិយ៍ភិក្ខុថា ព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធ ដោយបានចាកចេញឆ្ងាយពីកិលេសហើយ

គង់លើអាសនៈដែលបានរៀបចំថ្វាយចំពោះព្រះអង្គ ព្រះសម្មាសម្ពុទ្ធទ្រង់ចាប់ផ្ដើមប្រោសប្រទានធម្មទេសនាថា «ម្នាលភិក្ខុទាំងឡាយ តថាគតបានរកឃើញនូវមាគ៌ាទៅកាន់និព្វាន ដោយប្រពៃដោយខ្លួនឯងហើយ ។ តថាគតមានបំណងនឹងអធិប្បាយអំពីសច្ចៈធម៌ដែលតថាគតបានត្រាស់ដឹងនេះ ចំពោះអ្នកទាំងឡាយ ។ ប្រសិនបើអ្នកទាំងឡាយធ្វើតាមពាក្យប្រៀនប្រដៅរបស់តថាគតនោះ អ្នកទាំងឡាយអាចនឹងដឹងច្បាស់អំពីសច្ចៈធម៌នោះនៅទីនេះ និងក្នុងគ្រាឥឡូវនេះ ។ តថាគតនឹងសម្ដែងចំពោះអ្នកទាំងឡាយ តែអំពីសច្ចៈធម៌ដែលឥតមានទាំងការកើត ទាំងការស្លាប់» ។

Taking the seat prepared for Him, the Buddha started to preach a sermon. "O Ascetics, I have discovered the unconditioned Nibbana. I want to expound this Truth to you. If you followed my advice, you will be able to realize the Truth here and now. I will preach you the only Truth that is devoid of both Birth and Death".

Preaching the First Sermon to the five Ascetics.

ការសម្តែងបឋមទេសនា ចំពោះបញ្ចវគ្គិយ៍ភិក្ខុ

ពួកបញ្ចវគ្គិយ៍ភិក្ខុ នៅមានការអល់អែកដោយសារតែព្រះសម្មាសម្ពុទ្ធទ្រង់បានបោះបង់ចោលការប្រព្រឹត្តតបកម្ម នៅពាក់កណ្តាលផ្លូវ ។ ដូច្នេះ ពួកគេមិនបានរៀបខ្លួន ដើម្បីទទួលយកព្រះធម៌របស់ព្រះពុទ្ធទេ ពួកគេបានចោទសួរទៅព្រះពុទ្ធវិញនូវសំណួរច្រើនប្រការ ។ នៅទីចុងបំផុត ព្រះសម្មាសម្ពុទ្ធ មានបន្ទូលដូច្នេះថា «ម្នាលភិក្ខុទាំងឡាយ ពេលដែលយើងរស់នៅជាមួយគ្នាក្នុងកាលកន្លងមក តើតថាគតមានដែលបាននិយាយបែបនេះចំពោះអ្នកទាំងអស់គ្នាពីមុនមកទេ? តើតថាគតមានដែលបានប៉ុនប៉ងអូសទាញ អ្នកទាំងអស់គ្នាឱ្យជឿថា តថាគតបានរកឃើញនូវអរិយសច្ចៈឬទេ?» ។ ពួកបញ្ចវគ្គិយ៍ភិក្ខុ យល់ព្រមទទួលស្គាល់ថា ពួកគេមិនដែលបានឮព្រះសម្មាសម្ពុទ្ធ មានព្រះបន្ទូលបែបនេះពីមុនមកទេ ។ ទីបំផុត ពួកគេបានប្រុងប្រៀបស្តាប់ព្រះធម៌របស់ព្រះពុទ្ធ ។

The five Ascetics were sceptic since the Buddha had given up His austerities half way. Though they were not prepared to accept His Doctrine, they asked Him many questions. At the end the Buddha said thus: "O Ascetics, when we lived together in the past, have I ever spoken to you like this earlier? Have I tried to convince you that I have discovered the Absulute Truth?", the five Ascetics granted that He had not spoken that way previously. At last they were ready to listen to the Buddha's Doctrine.

Ascetic Kondanna achieves realization after listening to the First Sermon – "Dhamma Chakka Pavattana".
ភិក្ខុកោណ្ឌញ្ញ បានត្រាស់ដឹងនូវលោកុត្តរធម៌ បន្ទាប់ពីបានស្តាប់បឋមទេសនាឈ្មោះ "ធម្មចក្កប្បវត្តន"

ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងបឋមទេសនាចំពោះបញ្ចវគ្គិយ៍ភិក្ខុ នៅក្នុងព្រៃមិគទាយវ័ន ។ បឋមទេសនានេះត្រូវបានគេពណ៌នាថាជា "ធម្មចក្កប្បវត្តនសូត្រ" ។ ក្នុងលំដាប់នៃការសម្តែងបឋមទេសនានោះ ភិក្ខុកោណ្ឌញ្ញបានត្រាស់ដឹងនូវអរិយសច្ចៈ ។ ភិក្ខុកោណ្ឌញ្ញ បានសុំផ្នួសពីព្រះសម្មាសម្ពុទ្ធ ។

ដោយហេតុនោះ លោកបានក្លាយទៅជាភិក្ខុទីមួយក្នុងពុទ្ធសាសនា ដែលពីមុនមកមិនដែលធ្លាប់មានសោះ ។ ចាប់ពីពេលនោះមក ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងព្រៃមិគទាយវ័នរហូត ។ នៅពេលភិក្ខុពីរអង្គនិមន្តទៅបិណ្ឌបាត ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានធម្មទេសនាប្រោសភិក្ខុបីអង្គផ្សេងទៀត ។ នៅពេលភិក្ខុបីអង្គនិមន្តចេញទៅខាងក្រៅ ព្រះអង្គទ្រង់ទេសនាប្រោសភិក្ខុពីរអង្គដែលនៅសល់ ។ ដោយធ្វើរបៀបនេះ ភិក្ខុទាំងអស់បានត្រាស់ដឹងយ៉ាងសុក្រឹតអំពីព្រះធម៌របស់ព្រះពុទ្ធ ។ សិល្បវិធីនេះទទួលបានជោគជ័យ ពីព្រោះព្រះពុទ្ធជាសាស្តាចារ្យដ៏ឆ្នើមបំផុត ដែលពិភពលោកទាំងមូលទទួលស្គាល់ ។ បញ្ចវគ្គិយ៍ភិក្ខុ បានប្រតិបត្តិតាមពុទ្ធោវាទដោយយកចិត្តទុកដាក់បំផុត ។ ភិក្ខុទាំងប្រាំអង្គគឺជាព្រះអរហន្តដំបូងបង្អស់នៃពិភពលោក ។ ធម្មទេសនាជាបន្ទាប់មកសម្រាប់បញ្ចវគ្គិយ៍ភិក្ខុ សម្តែងអំពី "អនត្តលក្ខណសូត្រ" ។

The Buddha preached the First Sermon to the five Ascetics at Migadaya. This first Sermon has been described as "Dhammacakkapavattana Sutta". While the first Sermon was being preached, Ascetic Kondanna, realized the Truth. He asked the Buddha to ordain him. This way he became the first-ever Buddhist Bhikkhu, in the Buddha's Dispensation. From then on He dwelt at Migadaya. When two Bhikkhus went out for alms He preached to the other three. When three went out he preached to the remaining two. This way all realized the Doctrine perfectly. This method became successful because the Buddha is the Greatest Teacher the World has known. The five Ascetics practised the Teaching assiduously Five of them were the first Arahants of the World. Next Sermon for them was "Anatta Lakkhana Sutta".



Ordaining Yasa at Migadaya.
ការបំបួស យសកុលបុត្ត នៅព្រៃមិគទាយវ័ន

នៅក្នុងពេលដែលព្រះសម្មាសម្ពុទ្ធ កំពុងគង់នៅក្នុងព្រៃមិគទាយវ័ន យស ដែលជាកូនប្រុសនៃគ្រួសារមួយដែលសម្បូរដោយទ្រព្យធន កើតមានចិត្តនឿយណាយយ៉ាងខ្លាំងចំពោះជីវិតជា ឃរាវាស ក៏បានរត់ចេញពីផ្ទះ ។ នៅតាមផ្លូវ យសកុលបុត្តបានជួបនឹងព្រះសម្មាសម្ពុទ្ធ បានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ និងមានប្រាថ្នាចង់បួសជាភិក្ខុ ។ ឪពុករបស់ យស ក៏បានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែរ ហើយចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះពុទ្ធោវាទ ទើបគាត់អនុញ្ញាតឱ្យកូនប្រុសរបស់គាត់ទទួលបព្វជ្ជាជាភិក្ខុ ។

When the Buddha was at Migadaya, Yasa the son of an affluent family became disillusioned with lay life. He ran away from home. On the way he met the Buddha, listened to Him and wanted to become a Bhikkhu. His father too listened to the Buddha and impresed with the Buddha's teaching, he allowed his son to become a Bhikkhu.

Yasa's father takes the Three-fold Refuge.

ឪពុករបស់ យសកុលបុត្ត សុំទទួលត្រៃសរណគមន៍

ឪពុករបស់ យស បានសុំយាងព្រះសម្មាសម្ពុទ្ធទៅទទួលភត្តនៅផ្ទះរបស់គាត់ ។ មិត្តសំឡាញ់ យសកុលបុត្តទាំងបួននាក់ទៀត បានទទួលបព្វជ្ជាជាភិក្ខុដែរ ។ លុះបានឮដំណឹងដូច្នេះ សំឡាញ់របស់យសកុលបុត្ត ដែលសុទ្ធតែជាកូនអ្នកមានសម្បត្តិស្តុកស្តម្ភចំនួនហាសិបនាក់ទៀត បានសុំបព្វជ្ជាជាភិក្ខុដែរ ។ មិនយូរប៉ុន្មាន ភិក្ខុទាំងនោះបានសម្រេចជាព្រះអរហន្តទាំងអស់គ្នា ។

The father, invited the Buddha to his home for alms. Four of Yasa's friends too became Bhikkhus.Hearing this, another fifty from affluent families became Bhikkhus. Before very long all of them became Arahants.

When the number of Arahants increased to sixty, they were sent out to propagate the Teaching.
នៅពេលព្រះអរហន្ត បានកើនចំនួនដល់ហុកសិបអង្គ ព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ជូនព្រះអរហន្តទាំងនោះទៅផ្សព្វផ្សាយព្រះធម៌នៅគ្រប់ទិសទី

នៅពេលព្រះសាវ័កភិក្ខុរបស់ព្រះសម្មាសម្ពុទ្ធ មានចំនួនហុកសិបអង្គហើយ ព្រះអង្គទ្រង់ត្រាស់ប្រជុំព្រះអរហន្តទាំងនោះ រួចបង្គាប់ព្រះអរហន្តទាំងនោះឱ្យនិមន្តចេញទៅធ្វើការផ្សព្វផ្សាយព្រះធម៌ ដើម្បីជាប្រយោជន៍ដល់សត្វទាំងឡាយ និងដើម្បីសង្គ្រោះសត្វទាំងពួងឱ្យបានច្រើនបំផុត ។ ព្រះអង្គណែនាំព្រះអរហន្តទាំងនោះ កុំឱ្យធ្វើដំណើរជាមួយគ្នាពីរនាក់តាមផ្លូវតែមួយ ។ ព្រះអង្គមានព្រះបន្ទូលថា ទ្រង់នឹងយាងទៅកាន់តំបន់ឧរុវេល ។

When His Bhikku disciples numbered sixty, He summoned them and instructed them to disseminate the Teaching for the good of the many and for the welfare of the many. He instructed them and said two of them should not travel together along the same road. He said that He himself was travelling to Uruvela.

Enlightened One visits the settlement of Uruvela, leading to the ordaining of a thousand persons headed by Uruvela Kasyapa.
ព្រះសម្មាសម្ពុទ្ធទ្រង់និមន្តទៅកាន់ឧរុវេលនិគម សំដៅទៅបំបួសមនុស្សមួយពាន់នាក់ ដែលដឹកនាំដោយឧរុវេលកស្សប

បន្ទាប់ពីព្រះអរហន្តទាំងហុកសិបអង្គ បាននិមន្តចាកចេញបាត់ទៅ ព្រះសម្មាសម្ពុទ្ធទ្រង់យាងឆ្ពោះទៅតំបន់ឧរុវេល ។ ព្រះអង្គទ្រង់គង់ប្រថាប់នៅនឹងកន្លែងមួយដែលមានតាបសមួយពាន់នាក់កំពុងស្នាក់អាស្រ័យ ។ អ្នកដឹកនាំរបស់ពួកគេគឺ បងប្អូនបីនាក់នៃត្រកូលកស្សបៈ ។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងនូវព្រះធម៌ដែលព្រះអង្គទើបត្រាស់ដឹង ក្នុងបំណងកំចាត់មិច្ឆាទិដ្ឋិ របស់តាបសទាំងនោះ ។ ដោយយល់ច្បាស់អំពីព្រះធម៌របស់ព្រះពុទ្ធ បងប្អូននៃត្រកូលកស្សបៈ មួយអន្លើដោយសាវ័កទាំងមួយពាន់នាក់បានសុំបព្វជ្ជាជាភិក្ខុ ។ ក្រោយមក ភិក្ខុទាំងអស់នោះបានសម្រេចជាព្រះអរហន្តទាំងអស់ ។

After the sixty Arahants left, the Buddha travelled to Uruvela. He stayed at a place where 1000 Ascetics lived. Their leaders were the three Kasyapa brothers. The Buddha preached the Truths He had recently realized, in order to dispel their misbeliefs. Realizing the Truth, the Kasyapa brothers and their one thousand followers became Bhikkus. Eventually all of them attained Arahantship.

The Enlightened One visits Rajagaha in the company of Bhikkhus to meet King Bimbisara.
ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ ដោយមានភិក្ខុទាំងឡាយនិមន្តទៅជាមួយ ដើម្បីជួបព្រះបាទពិម្ពិសារ

បន្ទាប់មក ព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើដំណើរទៅកាន់នគរមគធៈ ដើម្បីឆ្លើយតបតាមពាក្យសន្យារបស់ព្រះអង្គ ចំពោះព្រះបាទពិម្ពិសារ ។ ព្រះអង្គទ្រង់គង់នៅក្នុងព្រៃឫស្សី (ឧទ្យានវេឡុវ័ន) ។ ព្រះបាទពិម្ពិសារ និងប្រជារាស្ត្រនៃនគរមគធៈ សុទ្ធតែមានសេចក្តីប្រាថ្នា ចង់ធ្វើជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធគ្រប់គ្នា ។

Next, the Buddha visited Magadha, to fulfil His promise to King Bimbisara. He dwelt at the Bamboo Grove (Veluvana). King Bimbisara and the people of Magadha expressed their wish to become Buddha's followers.



King Bimbisara gifts Veluvanarama to the Enlightened One.
ព្រះបាទពិម្ពិសារ ទ្រង់ប្រទានវេឡុវនារាមចំពោះព្រះសម្មាសម្ពុទ្ធ

ព្រះបាទពិម្ពិសារ ទ្រង់បានសម្រេចបំណងប្រាថ្នារបស់ព្រះអង្គ ដោយបានស្តាប់ព្រះធម៌ព្រះពុទ្ធក្នុងចំណោមអ្នកស្តាប់មុនគេបង្អស់ ។ ពេលនេះ សេចក្តីប្រាថ្នារបស់ព្រះអង្គបានក្លាយជាការពិតហើយ ព្រះអង្គទ្រង់សម្រេចព្រះទ័យថ្វាយព្រះកាយជាឧបាសក ។ ព្រះបាទពិម្ពិសារ បានប្រទានឧទ្យានវេឡុវ័នចំពោះព្រះពុទ្ធ និងព្រះភិក្ខុសង្ឃ ។ ដោយហេតុនេះទើបវេឡុវ័នបានក្លាយទៅជាវត្តមុនគេបង្អស់ នៅក្នុងប្រវត្តិសាស្ត្រនៃពុទ្ធសាសនា ។

King Bimbisara attained his wish to be among the first to listen to the Buddha's Doctrine. Now that his wish became a reality he decided to be a lay devotee. King Bimbisara donated Veluvana to the Buddha and the Brotherhood (the Sangha). This way, Veluvana became the first Buddhist monastery in the history of Buddhism.

While residing at Veluvanaramaya in Rajagaha, the Enlightened One expounds the Truth to a young man, performing the ritual of worshipping six directions.

ក្នុងពេលដែលព្រះអង្គគង់ក្នុងវត្តវេឡុវនារាមនៃក្រុងរាជគ្រឹះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះធម៌ចំពោះមាណពម្នាក់ដែលគោរពបូជាដោយថ្វាយបង្គំចំពោះ ទិសទាំងប្រាំមួយ

ព្រឹកមួយនោះ នៅពេលដែលព្រះសម្មាសម្ពុទ្ធកំពុងធ្វើដំណើរឆ្ពោះទៅក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ព្រះអង្គទ្រង់ជួបមាណពម្នាក់ដែលបែកញើសទទឹកខ្លួនជោគ ហាក់បីដូចជាទើបតែងើបចេញពីក្នុងទឹកដូច្នោះ ។ ដោយឈរនៅកណ្តាលផ្លូវ គាត់ថ្វាយបង្គំទិសខាងកើត ទិសខាងត្បូង ទិសខាងលិច ទិសខាងជើងតាមលំដាប់បន្តបន្ទាប់គ្នា ។ បន្ទាប់មក គាត់ថ្វាយបង្គំទិសខាងលើ ហើយចុងក្រោយបំផុត គាត់លុតជង្គង់ចុះ រួចថ្វាយបង្គំព្រះធរណី ។ បន្ទាប់មកទៀត គាត់បាចគ្រាប់ធញ្ញជាតិទៅគ្រប់ទិសដែលគាត់បានថ្វាយបង្គំ ។

One morning while the Buddha was on His way to the city of Rajagaha for alms, He met a young man who was drenched, as if he had emerged from an immersion in the water. Standing in the middle of the road, he worshipped the East, the South, the West and the North, respectively. Next he worshipped the sky. Lastly he knelt down and worshipped the earth. Next he scattered grains in the directions he worshipped.

The Buddha explains the significance of the six directions.
ព្រះសម្មាសម្ពុទ្ធទ្រង់ពន្យល់អំពីអត្ថន័យនៃទិសទាំងប្រាំមួយ

ដោយទ្រង់សង្កេតមើលការគោរពបូជារបស់មាណពប្រកបដោយការចង់ដឹង ព្រះសម្មាសម្ពុទ្ធទ្រង់សួរទៅមាណពនោះថា ហេតុអ្វីបានជាគាត់ធ្វើដូច្នេះ ។ មាណពនោះឆ្លើយតបថា គាត់ធ្វើតាមដំបូន្មានរបស់ឪពុកគាត់ ហើយថាតាមរយៈការគោរពបូជានេះ គាត់អាចបំបែរមហន្តរាយផងទាំងពួងឱ្យងាកចេញពីទិសទាំងនេះ ។ ដោយទ្រង់ព្រះសណ្ដាប់ឮដូច្នោះ ព្រះសម្មាសម្ពុទ្ធទ្រង់មានបន្ទូលទៅកាន់មាណពនោះដូច្នេះថា «វាជាប្រការប្រពៃហើយចំពោះអ្នក ដែលបានគោរពយ៉ាងហ្មត់ចត់តាមពាក្យទូន្មានរបស់សពឪពុកអ្នក តែការអនុវត្តន៍ដែលឪពុកអ្នកនឹកសង្ឃឹមចង់ឱ្យអ្នកប្រតិបត្តិ និងការបូជារបស់អ្នក វាមានភាពផ្ទុយគ្នា» ។

Observing his rituals with curiosity, the Buddha asked him why he did that. The youth replied that he was following the dying advice of his father and that through this ritual he could avert disasters from all those directions. Hearing this the Buddha spoke thus to the youth. "It is good of you scrupulously to follow your father's dying advice; the practices your father expected you to perform and your rituals are contradictory.



He explains in detail the worshipping of the six directions.
ព្រះសម្មាសម្ពុទ្ធទ្រង់ពន្យល់ដោយលំអិតអំពីការថ្វាយបង្គំទិសទាំងប្រាំមួយ

«ឪពុករបស់អ្នកទូន្មានឱ្យអ្នកគោរពបូជាទិសខាងកើត និងបាចគ្រប់ធញ្ញជាតិ អត្ថន័យពិតរបស់វាគឺ អ្នកគប្បីគោរពប្រណិប័តន៍ឪពុកម្តាយអ្នក និងជនទាំងឡាយណាដែលបានជួយសង្គ្រោះអ្នក និងបង្ហាញសេចក្តីមេត្តាដល់អ្នក ។ គោរពទិសខាងត្បូង មានន័យថា គោរពគ្រូបាធ្យាយ ។ គោរពទិសខាងលិច បានន័យថា ត្រូវយកចិត្តទុកដាក់ថែទាំបុត្រ ភរិយាអ្នក ។ គោរពទិសខាងជើង មានន័យថា ត្រូវសម្តែងសេចក្តីគោរពរាប់អានចំពោះមិត្តភ័ក្ត និងញាតិសន្តាន ។ គោរពទិសខាងលើ មានន័យថាគោរពសមណព្រាហ្មណាចារ្យ» ។

"Your father advised you to worship the East and scatter grains, it truly means that you should respect your parents and those who helped you and showed you compassion. South means respect to Teachers. West implies, protecting your wife and children carefully. Respecting North means showing deference to friends and relatives. Worshipping the sky means respecting religious teachers.

Teaches the Five Precepts to Householder Sigala

ព្រះសម្មាសម្ពុទ្ធទ្រង់បង្រៀនសីលប្រាំ ចំពោះសិង្គាល ដែលជាឃរាវាស

«គោរពទិសខាងក្រោម មានន័យថា អ្នកគប្បីគោរពរាប់អានអ្នកតូចតាច និងសព្វសត្វទាំងឡាយ រាប់ទាំងសត្វល្អិតតូចៗផង ។ ឪពុករបស់អ្នកបាន ទូន្មានអ្នកដូច្នេះ ពីព្រោះដោយគោរពបូជាចំពោះទិសទាំងឡាយតាមរបៀបនេះ គ្រោះកាចចង្រៃពីគ្រប់ទិសទីពុំកើតមានដល់អ្នកឡើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រទានឱវាទដល់សិង្គាលមាណព អំពីព្រះធម៌របស់ព្រះអង្គផងដែរ ។

"Worshipping the earth implies that you should respect animals and insects as well. Your father has instructed you this way, because by worshipping the directions in this manner no harm will come to you from any direction. Buddha advised Singala the youth in terms of His own teachings as well.

The Enlightened One explains to Sigala how He should use His wealth dividing it into four portions.
ព្រះសម្មាសម្ពុទ្ធទ្រង់ពន្យល់សិង្គាលមាណព អំពីរបៀបប្រើប្រាស់ទ្រព្យធនរបស់ខ្លួន ដោយបែងចែកជាបួនចំណែក

បន្ទាប់មកព្រះអង្គទ្រង់ក្រើនរំលឹកចៅមាណពឱ្យប្រកបរបររកទ្រព្យសម្បត្តិ ដោយសុចរិតទៀងត្រង់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់សុំឱ្យគាត់បែងចែកទ្រព្យសម្បត្តិជាបួនចំណែក ។ មួយចំណែកសម្រាប់ទុកចាយ ប្រើប្រាស់ចិញ្ចឹមជីវិត ពីរចំណែកទុកសម្រាប់ធ្វើដើមទុនប្រកបរបរជំនួញជួញដូរ ។ ចំណែកទីបួនគប្បីសន្សំទុកការពារក្នុងវេលាមានអាសន្នអន្តរាយទៅថ្ងៃមុខ ។ សិង្គាលមាណព បានក្លាយទៅជាឧបាសកក្នុងពុទ្ធសាសនា ។ ចាប់តាំងពីពេលនោះមក សិង្គាលមាណព ក៏គោរពបូជាទិសទាំងប្រាំមួយទៅតាមការណែនាំរបស់ព្រះសម្មាសម្ពុទ្ធ វិញ ។

Next He advised the youth to earn wealth righteously. The Buddha asked him to divide the wealth into four parts. One part for consumption, two parts for investment in trade and commerce. The fourth part should be saved against future mishasps. Sigala became a lay devotee. From then on he worshipped the six directions in terms of the Buddha's advice.

Kolitha and Upatissa reside at the hermitage of Sage Sanjaya.
កោលិត និងឧបតិស្ស: អាស្រ័យនៅក្នុងសំណាក់នៃមុនីតាបស សញ្ជ័យ

ពេលព្រះសម្មាសម្ពុទ្ធគង់នៅក្នុងក្រុងរាជគ្រឹះ មានអាចារ្យខាងពាហិរសាសនាដ៏ល្បីល្បាញម្នាក់ឈ្មោះ សញ្ជ័យ ពេលដ្ឋិបុត្ត រស់នៅក្នុងតំបន់នោះ ។ នៅក្នុងចំណោមសាវ័កពីររយនាក់របស់គាត់មានពីរនាក់មានចំណេះវិជ្ជាជ្រៅជ្រះជាងគេគឺ កោលិតនិងឧបតិស្ស: ។ ដោយមិនពេញចិត្តចំពោះលិទ្ធិរបស់អាចារ្យខ្លួន អ្នកទាំងពីរនោះ បាននាំគ្នាស្វែងរកនូវទស្សនវិជ្ជាដ៏ជ្រាលជ្រៅមួយ ដែលអាចកំចាត់បង់ទាំងការកើត ទាំងការស្លាប់ ។ អ្នកទាំងពីរនោះបានប្ដេជ្ញានឹងគ្នាថា «ប្រសិនបើនរណាម្នាក់ក្នុងចំណោមពីរនាក់នេះ រកឃើញនូវអមតធម៌មុន អ្នកនោះគប្បីប្រាប់ដល់ម្នាក់ទៀត» ។ អ្នកទាំងពីរក៏បានចេញដំណើរស្វែងរកអមតធម៌តែរៀងខ្លួន ។

When the Buddha dwelt at Rajagaha, a very well-known pagan Teacher named Sanjaya Bellatthiputta, lived in that region. Of his two-hundred disciples, the most erudite were Kolitha and Upatissa. Dissatisfied with the Doctrine of their Teacher, these two were on a quest for a deep philosophy that could eradicate both birth and death. They entered into a compact "If one of the two realized the Truth, he should keep the other informed of it". They embarked upon a quest for Truth.

Upatissa meets Venerable Assaji at Rajagaha.
ឧបតិស្សៈបានជួបព្រះអស្សជិភិក្ខុ នៅក្រុងរាជគ្រឹះ

នាព្រឹកមួយនោះ ក្នុងពេលដែលឧបតិស្សៈកំពុងធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ គាត់ភ្ញាក់និងមានអារម្មណ៍យ៉ាងរីករាយដោយបានឃើញសមណមួយអង្គប្រកបដោយឥរិយាបថស្ងប់ស្ងៀមរម្យទមគួរជាទីជ្រះថ្លា ។ ឧបតិស្សៈគិតថា «ជាការពិតណាស់ ភិក្ខុនេះប្រាកដជាបានសម្រេចនូវសច្ចៈធម៌ដែលយើងកំពុងស្វែងរកហើយ ។ ឬពុំនោះទេ ភិក្ខុនេះអាចជាសាវ័ករបស់នរណាម្នាក់ដែលបានត្រាស់ដឹងហើយ ។ អាត្មាអញនឹងធ្វើដំណើរទៅតាមគាត់ និងរៀនសូត្រអំពីអរិយសច្ចៈ ។ អាត្មាអញនឹងរកឱ្យឃើញ តើនរណាទៅជាគ្រូអាចារ្យរបស់គាត់ ។

One morning when Upatissa was on his way to Rajagaha, he was pleasantly surprised to see an Ascetic of exceedingly tranquil demeanour. Upatissa thought thus: "It is quite certain that this Ascetic has already attained the Absolute Truth we are seeking. Or else he must be the disciple of someone who has realized the Truth. I will follow him and learn the Absolute Truth. I will also find who his Teacher is."

Upataissa is impressed by Venerable Assaji's demeanour.
ឧបតិស្សៈ ចាប់អារម្មណ៍ចំពោះឥរិយាបថរម្យទមរបស់ភិក្ខុអស្សជិ

ឧបតិស្សៈ បានរង់ចាំរហូតដល់ពេលព្រះភិក្ខុអស្សជិ បិណ្ឌបាតចប់សព្វគ្រប់ ទើបគាត់ចូលទៅជិតសម្តែងសេចក្តីត្រេតអរីករាយ ល្មមឱ្យកើតសេចក្តីស្និទ្ធស្នាលដោយគោរពនិងគួរសមថា «បពិត្រ លោកដ៏មានអាយុ លោកម្ចាស់មានឥន្ទ្រីយ៍ស្ងប់ ស្ងៀមស្ងាត់ និងស្រស់បស់រម្យទមណាស់ ។ ខ្ញុំព្រះករុណាចង់ដឹងថា តើនរណាទៅជាគ្រូរបស់លោកម្ចាស់ តើធម៌របស់គ្រូលោកម្ចាស់សម្តែងដូចម្តេច?» ។

Upatissa waited until the Ascetic had completed his alms round and addressed him with deference and courtesy: "Noble One, you are so calm, tranquil and subdued. I like to know who your Teacher is and the Doctrine he teaches".



Upatissa talks to Venerable Assaji.
ឧបតិស្សៈ និយាយជាមួយព្រះភិក្ខុអស្សជិ

ព្រះភិក្ខុអស្សជិ ឆ្លើយតបទៅវិញថា «ម្នាលអាវុសោ ខ្ញុំនឹងនិយាយប្រាប់អ្នកអំពីមហាសមណមួយអង្គនៃត្រកូលសក្យៈ ដែលបានលះបង់ចាកចោលព្រះរាជាណាចក្ររបស់ខ្លួន ហើយទ្រង់សាងផ្នួស ។ ព្រះអង្គជាព្រះពុទ្ធ ។ ខ្ញុំឯងនេះបានលះបង់ជីវភាពជាគ្រហស្ថ ដើម្បីបួសជាសាវ័ករបស់ព្រះមហាសមណនោះ» ។ ឧបតិស្សៈបង្ហាញឱ្យជឿបានថា គាត់និងកោលិតប្រហែលជាអាចរកឃើញនូវសម្មាសម្ពោធិញ្ញាណបានតាមរយៈសាស្តាចារ្យនេះ ហើយជជីកសួរថា «តើអ្វីទៅជាព្រះធម៌របស់ព្រះពុទ្ធនោះ ។ ខ្ញុំចង់ដឹងអំពីព្រះធម៌នោះ» ។

The Ascetic replied: "I will tell you about the great Ascetic of the Sakya Clan, who renounced His Kingdom and became an Ascetic. He is the Buddha. I gave up lay life to become His disciple". Upatissa, convinced that he and Kolitha might be able to realize the Truth through this Teacher, enquired; "What is the Teaching of The Buddha? I like to know this".



Venerable Assaji recites a stanza and explains its significance to Upatissa.
ព្រះភិក្ខុអស្សជិ សូត្រគាថាមួយ និងពន្យល់ន័យរបស់គាថានោះ ចំពោះឧបតិស្សៈ

ព្រះភិក្ខុមានដីកាថា «អាត្មាខ្លួនឯងនេះជាភិក្ខុថ្មីទើបនឹងបួស ។ អាត្មាមិនទាន់បានរៀនសូត្រឱ្យបានជ្រៅជ្រះអំពីពុទ្ធវចនៈនៅឡើយទេ ដូច្នេះអាត្មាមិនអាចសម្តែងធម៌ឱ្យពិស្តារបានទេ តែអាត្មាគ្រាន់តែអាចពោលឱ្យអ្នកស្តាប់នូវសារៈរបស់ព្រះធម៌នេះ»។ ឧបតិស្សៈទូលតបវិញថា «សូមលោកម្ចាស់សម្តែងមកចុះ ខ្ញុំយល់ព្រមចាំស្តាប់» ។ ព្រះភិក្ខុបានពោលថា «ធម៌ទាំងឡាយ កើតឡើងអំពីហេតុ ទ្រុឌទ្រោមរលត់ទៅវិញ ក៏ព្រោះហេតុដែរ ។ នេះគឺជាវចនៈរបស់ព្រះសម្មាសម្ពុទ្ធ» ។

The Ascetic said: "I am only very recently ordained. I have not learnt the Buddha's Doctrine extensively, yet. I cannot fully expound His Doctrine. But, I will give you just its esence". "I will settle for that", Upatissa replied. The Ascetic said: "All phenomena arise from cause and effect; everything deteriorates too, due to cause and effect. That is the word of the Buddha".

Venerable Assaji advises Upatissa to visit the Buddha.
ព្រះភិក្ខុអស្សជិ ណែនាំឧបតិស្សៈ ឱ្យទៅជួបព្រះសម្មាសម្ពុទ្ធ

ក្នុងពេលដែលឧបតិស្សៈ បានស្តាប់សេចក្តីរ៉ាយរ៉ាប់អំពីព្រះធម៌នេះនៅត្រង់ខ្លោងទ្វារចូលទីក្រុងហើយ ដួងចិត្តរបស់គាត់ក៏ភ្លឺស្វាងភ្លាម ។ «ធម៌ទាំងឡាយដែលកើតមានក៏ព្រោះតែមានហេតុ ហើយវិនាសទៅវិញក៏ព្រោះមានហេតុ ។ ប្រសិនបើវត្ថុណាមួយកើតឡើងដោយគ្មានហេតុ វត្ថុនោះនឹងពុំមានសេចក្តីស្លាប់ទេ» ។ ឧបតិស្សៈមាណពនិយាយទៅកាន់ព្រះភិក្ខុថា «ប្រសិនបើលោកម្ចាស់ពិតជាបានទទួលព្រះធម៌នេះពីគ្រូរបស់លោកម្ចាស់មែននោះ លោកម្ចាស់ប្រាកដជាមិនខ្លាចសេចក្តីស្លាប់ទេ» ។ មាណពបានថ្លែងអំណរគុណចំពោះព្រះភិក្ខុ រួចទូលសួរអំពីទីកន្លែងដែលគាត់អាចទៅជួបព្រះសម្មាសម្ពុទ្ធបាន ។ បានទទួលដំណឹងនេះហើយ គាត់ក៏ធ្វើដំណើរទៅជួបកោលិត ដែលជាសម្លាញ់របស់គាត់ភ្លាម ។

The moment Upatissa heard this at the city-gate his mind was illuminated. "All phenomena that arise due to cause, get destroyed. If something were to arise without a cause it will be bereft of death". Upatissa addressed the Ascetic: "If you really received such a Doctrine from your Teacher you are truly unfrightened of Death". He thanked the Ascetic and asked where the Buddha can be met. Learning this he went in search of his friend Kolitha.

Upataissa narrates this incident to his friend Kolitha.
ឧបតិស្ស: និយាយរៀបរាប់អំពីព្រឹត្តិការណ៍នោះប្រាប់សម្លាញ់របស់គាត់ឈ្មោះ កោលិត

សេចក្ដីសុខដ៏ជ្រាលជ្រៅបានធ្វើឱ្យមុខមាត់របស់ឧបតិស្សៈរីករាយស្រស់ស្រាយចិញ្ចាចចិញ្ចែង ។ សម្លាញ់របស់គាត់ឈ្មោះកោលិតបានដឹងពីចម្ងាយថា សម្លាញ់របស់គាត់បានរកឃើញនូវអរិយសច្ចៈធម៌ហើយ ។ គាត់បានសួរទៅឧបតិស្សៈថា «ទឹកមុខប្រកបដោយរស្មីចិញ្ចែងរបស់សម្លាញ់ឯងបញ្ជាក់យ៉ាងប្រត្យក្សថា សម្លាញ់ឯងបានរកឃើញអមតធម៌ ដែលយើងកំពុងស្វែងរកហើយមែនទេ? ។ តើសម្លាញ់មិនមែនបានដឹងអំពីធម៌ ដែលនាំទៅរកជ័យជំនះលើជីវិត និងសេចក្ដីស្លាប់ទេឬ?» ។

ឧបតិស្សៈតបទៅវិញថា «ប្រាកដហើយសម្លាញ់ ខ្ញុំបានដឹងច្បាស់អំពីនិព្វានហើយ» ។ ឧបតិស្សៈបានពន្យល់កោលិតអំពីរឿងដែលគាត់បានជួបភិក្ខុអស្សជិ និងអំពីព្រះធម៌ដែលភិក្ខុនោះបង្រៀនគាត់ ។

Bliss illuminated Upatissa's face. His friend Kolitha realized in the distance itself that his friend has discovered the Absolute Truth. He asked Upatissa: "It is quite evident from the glow suffusing your face, that you have realized the Truth we were looking for. Have you not learnt the Doctrine that can overcome life and death? "Yes, my friend I have already realized Nibbana", Upatissa replied. He explained to Kolitha his meeting with the strange Ascetic and the Doctrine he taught.



Upatissa and Kolitha visit the Buddha.

ឧបតិស្សៈ និងកោលិត ចូលទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ

នៅក្នុងពេលដ៏ខ្លីនោះដែរ កោលិតក៏បានដឹងច្បាស់នូវអមតធម៌ ។ គាត់បានដឹងច្បាស់ថា អ្វីៗទាំងឡាយដែលនៅក្នុងលោកសុទ្ធតែកើតឡើងដោយហេតុ និងបច្ច័យ គ្មានអ្វីដែលគ្មានហេតុ និងបច្ច័យអាចកើតមាននៅក្នុងលោកនោះទេ ។ គាត់យល់ដែរថា អ្វីៗដែលពុំមានហេតុ និងបច្ច័យ ពុំអាចកើតឡើង ឬវិនាសទៅវិញទេ ។ បុរសទាំងពីរនាក់បានធ្វើដំណើរទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ។ ទាំងពីរនាក់បានទទួលផ្នួសពីព្រះពុទ្ធ និងសម្រេចជាព្រះអរហន្ត ។ ភិក្ខុទាំងពីរព្រះអង្គនោះ បានក្លាយទៅជាប្រធាននៃពុទ្ធសាវ័កទាំងឡាយ ។ ភិក្ខុទាំងពីរអង្គនេះ មានកិត្តិនាមល្បីល្បាញពាសពេញផ្ទៃប្រទេសឥណ្ឌា ដោយសារតែពលានុភាពខាងប្រាជ្ញាញាណ និងទិព្វញ្ញាណរបស់ព្រះអង្គ ។ ក្នុងនាមជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ព្រះភិក្ខុទាំងពីរអង្គនេះត្រូវបានគេស្គាល់ថាជាសារីបុត្តនិងមោគ្គល្លាន ។ ភិក្ខុទាំងពីរអង្គនេះ បានរៀនអំពីខ្លឹមសារនៃព្រះពុទ្ធសាសនាពីព្រះភិក្ខុអស្សជិ ។

In a trice Kolitha too realized the Truth. He realized that the unconditioned could not exist with worldly things. He also understood that the unconditioned cannot be created or destroyed. The two of them went to meet the Buddha. They were ordained and became Arahants. The two of them became the Buddha's Chief Disciples. They became known throughout the length and breadth of India, for their wisdom and psychic powers. As Buddha's Disciples they came to be known as Sariputta and Mogallana. They were taught the essence of Buddhism by Venerable Assaji.

At Veluvanarama in Rajagaha the Enlightened One deploys about 1250 Arahants, assigning them to preach the Teachings in various areas.
នៅឯវត្តវេឡុវនារាមក្រុងរាជគ្រឹះ ព្រះសម្មាសម្ពុទ្ធទ្រង់បានចាត់បញ្ជូនព្រះអរហន្តចំនួន១២៥០អង្គឱ្យចេញទៅទេសនាផ្សព្វផ្សាយពុទ្ធវចនៈនៅតំបន់ផ្សេងៗ

នៅក្នុងថ្ងៃពេញបូរមីមួយនោះ ព្រះឯហិភិក្ខុទាំង១២៥០អង្គ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ជូនឱ្យទៅផ្សព្វផ្សាយព្រះធម៌នៅទីផ្សេងៗ បានត្រឡប់មកជួបជុំគ្នាវិញ នៅក្នុងវេឡុវនារាមនាក្រុងរាជគ្រឹះ ។ ក្នុងពេលនោះ ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅទីនោះដែរ ។ សង្ឃសន្និបាតនាពេលនោះ មានសារសំខាន់ដ៏ពិសេសមួយ ពីព្រោះថានោះគឺជាលើកទីមួយហើយដែលឯហិភិក្ខុទាំងអស់នោះ បានមកប្រជុំគ្នា និងដោយសារឯហិភិក្ខុទាំងនោះនិមន្តមក ដើម្បីធ្វើសេចក្តីរាយការណ៍ថ្វាយព្រះសម្មាសម្ពុទ្ធអំពីលទ្ធផលនៃកិច្ចការធម្មទូតរបស់ខ្លួនផងដែរ ។ ព្រះសម្មាសម្ពុទ្ធ និងព្រះសាវ័កទាំងអស់ទ្រង់មានព្រះហឫទ័យរីករាយណាស់ចំពោះសន្និបាតនេះ ។

On a certain Fullmoon day 1250 Bhikkhus who had been spreading the teaching in various places, returned to Veluvanarama in the city of Rajagaha. The Buddha dwelt there at that time. This assembly had a special significance, since this was the first time these Bhikkhus came together and also because they had come to report to the Buddha the results of their missionary work. The Buddha and the Disciples were pleased about it.

At Veluvanaramaya, the Enlightened One instructs the Bhikkhus in the techniques of preaching the Dhamma.
នៅក្នុងវេឡុវនារាម ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានឱវាទដល់ព្រះភិក្ខុទាំងឡាយអំពីបច្ចេកទេសក្នុងការទេសនាផ្សព្វផ្សាយព្រះធម៌

ព្រះសម្មាសម្ពុទ្ធ ទ្រង់យល់ច្បាស់ថានេះជាឱកាសដ៏ប្រពៃណាស់សម្រាប់ធ្វើការណែនាំសាវ័ករបស់ព្រះអង្គ ។ ព្រះអង្គទ្រង់បាននិមន្តឯហិភិក្ខុទាំងអស់ឱ្យមកជួបជុំគ្នានៅក្នុងវត្តវេឡុវនារាម ហើយទ្រង់ទូន្មានភិក្ខុទាំងអស់នោះឱ្យប្រព្រឹត្តខ្លួនឱ្យបានល្អតាមការណែនាំដូចតទៅនេះ : មួយគឺ ចៀសវាងកុំប្រព្រឹត្តអំពើបាបផងទាំងពួង ។ ពីរគឺ ធ្វើតែអំពើណាដែលជាកុសល ។ បីគឺ ជម្រះចិត្តឱ្យបរិសុទ្ធប្រាសចាកនូវគ្រឿងសៅហ្មង គឺកិលេសផងទាំងឡាយ ។ មហាសន្និបាតនៃឯហិភិក្ខុនាពេលនោះប្រកបដោយលក្ខណៈគួរចងចាំ៤យ៉ាង ។

The Buddha realized that this was the most opportune time to advise His disciples. He got them to assemble at Veluvanarama and advised them to conduct themselves in terms of the following guidelines: 1. Eschew all sinful activities. 2. Perform all the meritorious activities. 3. Cleanse the mind of defilements. This assembly of the Bhikkus bears four memorable characteristics.

The Enlightened One instructs all the Bhikkhus to preach the Patimokkha – The Code of Ethics.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានឱវាទដល់ព្រះភិក្ខុទាំងអស់ ឱ្យបង្រៀននូវឱវាទបាតិមោក្ខ (គោលចរិយាធម៌)

១- ភិក្ខុទាំងអស់ដែលបាននិមន្តមកប្រជុំគ្នាក្នុងពេលនេះ សុទ្ធតែជាព្រះអរហន្ត ។ ២- ព្រះអរហន្តទាំងអស់នោះ សុទ្ធតែបំបួសដោយព្រះសម្មាសម្ពុទ្ធផ្ទាល់ ។ ៣- ពុំមានការកំណត់ជាមុន ចំពោះព្រះអរហន្តទាំង១២៥០អង្គ ថាឱ្យមកប្រជុំគ្នាក្នុងថ្ងៃនោះទេ ។ ៤- ថ្ងៃនោះត្រូវបានចាត់ទុកថា ជាទិវានៃឱវាទសន្និបាតដំបូងបង្អស់ដែលបានធ្វើឡើង សម្រាប់ព្រះពុទ្ធសាវ័ក ។ ដើម្បីរំលឹកដល់លក្ខណៈពិសេសទាំង៤នេះ រៀងរាល់ថ្ងៃពេញបូរមី ខែមាឃ រាល់ឆ្នាំ ត្រូវបានគេកំណត់ដោយឡែកថាជាថ្ងៃសម្រាប់បូជាចំពោះព្រះធម៌តាំងពីថ្ងៃនោះរហូតមក ។

1. All those who assembled there were Arahants. 2. All these disciples were ordained by the Buddha Himself. 3. No earlier arrangement had been made for these 1250 Arahants to assemble there that day. 4. This day came to be known as the day of the First Advisory Assembly held for the Buddha's disciples. To commemorate these four outstanding characteristics, from that day on, the third full-moon day of each year is set aside as the day of deference for the Dhamma.

King Suddhodana sends a Minister as emissary to request the Buddha to visit Kapilavastu.
ព្រះបាទសុទ្ធោទនៈ ទ្រង់បានបញ្ជូនអាមាត្យម្នាក់ជាទូតឱ្យទៅសុំយាងព្រះសម្មាសម្ពុទ្ធឱ្យនិមន្តមកនគរកបិលពស្តុ

ព្រះបាទសុទ្ធោទនៈ ទ្រង់ជ្រាបថាព្រះរាជបុត្ររបស់ព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធហើយ ហើយកំពុងគង់នៅឯក្រុងរាជគ្រឹះ ទ្រង់ក៏ចាត់បញ្ជូនសារសុំយាងតាមរយៈអាមាត្យកាឡុទ័យ ដែលជាមិត្តសម្លាញ់របស់ព្រះអង្គម្ចាស់សិទ្ធត្ថកាលពីកុមារភាព ដើម្បីសុំឱ្យព្រះសម្មាសម្ពុទ្ធយាងទៅកាន់នគរកបិលពស្តុ ។ ព្រះបាទសុទ្ធោទនៈ មានព្រះហឫទ័យចង់ឃើញព្រះសម្មាសម្ពុទ្ធខ្លាំងណាស់ មុនពេលព្រះអង្គចូលទិវង្គត ។

នៅពេលដែលឱកាសល្អសម្រាប់ព្រះសម្មាសម្ពុទ្ធ ដើម្បីបំពេញបំណងប្រាថ្នារបស់ព្រះបិតាព្រះអង្គបានមកដល់ ព្រះអង្គក៏ទ្រង់យាងទៅនគរកបិលពស្តុជាមួយនឹងសាវ័ករបស់ព្រះអង្គ ។

King Suddhodhana, learning that his Son has attained Enlightenment and is dwelling at Rajagaha sent out an invitation through Minister Kaludai – a childhood friend of Prince Siddhartha, requesting the Buddha to visit Kapilavastu. King Suddodhana was keen to see the Buddha, before his death.

When time was ripe for the Buddha to fulfil the wishes of His father, He visited Kapilavastu with His Disciples.

The Buddha visits Nyagrodharama in Kapilavastu, with a retinue of Arahants.
ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងចូលទៅកាន់និគ្រោធារាមមួយអន្លើដោយមានព្រះអរហន្តតាមហែហម

ព្រះសម្មាសម្ពុទ្ធ និងព្រះសាវ័កបាននិមន្តទៅដល់នគរកបិលពស្តុនៅពេលល្ងាច ទ្រង់គង់ប្រថាប់នៅក្នុងកន្លែងដែលព្រះបាទសុទ្ធោទនៈ ទ្រង់បានរៀបចំទុកនៅក្នុងនិគ្រោធារាម ដែលនៅខាងក្រៅក្រុង ។ នៅព្រឹកថ្ងៃបន្ទាប់មក ព្រះសម្មាសម្ពុទ្ធ និងព្រះសាវ័កទ្រង់បាននិមន្តបិណ្ឌបាតជាប្រក្រតីតាមទម្លាប់របស់ព្រះអង្គ ។ នៅពេលដែលព្រះបាទសុទ្ធោទនៈ ទ្រង់ជ្រាបថាព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅបិណ្ឌបាតពីប្រជារាស្ត្ររបស់ព្រះអង្គ ព្រះអង្គទ្រង់ភ្ញាក់ព្រះហឫទ័យ និងអាម៉ាសព្រះភក្ត្រខ្លាំងណាស់ ។

The Buddha and His disciples arrived in Kapilavastu in the evening and stayed at the places arranged by King Suddhodhana at Nigrodarama, outside the City. The next morning the Buddha and His Disciples, went out on their alms round as was their usual habit. When the King heard that the Buddha was going round begging alms from his subjects, he was surprised and ashamed.

The Enlightened One goes on the Alms round with His disciples in the City of Kapilavastu.
ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងបិណ្ឌបាតជាមួយសាវ័ករបស់ព្រះអង្គ នៅក្នុងក្រុងកបិលពស្ដុ

ព្រះរាជាទ្រង់ត្រាស់ឱ្យនាយសារថីរបស់ព្រះអង្គបរព្រះរាជរថនាំព្រះអង្គទៅរកវិថី ដែលព្រះសម្មាសម្ពុទ្ធកំពុងនិមន្តបិណ្ឌបាត ។ បាត្ររបស់ព្រះសម្មាសម្ពុទ្ធ និងបាត្ររបស់សាវ័កពេញពោរទៅដោយភោជនាហារ ។ វាពុំមានអ្វីសំខាន់សោះ ប៉ុន្តែជារឿងធម្មតាទេដែលព្រះរាជាទ្រង់អាម៉ាស ព្រោះព្រះសម្មាសម្ពុទ្ធ ជារជ្ជទាយាទនៃព្រះរាជាណាចក្រ គួរអីមកសុំអាហារពីប្រជារាស្ត្ររបស់ខ្លួនយ៉ាងនេះ ។

The King got his charioteer to drive him to the street where the Buddha was begging alms. The begging bowls of the Buddha and His Disciples were full. It is nothing but natural that the King felt ashamed that the Buddha – The Crown Prince of the Kingdom, should beg for food from his own people.

King Suddhodhana finds fault with the Buddha for begging Alms in the City of Kapilavastu.
ព្រះបាទសុទ្ធោទនៈ ទ្រង់បន្ទោសព្រះសម្មាសម្ពុទ្ធ ដែលបានយាងបិណ្ឌបាតនៅក្នុងទីក្រុងនៃនគរកបិលពស្តុ

ព្រះបាទសុទ្ធោទនៈ ទ្រង់បានបន្ទោសព្រះសម្មាសម្ពុទ្ធថា «បុត្តបិតា អំពើរបស់បុត្ត គឺជាការបង្អាប់បង្អោនរាជត្រកូល ។ ព្រះអង្គទ្រង់ធ្វើឱ្យរាជត្រកូលអាម៉ាសមុខយ៉ាងខ្លាំងក៏សឹងថាបាន ។ តើព្រះរាជវង្សរបស់ព្រះអង្គមានដែលបានប្រព្រឹត្តដូច្នោះទេ? តើយើងមានដែលសុំទានចំណីអាហារគេ ដូចស្មូមយាចកយ៉ាងនេះទេ?» ។

The King found fault with the Buddha for this. "My Son, your Act is a shame. You have done the greatest possible insult to the Royal Family. Have Your ancestors done anything like this? Have we ever asked for food like beggars?".

The Buddha informs the King that begging for Alms is a tradition of His Dynasty.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ទូលតបទៅព្រះរាជាថា ការបិណ្ឌបាតជាប្រពៃណីនៃរាជវង្សរបស់ព្រះអង្គ

ព្រះសម្មាសម្ពុទ្ធ ទ្រង់មានពុទ្ធដីកាតបទៅព្រះរាជា ជាព្រះរាជបិតា ដែលទ្រង់មិនទាន់បានដឹងអំពីព្រះពុទ្ធវចនៈថា «មហារាជ តថាគតប្រព្រឹត្តយ៉ាងដូច្នេះ គឺធ្វើតាមប្រពៃណីរបស់វង្សនៃតថាគត» ។ ព្រះរាជាតបទៅវិញថា «នរណាក៏ដឹងដែរថា រាជវង្សរបស់ព្រះអង្គ គឺជាមហាក្សត្រ ហើយពុំដែលមានព្រះមហាក្សត្រអង្គណាប្រព្រឹត្តអំពើដ៏ឥតអៀនខ្មាសយ៉ាងនេះទេ» ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ពន្យល់រឿងនេះដោយព្រះហឫទ័យស្ងប់ថា «បពិត្រព្រះវរបិតា អ្វីដែលព្រះអង្គមានបន្ទូលនោះជាការពិតហើយ ។ ប៉ុន្តែ តថាគតមិនបានពោលអំពីរាជវង្សលោកិយរបស់តថាគតទេ» ។

Addressing the King His father, who did not have any idea of the Buddha's status, The Enlightened One said: "I have done this in terms of the tradition of my ancestors". The King replied: "Everybody knows that all Your ancestors were Kings and that none of them did anything so shameless". The Buddha explained matters calmly: "Father what you said is true. But, I am not talking about my worldly ancestors.

King Suddhodhana offers Alms to the Buddha and His Disciples.
ព្រះបាទសុទ្ធោទនៈ ទ្រង់ថ្វាយចង្ហាន់បិណ្ឌបាតចំពោះព្រះសម្មាសម្ពុទ្ធ និងសាវ័ករបស់ព្រះអង្គ

«ពេលនេះតថាគតកំពុងធ្វើតាមប្រពៃណីរបស់ព្រះពុទ្ធទាំងឡាយពីបុរាណមក ។ ព្រះពុទ្ធពីមុនៗមកទាំងប៉ុន្មានសុទ្ធតែត្រាច់និមន្តបិណ្ឌបាត ។ សូមព្រះអង្គទ្រង់ជ្រាបថាតថាគតធ្វើយ៉ាងនេះ គឺដើម្បីប្រមូលមហាជនឱ្យដើរលើមាគ៌ានៃគុណធម៌» ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានរំងាប់ព្រះហឫទ័យព្រះបាទសុទ្ធោទនៈ។ ព្រះរាជាទ្រង់យាងព្រះសម្មាសម្ពុទ្ធនិងព្រះសាវ័កទៅទទួលភត្តាហារនៅក្នុងព្រះរាជវាំង ។

"I now follow the traditions of the Buddha's of old. All the previous Buddhas went on the alms round. Please appreciate that this is done to establish the masses on the path of virtue. The Buddha pacified King Suddhodhana. The King invited the Buddha and the disciples to take alms at the Palace.

After the partaking of the Alms, the Buddha preaches the doctrine to His Clansmen gathered there.

បន្ទាប់ពីទទួលភត្តាហាររួច ព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសប្រទានធម្មទេសនាចំពោះព្រះញាតិវង្សរបស់ព្រះអង្គ ដែលបានយាងមកជួបជុំគ្នាក្នុងទីនោះ

បន្ទាប់ពីសោយភត្តាហារពិសេស ដែលរៀបចំថ្វាយនៅក្នុងព្រះរាជវាំងរួចមក ព្រះសម្មាសម្ពុទ្ធក៏ទ្រង់សម្តែងព្រះធម៌ចំពោះព្រះរាជា ព្រះញាតិវង្ស រាជាមាត្យ ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីដទៃទៀត ដែលយាងនិងអញ្ជើញមកប្រជុំគ្នាក្នុងទីនោះ ។ ព្រះអង្គទ្រង់ពន្យល់អំពីព្រះអរិយសច្ចៈធម៌ ដែលទ្រង់បានត្រាស់ដឹង ព្រមទាំងមាគ៌ាដែលនាំទៅរកការរំលត់ទុក្ខ ។ គ្រប់ៗគ្នាសុទ្ធតែបានជ្រាបច្បាស់អំពីព្រះធម៌ ។ ព្រះញាតិវង្ស ព្រមទាំងរាជាមាត្យទាំងអស់ បានសម្រេចព្រះហឫទ័យធ្វើតាមព្រះសម្មាសម្ពុទ្ធ ដោយសទ្ធាយ៉ាងមាំ ។

After partaking of the special meal given at the Palace, the Buddha preached the Doctrine to the King, his relations, Ministers and all others assembled there. He explained the truths He realized, and the path to end suffering. All understood the Doctrine. They decided to follow the Buddha with confidence.



At the request of King Suddhodhana the Buddha accompanied by His two Chief Disciples visits Yasodhara. The ordination of Prince Rahula.
ដោយមានព្រះអគ្គសាវ័កទាំងពីរព្រះអង្គយាងអមព្រះរាជដំណើរផង ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅប្រោសព្រះនាងយសោធរា តាមព្រះរាជតម្រាស់និមន្ត្ររបស់ព្រះបាទសុទ្ធោទនៈ ។ ពិធីបំបួសព្រះរាជកុមាររាហុល ។

តាមព្រះរាជតម្រាស់និមន្ត្ររបស់ព្រះបាទសុទ្ធោទនៈ ព្រះសម្មាសម្ពុទ្ធបានទ្រង់យាងទៅកាន់និវេសន៍ព្រះនាងយសោធរា ដោយមានព្រះអគ្គសាវ័កទាំងពីរព្រះអង្គយាងអមព្រះរាជដំណើរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅកាន់និវេសន៍ព្រះនាង ដើម្បីពង្រឹងស្មារតីព្រះនាងឡើងវិញ ពីព្រោះព្រះនាងមានស្មារតីទន់ខ្សោយ ពុំអាចស្តាប់ធម្មាធិប្បាយរបស់ព្រះសម្មាសម្ពុទ្ធបាន ។ ដោយទ្រង់បានពោលសរសើរចំពោះគុណសម្បត្តិរបស់ព្រះនាង ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះធម៌ប្រោសព្រះនាង ។ ក្នុងពេលនោះ ព្រះរាជកុមាររាហុលទ្រង់មានព្រះជន្មប្រាំពីរវស្សា ។ ព្រះរាជកុមាររាហុលត្រូវបានបំបួសជាសមណេរមុនគេបង្អស់ ដែលពុំដែលមានពីមុនមក ។

At the request of King Suddhodhana, the Buddha visited Yasodhara, in the company of His Chief Disciples. The Buddha visited her to console her, because she was not able to listen to the Buddha's exposition. Praising her virtuous ways the Buddha preached her the Doctrine. At that time Prince Rahula was seven. Prince Rahula was ordained as the first-ever novice.



The Ordination of Prince Nanda.
ការបំបួសរាជកុមារនន្ទ

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានបំបួសសក្យកុមារដទៃទៀតជាច្រើនរាប់ទាំងបងប្អូនជីដូនមួយរបស់ព្រះអង្គឈ្មោះ នន្ទកុមារផង ។ មានយុវជនជាច្រើននៃនគរកបិលពស្តុបានលះបង់ឃរាវាស ហើយទៅបួសជាភិក្ខុតាមលំអានរបស់ព្រះសម្មាសម្ពុទ្ធ ។ ចំណែកសក្យបុត្រ ៦អង្គផ្សេងទៀត គឺភទ្ទិយ អនុរុទ្ធ ភគុ កិម្ពិល អានន្ទ និងទេវទត្ត ក៏បានសុំឱ្យព្រះសម្មាសម្ពុទ្ធបំបួសពួកគេដែរ ។

The Buddha ordained several other Sakya Princes, including His cousin Prince Nanda.Many youths of Kapilavastu left the lay life and became Bhikkus, following the steps of the Buddha. Six other Sakya Princes , namely, Bhaddiya, Anuruddha, Bhagu, Kimbila, Ananda and Devadatta also requested the Buddha to ordain them.

The Buddha accompanied by Arahants Sariputta and Moggallana visits the ailing King Suddhodhana.
ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅប្រោសព្រះបាទសុទ្ធោទនៈ ដែលកំពុងប្រឈួនធ្ងន់ ដោយមានព្រះអរហន្តសារីបុត្ត និងមោគ្គល្លានអមព្រះរាជដំណើរផង

ច្រើនឆ្នាំក្រោយមក ព្រះសម្មាសម្ពុទ្ធទ្រង់បានយាងត្រឡប់មកនគរកបិលពស្តុវិញ ជាមួយនឹងព្រះភិក្ខុនន្ទ សារីបុត្ត អានន្ទ និងមោគ្គល្លាន ។ ព្រះសម្មាសម្ពុទ្ធយាងទៅប្រោសព្រះបាទសុទ្ធោទនៈ ដែលកំពុងប្រឈួន ។ ពេលទ្រង់ទតឃើញព្រះសម្មាសម្ពុទ្ធ ព្រះរាជាទ្រង់បានជាសះស្បើយជាបណ្តោះអាសន្ន ។ ប៉ុន្តែដោយសារព្រះអង្គទ្រង់ជរាណាស់ទៅហើយនោះ បន្តិចក្រោយមកព្រះរាជសុខភាពរបស់ព្រះអង្គក៏ថមថយទៅ ហើយទ្រង់ក៏ចូលទិវង្គតទៅជាហេតុធ្វើឱ្យព្រះញាតិវង្ស និងប្រជារាស្ត្រទាំងអស់មានទុក្ខក្រៀមក្រំជាទម្ងន់ ។

Several years later the Buddha revisted Kapilavastu with Bhikkus Nanda, Sariputta, Ananda and Mogallana.When He visited him King Sudhodhana was ill. Seeing the Buddha, the King regained his health temporarily. But, since he was very old, soon his health deteriorated and he died to the grief of all.

Maha Prajapati Gotami seeks permission to enter the Order.
ព្រះនាងមហាបជាបតីគោតមីស្នើសុំព្រះរាជានុញ្ញាត ដើម្បីបួសជាភិក្ខុនី

ព្រះនាងមហាបជាបតីគោតមី ដែលបានចិញ្ចឹមបីបាច់រក្សាព្រះរាជកុមារសិទ្ធត្ថដូចជាព្រះរាជបុត្រព្រះនាងបង្កើត ទ្រង់ភ័ន្តភាំងស្មារតីយ៉ាងខ្លាំង ដោយសារការចូលទិវង្គតរបស់ព្រះបាទសុទ្ធោទនៈ ដែលជាព្រះស្វាមី ។ ព្រះនាងទ្រង់យាងទៅថ្វាយបង្គំសូមបព្វជ្ជាពីព្រះសម្មាសម្ពុទ្ធដោយមានក្សត្រីជារាជបរិវារទៅជាមួយផង ។ ក្សត្រីទាំងនោះសុទ្ធតែមានប្រាថ្នាទទួលបព្វជ្ជាជាភិក្ខុនីដូចព្រះនាងដែរ ។

Maha Prajapathi Gothami, who brought up Prince Siddhartha as her own son, was greatly distracted by the death of her husband King Suddhodhana. She was keen to follow the Buddha and to become a nun. She visited the Buddha, with a retinue of women, who were equally keen to receive ordination.

The ladies break down and cry, when their request to be ordained is rejected.
ក្សត្រីទាំងនោះខ្ទួចព្រះទ័យ និងទ្រង់ព្រះកន្សែងនៅពេលសំណើសុំបួសរបស់ខ្លួនត្រូវបានព្រះសម្មាសម្ពុទ្ធបដិសេធ

ព្រះនាងមហាបជាបតីគោតមី បានសុំអនុញ្ញាតពីព្រះសម្មាសម្ពុទ្ធ ដើម្បីបួសជាភិក្ខុនី ។ ទោះបីព្រះនាងបានទទូចសុំជាច្រើនសារ ក្នុងព្រះនាមព្រះនាងផ្ទាល់ និងក្នុងព្រះនាមសក្យក្សត្រីដទៃឯទៀតក៏ដោយ ក៏ព្រះសម្មាសម្ពុទ្ធទ្រង់បានបដិសេធចំនួនបីលើក ។ ក្សត្រីទាំងឡាយនោះរំជួលព្រះទ័យយ៉ាងខ្លាំង ចំពោះការបដិសេធដដែលៗនេះ រហូតដល់ទ្រង់ខ្ទួចព្រះទ័យ និងទ្រង់ព្រះកន្សែង ។

Maha Prajapathi Gothami requested the Buddha's permission to enter the Order as a nun (Bhikkuni). In spite of her repeated requests, on her own behalf and on behalf of the other Sakyan ladies, the Buddha refused three times. The ladies were so moved by these repeated rejections that they broke down and cried.

The ladies led by Maha Prajapati Gothami seek an audience with the Buddha.
ពួកក្សត្រីដែលដឹកនាំដោយ ព្រះនាងមហាបជាបតី គោតមី ទ្រង់ស្វែងទៅសុំចូលគាល់ព្រះសម្មាសម្ពុទ្ធ

បន្ទាប់ពីពិធីបុណ្យបូជាព្រះសពរបស់ព្រះបាទសុទ្ធោទនៈ ព្រះសម្មាសម្ពុទ្ធទ្រង់យាងចេញពីក្រុងកបិលពស្តុ ហើយទ្រង់យាងទៅសម្តែងធម្មទេសនានៅកន្លែងផ្សេងៗ ។ មានឱកាសមួយនោះ ក្នុងគ្រាដែលព្រះអង្គកំពុងគង់ក្នុងវត្តមហាវ៉ននៃក្រុងវេសាលី ព្រះនាងមហាបជាបតីគោតមី និងក្សត្រីជារាជបរិវារ ទ្រង់បានយាងទៅដល់ទីក្រុងនោះដោយកោរព្រះកេសនិងទ្រង់គ្រងសំពត់ពណ៌លឿង ។ ដោយសារទ្រង់យាងដោយផ្ទាល់ព្រះបាទាដូច្នេះ ព្រះនាងនិងក្សត្រីទាំងនោះ ត្រូវចំណាយអស់ពេលដ៏យូរទើបយាងទៅដល់ក្រុងវេសាលី ។

After the cremation of King Suddhodhana, the Buddha left Kapilavastu and went on a preaching tour. On one occasion when He was staying at Mahavana monastery at Visala, Maha Prajapati Gotami and her retinue walked to that City, heads shaven and wearing yellow robes. As they came on foot, it took them a long time to reach the City of Visala.

The ladies meet Venerable Ananda at the gate of the Monastery.
ពួកក្សត្រីបានជួបព្រះអានន្ទភិក្ខុ នៅនឹងខ្លោងទ្វារវត្ត

ពួកក្សត្រីទាំងនោះទ្រង់អស់ព្រះកាយពលយ៉ាងខ្លាំង និងមានព្រះបាទាហើមពោរ បណ្ដាលមកពីការធ្វើដំណើរឆ្ងាយពេក ។ ដោយមានព្រះជលនេត្រហូរសស្រាក់ ព្រះនាងមហាបជាបតីគោតមី ទ្រង់ពន្យល់ព្រះអានន្ទថា ព្រះនាងមានព្រះរាជបំណងនឹងបំពេញបព្វជ្ជាជាភិក្ខុនី ។ ព្រះអានន្ទយាងទៅទូលព្រះសម្មាសម្ពុទ្ធ និងជួយអង្វរព្រះអង្គក្នុងព្រះនាមក្សត្រីទាំងឡាយនោះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់នៅតែបដិសេធ ហើយមានព្រះបន្ទូលទៅកាន់ព្រះអានន្ទថា ព្រះអង្គពុំអាចអនុញ្ញាតបានឡើយ ។

They were totally exhausted and their feet were swollen due to excessive walking. In tears Prajapati Gotami explained to Venerable Ananda that they wanted to enter the Order. Venerable Ananda went to the Buddha and pleaded on behalf of the ladies. The Buddha was adamant and told Ananda that He cannot give permission.

Venerable Ananda's request to ordain ladies and the Buddha's refusal.

សំណើសុំបំបួសក្សត្រីជាភិក្ខុនីរបស់ព្រះអានន្ទ និងសេចក្ដីបដិសេធរបស់ព្រះសម្មាសម្ពុទ្ធ

ព្រះអានន្ទនៅតែទទូចអង្វរជាពីរ ជាបីលើក តែព្រះសម្មាសម្ពុទ្ធទ្រង់នៅតែបន្តបដិសេធដដែល ។ បន្ទាប់មក ព្រះអានន្ទទូលសួរព្រះសម្មាសម្ពុទ្ធថា តើនឹងមានឧបសគ្គអ្វីខ្លះ ដែលរារាំងស្ត្រីភេទមិនឱ្យសម្រេចព្រះនិព្វានទេ ប្រសិនបើពួកគេរស់នៅដោយគោរពវិន័យជាអ្នកបួសយ៉ាងតឹងរ៉ឹង និងមិនសេពកាម ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់តបវិញថា «ម្នាលអានន្ទ ប្រសិនបើពួកគេលះបង់ជីវិតជាឃរាវាស ហើយបួសជាភិក្ខុនី និងគោរពតាមបញ្ញត្តិនៃព្រះធម៌បាន ពួកគេក៏អាចសម្រេចព្រះនិព្វាននៅក្នុងជីវិតបច្ចុប្បន្ននេះបានដូចគ្នា» ។

Ananda kept on pleading – twice, thrice. But the Buddha kept on refusing. Next Ananda asked the Buddha, whether there was any obstacle that would bar women from attaining Nibbana if they lived a strict life of religious discipline and were celibate. The Buddha replied : "Ananda, if they renounce lay life, enter the Order and observe the Laws of the Doctrine they too can attain Nibbana, during this life-time itself".

Venerable Ananda discusses with the Buddha the issue of ordaining ladies.
ព្រះអានន្ទភិក្ខុ ទ្រង់ពិភាក្សាជាមួយព្រះសម្មាសម្ពុទ្ធ ដើម្បីរកច្រកចេញក្នុងការបំបួសស្ត្រីភេទ

ព្រះអានន្ទភិក្ខុមានដីកាថា «បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ប្រសិនបើដូច្នេះមែន ទូលព្រះបង្គំសូមព្រះអង្គទ្រង់ព្រះតម្រិះអំពីបញ្ហានេះ ។ ព្រះមាតាចិញ្ចឹមរបស់ព្រះអង្គ គឺជាអ្នកចិញ្ចឹម បីបាច់រក្សាព្រះអង្គតាំងពីតូចរហូតមក ។ ចាប់ពីពេលដែលព្រះមាតាព្រះអង្គទ្រង់ចូលទិវង្គតទៅ គឺព្រះមាតាចិញ្ចឹមនេះហើយជាអ្នកបំបៅដោះព្រះអង្គ ។ ដោយហេតុនេះ បពិត្រព្រះអង្គ ទូលព្រះបង្គំសូមអង្វរក្នុងព្រះនាមព្រះមាតាចិញ្ចឹមរបស់ព្រះអង្គ សូមព្រះអង្គទ្រង់ព្រះមេត្តាអនុញ្ញាតឱ្យព្រះនាងបានបួសជាភិក្ខុនីផង» ។

Venerable Ananda stated thus : "If that were so, I will request the Buddha to consider this. Your step-mother is the person who brought you up. From the time your mother died she breastfed you. Therefore Sir, I plead on her behalf. Please allow women too to enter the Order.



Venerable Ananda gets the Buddha's permission to ordain women.
ព្រះអានន្ទភិក្ខុបានទទួលពុទ្ធានុញ្ញាតឱ្យបំបួសស្ត្រីភេទ

នៅទីបំផុត ព្រះសម្មាសម្ពុទ្ធទ្រង់មានបន្ទូលថា «មិនថ្វីទេ ម្នាលអានន្ទ ប្រសិនបើព្រះនាងមហាបជាបតីគោតមី យល់ព្រមប្រព្រឹត្តតាមបញ្ញត្តិនៃព្រះធម៌ តថាគតអនុញ្ញាតឱ្យព្រះនាងទទួលបព្វជ្ជាជាភិក្ខុនីចុះ» ។ ព្រះនាងទ្រង់មានព្រះហឫទ័យត្រេកអរក្រៃលែងដោយបានឮដំណឹងនេះ ។ ព្រះនាងទ្រង់មានព្រះបន្ទូលថា ព្រះនាងនឹងធានាថា ព្រះនាងនឹងគោរព និងប្រតិបត្តិតាមបញ្ញត្តិនៃព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធរហូតអស់មួយជីវិត ។

At last the Buddha said: "All right Ananda, if Maha Prajapati Gotami, agrees to abide by the rules of the Doctrine. I wish to permit her to enter the Order". The lady was overjoyed to hear this. She said that she will give an assurance that she will honour and respect the Laws of the Buddha's Doctrine, throughout her life-time.



Venerable Ananda gets the Buddha's permission to ordain women, if they accept eight conditions.
ព្រះអានន្ទភិក្ខុ បានទទួលព្រះពុទ្ធានុញ្ញាតឱ្យបំបួសស្ត្រីភេទ ប្រសិនបើស្ត្រីទាំងនោះយល់ព្រមទទួលលក្ខខណ្ឌប្រាំបីប្រការ

ព្រះអានន្ទភិក្ខុ បានទូលព្រះសម្មាសម្ពុទ្ធថា ព្រះនាងមហាបជាបតីគោតមី ទ្រង់បានទទួលរ៉ាប់រងថានឹងប្រតិបត្តិយ៉ាងហ្មត់ចត់បំផុតតាមគរុធម៌ទាំងប្រាំបីប្រការ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ញត្តិ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានធ្វើការសង្កេតដូច្នេះថា «គណៈភិក្ខុនីមិនអាចឋិតថេរបានយូរអង្វែងដូចជាគណៈភិក្ខុទេ ។ គណៈភិក្ខុនីដែលមិនអាចឋិតថេរបានយូរអង្វែងនោះក៏ព្រោះតែភិក្ខុនី» ។ ព្រះអានន្ទភិក្ខុបានផ្តល់ពត៌មានអំពីសេចក្តីសម្រេចព្រះហឫទ័យរបស់ព្រះសម្មាសម្ពុទ្ធ ចំពោះព្រះនាងមហាបជាបតីគោតមី ។

Venerable Ananda informed the Buddha, that Maha Prajapati Gotami has undertaken to observe scrupulously the eight-fold solemn principles of Dhamma, advocated by the Buddha. The Buddha made this observation: "The Order of Nuns will not last long as the Order of Bhikkhus. The dispensation will not last very long because of Bhikkhunis". Ven. Ananda informed the Buddha's decission to Prajapathi Gotami.



Venerable Ananda is appointed Chief Attendant of the Buddha.
ព្រះអានន្ទភិក្ខុ ត្រូវបានតែងតាំងជាប្រធានវេយ្យាវច្ចករ របស់ព្រះសម្មាសម្ពុទ្ធ

ក្នុងចំណោមសាវ័ករបស់ព្រះសម្មាសម្ពុទ្ធទាំងអស់ មានតែព្រះអានន្ទដែលជាបងប្អូនជីដូនមួយរបស់ព្រះសម្មាសម្ពុទ្ធទេ ដែលទ្រង់មានសេចក្ដីស្រឡាញ់ និងគោរពចំពោះព្រះសម្មាសម្ពុទ្ធជាងគេ ។ ដោយហេតុនោះ ទើបព្រះអានន្ទត្រូវបានគេជ្រើសតាំងឱ្យធ្វើជាវេយ្យាវច្ចករដ៏ជិតស្និទ្ធបំផុតនៃព្រះសម្មាសម្ពុទ្ធ ។ នៅពេលព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះជន្មហាសិបប្រាំវស្សា មានបងប្អូនជីដូនមួយរបស់ព្រះអង្គមួយអង្គទៀត បានទទួលបព្វជ្ជាជាភិក្ខុ ។ ប៉ុន្តែ ចរិយារបស់ភិក្ខុអង្គនោះ មានលក្ខណៈផ្ទុយស្រឡះពីចរិយារបស់ព្រះអានន្ទ ។ បងប្អូនជីដូនមួយ មួយអង្គនេះជាគូប្រជែងនឹងព្រះសម្មាសម្ពុទ្ធជាដរាប ។ លោកបានប្រព្រឹត្តគ្រប់យ៉ាងតាមដែលអាចធ្វើបាន ដើម្បីធ្វើឱ្យមានការប្រេះស្រាំក្នុងចំណោមភិក្ខុទាំងឡាយ ។ លោកថែមទាំងបានប្រើអំពើឧក្រិដ្ឋ ដើម្បីបង្កគ្រោះថ្នាក់ដល់ព្រះសម្មាសម្ពុទ្ធទៀតផង ។ បងប្អូនជីដូនមួយអង្គនោះគឺ ភិក្ខុទេវទត្ត ។

Of all the disciples of the Buddha, Ananda; the Buddha's cousin entertained the greatest love and respect for the Buddha. In consequence, Ananda was selected as the closest attendant of the Buddha. When the Buddha was fifty-five another of His cousins entered the Order. But, his behaviour was totally in contrast to that of Ananda. That cousin was always the Buddha's rival. He did whatever he could to bring about a rift among the Bhikkus. He even employed thugs to harm the Buddha. This cousin was Devadatta.



Devadatta meets Prince Ajatasattu.

ភិក្ខុទេវទត្ត បានជួបព្រះអង្គម្ចាស់ អជាតសត្តុ

ភិក្ខុទេវទត្តជាអ្នកមានអំនួតក្រអឺតក្រអោងហួសហេតុ ។ លោកមិនពេញចិត្តចំពោះគំនិតដែលថាព្រះសារីបុត្តនិងព្រះមោគ្គល្លាន ដែលមិនមែនជាមនុស្សនៃសក្យត្រកូល គប្បីត្រូវបានតែងតាំងឱ្យធ្វើជាប្រធាននៃពុទ្ធសាវ័កទេ ។ លោកក៏បានបំបែកខ្លួន ចេញពីក្រុមសង្ឃ ហើយងាកទៅចងមិត្តជាមួយនឹងព្រះកុមារអជាតសត្តុ ដែលជាក្សត្រត្រូវសោយរាជ្យបន្តពីព្រះបាទពិម្ពិសារ ។ ព្រះកុមារអជាតសត្តុទ្រង់បានកសាងវត្តមួយយ៉ាងស្អាតប្រគេនព្រះទេវទត្ត និងបានសន្យាចំពោះព្រះទេវទត្តថានឹងឧបត្ថម្ភគ្រប់យ៉ាងឱ្យតែលោកត្រូវការ ។

Devadatta was inordinately proud. He did not like the idea that Sariputta and Mogallana who were not of the Sakya Clan should have been made the Chief Disciple. He broke away from the Brotherhood and made friends with Ajatasattu, who was to succeed to the throne of Bimbisara. Ajatasattu built a handsome monastery for Devadatta and promised him all the help he needed.



Devadatta seeks the Buddha's permission, to launch a new Bhikku Order.

ព្រះទេវទត្តស្វែងរកពុទ្ធានុញ្ញាត ដើម្បីបង្កើតគណៈភិក្ខុថ្មីមួយ

ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅដល់ក្រុងរាជគ្រឹះ បន្ទាប់ពីពេលវេលាបានកន្លងទៅជាច្រើនឆ្នាំ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានបដិសេធចំពោះការសុំបំបែកគណៈសង្ឃរបស់ភិក្ខុទេវទត្ត ។ ប៉ុន្តែភិក្ខុទេវទត្ត នៅតែបន្តអនុវត្តផែនការរបស់ខ្លួនដដែល ដោយពុំខ្វីយកចិត្តទុកដាក់ចំពោះដីការបស់ព្រះសម្មាសម្ពុទ្ធឡើយ ។ នៅក្នុងរឿងនេះភិក្ខុទេវទត្តបានទទួលជំនួយឧបត្ថម្ភឥតមានព្រំដែនពីអជាតសត្តុកុមារ ។ រីឯព្រះបាទពិម្ពិសារក៏នៅតែបន្តផ្គត់ផ្គង់ព្រះសម្មាសម្ពុទ្ធយ៉ាងខ្ជាប់ខ្ជួនដដែល ។

The Buddha arrived in Rajagaha, after the lapse of a few years. The Buddha refused Devadatta's offer to divide the Brotherhood. But, without paying heed to the word of the Buddha, Devadatta went ahead to implement his plan. In this, he received Ajatasattu's unstinted assistance. King Bimbisara continued to be a steadfast supporter of the Buddha.



Devadatta entices Prince Ajatasattu

ភិក្ខុទេវទត្តល្បួងព្រះអង្គម្ចាស់អជាតសត្តុ

ភិក្ខុទេវទត្តបានបញ្ចុះបញ្ចូលឱ្យព្រះអង្គម្ចាស់អជាតសត្តុទម្លាក់ព្រះបាទពិម្ពិសារចេញពីរាជបល្ល័ង្ក ហើយឡើងសោយរាជ្យជំនួសក្នុងព្រះរាជវាំងរបស់ព្រះបាទពិម្ពិសារ ។ ព្រះអង្គម្ចាស់អជាតសត្តុយល់ព្រមធ្វើតាម ។ ទ្រង់បានចាប់ព្រះវរបិតា គឺព្រះបាទពិម្ពិសារយកទៅដាក់គុក ។ ទ្រង់បានបង្អត់អាហារព្រះបិតាទ្រង់រហូតដល់ព្រះបាទពិម្ពិសារចូលទិវង្គត ។ រឿងនេះបានកើតឡើងនៅក្នុងឆ្នាំទី៣៧ បន្ទាប់ពីព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ ។

Devadatta, persuaded Ajatasattu to oust King Bimbisara from the Throne and to become King in his place. Ajatasattu agreed. He imprisoned his father – King Bimbisara. By preventing food to his father he made King Bimbisara starve to death. This event occurred in the 37th year after the Buddha's Enlightenment.

Won over by Devadatta, Prince Ajatasattu organizes a band to assassinate the Buddha.
ដោយឈ្លក់វង្វេងតាមពាក្យបញ្ចុះបញ្ចូលរបស់ភិក្ខុទេវទត្ត ព្រះអង្គម្ចាស់អជាតសត្តុទ្រង់ចាត់តាំងមនុស្សមួយក្រុមឱ្យទៅធ្វើឃាតព្រះសម្មាសម្ពុទ្ធ

ព្រះអង្គម្ចាស់អជាតសត្តុទ្រង់បានត្រៀមជាស្រេចថានឹងធ្វើអ្វីៗគ្រប់យ៉ាង ដែលព្រះទេវទត្តបញ្ជាឱ្យព្រះអង្គធ្វើ ។ ព្រះទេវទត្តប្រាប់ទៅព្រះរាជាឱ្យជួលខ្មាន់ធ្នូដែលត្រង់មួយក្រុមឱ្យទៅធ្វើឃាតព្រះសម្មាសម្ពុទ្ធ ។ ខ្មាន់ធ្នូដែលគេជួលទាំងនោះទទួលបរាជ័យ ដោយសារភាពស្ងប់ស្ងៀម សេចក្ដីមេត្តាករុណា និងអរហត្តភាពរបស់ព្រះសម្មាសម្ពុទ្ធ រហូតដល់សម្រេចចិត្តថា ទោះបីយ៉ាងណាក៏ពួកគេមិនបង្កឱ្យមានគ្រោះថ្នាក់ដល់ព្រះសម្មាសម្ពុទ្ធឡើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់អភ័យទោសដល់អ្នកទាំងនោះ នៅពេលដែលពួកគេសារភាពថាពួកគេត្រូវគេជួលឱ្យមកធ្វើគុតព្រះអង្គ ។ ពួកខ្មាន់ធ្នូ ដែលគេជួលទាំងប៉ុន្មានបានប្ដូរគំនិតបែរមកកាន់សីលតាមព្រះសម្មាសម្ពុទ្ធវិញ ។

King Ajatasattu was ready to do whatever Devadatta ordered him to do. Devadatta asked the King to hire a band of efficient Archers to kill the Buddha. The hired Archers were so overcome by the tranquility, compassion and the saintliness of the Buddha that they decided not to harm the Buddha in any way. The Buddha forgave them when they confessed that they were hired to kill Him. The hired Archers made up their minds to follow the Buddha's precepts.

Devadatta hurls a rock from Gijjakuta Mountain to kill the Buddha.
ព្រះទេវទត្តច្រានទម្លាក់ដុំថ្មមួយដុំពីលើភ្នំ គិជ្ឈកូដ ដើម្បីធ្វើឃាតព្រះសម្មាសម្ពុទ្ធ

នៅពេលដែលគម្រោងធ្វើឃាតព្រះសម្មាសម្ពុទ្ធ ដោយជួលឃាតកររបស់លោកត្រូវបរាជ័យ ព្រះទេវទត្តបានឡើងទៅពួននៅលើភ្នំគិជ្ឈកូដ ក្នុងបំណងចាំធ្វើឃាតព្រះសម្មាសម្ពុទ្ធដោយខ្លួនឯងផ្ទាល់ ។ ល្ងាចមួយ ភិក្ខុទេវទត្ត ដែលគង់នៅពីខាងលើកន្លែងដែលព្រះសម្មាសម្ពុទ្ធធ្លាប់តែយាងចង្ក្រម បានច្រានថ្មមួយដុំយ៉ាងធំសម្បើមទម្លាក់មកលើព្រះសម្មាសម្ពុទ្ធ ។ ដុំថ្មបែកក្លាយជាបំណែកតូចៗ ។ មានថ្មមួយដុំតូចបានខ្ទាតទៅប៉ះព្រះបាទា ធ្វើឱ្យព្រះសម្មាសម្ពុទ្ធមានរបួសស្រាល ។ មានឈាមហូរចេញពីមុខរបួស ។ លោកគ្រូពេទ្យឈ្មោះ ជីវក បានអញ្ជើញមកដល់វត្តរបស់ព្រះសម្មាសម្ពុទ្ធ ហើយព្យាបាលរបួសថ្វាយព្រះអង្គ ។

When his plans to kill the Buddha by hiring assassins failed, Devadatta lurked in the mountain Gijjhakuta with the intention of killing the Buddha himself. One evening, standing above the place where the Buddha was wont to walk, Devadatta hurled a huge rock on the Buddha. The rock broke into fragments. A stray fragment hit the Buddha's foot, injuring the Buddha slightly. The injury bled. Physician Jivaka came to the Buddha's monastery and attended to the wound.



Deploying the introxicated elephant Nalagiri to kill the Buddha.

ការប្រើដំរី នាឡគិរី ដែលគេបង្អកស្រាឱ្យស្រវឹង ឱ្យទៅព្រេចព្រះសម្មាសម្ពុទ្ធ

នៅពេលដែលការប៉ុងប៉ងនោះត្រូវបរាជ័យ ព្រះទេវទត្តបានរិះរកវិធីផ្សេងទៀត ។ លើកនេះលោកគ្រោងនឹងបញ្ជូនដំរីស្រវឹងស្រាមួយក្បាលឈ្មោះ នាឡគិរី ឱ្យទៅព្រេចព្រះសម្មាសម្ពុទ្ធ ។ នៅពេលឃើញព្រះសម្មាសម្ពុទ្ធ ដំរីដែលគេបង្អកស្រានោះត្រឡប់ទៅជាស្ងប់ស្ងៀម និងស្លូតបូតដោយសារមេត្តាធម៌ដ៏ធំធេងរបស់ព្រះសម្មាសម្ពុទ្ធ ។ ដោយបោះបង់ចោលគម្រោងរបស់លោកក្នុងការធ្វើឃាតព្រះសម្មាសម្ពុទ្ធ ពេលក្រោយមកភិក្ខុទេវទត្តបានងាកមករកវិធីបំបែកគណៈភិក្ខុសង្ឃវិញម្តង ។

When that attempt failed Devadatta tried again. This time he planned to deploy the Drunken Elephant Nalagiri to kill the Buddha. Seeing the Buddha, the intoxicated elephant became totally calm and docile, due to the Buddha's immeasurable compassion. Giving up his plan to assassinate the Buddha, Devadatta next tried to divide the Bhikkhu Order.

Devadatta meets the Buddha, and requests special boons.
ព្រះទេវទត្តបានចូលគាល់ព្រះសម្មាសម្ពុទ្ធ និងស្នើសុំប្រយោជន៍ពិសេស

ដោយបង្កើតឱ្យមានការចាប់អារម្មណ៍ក្នុងចំណោមភិក្ខុសង្ឃជាសាវ័ករបស់លោកថាបរិសុទ្ធជាងសាវ័ករបស់ព្រះពុទ្ធ ភិក្ខុទេវទត្ត បាននិមន្តទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ។ លោកបានសុំឱ្យព្រះសម្មាសម្ពុទ្ធ ដាក់បញ្ញត្តិវិន័យឱ្យកាន់តែតឹងថែមទៀតចំពោះសង្ឃ ឱ្យដូចជាអាចារ្យនៃសាសនាផ្សេងៗទៀត ។ បញ្ញត្តិដែលព្រះទេវទត្តចង់ដាក់បង្ខំទាំងនោះ គឺ «ភិក្ខុទាំងឡាយត្រូវរស់នៅក្រោមដើមឈើ មិនមែននៅក្នុងកុដិទេ ។ ភិក្ខុទាំងឡាយត្រូវតមកុំឆាន់ត្រីនិងសាច់ ។ ប្រសិនបើមានភិក្ខុអង្គណាមិនព្រមគោរពតាមបញ្ញត្តិនេះទេ ភិក្ខុអង្គនោះត្រូវតែបណ្តេញចេញពីគណៈសង្ឃ» ។

Creating the impression among the Bhikkhus that his principles were purer than those of the Buddha, he went to see the Buddha. He asked the Buddha to impose more rigid Laws on the Sangha, like other religious teachers. These were the Laws, Devadatta wanted imposed : "The Bhikkhus must live under trees and not in houses. Bhikkhus must refrain from eating fish and flesh. If a Bhikkhu disobeyed these Laws, he should be expelled from the Bhikkhu Order".



The Buddha refuses to grant Devadatta's request.
ព្រះសម្មាសម្ពុទ្ធ បដិសេធចំពោះសំណូមពររបស់ភិក្ខុទេវទត្ត

ព្រះសម្មាសម្ពុទ្ធ ទ្រង់បដិសេធដោយឥតលាក់លៀម ចំពោះសំណើរបស់ភិក្ខុទេវទត្ត ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបន្ទូលដូច្នេះថា «ប្រសិនបើ ព្រះភិក្ខុដែលបានទទួលបព្វជ្ជាអង្គណាមានប្រាថ្នាចង់រស់នៅក្រោមដើមឈើ សូមទុកឱ្យលោកសម្រេចដោយខ្លួនឯងចុះ ។ សូមទុកឱ្យព្រះភិក្ខុទាំងឡាយសម្រេចជ្រើសរើសយកនូវទីលំនៅដែលទាយករបស់ខ្លួនបានរៀបចំប្រគេន ដោយព្រះអង្គឯង ។ ប្រសិនបើភិក្ខុអង្គណាចង់ឆាន់ត្រី ឬសាច់ សូមទុកឱ្យលោកឆាន់ចុះ» ។ ព្រះសម្មាសម្ពុទ្ធទ្រង់គ្រើនរំលឹកភិក្ខុទេវទត្តថា «ផលនៃអំពើនេះ វានឹងដើរតាមក្រោយអ្នកប្រព្រឹត្តដោយគេចមិនផុតឡើយ ។ ដោយហេតុនោះ សូមកុំប៉ុនប៉ងបំបែកបំបាក់គណៈសង្ឃឱ្យសោះ» ។

The Buddha openly rejected Devadatta's request. The Buddha spoke thus : "If a given Bhikkhu wished to live under a tree let him do so. Let the Bhikkhus select any of the abodes prepared for them by their supporters. If a Bhikku wishes to take fish and flesh let him do so"; the Buddha warned Devadatta: "The results of this action will inevitably follow the doer. Therefore, please do not try to disrupt the Brotherhood".

Devadatta innaugurates a new order of Bhikkhus, but those Bhikkhus are brought back to the Buddha by Venerable Sariputta.
ភិក្ខុទេវទត្តបានបង្កើតសង្ឃនិកាយថ្មីមួយ ប៉ុន្តែ ភិក្ខុសារីបុត្តបានទៅនាំភិក្ខុទាំងឡាយនោះមកខាងព្រះសម្មាសម្ពុទ្ធវិញទាំងអស់

ដោយពុំយកចិត្តទុកដាក់ចំពោះដីការបស់ព្រះសម្មាសម្ពុទ្ធ ភិក្ខុទេវទត្តបាននិមន្តចេញពោរពេញទៅដោយគំនុំ ។ លោកបានបង្កើតនិកាយរបស់លោក ដោយបង្ខំឱ្យភិក្ខុទាំងឡាយប្រតិបត្តិតាមវិន័យដ៏តឹងរ៉ឹងបំផុត និងឥតសមហេតុសមផលរបស់លោក ។ ព្រះសម្មាសម្ពុទ្ធ បានបញ្ជូនព្រះភិក្ខុសារីបុត្តទៅជួយសង្គ្រោះភិក្ខុទាំងនោះឱ្យរួចផុតពីស្ថានការណ៍ដ៏អភ័ព្វនោះ ។ ក្នុងពេលដែលព្រះទេវទត្តផ្ទំលក់ ព្រះភិក្ខុសារីបុត្ត បានពន្យល់ការពិតដល់ភិក្ខុទាំងឡាយ ។ ព្រះអង្គបានពន្យល់អំពីយោបល់របស់ព្រះសម្មាសម្ពុទ្ធចំពោះបញ្ហានោះដោយស្មោះត្រង់ ។ បន្ទាប់ពីបានស្តាប់ព្រះភិក្ខុសារីបុត្ត ភិក្ខុទាំងឡាយនោះបានប្តូរគំនិត ហើយបាននាំគ្នាត្រឡប់តាមព្រះភិក្ខុសារីបុត្តទៅនៅជាមួយ ព្រះសម្មាសម្ពុទ្ធវិញ ។

Without heeding the word of the Buddha, Devadatta walked away full of spite. He set up his own Brotherhood imposing his unrealistically rigid rules on the Bhikkhus. The Buddha sent Venerable Sariputta, to save those Bhikkkus from that unfortunate situation. While Devadatta was asleep, Venerable Sariputta explained the facts to the Bhikkhus. He explained the Buddha's views on the matter, with frankness. Changing their mind after listening to Venerable Sariputta, the Bhikkhus went back to the Buddha with Venerable Sariputta.

Seeing that His Disciples had left Him, Devadatta requests that he be taken to see the Buddha.
ដោយឃើញថាសាវ័កនាំគ្នាទៅចោលលោកអស់ ព្រះទេវទត្តបានសុំឱ្យគេនាំលោកទៅជួបព្រះសម្មាសម្ពុទ្ធ

នៅពេលភិក្ខុទេវទត្តតើនឡើង លោកបានដឹងថាភិក្ខុទាំងឡាយបាននិមន្តទៅចោលលោកអស់រលីងហើយ ។ លោកបានឮថា ព្រះសារីបុត្តបាននាំភិក្ខុទាំងនោះ ទៅគង់ជាមួយព្រះសម្មាសម្ពុទ្ធវិញ ។ ព្រះទេវទត្តឆេះឆួលយ៉ាងខ្លាំងទៅដោយកំហឹង ។ ដោយលោកមានកម្លាំងទន់ខ្សោយ និងមិនអាចនិមន្តដោយព្រះបាទាបាន លោកបានប្រើវេយ្យាវច្ចកររបស់លោកឱ្យយកគ្រែស្នែងសែងលោកទៅជួបព្រះសម្មាសម្ពុទ្ធ ។

When Devadatta awoke, he found that all the Bhikkhus had left him. He heard that Venerable Sariputta took the Bhikkus back to the Buddha. Devadatta was in a towering rage. As he was weak and unable to walk, he got his attendants to take him to the Buddha, in a palanquin.

Devadatta dies even before he could see the Buddha.
ព្រះទេវទត្តសុគតមុនពេលដែលលោកបានជួបព្រះសម្មាសម្ពុទ្ធ

ពេលបានឃើញព្រះទេវទត្ត ដែលកំពុងឆេះឆួលដោយកំហឹង កំពុងធ្វើដំណើរចូលទៅរកព្រះសម្មាសម្ពុទ្ធ ព្រះភិក្ខុទាំងឡាយបានទូលព្រះសម្មាសម្ពុទ្ធឱ្យយាងទៅពួន ខ្លាចក្រែងព្រះទេវទត្តបង្កឱ្យមានគ្រោះថ្នាក់ដល់ព្រះអង្គ ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធ ទ្រង់ពុំមានភ័យខ្លាចដល់តិចតួចសោះឡើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានធ្វើកំណត់សម្គាល់ទៅព្រះសារីបុត្តវិញថា ព្រះទេវទត្តពុំអាចបង្កគ្រោះថ្នាក់ដល់ព្រះសម្មាសម្ពុទ្ធបានទេ ។ បន្តិចក្រោយមក នរណាក៏បានយល់អំពីសេចក្តីពិតនៃបន្ទូលរបស់ព្រះសម្មាសម្ពុទ្ធដែរ ។ នៅពេលដែលពួកអ្នកសែងដាក់ស្នែងចុះដើម្បីសម្រាកមួយភ្លែតនោះ ពួកគេបានឃើញថាព្រះទេវទត្តបានសុគតបាត់ទៅហើយ ។ ចាប់តាំងពីពេលនោះរហូតដល់ពេលដែលព្រះសម្មាសម្ពុទ្ធបរិនិព្វាន ពុំដែលមានការបែងចែកនិកាយផ្សេងៗក្នុងគណៈសង្ឃទេ ។

Seeing enraged Devadatta coming towards the Buddha, the Bhikkhus advised the Buddha to hide lest Devadatta should harm him. But, the Buddha was not at all frightened. He observed to Sariputta, that Devadatta could not harm the Buddha. Later on people understood the truth of the Buddha's word. When the palanquin-bearers put the palanquin down to rest for a while they found that Devdatta was dead. Since that time until the demise of the Buddha there was no disruption of the Bhikkhu Order.

The Buddha dwelt in Veluvana, Jetavana and other Monasteries spreading the Dhamma for 45 years.
ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន នៅវត្តជេតពន និងវត្តដទៃជាច្រើនទៀត ដើម្បីសម្តែងធម្មទេសនាអស់រយៈពេល៤៥ វស្សា ។

ក្នុងរយៈពេល៤៥វស្សា ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែងធម្មទេសនា និងណែនាំមហាជនឱ្យប្រព្រឹត្តតាមមាគ៌ានៃគុណធម៌ ។ ព្រះអង្គទ្រង់បានយាងទៅកាន់រាជាណាចក្រផ្សេងៗដោយព្រះបាទា ដោយឥតពឹងពាក់យានជំនិះឡើយ ។ នៅក្នុងរដូវភ្លៀង ទ្រង់គង់នៅក្នុងវត្តអារាមដែលទាយកបានប្រគេនព្រះអង្គ ។ ព្រះអង្គទ្រង់បានចំណាយពេលភាគច្រើនគង់នៅក្នុងវត្តជេតពនារាម ដែលសង់ថ្វាយដោយមហាសេដ្ឋីឈ្មោះ អនាថបិណ្ឌិកៈ និងនៅក្នុងវត្តបុព្វារាម ដែលនាងមហាឧបាសិកាវិសាខា កសាងថ្វាយព្រះអង្គ ។ ក្នុងអំឡុងឆ្នាំទាំងនោះ ព្រះអង្គទ្រង់ខំប្រឹងឥតសំចៃក្នុងការប្រៀនប្រដៅ និងផ្សព្វផ្សាយព្រះធម៌របស់ព្រះអង្គ ។

For forty five years the Buddha preached the Doctrine and led masses in the path of virtue. He travelled in various Kingdoms entirely on foot without resort to vehicles. During the rainy season, He dwelt in the monasteries donated to Him by His supporters. For the most part, the Buddha dwelt in Jetavanarama built by Guild-leader Anata Pindika and in Poorvarama built for Him by the Great Devotee Vishakha. Throughout all these years He strove hard to teach and to propagate the Doctrine.

The Buddha preached the Doctrine to the masses.
ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងធម្មទេសនាចំពោះមហាជន

ព្រះសម្មាសម្ពុទ្ធ ទ្រង់តើនពីផ្ទុំពីព្រលឹមរៀងរាល់ថ្ងៃ ។ បន្ទាប់ពីជម្រះព្រះកាយរួច ព្រះអង្គទ្រង់ប្រមើលមើលនិស្ស័យសត្វលោក តាមរយៈមហាមេត្តា សមាធិរបស់ព្រះអង្គ ។ ប្រសិនបើ ព្រះសម្មាសម្ពុទ្ធទ្រង់រកឃើញថា មានជនណាម្នាក់មានលក្ខណៈខាងផ្លូវចិត្តរីកចំរើនដល់កំរិតសមនឹងទូន្មានបានហើយ ព្រះអង្គទ្រង់យាងទៅប្រោសជននោះនៅក្នុងថ្ងៃនោះតែម្តង ។ ព្រះអង្គតែងតែយាងទៅបិណ្ឌបាតតាំងពីព្រលឹម ជួនកាលទ្រង់យាងតែមួយព្រះអង្គឯង ។ ជួនកាលទ្រង់យាងដោយមានព្រះភិក្ខុទាំងឡាយនិមន្តជាមួយ ដើម្បីបិណ្ឌបាតពីផ្ទះមួយទៅផ្ទះមួយ ។

The Buddha awoke early each day. After morning ablutions He scrutinized the World and men through His great compassionate concentration of the mind. If the Buddha found that someone was ripe for spiritual advancement he would go to him and convert him the same day. Early in the morning He would go out for alms – at times, all alone. Sometimes He would go out with the retinue of Bhikkhus begging alms from house to house.



The Buddha accepted Alms from many.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ទទួលចង្ហាន់បិណ្ឌបាតពីជនទាំងឡាយ

ពេលប្រជាជនយាងព្រះអង្គទៅទទួលភត្តនៅតាមគេហដ្ឋានរបស់ខ្លួន ព្រះអង្គនឹងទទួលយកការអារាធនានោះ លុះត្រាតែទ្រង់ពិចារណាទៅឃើញមានហេតុផលសមស្រប ។ នៅពេលដែលទ្រង់ព្រមទទួលការអារាធនាបែបនេះ ព្រះអង្គទ្រង់តែងតែសោយភត្តាហាររួចលាងព្រះហស្ត និងប្រទានធម្មទេសនាចំពោះជនានុជនដែលមកប្រជុំគ្នានៅទីនោះ ។ បន្ទាប់ពីនោះ ព្រះអង្គទ្រង់តែងតែយាងត្រឡប់ទៅវត្តវិញ ។

When people invited Him to their homes for alms-offerings, He would accept the invitation only if there was a good reason. When He accepts such an invitation He would partake of the meal, wash His hands and preach a Sermon for those assembled. After that He would go back to the Monastery.

The Buddha preaching the Dhamma to the Bhikkus and Bhikkunis.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានធម្មទេសនាចំពោះភិក្ខុ និងភិក្ខុនី

ព្រះសម្មាសម្ពុទ្ធ តែងតែគង់យ៉ាងស្ងប់ស្ងៀមនៅក្រោមដើមឈើ ឬនៅក្នុងឧបដ្ឋានសាលារហូតដល់ព្រះភិក្ខុទាំងឡាយឆាន់ចង្ហាន់រួចរាល់ ។ បន្ទាប់ពីនោះ ព្រះអង្គតែងតែយាងទៅសម្រាកនៅក្នុងកុដិរបស់ព្រះអង្គ ។ នៅពេលព្រះភិក្ខុទាំងអស់និមន្តមកជួបជុំគ្នានៅក្នុងធម្មសាលាហើយ ព្រះអង្គតែងតែសម្តែងធម៌ដែលសមស្របទៅនឹងកាលវេលានោះ ឬក៏លើសពីនេះទៀត ព្រះអង្គទ្រង់ដឹកនាំធម្មសាកច្ឆា ដើម្បីតម្រង់ទិសព្រះភិក្ខុទាំងឡាយឱ្យសម្រេចព្រះនិព្វាននៅក្នុងបច្ចុប្បន្នជាតិនេះ ។

The Buddha would sit calmly under a tree or in the Assembly Hall, until all the Bhikkhus had taken their meals. After that He would enter His cell to .rest. When all the Bhikkhus are assembled in the Preaching Hall, He would preach a sermon appropriate for that moment, or else He would lead a discussion directing the Bhikkhus to attain Nibbana during this life-time itself.

The Buddha visiting, villages, settlements and cities with a retinue of Bhikkhus.
ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅកាន់ភូមិ និគម និងទីក្រុងនានា ដោយមានព្រះភិក្ខុទាំងឡាយអមព្រះរាជដំណើរ

បន្ទាប់ពីស្តាប់ការសម្តែងធម៌របស់ព្រះសម្មាសម្ពុទ្ធ មានភិក្ខុខ្លះបានសុំឱ្យព្រះសម្មាសម្ពុទ្ធធ្វើការសង្ខេបឡើងវិញនូវធម្មទេសនានោះ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់តែងតែសម្តែងធម៌ ដើម្បីឱ្យសមស្របទៅតាមកំរិតរីកចំរើនខាងបញ្ញាស្មារតីរបស់បុគ្គលម្នាក់ៗ ។ បន្ទាប់ពីបានស្តាប់ព្រះធម្មទេសនារួច ព្រះភិក្ខុទាំងឡាយបាននិមន្តចេញទៅធ្វើសមាធិ ដោយជ្រើសរើសកន្លែងដែលមានភាពស្ងប់ស្ងាត់ដូចជានៅតាមគល់ឈើនៅក្នុងព្រៃ ឬនៅក្នុងផ្ទះទំនេរឥតមនុស្សនៅ ។ ព្រះភិក្ខុទាំងឡាយនោះ តែងតែសូត្រធ្យាយគាថានានា ។ បន្ទាប់ពីនោះមកទាំងព្រះសម្មាសម្ពុទ្ធក៏ទ្រង់យាងទៅកាន់កុដិរបស់ព្រះអង្គវិញដែរ ។

After the Buddha's sermon, certain Bhikkhus request the Buddha for a summary of the Sermon. The Buddha would preach to suit the stage of spiritual development of each individual. The Bhikkus go out after the Sermon, and meditate selecting such a quiet place as the foot of a tree, a forest or an empty house. They would recite stanzas. After this, the Buddha too goes back to His cell.

The Buddha receives sundry offerings at various places, during the Spring.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ទទួលតង្វាយ នៅតាមទីកន្លែងផ្សេងៗក្នុងរដូវផ្ការីក

នៅរដូវក្តៅ រាល់ពេលល្ងាចពុទ្ធបរិស័ទដែលនៅក្បែរវត្ត តែងតែចូលទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ខ្លះបានយកតង្វាយមកជាមួយ ។ ខ្លះទៀតមកដើម្បីស្តាប់ធម៌ ។ ដោយប្រើភាសាយ៉ាងជំនាញ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ទេសនាចំពោះអ្នកទាំងនោះរហូតដល់ទាក់ទាញចិត្តគំនិតពួកគេឱ្យជឿតាមព្រះអង្គទាំងអស់គ្នា ។ អ្នកចូលរួមក្នុងអង្គប្រជុំម្នាក់ៗតែងតែគិតថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានធម៌ទេសនាជាពិសេសសំរាប់ខ្លួន ។ នៅទីបញ្ចប់នៃធម្មទេសនា អ្នកទាំងឡាយនោះសុទ្ធតែមានសេចក្តីរីករាយ និងសច្ចាថានឹងកាន់ព្រះពុទ្ធសាសនា រហូតអស់មួយជីវិត ។

In the summer, of an evening, neighbours would visit the Buddha, some brought along offerings. Some came to listen to sermons. Using the language adeptly the Buddha preached to them winning their minds and hearts. Each person in the Assembly would think that the Buddha spoke specifically to him or to her. At the end of the sermon, they all became happy and pledged to practise Buddhism life-long.

The Buddha taking a bath in the river next to the Monastery, after the people who visited Him had left.
ព្រះសម្មាសម្ពុទ្ធទ្រង់ស្រង់ទឹកស្ទឹងនៅជិតវត្ត បន្ទាប់ពីប្រជាជនដែលមកថ្វាយបង្គំព្រះអង្គត្រឡប់ទៅវិញ

បន្ទាប់ពីពួកឧបាសក ឧបាសិកាចេញផុតទៅ ព្រះសម្មាសម្ពុទ្ធទ្រង់តែងតែយាងត្រឡប់ទៅកាន់វត្តវិញ ដើម្បីស្រង់ទឹក ។ បើមានស្ទឹង ឬត្រពាំងនៅជិតធម្មសាលា ព្រះសម្មាសម្ពុទ្ធតែងតែស្រង់ទឹកនៅពេលល្ងាច ។ ព្រះអង្គទ្រង់តែងតែគង់ក្នុងអារម្មណ៍ស្ងប់មួយរយៈបន្ទាប់ពីស្រង់ទឹករួច ។ បន្ទាប់ពីនោះ ព្រះអង្គតែងតែមានដីកាទៅកាន់ព្រះភិក្ខុទាំងឡាយដែលនិមន្តមកពីតំបន់នានា ។ បន្ទាប់ពីអធិប្បាយចំណុចលំបាកនានារបស់ព្រះធម៌រួច ព្រះអង្គតែងតែយាងទៅសម្រាកនៅក្នុងកុដិ ដោយសេចក្តីស្ងប់ក្នុងអារម្មណ៍ ។

After the devotees left, the Buddha would go back to the Monsatery to bathe. If their was a river or pond near the Assembly Hall the Buddha would bathe in the evening. He would remain in tranquil mind for a while after the bath. Next, He would speak to the Bhikkhus who had come from other regions: after expounding difficult places of the Doctrine, the Buddha would go back to His cell with tranquil mind.

The Buddha preaching to the lay Devotees in the afternoon.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានធម្មទេសនាចំពោះឧបាសក ឧបាសិកា នៅពេលរសៀល

ព្រះសម្មាសម្ពុទ្ធទ្រង់យាងចង្ក្រមនៅពេលរសៀល ដើម្បីបំបាត់ភាពងោកងុយដែលបណ្តាលមកពីការងងុយផ្ទុំពេលថ្ងៃ ។ បន្ទាប់ពីការធ្វើដំណើរចង្ក្រមមក ព្រះអង្គតែងតែយាងទៅជួបព្រះភិក្ខុម្តងទៀតនៅពេលល្ងាច ដើម្បីសន្ទនាធម៌ជាមួយភិក្ខុទាំងនោះ ។ នៅពេលយប់មានមនុស្សសំខាន់ៗ ដូចជាព្រះរាជាជាដើម បានចូលមកថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ និងពិភាក្សាអំពីបញ្ហាផ្សេងៗ ។ នៅពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានចម្លើយហើយ ពួកគេតែងតែត្រឡប់ទៅវិញដោយរីករាយ ។

The Buddha walked in the afternoon to overcome the weariness from the day-time nap. After His walk, He would once again meet the Bhikkhus in the evening and talk to them. In the night important people like Kings visited the Buddha and discussed problems. When the Buddha responded, they would go back happily.



The Buddha rests at night at the proper hour.

ព្រះសម្មាសម្ពុទ្ធ ទ្រង់ផ្ទុំនៅពេលយប់ ទៅតាមកាលកំណត់ដ៏ត្រឹមត្រូវ

បន្ទាប់មកទៀត គឺជាពេលសម្រាក ។ ព្រះសម្មាសម្ពុទ្ធទ្រង់តែងតែផ្ទុំផ្អៀងទៅផ្នែកខាងស្តាំនៃព្រះកាយព្រះអង្គជានិច្ច ។ ព្រះអង្គទ្រង់ផ្ទុំដោយមានឥរិយាបថអង្កុញបន្តិច ដោយព្រះបាទឆ្វេងសណ្តូកពីលើព្រះបាទស្តាំ និងដាក់ព្រះហស្តស្តាំនៅពីក្រោមថ្ពាល់ស្តាំ ។ ព្រះអង្គតើនមុនពេលថ្ងៃរះជានិច្ច ។ បន្ទាប់មកព្រះអង្គទ្រង់តែងតែប្រមើលមើលនិស្ស័យសត្វលោក ប្រកបដោយមហាមេត្តាធម៌ដើម្បីស្វែងរកសាវ័កសម្រាប់ថ្ងៃអនាគត ។

Next, it is the time to rest. The Buddha always slept on the right side of His body. He slept with His legs slightly bent, with His left leg on the right leg and with His right hand under the right cheek. He awoke before dawn. Then He would scrutinize the World with great compassion, for future disciples.

The Buddha preaching to masses at all levels of society.
ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងធម៌ចំពោះមនុស្សគ្រប់ស្រទាប់ក្នុងសង្គម

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាច់ចរទៅកាន់ព្រះរាជាណាចក្រតូច ធំ និគមជនបទទាំងឡាយនៃប្រទេសឥណ្ឌា អស់រយៈពេល ៤៥ព្រះវស្សា ដើម្បីធ្វើឱ្យមហាជនរស់នៅប្រកបដោយគុណធម៌ ។ ព្រះកាយពលរបស់ព្រះអង្គ ពុំមានថមថយឡើយ ។ នៅពេលព្រះអង្គទ្រង់ពុំយាងទៅទីណា ព្រះអង្គទ្រង់ចំណាយពេលនោះ ពុំមែនដើម្បីគ្រាន់តែសម្តែងធម្មទេសនាទេ ប៉ុន្តែទ្រង់ថែមទាំងបានជួយដោះស្រាយបញ្ហារបស់ជនទាំងឡាយដែលព្រះអង្គបានជួប និងពន្យល់ជនទាំងនោះឱ្យយល់ច្បាស់អំពីអត្ថន័យនៃជីវិត ។ ព្រះអង្គទ្រង់ រីករាយក្នុងព្រះហឫទ័យណាស់ពេលទតឃើញជនទាំងឡាយដូចជា កសិករ អ្នកថែសួន ជាងដែក ឬជាងធ្វើរទេះចូលមកថ្វាយបង្គំព្រះអង្គដើម្បីស្វែងរកដំណោះស្រាយនៃបញ្ហារបស់ពួកគេ ។

The Buddha travelled about in minor and major Kingdoms of India for 45 years making the people lead a virtuous life. His vigour was unflagging. When He was not travelling around He spent His time not only to preach sermons, but also to solve the problems of the people He met and to make them understand the meaning of life. He was happy whenever such people as farmers, gardeners, blacksmiths or chariot-makers came to see Him to find solutions for their problems.

The Buddha solving various problems of a variety of people.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ដោះស្រាយបញ្ហាផ្សេងៗរបស់ជនច្រើនប្រភេទ

ព្រះសម្មាសម្ពុទ្ធ មិនដែលមិនសព្វព្រះហឫទ័យក្នុងការរកដំណោះស្រាយចំពោះបញ្ហាដ៏លំបាកៗឡើយ ។ ជានិច្ចជាកាលព្រះអង្គទ្រង់សម្ដែងធម្មទេសនាសំដៅសម្របទៅតាមចរិតលក្ខណៈពិសេសរបស់បុគ្គលម្នាក់ៗ ដែលបានចូលមកគាល់ព្រះអង្គ ។ ព្រះអង្គទ្រង់ទទួលស្វាគមន៍អ្នកទាំងអស់នោះដោយស្មោះស្មើដូចគ្នា មិនថាអ្នកនោះមកដើម្បីទូលសួរព្រះអង្គអំពីដំណោះស្រាយខាងទស្សនវិជ្ជាជ្រៅៗ ឬក៏មកគ្រាន់តែដើម្បីរំខានព្រះអង្គទេ ។ ព្រះអង្គទ្រង់ឈ្នះដោយព្រះប្រាជ្ញាញាណរកប្រដូចគ្មានរបស់ព្រះអង្គចំពោះជនណាដែលចង់ប្រកួតប្រជែងព្រះអង្គ ឬក៏មកពិនិត្យសង្កេតមើលកំហុសព្រះអង្គ ។ ទីបំផុត អ្នកទាំងនោះបានក្លាយទៅជាអ្នកគោរពបូជាចំពោះព្រះអង្គទាំងអស់ ។

The Buddha never disliked the idea of finding solutions for difficult questions. He always preached in terms of the particular character of the people who came to see Him. He greeted all with even mind, whether they came to question Him about profound philosophic issues, or merely to harrass Him. He vanquished with His unparalleled wisdom, those who challenged Him or came to scrutinize Him. All of them later became His devoted followers.

The Buddha reaches to eightieth year after teaching the Dhamma to both the Clergy and the Laity for forty five years.
ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះជន្មជិតប៉ែតសិបវស្សា បន្ទាប់ពីបានប្រោសប្រទានធម្មទេសនាចំពោះព្រះសង្ឃនិងគ្រហស្ថអស់រយៈសែសិបប្រាំវស្សាមក

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានធ្វើដំណើរអស់រយៈពេលប្រមាណជាសែសិបប្រាំវស្សា នៅក្នុងបេសកកម្មផ្សព្វផ្សាយព្រះធម៌របស់ព្រះអង្គ ។ ឥឡូវនេះ ព្រះជន្មរបស់ព្រះអង្គបានឈានមកដល់ជិតប៉ែតសិបវស្សាហើយ ។ បញ្ញាស្មារតីរបស់ព្រះអង្គនៅតែរឹងមាំដដែល ទោះបីព្រះកាយពលរបស់ព្រះអង្គមានភាពទន់ខ្សោយក៏ដោយ ។ ហេតុដូច្នេះ ព្រះអង្គទ្រង់ជ្រាបថា បេសកកម្មរបស់ព្រះអង្គបានឈានមកដល់ទីបញ្ចប់ហើយ ។ ដោយទ្រង់ជ្រាបច្បាស់ថា ព្រះអង្គពុំមានពេលច្រើនតទៅទៀតសម្រាប់ជីវិតរបស់ព្រះអង្គទេនោះ ព្រះអង្គបានសម្រេចព្រះហឫទ័យយាងទៅកាន់ជើងភ្នំហេមពាន្ត ជាទីដែលព្រះអង្គធ្លាប់បានស្គាល់កាលពីកុមារភាព ។ ព្រះអង្គមានបំណងចង់ចូលបរិនិព្វាននៅត្រង់កន្លែងនោះ ។ ដោយព្រះតម្រិះដូច្នេះ ព្រះអង្គក៏ទ្រង់យាងចេញពីក្រុងរាជគ្រឹះដោយមានព្រះអានន្ទ និងព្រះភិក្ខុទាំងឡាយអមព្រះរាជដំណើរទៅជាមួយផង ។

The Buddha who had travelled about for 45 years in His mission of spreading the Doctrine, was now nearing eighty. Though His mind was as strong as ever His physical vigour was weakening. Therefore, he felt that His mission was coming to an end. Realizing that, He did not have very much time to live, He decided to travel towards the foot-hills of the Himalayas, familiar to Him from His youth. He intended to depart the World in that location. With this in mind, He left Rajagaha accompanied by Ananda and a retinue of Bhikkhus.

The Buddha meets Ambapali at Vesali.
ព្រះសម្មាសម្ពុទ្ធ ទ្រង់បានជួបនាង អម្ពបាលី នាក្រុងវេសាលី

ចាប់ផ្តើមពីទីនោះទៅ ព្រះសម្មាសម្ពុទ្ធទ្រង់យាងកាត់ព្រះរាជាណាចក្របាដលី ហួសទៅដល់ក្រុងវេសាលី និងបានយាងទៅទិសខាងជើង ។ ក្រុងវេសាលី ជាកន្លែងមួយដែលព្រះអង្គធ្លាប់គង់ពីមុនមក ។ គឺនៅក្នុងក្រុងវេសាលីនេះហើយ ដែលនាងអម្ពបាលីបានថ្វាយចំការស្វាយចំពោះព្រះអង្គដោយប្រកួតប្រជែងជាមួយនឹងព្រះរាជាទាំងឡាយ ដែលមានសទ្ធាជ្រះថ្លាបំផុតក្នុងការផ្តត់ផ្គង់ចំពោះព្រះសម្មាសម្ពុទ្ធ ។ ព្រះអង្គទ្រង់អនុញ្ញាតឱ្យភិក្ខុទាំងឡាយគង់ចាំវស្សានៅភូមិណាក៏បានតាមតែសព្វព្រះទ័យ ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធ និងព្រះអានន្ទទ្រង់គង់ចាំព្រះវស្សានៅក្នុងភូមិជាមួយគ្នា ។

Starting from there, the Buddha walked through the Kingdom of Patali, passed Vesali and travelled North. The city of Vesali was one of His former dwelling places. It was at Vesali that the courtesan Ambapali offered Him the mango grove, vying with Kings who were keen to make offerings to the Buddha. He asked the Bhikkhus to spend the rainy season in any village they liked. But, the Buddha and Ananda spent the rainy season in the same village.

The Buddha is taken seriously ill during the last rainy season.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រឈួនជាទម្ងន់នៅក្នុងរដូវភ្លៀងចុងក្រោយ

ក្នុងពេលគង់ចាំវស្សានៅក្នុងភូមិ វេឡុវ៉ន ព្រះសម្មាសម្ពុទ្ធទ្រង់ប្រឈួនជាទម្ងន់ តែព្រះអង្គក៏ទ្រង់បានជាសះស្បើយឡើងវិញជាលំដាប់ ហើយការឈឺចុកចាប់ក៏រសាយបាត់អស់ទៅ ។ ព្រះភិក្ខុអានន្ទ បានថ្វាយការកត់សំគាល់ថា «បពិត្រ ព្រះដ៏មានព្រះភាគជាអម្ចាស់ ខ្ញុំព្រះអង្គមានសេចក្ដីទុក្ខព្រួយពន់ពេកណាស់នៅពេលព្រះអង្គទ្រង់ប្រឈួន ។ ខ្ញុំព្រះអង្គមានសេចក្ដីត្រេតអរដោយឃើញព្រះអង្គទ្រង់បានជាសះស្បើយឡើងវិញ ។ នៅពេលព្រះអង្គទ្រង់ប្រឈួន ខ្ញុំព្រះអង្គមានជំនឿថា ព្រះអង្គនឹងមិនបរិនិព្វានក្នុងពេលនោះទេ ។ ខ្ញុំព្រះអង្គសង្ឃឹមថា ព្រះអង្គនឹងប្រទានឱវាទទុកឱ្យអ្នកខាងក្រោយធ្វើតាម បន្ទាប់ពីព្រះអង្គបរិនិព្វានទៅ » ។

While spending the rainy season in the village of Veluvana the Buddha became gravely ill. He recovered eventually and the pain disappeared fully. Venerable Ananda observed: "O Sir, I was very much grieved when you were ill. I am happy that You have recovered. When You were seriously ill, I expected that You will not die at that time. I hoped that You will give instructions to be followed after Your demise".



The Buddha instructs Venerable Ananda.
ព្រះសម្មាសម្ពុទ្ធ ប្រទានឱវាទដល់ព្រះអានន្ទ

ព្រះសម្មាសម្ពុទ្ធ មានដីកាតបទៅវិញដូច្នេះថា «តថាគតបានបង្រៀនភិក្ខុទាំងឡាយសព្វប្រការអស់ហើយ តថាគតឥតមានលាក់លៀមអាចិកំបាំងណាមួយទុកសោះឡើយ ។ តថាគតបានបង្រៀនភិក្ខុទាំងឡាយនូវអ្វីៗទាំងអស់ ដែលភិក្ខុគប្បីដឹងរហូតដល់ពេលដែលភិក្ខុទាំងនោះបានរួចរំដោះផុតពីសេចក្ដីទុក្ខ ។ ម្នាលអានន្ទ ! ឥឡូវនេះ តថាគតជាមនុស្សចាស់ជរាហើយ ។ ជីវិតរបស់តថាគតបានខិតមកជិតទីបញ្ចប់ហើយ ។ ឥឡូវនេះ តថាគតមានព្រះជន្មាយុប៉ែតសិបវស្សាហើយ ។ ពេលនេះ អ្នកត្រូវជួយខ្លួនដោយខ្លួនឯង ព្រះធម៌គឺជាទីពឹងតែមួយគត់របស់អ្នក» ។

The Buddha replied him thus: "I have taught the Bhikkhus everything, I have never held back any secrets. I have taught them everything they should know until they are liberated from suffering. Ananda, I am an old person now. My life is nearing its end. I am eighty now. You must now help yourself, the Doctrine is your only help".

The Buddha decides to pass away on Vesak Full-moon Day.
ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្រេចថានឹងបរិនិព្វាននៅថ្ងៃពេញបូរមី ខែពិសាខ

នៅព្រឹកថ្ងៃបន្ទាប់ ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅបិណ្ឌបាត នៅក្នុងក្រុងប៉ាវ៉ា ។ លុះទ្រង់សោយចង្ហាន់បិណ្ឌបាតរួច ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ប្រើព្រះអានន្ទឱ្យរៀបចំទីអាសនៈថ្វាយព្រះអង្គ ។ ព្រះអង្គទ្រង់ចំរើនឈានភាវនា ហើយទ្រង់សម្រេចថាព្រះអង្គនឹងបរិនិព្វានក្នុងរយៈពេលបីខែទៀត គិតពីពេលនេះទៅ ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីកាទៅកាន់ព្រះអានន្ទថា «ម្នាលអានន្ទ ! តថាគតនឹងបរិនិព្វានឃ្លាតឆ្ងាយពីលោកនេះទៅនៅថ្ងៃពេញបូរមី ខែពិសាខហើយ ឥឡូវនេះនៅសល់តែបីខែគត់ទៀតទេ» ។

Next morning He went to the City of Pava for alms. After his meals He asked Ananda to prepare Him a seat. He contemplated and decided, that He should depart this life, three months hence. He said to Ananda : "Ananda, the Buddha will depart this World on the Full-moon Day of Vesak; there are only 3 months left now".

Venerable Ananda request the Buddha not to pass away.

ព្រះអានន្ទ ទូលអារាធនាសុំព្រះសម្មាសម្ពុទ្ធកុំបរិនិព្វាន

ព្រះអានន្ទភិក្ខុទទូចអង្វរសុំព្រះសម្មាសម្ពុទ្ធឱ្យស្តេចគង់ព្រះជន្មនៅបន្តទៅទៀត ដើម្បីជាប្រយោជន៍នៃមនុស្សផងទាំងឡាយ ។ ព្រះសម្មាសម្ពុទ្ធមានពុទ្ធដីកាដូច្នេះថា «ម្នាលអានន្ទ ! តថាគតនឹងបរិនិព្វានទៅក្នុងអំឡុងបីខែទៀតរាប់ចាប់ពីឥឡូវនេះទៅ ។ គ្មាននរណាម្នាក់អាចគេចផុតពីសេចក្តីស្លាប់បានទេ ។ គ្មាននរណាម្នាក់អាចរស់នៅរហូតនោះទេ ។ ម្នាលអានន្ទ ! ចូរអ្នកប្រមូលព្រះភិក្ខុទាំងអស់មកប្រជុំគ្នានៅក្នុងវត្តមហាវ័ន » ។ ព្រះអានន្ទក៏ទូលថ្វាយដំណឹងដល់ព្រះសម្មាសម្ពុទ្ធ នៅពេលព្រះភិក្ខុទាំងឡាយនិមន្តមកជួបជុំគ្នាអស់ហើយ ។

Venerable Ananda entreated the Buddha to continue to live for the good of the people. The Buddha spoke to him thus: "Ananda, I will die three months hence. No one can avoid death. No one can live forever. Ananda get all the Bhikkhus to asemble at the monastery of Mahavana". Ananda informed the Buddha when the Bhikkhus had assembled.

The Buddha provides advice to the Disciples.

ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទាននិវាទដល់សាវ័កទាំងឡាយ

ព្រះសម្មាសម្ពុទ្ធ ទ្រង់មានបន្ទូលទៅកាន់អង្គប្រជុំនៃភិក្ខុសង្ឃ និងដាស់តឿនឱ្យភិក្ខុទាំងអស់ប្រតិបត្តិតាមព្រះធម៌ និងជួយមហាជនឱ្យប្រព្រឹត្តតែអំពើល្អក្នុងជីវិត ។ នៅទីបញ្ចប់ ព្រះអង្គទ្រង់ត្រាស់ទូន្មានព្រះភិក្ខុសង្ឃទាំងនោះថា «វត្ថុជាសម្ភារៈទាំងឡាយសុទ្ធតែប្រែប្រួល ។ វត្ថុទាំងនោះ គឺជាមាយាការដែលនាំឱ្យយល់ខុស ។ ដូច្នេះ ចូររៀនព្រះធម៌ និងគោរពតាមគោលការណ៍របស់ព្រះធម៌កុំបីបង្អង់យូរឡើយ ។ ចូររៀបចំចិត្តគំនិតអ្នកឱ្យមានវិន័យ ។ ចូរកុំចំណាយពេលវេលាចោលទទេៗ ។ តាមមាគ៌ានេះ អ្នកអាចគេចផុតពីសេចក្តីទុក្ខក្នុងសង្សារវដ្តបានជាពុំខាន » ។

He addressed the Assembly of Bhikkus and exhorted them to follow the Doctrine and to help the masses to lead virtuous lives. Finally He advised them thus : "All material things change. They are an illusion. Learn the Doctrine and follow its principles without delay. Discipline your mind. Do not be slothful. That way you can escape the sufferings of Sansara".

The Buddha looks on at Vesali for the last time.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ទតមើលទៅទីក្រុងវេសាលី ជាលើកចុងក្រោយ

ព្រឹកមួយនោះ ព្រះសម្មាសម្ពុទ្ធ និងព្រះអានន្ទទ្រង់យាងទៅបិណ្ឌបាតនៅក្នុងក្រុងវេសាលី ព្រោះព្រះសម្មាសម្ពុទ្ធមានព្រះរាជបំណងចង់ទតក្រុងនេះជាលើកចុងក្រោយ ។ ព្រះអង្គទ្រង់មានពុទ្ធដីកាទៅកាន់ព្រះអានន្ទថា «ម្នាលអានន្ទ ! តថាគតឃើញក្រុងវេសាលីម្តងនេះជាទីបំផុតហើយ ។ ឥឡូវចូរយើងធ្វើដំណើរទៅកាន់ភណ្ឌគ្រាម» ។ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសប្រទានធម្មទេសនាចំពោះអ្នកស្រុកភណ្ឌគ្រាមរួចហើយបន្តដំណើរហួសទៅហត្ថីគ្រាម អម្ពគ្រាម និងជម្ពូគ្រាម ។ បន្ទាប់មកទៀតព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅដល់ក្រុងភគៈ[១] ។ ចេញពីទីនោះ ព្រះសម្មាសម្ពុទ្ធទ្រង់យាងត្រឡប់មកក្រុងប៉ាវ៉ាវិញ ហើយទ្រង់គង់ប្រថាប់នៅក្នុងព្រៃស្វាយរបស់នាយចុន្ទ ។

One morning the Buddha and Ananda went on their alms round in the City of Vesali, as the Buddha wanted to see the City for the last time. He spoke to Ananda thus : "Ananda, this is the last time I see the City of Vesali. Let us go to Bhanda Village". He preached to the villagers of Bhanda and travelled to the villages of Hathi, Amba and Jambu. Next He visited the City of Bhaga. From there He returned to the City of Pava, and stayed in the mango-grove of Chunda.

(១) កំណត់អ្នកបកប្រែៈ ក្នុងពុទ្ធប្បវត្តិសង្ខេបនិទានថា" ភោគនគរ "

The Buddha accepts Alms from Chunda.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ទទួលភត្តាហាររបស់នាយចុន្ទ

ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងធម្មទេសនាចំពោះនាយចុន្ទ និងសមាជិកទាំងអស់ក្នុងគ្រួសារគាត់ ដើម្បីណែនាំអ្នកទាំងនោះឱ្យគោរពព្រះរតនត្រ័យ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ទទួលការអារាធនានិមន្តរបស់នាយចុន្ទ ដើម្បីទទួលភត្តកិច្ចនៅថ្ងៃបន្ទាប់ ។ នៅក្នុងភត្តាហាររបស់នាយចុន្ទនោះ មានផ្សិតជាច្រើនមុខដែលដុះនៅក្នុងព្រៃចន្ទន៍ក្រស្នា ។ នៅពេលព្រះសម្មាសម្ពុទ្ធ ទ្រង់ឆាន់ភត្តាហាររបស់នាយចុន្ទរួច ជម្ងឺចាស់របស់ព្រះអង្គក៏រើឡើងវិញ ដោយអាការធ្ងន់ធ្ងរបំផុត ។ ប៉ុន្តែ ព្រះសម្មាសម្ពុទ្ធនៅតែបន្តព្រះរាជដំណើរតទៅទៀត ដោយទ្រង់ទ្រាំទ្រអត់សង្កត់នូវទុក្ខវេទនានោះ បម្រុងនឹងយាងឱ្យដល់ក្រុង កុសិនារា ។

The Buddha expounded the Doctrine to Chunda and to the members of his family, to persuade them to follow the Triple Gem. The Buddha accepted Chunda's invitation and offer of alms for the next day. A variety of mushrooms grown in the Sandalwood forest had been part of the meal offered by Chunda. When the Buddha partook of this meal His previous illness recurred with greater severity.But, the Buddha travelled on, patiently bearing up the pain, intending to reach the City of Kusinara.

The Buddha arrives in stages at the City of Kusinara.
ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងដោយឈប់ជាដំណាក់ៗរហូតដល់ក្រុង កុសិនារា

ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងយឺតៗរហូតដល់ក្រុងកុសិនារា ហើយទ្រង់គង់ប្រថាប់នៅក្រោមដើមឈើមួយដើម ។ នៅទីនោះ ព្រះអង្គទ្រង់បានជួបសាវ័កម្នាក់របស់អាឡារកាឡាមតាបស ដែលបានស្វែងរកជួបព្រះសម្មាសម្ពុទ្ធជាយូរមកហើយ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងធម៌ចំពោះជននោះ ។ ដោយសេចក្តីត្រេកអរខ្លាំងពេក គាត់ក៏មានចិត្តជ្រះថ្លាថ្វាយសំពត់ពណ៌មាសពីរផ្ទាំង ចំពោះព្រះសម្មាសម្ពុទ្ធ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ទទួលយកមួយផ្ទាំង ហើយមួយផ្ទាំងទៀតព្រះអង្គប្រគេនទៅព្រះអានន្ទ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើដំណើរឆ្លងកាត់ស្ទឹងកកុធានទី ទ្រង់សម្រាកព្រះកាយមួយសន្ទុះ រួចទ្រង់យាងបន្តទៅដល់ស្ទឹងហិរញ្ញវតី ដែលជាព្រំសីមានៃក្រុងកុសិនារា ។

In slow stages the Buddha reached the City of Kusinara and rested under a tree. There He met a disciple of Sage Alara Kalama, who had been seeking an audience with the Buddha: the Buddha preached to him. Exceedingly pleased he offered two golden coloured clothes to the Buddha. The Buddha accepted one and the other was offered to Ananda. The Buddha crossed River Kakutha, rested a while and reached River Hiranyawathi, within the boundaries of the City of Kusinara.

The Buddha lies down between two Sala trees in the Sala Park of the Malla Kings, getting ready for His Great Demise
ព្រះសម្មាសម្ពុទ្ធ ទ្រង់ផ្ទំនៅចន្លោះដើមសាលព្រឹក្សមួយគូ នៅក្នុងឧទ្យានសាលវ័ននៃមល្លក្សត្រ ដើម្បីត្រៀមបំរុងនឹងចូលបរិនិព្វាន

ឆ្លងផុតស្ទឹងហិរញ្ញវតី ព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃជាព្រះរាជបរិពារបានយាងទៅដល់ព្រៃសាលវ័ន ដែលជាឧទ្យានសម្រាប់កំសាន្តរបស់ពួកមល្លក្សត្រ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបថា ព្រះអង្គពុំអាចបន្តដំណើរទៅទៀតបានទេ ទើបទ្រង់ត្រាស់បង្គាប់ទៅព្រះអានន្ទឱ្យរៀបចំទីសេយ្យាថ្វាយព្រះអង្គផ្ទំនៅចន្លោះដើមសាលព្រឹក្សមួយគូ ។ ព្រះអានន្ទបានបត់សំពត់សង្ឃាដីរបស់ព្រះសម្មាសម្ពុទ្ធ ក្រាលថ្វាយជាទីកន្លែងសម្រាប់ព្រះសម្មាសម្ពុទ្ធផ្ទំ ។ ព្រះអង្គផ្ទំដោយមានព្រះកេសឆ្ពោះទៅទិសខាងជើង ។

Crossing River Hiranyawathi, the Buddha and His retinue arrived at Salavana, the pleasure park of the members of Malla Royalty. The Buddha felt that He could not walk any further and asked Ananda to prepare a place for Him to rest between two Sala trees. Ananda, folding the Buddha's robe prepared a place for Him to lie down. He lay down with His head towards the North.

Venerable Ananda is deeply aggrieved.

ព្រះអានន្ទភិក្ខុកើតទុក្ខខ្លាំងណាស់

ព្រះអានន្ទបានដឹងច្បាស់ថា ពេលនេះព្រះសម្មាសម្ពុទ្ធទ្រង់ចាកចេញឆ្ងាយពីពួកភិក្ខុទាំងឡាយហើយ ។ ព្រះអានន្ទនិមន្តទៅឆ្ងាយពីគេឯង រួចក៏ចាប់ផ្ដើមសោយសោករៀបរាប់ថា «អាត្មាអញមិនទាន់បានសម្រេចជាព្រះអរហន្តនៅឡើយ មិនដូចសាវ័កឯទៀតសោះ ។ ប៉ុន្តែព្រះសម្មាសម្ពុទ្ធបរមសាស្ដា ទ្រង់នឹងយាងចាកចោលអាត្មាអញហើយ ។ អាត្មាអញនឹងបាត់បង់នូវព្រះសាស្ដាដ៏ប្រសើររកគ្មានហើយ» ។ ជលនេត្របានហូរសស្រាក់ពីព្រះនេត្រព្រះអង្គ ។

Ananda realized that this time the Buddha was leaving them. All alone he began to weep. "I have not attained Arahantship so far, unlike other disciples. But, My Teacher will depart, leaving me behind. I will lose my kind Teacher forever". Tears welled from his eyes.



Consoling Venerable Ananda.

ការលួងលោមចំពោះព្រះអានន្ទ

ព្រះសម្មាសម្ពុទ្ធ ទ្រង់បើកព្រះនេត្ររកមើលមិនឃើញព្រះអានន្ទ ក៏ទ្រង់ត្រាស់សួររក តើព្រះអានន្ទនិមន្តទៅណា ។ សាវ័កទាំងឡាយក្រាបទូលព្រះអង្គថា ព្រះអានន្ទកំពុងសោយសោក ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បង្គាប់ភិក្ខុមួយអង្គឱ្យទៅនិមន្តព្រះអានន្ទមកចូលគាល់ ។ លុះព្រះអានន្ទត្រឡប់មកក្រាបបង្គំគាល់ហើយ ព្រះអង្គទ្រង់ត្រាស់លួងលោមព្រះអានន្ទដោយពុទ្ធដីកាដ៏ប្រពៃ ។

The Buddha opened His eyes and not seeing Ananda around enquired about him. The other disciples informed Him that Ananda was weeping.

The Buddha asked one of the Bhikkhus to fetch Ananda. When Ananda returned, the Buddha consoled him with kind words.



In the Assembly of the Disciples the Buddha praises Venerable Ananda.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សរសើរព្រះភិក្ខុអានន្ទ នៅចំពោះមុខអង្គប្រជុំនៃសាវ័កទាំងឡាយ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សរសើរព្រះអានន្ទ នៅចំពោះមុខនៃសាវ័កទាំងឡាយ ។ ព្រះអង្គទ្រង់មានព្រះបន្ទូលថា អានន្ទគឺជាពុទ្ធុប្បដ្ឋាកដ៏ប្រសើរក្រៃលែងជាងពុទ្ធុប្បដ្ឋាកពីអតីតកាល និង ពុទ្ធុប្បដ្ឋាក នាអនាគតកាល ។«អានន្ទជាពុទ្ធុប្បដ្ឋាកដ៏ប្រសើរបំផុតរបស់តថាគត ជាដរាបរៀងមក» ។

In the presence of the disciples the Buddha praised Ananda. The Buddha said that Ananda was better than any attendant of any Buddha of the past or the future. "Ananda has always been my most outstanding attendant."

Venerable Ananda requests the Buddha to pass away in a great City like Rajagaha or Sravasti.
ព្រះភិក្ខុអានន្ទអារាធនា ព្រះសម្មាសម្ពុទ្ធឱ្យទ្រង់បរិនិព្វាន នៅក្នុងទីក្រុងធំៗ ដូចជាក្រុងរាជគ្រឹះ ឬក្រុងសាវត្ថី

ព្រះភិក្ខុអានន្ទក្រាបទូលតបទៅព្រះសម្មាសម្ពុទ្ធដូច្នេះថា «បពិត្រ ព្រះដ៏មានព្រះភាគជាអម្ចាស់ សូមព្រះអង្គទ្រង់កុំស្ដេចបរិនិព្វាន ក្នុងទីឋានចុងកាត់មាត់ញកពុំសមរម្យ និងពុំមានន័យដូច្នេះក្រាបទូល ។ សូមព្រះអង្គទ្រង់ព្រះមេត្តាជ្រើសរើសយកក្រុងសាវត្ថី ឬក្រុងរាជគ្រឹះធ្វើជាកន្លែងស្ដេចបរិនិព្វានទៅក្រាបទូល ។ នៅក្នុងទីក្រុងទាំងនោះ មានឧបាសកអ្នកមានសទ្ធាជ្រះថ្លាដ៏ច្រើនសុទ្ធតែជាអ្នកមានឥទ្ធិពលខ្លាំងៗ និងសម្បត្តិស្ដុកស្ដម្ភ ដែលអាចចាត់ចែងពិធីបូជាព្រះពុទ្ធសរីរៈដោយការទទួលខុសត្រូវខ្ពស់បាន » ។

Venerable Ananda replied the Buddha thus: "O Sir please do not pass away in this unsuitable, insignificant corner of the World. Please select a City like Vesali, Shravasti or Rajagaha as the place where You would pass away. In those Cities, there are powerful and affluent devotees who would organize your funeral ceremony with great responsibility".

The Buddha explains the importance of the City of Kusinara.

ព្រះសម្មាសម្ពុទ្ធ ទ្រង់ពន្យល់អំពីសារសំខាន់នៃក្រុងកុសិនារា

ព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះបន្ទូលតបវិញថា «ម្នាលអានន្ទ ! ចូរអ្នកកុំគិតដូច្នេះ ។ ទីនេះពីមុនជាព្រះរាជាណាចក្រមួយ ដែលមានការរីកចំរើនខ្លាំងណាស់ ។ ពីមុនទីក្រុងនេះ ជារាជធានីនៃព្រះចៅចក្រពត្រាធិរាជមួយអង្គ ។ ម្នាលអានន្ទ ចូរអ្នកធ្វើដំណើរទៅកាន់ក្រុងកុសិនារា រួចផ្តល់ដំណឹងចំពោះព្រះរាជា និងប្រជាជនឱ្យបានជ្រាបថា តថាគតនឹងបរិនិព្វានក្នុងទីបំផុតនៃបច្ឆិមយាមក្នុងរាត្រីនេះហើយ ហើយប្រសិនបើពួកគេចង់ចូលគាល់តថាគត សូមឱ្យអ្នកទាំងឡាយនោះចូលមកឱ្យបានមុនពេលដែលបានកំណត់នោះ » ។ ព្រះអានន្ទបានផ្សព្វផ្សាយដំណឹងនេះទៅដល់ព្រះរាជា និងប្រជាជនទាំងអស់ ។

The Buddha replied: "Ananda, do not think thus. This was a very prosperous Kingdom at one time. It was the capital of a Universal Monarch. Ananda, go to the City of Kusinara and inform the King and the people that I will pass away in the last watch of the night and that they should come before that time if they wish to see me". Ananda, communicated this to the King and the people.



The people of Kusinara get to know that the Buddha is about to pass away.
ប្រជាជននៃក្រុងកុសិនារា បានជ្រាបដំណឹងថាព្រះសម្មាសម្ពុទ្ធ ទ្រង់រៀបនឹងបរិនិព្វានហើយ

លុះបានឮថាព្រះសម្មាសម្ពុទ្ធ ទ្រង់ហៀបនឹងបរិនិព្វានដូច្នេះ ព្រះរាជា និងប្រជារាស្ត្រនៃក្រុងកុសិនារាទ្រង់ព្រះកន្សែងទួញសោក ដោយសេចក្តីស្តាយថា «មិនទាន់ដល់ពេលដែលព្រះសម្មាសម្ពុទ្ធបរិនិព្វានទេ ហេតុអ្វីបានជាដួងប្រទីបនៃពិភពលោករលត់ទៅវិញឆាប់ម្ល៉េះ? » ។ មនុស្សម្នាកុះករនាំគ្នាធ្វើដំណើរឆ្ពោះទៅឧទ្យាន ដើម្បីថ្វាយបង្គំ ព្រះសម្មាសម្ពុទ្ធ ។ ខ្លះយំខ្សឹបខ្សួល ខ្លះស្រែកទ្រហោ ខ្លះទួញរៀបរាប់ ពួកគេបាននាំគ្នាទៅកាន់ទីនោះ ហើយរេរាមិនចង់ចេញពីទីនោះឡើយ ។

Hearing that the Buddha was about to pass away, the King and the people of Kusinara lamented : "It is not yet time for the Buddha's great demise. Has the Light of the World gone out so soon?"Masses trekked to the Park to see the Buddha. Weeping, wailing and lamenting they went there and lingered on unwilling to leave".

Subadda seeks an auedience with the Buddha.
បរិព្វាជក សុភទ្ទ សូមចូលគាល់ព្រះសម្មាសម្ពុទ្ធ

ក្នុងឱកាសនោះ មានបរិព្វាជកដ៏ក្មេងម្នាក់ឈ្មោះ សុភទ្ទ ជាតាបសដែលប្រកាន់ទស្សនៈមិនត្រឹមត្រូវ ស្នាក់អាស្រ័យនៅក្នុងក្រុងកុសិនារា ។ លុះបានឮថាព្រះសម្មាសម្ពុទ្ធ ទ្រង់នឹងបរិនិព្វានយ៉ាងនេះ គាត់ក៏ប្រញាប់ប្រញាល់ចេញទៅគាល់ព្រះអង្គ ដោយសារគាត់ធ្លាប់ឮគេប្រាប់គាត់ថា មានតែព្រះសម្មាសម្ពុទ្ធតែប៉ុណ្ណោះដែលអាចដោះស្រាយបញ្ហារបស់គាត់បាន ។ សុភទ្ទបានចូលទៅដល់សំណាក់ព្រះអានន្ទ ហើយអង្វរសូមចូលគាល់ព្រះសម្មាសម្ពុទ្ធ ដើម្បីសុំចម្លើយនៃបញ្ហារបស់ខ្លួន មុនពេលព្រះសម្មាសម្ពុទ្ធបរិនិព្វាន ។

At that time a young Ascetic by the name of Subadda, who held false views, lived in the City of Kusinara. Hearing that the Buddha was dying he was keen to see Him, as he was convinced that only the Buddha could solve the problems he had. Subadda met Ananda and asked for permission to get answers for his problems, before the Buddha passed away.

Venerable Ananda refuses Subadda's request.
ព្រះអានន្ទ បដិសេធមិនទទួលពាក្យអង្វររបស់សុភទ្ទ

ព្រះអានន្ទមានដីកាទៅកាន់សុភទ្ទថា «ម្នាលសុភទ្ទដ៏មានអាយុ ប្រការនេះមិនអាចអនុញ្ញាតបានទេ ។ ព្រះសម្មាសម្ពុទ្ធ កំពុងមានព្រះកាយពលខ្សោយណាស់ ។ ចូរអ្នកកុំនាំលំបាកដល់ព្រះអង្គ ដោយសារសំណួររបស់អ្នក» ។ សុភទ្ទចេះតែទទូចអង្វរព្រះអានន្ទ ព្រះអានន្ទនៅតែមិនព្រមបើកឱកាសឱ្យ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានឮការចរចារបស់ព្រះអានន្ទ និងសុភទ្ទ ក៏ទ្រង់ជ្រាបច្បាស់អំពីបំណងរបស់សុភទ្ទ ទើបព្រះអង្គទ្រង់ត្រាស់ប្រាប់ទៅព្រះអានន្ទឱ្យបើកឱកាសឱ្យសុភទ្ទបានឃើញព្រះអង្គចុះ ។

Ananda told him : "Subadda, this cannot be allowed. The Buddha is exhausted. You must not trouble Him with your questions". Subadda kept on seeking Ananda's permission, while Ananda continued to refuse. The Buddha overheard their conversation and realizing the intentions of Subadda, asked Ananda to give Subadda permission to see Him.

The Buddha calls Subadda to Him.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ហៅសុភទ្ទឱ្យចូលគាល់ព្រះអង្គ

ព្រះសម្មាសម្ពុទ្ធ មានព្រះបន្ទូលទៅកាន់ព្រះអានន្ទថា «ចូរអនុញ្ញាតឱ្យសុភទ្ទចូលមកគាល់តថាគតចុះ ។ គាត់មិនមានបំណងចង់បៀតបៀន នាំលំបាកដល់តថាគតដោយប្រស្នាមិនចាំបាច់នោះទេ ។ ប៉ុន្តែ គាត់ចង់រកឱ្យឃើញនូវដំណោះស្រាយ ចំពោះបញ្ហាពិតទាំងពួង ដែលទាក់ទងទៅនឹងព្រះធម៌របស់តថាគត » ។ ព្រះអានន្ទបានបើកឱកាសឱ្យសុភទ្ទចូលគាល់ព្រះសម្មាសម្ពុទ្ធ ។

The Buddha spoke to Ananda. "Please allow Subadda to come and see me. He does not want to trouble me with unnecessary questions. But wants to seek solutions for genuine problems regarding my Doctrine". Ananda gave Him permission to see the Buddha.

The Buddha preaches the Doctrine to Subadda and ordains him.
ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងធម៌ប្រោសសុភទ្ទ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានសវនាការចំពោះសុភទ្ទ និងសម្ដែងព្រះធម៌ទេសនាចំពោះសុភទ្ទ ដោយធ្វើឱ្យបញ្ហាទាំងប៉ុន្មានរបស់គាត់ត្រូវបានដោះស្រាយទាំងអស់ ។ សុភទ្ទបានទូលសូមបព្វជ្ជាពីសំណាក់ព្រះសម្មាសម្ពុទ្ធ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសប្រទានបព្វជ្ជាដល់សុភទ្ទ ។ ដោយហេតុនោះសុភទ្ទ គឺជាសាវ័កក្រោយគេបំផុតរបស់ព្រះសម្មាសម្ពុទ្ធ ។ ដូចគ្នានឹងកោណ្ឌញ្ញដែលបានស្ដាប់ព្រះបឋមទេសនារបស់ព្រះសម្មាសម្ពុទ្ធ សុភទ្ទក៏ដូច្នោះដែរ លោកបានខិតខំរៀនព្រះធម៌ ហើយនៅទីបំផុតបានសម្រេចជាព្រះអរហន្ត ។

The Buddha gave Subadda a hearing and preached him the Doctrine so that all his problems will be solved. Subadda requested the Buddha to ordain him. The Buddha ordained him. This way Subadda became the Buddha's last disciple. Just as Kondanna who listened to the Buddha's first Sermon, Subadda too studied the Doctrine and eventually attained Arahantship.



The Buddha preaches His last words to His Disciples.
ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានឱវាទចុងក្រោយដល់សាវ័កព្រះអង្គ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានឱវាទចុងក្រោយបំផុតដល់សាវ័ករបស់ព្រះអង្គ ដើម្បីជម្រះមន្ទិលសង្ស័យដែលម្នាក់ៗមានចំពោះព្រះធម៌ ។ ប៉ុន្តែ ពុំមានសាវ័កអង្គណាមានមន្ទិលសង្ស័យចំពោះព្រះសរណត្រ័យសោះឡើយ ។ នេះគឺជាពុទ្ធោវាទចុងក្រោយបំផុត «ម្នាលភិក្ខុទាំងឡាយ ! ពេលនេះជាឱកាសចុងក្រោយហើយ ដែលតថាគតទូន្មានអ្នកទាំងឡាយ ។ វត្ថុទាំងឡាយនៅក្នុងលោកនេះសុទ្ធតែមិនស្ថិតស្ថេរ ។ ចូរកុំមានឧបាទានចំពោះវត្ថុមិនស្ថិតស្ថេរទាំងនោះ ។ ចូរកុំពន្យារពេលក្នុងការកំចាត់ទុក្ខតទៅទៀតឡើយ » ។

The Buddha gave the disciples a final opportunity to clear any doubts anyone had, about the Doctrine. But, no one had any doubt whatsoever about the three Refuges. This was the Buddha's last advice: "O Bhikkhus, this is the last time I get to address you. Everything in the World is impermanent. Do not crave for impermanent things. Do not delay".

The Enlightened One Passes away at the age of Eighty at Kusinara.

ព្រះសម្មាសម្ពុទ្ធ ទ្រង់បរិនិព្វានក្នុងព្រះជន្មាយុប៉ែតសិបព្រះវស្សា នាក្រុងកុសិនារា

ព្រះសម្មាសម្ពុទ្ធទ្រង់យាងចូលកាន់ឈានយ៉ាងស្ងប់ ។ ព្រះអង្គទ្រង់ចូលកាន់បឋមជ្ឈានរួចបន្តពីនោះទ្រង់ចូលកាន់ចតុត្ថជ្ឈាន ។ ចាកផុតពីចតុត្ថជ្ឈាន ព្រះអង្គទ្រង់សម្រេចបាននូវព្រះនិព្វានដោយបរិបូរណ៍ ។ ចាប់ពីនេះតទៅ ព្រះអង្គលែងកើត និងលែងស្លាប់ទៀតហើយ ។ ព្រះសម្មាសម្ពុទ្ធ ដែលក្នុងពេលនោះមានព្រះជន្មាយុប៉ែតសិបព្រះវស្សា ទ្រង់បានសម្រេចព្រះនិព្វាននៅ ថ្ងៃពេញបូរមី ខែពិសាខ នាឧទ្យានសាលវ័នក្នុងក្រុងកុសិនារារបស់ពួកស្តេចមល្លរាជ ។

The Buddha entered into deep meditation. He entered the first stage and from there He entered the fourth stage. Liberating from the fourth stage He achieved the Great Demise. Hereafter He will not be born again and will not die again.

The Buddha who was eighty at that time attained the great Demise on the Full-moon Day of Vesak, in the Sala Grove, outside Kusinara, ruled by Malla Kings.

The Great Light of the World is gone. But the beacon of Dhamma lasts for Ages.
មហាពន្លឺ នៃពិភពលោកបានរលត់ទៅហើយ ប៉ុន្តែប្រទីបបំភ្លឺផ្លូវនៃព្រះធម៌នៅតែភ្លឺអស់កាលជាអង្វែងតទៅ

មហាពន្លឺដ៏ចិញ្ចាចបានរលត់បាត់ហើយ ។ ប៉ុន្តែ ចង្កៀងនៃពាក្យប្រៀនប្រដៅរបស់ព្រះអង្គនៅតែភ្លឺជារៀងរហូត ក្នុងការជួយ បុរស ស្ត្រីផងទាំងឡាយ ឱ្យឆ្លងផុតមហាសមុទ្រនៃវដ្តសង្សារបាន ។

The Bright Light went out. But the Lamp of His Teaching, remains bright forever enabling numerous men and women to cross the Ocean of Sansara.

លោវាទ សង្គារវៈ

ព្រះសូត្រដើម្បីជាប្រយោជន៍ ដល់មនុស្សជាតិ

LOVÄDA SANGARAVA

កំណត់សម្គាល់របស់អ្នកបកប្រែៈ

លោវាទ សង្គារវៈ នេះជាឈ្មោះកំណាព្យពន្យល់អំពីពុទ្ធសាសនាជាភាសាសិង្ហល ដែលនិពន្ធដោយព្រះភិក្ខុ វិទាគម មេត្រីមហាថេរោ ។



ប្រសិនបើ គេកើតជាសត្វតិរច្ឆាន
If one is born as an Animal

ប្រសិនបើ គេកើតជាសត្វតិរច្ឆាន គេពុំមានសេចក្ដីស្ងប់ខាងផ្លូវចិត្តដើម្បីបូជាខ្លួនចំពោះអំពើប្រកបដោយគុណធម៌ និងកុសលធម៌ បានឡើយ ។

If one is born as an animal, one does not have the peace of mind to devote one's self to virtuous and meritorious activities.

ប្រសិនបើ គេកើតជាប្រេតអសុរកាយ

If persons are born as manes-evil spirits

ប្រសិនបើ បុគ្គលណាកើតមកជាប្រេតអសុរកាយ គេមិនអាចទទួលសូម្បីល្អងធូលីមួយគ្រាប់ធ្វើជាអាហារបានឡើយ ។ ទាំងមិនអាចបំបាត់សេចក្តីស្រេកបាន សូម្បីគេធ្លាក់នៅក្នុងស្ទឹងនៃឋានសួគ៌ក៏ដោយ ។ ដូច្នេះ អំពើជាកុសលមិនអាចកើតមានបានឡើយ ទោះបីគេមានបំណងចង់ធ្វើក៏ដោយ ។

If persons are born as manes – evil spirits, they do not get even dirt for food. Nor can their thirst be quenched even if they fall in the heaven's river. Therefore, meritorious deeds cannot be done even if one desired.

សូម្បីអណ្តើកងើបពីបាតមហាសមុទ្រ

Even if a Turtle emerging from the depth of the Ocean

សូម្បីសត្វអណ្តើកសមុទ្រ ដែលងើបពីបាតមហាសាគរក្នុងមួយរយឆ្នាំម្តង ក៏គង់មានវាសនាបានឃើញពន្លឺតាមរន្ធក្លួនកំព្រា(១) ដែលរសាត់លើផ្ទៃទឹក តែចំពោះបុគ្គលដែលប្រព្រឹត្តអំពើបាបវិញ គេពុំមានវាសនាបានឃើញពន្លឺព្រះធម៌ទេ ទោះបីបានកើតមកជាមនុស្ស ហើយក៏ដោយ ។

Even if a turtle emerging from the depth of the ocean once in hundred years can get the chance of seeing through a stray reed, a person who has sinned has no chance whatsoever of being born as a human being.

(១) អ្នកស្រុកស្រីលង្កា យកបន្ទះក្តារ មកចោះរន្ធពីររាងដូចកាំច្រវាក់ ដើម្បីធ្វើជាក្លួនកំព្រាសម្រាប់ខ្ទាស់កាំនឹម



ជនប្រព្រឹត្តបាបកម្ម ៥យ៉ាងនៅក្នុងជាតិនេះ
People commit five-fold sins during this Birth

ជនប្រព្រឹត្តបាបកម្ម ៥យ៉ាងនៅក្នុងជីវិតនេះ លុះស្លាប់ពីជាតិនេះទៅ នឹងរងទុក្ខវេទនាគ្មានទីបញ្ចប់នៅឋាននរក ។ ដូច្នេះ សូមធ្វើឱ្យកំណើតជាមនុស្សនេះមានប្រយោជន៍ ដោយខំប្រមូលកុសលឱ្យបានច្រើន នៅក្នុងពេលកំពុងមានជីវិតរស់នៅ ។

People commit five – fold sins during this birth and after death too suffer endlesely in hell. Therefore, make this human existence worthwhile by gathering merit during your life-time.



ជនដែលមានភ្លើងឆេះសក់
A person whose hair is on fire

ជនដែលមានភ្លើងឆេះសក់ មិនអាចពន្យាពេលក្នុងការពន្លត់ភ្លើងនោះឡើយ ។ ដូចគ្នានេះដែរ ចូរកុំពន្យារពេលក្នុងការព្យាយាមបញ្ចប់សង្សារទុក្ខ ។

A person whose hair is on fire, will never delay to quell that fire. Similarly never delay in your effort to put an end to the suffering of sansara – (The ocean of rebirths).



មារៈ (សេចក្ដីស្លាប់) រង់ចាំមនុស្សជានិច្ចជាកាល នៅគ្រប់ទីកន្លែង
Mara (Death) awaits man always, in all places

មារៈ (សេចក្ដីស្លាប់) តែងតែរង់ចាំមនុស្សជានិច្ចជាកាល នៅគ្រប់ទីកន្លែង ។ ដូច្នេះ សូមទទួលយកពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទៅ ។ ចូរចៀសវាងការរាំរែក និងការសប្បាយភ្លើតភ្លើន ហើយព្យាយាមដណ្ដើមជ័យជំនះលើសង្សារទុក្ខវិញ ។

Mara (Death) awaits man always in all places. Therefore accept the teachings of the Buddha. Eschew, dancing and revelling and attempt to overcome the sufferings of sansara.

ដូចជាសុនខ លិតឆ្អឹងទទេដូច្នោះ
Just as a dog licking a dry bone

សត្វឆ្កែដែលលិតឆ្អឹងទទេ វាមិនបានស្គាល់រសជាតិឆ្ងាញ់យ៉ាងណា ជនដែលត្រេកត្រអាលនឹងកាមរាគៈ ក៏មិនដែលទទួលសេចក្តីសប្បាយរីករាយយ៉ាងដូច្នោះដែរ ។

Just as a dog licking a dry-bone does not derive a taste, those who indulge in sensual pleasures do not get a joy.

សត្វស្ទាំងកំពុងពាំសាច់មួយដុំ
A Hawk carrying a lump of flesh

សត្វស្ទាំងមួយក្បាល កំពុងពាំសាច់មួយដុំនឹងចំពុះវា ត្រូវសត្វស្ទាំងផ្សេងទៀតចឹកសម្លាប់ ។ ដូចគ្នានេះដែរ ជនណាដែលបណ្តោយខ្លួនឱ្យធ្លាក់ទៅក្នុងការភ្លើតភ្លើននៃកាមរាគៈ នឹងទទួលនូវសេចក្តីវិនាសអន្តរាយជាមិនខាន ។

A hawk carrying a lump of flesh in its beak is killed by other hawks. Similarly, those who indulge in sensual pleasures come to grief.



សត្វក្ដាមនៅក្នុងឆ្នាំងសប្បាយ រហូតដល់ភ្លើងឆេះពីក្រោមវា
The Crab in the pot is joyous until the fire is lit under it

សត្វក្ដាមនៅក្នុងឆ្នាំង សប្បាយរហូតដល់ភ្លើងឆេះក្ដៅពីក្រោមវាយ៉ាងណា ជនដែលសប្បាយនឹងកាមតណ្ហា ក៏មានឧបមេយ្យដូច្នេះដែរ ។

The Crab in the pot is joyous until the fire is lit under it. Those who enjoy sense-pleasure too are similar.

ស្មៅស្ងួត ត្រូវភ្លើងឆេះ
The burning dry grass

ស្មៅស្ងួតឆេះក្នុងដៃ អាចធ្វើឱ្យដៃរលាក ប្រសិនបើមិនទម្លាក់វាចោល ។ ជនដែលប្រកាន់យកកាមរាគៈ ថាជាបរមសុខក៏កំពូល នឹងបានដឹងថា ការត្រេកត្រអាលនោះជាផ្លូវនាំទៅកាន់ឋាននរកជាមិនខាន ។

The burning dry grass held in the hand will burn the hand if it is not dropped. Those who rate sensual pleasures as the highest bliss, will find it a path to hell.

ចោរត្រូវផ្តន្ទាទោសប្រហារជីវិត
The "Bandit condemned to death

ចោរដែលត្រូវផ្តន្ទាទោសដោយនាំទៅប្រហារជីវិត ត្រូវបានគេដង្ហែដោយក្រុមអ្នកវាយស្គរ និងតុបតែងដោយផ្កាពណ៌ក្រហម ។ ដូចគ្នានេះដែរ ជនដែលមានសេចក្តីលោភ យល់ថាទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ អាចបំភាន់សេចក្តីស្លាប់បាន ។

The bandit condemned to death is given a retinue of drums decked with red flowers. Similarly the greed one feels for wealth is a deception of the Mara (Death).

ចោរត្រូវគេប្រហារជីវិត ដោយច្រានទម្លាក់ពីលើចំណោតភ្នំ
The Bandit hurled down a precipice to his death

ចំពោះចោរ ដែលគេសម្លាប់ដោយច្រានទម្លាក់ពីលើចំណោតភ្នំនោះ ខ្យល់ពុំមានន័យអ្វីក្នុងការខ្ទប់ដង្ហើមចោរនោះទេ ។ ដូចគ្នានេះដែរ ចំពោះជនដែលត្រូវតែស្លាប់ និងចាស់ជរា តើកាមរាគៈ មានន័យអ្វីទៅ ?

To the bandit hurled down a precipice to death, the wind is of no use to quell his body-heat. Similarly, for those who are subject to death and decay, of what use is sensual pleasure?



បុរសទាំងឡាយត្រូវតែលះបង់
Men must renounce

បុរសទាំងឡាយត្រូវតែលះបង់នៅពេលដែលខ្លួនបានឃើញសេចក្ដីទុក្ខទាន់ហន់ ដែលកើតឡើងពីកាមរាគៈ ។ តើបុរសម្នាក់ដែលនៅលើចុងឈើមិនប្រវាចុះពីលើដើមឈើនោះ នៅពេលគាត់ឃើញថា មានគេកំពុងកាប់ដើមឈើនោះ ឬទេ?

Men must renounce when they see the dire suffering brought on by sensual pleasure. Will a man on top of a tree, not climb down when he sees that the tree is being cut down?

ជនដែលចូលចិត្តបរិភោគអាហារឆ្ងាញ់
People who enjoy delicious food

ជនដែលចូលចិត្តបរិភោគអាហារឆ្ងាញ់ លាបគ្រឿងក្រអូប និងស្លៀកសំពត់អាវល្អៗ ជននោះប្រៀបដូចជាតួល្ខោនដែលកំពុងសម្ដែងជាបណ្ដោះអាសន្ន មុនពេលចុះចេញពីលើឆាក ។

People who enjoy delicious food, wear perfumes and fine clothes are like actors who are temporarily on stage before their exit.



ថ្វីបើយើងពេញចិត្តនឹងសេចក្ដីរីករាយដែលយើងមាន
Though we are proud of the pleasures we enjoy

ថ្វីបើយើងពេញចិត្ត ចំពោះសេចក្ដីសប្បាយរីករាយដែលយើងទទួលបាន តែនោះវាជាការក្លែងបន្លំ ដូចជាគ្រឿងក្រអូប ដែលគេលាបក្នុងសុបិន្តដូច្នោះដែរ ។ ប្រសិនបើ អ្នកគ្មានគុណធម៌ទេ កម្មរបស់អ្នកនឹងនាំអ្នកពីទីភ្លឺទៅកាន់ទីងងឹតហើយ ។

Though we are proud of the pleasures we enjoy, they are as false as perfumes worn in a dream. If you are not virtuous, your Kamma will take you to the darkness from the light.



នៅពេលដែលផ្ទះអ្នកជិតខាងត្រូវចោរប្លន់

When a neighbour's house is burgled

នៅពេលដែលផ្ទះអ្នកជិតខាងត្រូវចោរប្លន់ មនុស្សម្នាតែងការពារផ្ទះរបស់ខ្លួនទ្វេឡើង ។ ប៉ុន្តែ ហេតុដូចម្តេចបានជាគេមិនរស់នៅប្រកបដោយគុណធម៌ នៅពេលដែលគេបានឃើញថា យមរាជប្រមូលយកសត្វមានជីវិតទាំងអស់នោះ? ។

When a neighbour's house is burgled, people protect their own houses with double care. But how is it that they do not lead virtuous lives when they see that death takes away all beings?



ក្អែកលោភស៊ីសាកសពដំរី

The greedy Crow feeding on the carcass of an Elephant

សត្វក្អែក ដ៏លោភមួយក្បាល ទំស៊ីសាកសពដំរីដែលកំពុងអណ្តែតទឹកស្ទឹង រហូតដល់ខ្សែទឹកនាំវាទៅដល់កណ្តាលសមុទ្រ ហើយក៏លង់ងាប់បាត់ទៅ ។ ប្រសិនបើ បុគ្គលណាម្នាក់លោភនឹងទ្រព្យសម្បត្តិដែលខ្លួនមាន បុគ្គលនោះនឹងពុំអាចឆ្លងផុតមហាសមុទ្រ នៃវដ្តសង្សារឡើយ ។

The greedy crow feeding on the carcass of an elephant floating down a river, is taken to mid-ocean and death. If, a man were to be greedy of one's wealth he will never be able to cross the ocean of existence.

បុរសម្នាក់លង់ទឹកដោយគ្មានគេជួយ
A Man taken helplessly down the river

បុរសម្នាក់លង់ទឹកស្ទឹង ពេលមានទឹកជំនន់ដោយគ្មានគេជួយ មិនអាចឡើងលើទូកដែលគេអុំនៅក្បែរខ្លួនបានឡើយ ។ យ៉ាងណាមិញ ជនដែលមិនយកចិត្តទុកដាក់ស្តាប់ធម៌ទេសនាដែលណែនាំទៅរកបរមសុខ មានខ្លះនឹងរងទុក្ខក្នុងស្ថាននរក ។

A man taken helplessly down the river by flood does not get into the boat brought near him. In the same way, without heeding the preaching that confers bliss some suffer in hell.



ជនដែលប្រើសំដីរអេចរអូចជាអាវុធប្រល័យជីវិត
People use the deadly weapon of tale-bearing

ជនដែលប្រើពាក្យសំដីញុះញង់រអេចរអូច ជាអាវុធប្រល័យជីវិត និងបំផ្លាញភាពសុខដុមរវាងមនុស្សផងគ្នា ក៏ព្រោះតែជននោះល្ងង់ខ្លៅមិនយល់អំពីសេចក្ដីទុក្ខវេទនាទៅអនាគត ដែលបណ្ដាលមកពីអំពើទាំងនោះ ។

People use the deadly weapon of tale-bearing and destroy harmony between people, because they are ignorant of the future suffering it causes.

កង្កែបនៅពេលវាកំពុងធ្លាក់ខ្លួនជាចំណីនៃសត្វពស់

The frog while being a prey to snakes

សត្វកង្កែបពេលកំពុងធ្លាក់ខ្លួនជាចំណីនៃសត្វពស់ទៅហើយ ក៏នៅតែស៊ីជន្លេនយ៉ាងសប្បាយ ។ មនុស្សក៏ដូចគ្នានេះដែរ ថ្វីបើគេជាចំណីរបស់មារៈ (សេចក្ដីស្លាប់) ក៏ដោយ ក៏គេនៅតែបំផ្លាញជីវិតអ្នកដទៃ ។

The frog while being a prey to snakes, eats worms with enjoyment. Similarly man though he is the prey of Mara (Death) destroys the lives of others.

រឿងស្ត្រីម្នាក់បានកាត់កពពែញី
Once, a woman cut off the head of a she-goat

គ្រាមួយនោះ មានស្ត្រីម្នាក់បានកាត់កសត្វពពែញីមួយក្បាល រួចហើយបានធ្លាក់ទៅសោយទុក្ខ ក្នុងឋាននរកដោយសារអំពើនោះ ។ នាងនោះត្រូវគេកាត់កវិញជាច្រើនដង ស្មើនឹងចំនួនសក់ដែលនាងមាន ។ នេះគឺជាវាសនានៃមនុស្សដែលបានប្រព្រឹត្តបាបកម្ម ។

Once a woman cut off the neck of a she-goat and suffered in hell because of that action. She had her own head cut off as many times as she had hair on her body. This is the fate of all who commit sin.



រឿងបុរសម្នាក់ លួចសំលៀកបំពាក់សម្លាញ់របស់ខ្លួនលេងជាល្បែង
Once, a man stole his friend's clothes for fun

ម្តងនោះមានបុរសម្នាក់ បានលួចសំពត់អាវសម្លាញ់របស់ខ្លួនលេងជាល្បែង ហើយក្រោយមកបានយកមកប្រគល់ឱ្យសម្លាញ់គាត់វិញ ។ ប៉ុន្តែ ទោះបីបានប្រព្រឹត្តអំពើខុសឆ្គងក្នុងរយៈពេលដ៏ខ្លីក៏ដោយ ក៏ដល់ពេលជននោះទៅកើតជាទេព្តា គាត់ក៏អត់មានខោអាវស្លៀកពាក់ដែរ ។ ដូច្នេះ ការលួចរបស់គេ ជាអំពើគប្បីចៀសវាងកុំប្រព្រឹត្តឱ្យសោះ ។

Once a man stole his friend's clothes for fun and gave them back to him later. But, even for that lapse he was without clothes, though born a deity. Stealing should be shunned.

ជនមានបាបដោយលួចប្រពន្ធអ្នកដទៃ
A Sinner who coveted the wife of another

បាបជន ដែលលួចប្រពន្ធអ្នកដទៃ នឹងរងទុក្ខវេទនានៅស្ថាននរក ចំពោះបទឧក្រិដ្ឋ ដែលខ្លួនបានប្រព្រឹត្ត ។ ជនទាំងឡាយ ដែលប្រកបដោយគតិបណ្ឌិតមិនដែលប្រព្រឹត្តបាបកម្មបែបនេះទេ ។

A sinner who coveted the wife of another is still suffering in hell for that crime. Wise people never commit such sin.

ព្រះរាជាសម័យបុរាណមួយអង្គ បាត់បង់មហិទ្ធិឫទ្ធិ
An ancient King lost His psychic powers

ព្រះរាជាសម័យបុរាណមួយអង្គ បានបាត់បង់មហិទ្ធិឫទ្ធិរបស់ខ្លួន ហើយធ្លាក់ទៅស្ថាននរកយ៉ាងឆាប់បំផុតនៅពេលគាត់និយាយកុហក ។ ការពោលពាក្យភូតកុហក គឺជាបាបកម្ម ។

An ancient king lost his psychic powers and was dragged down to Hell, the moment he uttered a lie. Lying is sinful.

ជនដែលញុះញង់ឱ្យភិក្ខុពីរអង្គទាស់ទែងគ្នា
A person who crested dissension between two Bhikkhus

ជនដែលនាំរឿងចុះឡើង ដើម្បីញុះញង់ឱ្យភិក្ខុសង្ឃពីរអង្គទាស់ទែងគ្នា នឹងធ្លាក់ទៅកើតនៅស្ថាននរក ។ បន្ទាប់ពីរងទុក្ខវេទនានៅទីនោះ គាត់នឹងទៅកើតជាអសុរកាយ ដែលមានមុខវៀចខុសធម្មតា ។ ការនិយាយញុះញង់រអេចរអូចជាអំពើបាបដ៏ធ្ងន់មួយ ។

A person who created dissension between two Bhikkhus by carrying tales was born in Hell. After that suffering, he was born an Evil spirit with face deformed. Bearing tales is a grievous sin.



រឿងតាបសតិះដៀលព្រះសង្ឃ
Once an Ascetic scolded the Sangha

ម្តងនោះ មានតាបសម្នាក់បានស្តីបន្ទោសភិក្ខុសង្ឃ ដោយប្រើពាក្យអសុរោះ ។ ជាលទ្ធផលគាត់បានធ្លាក់ទៅស្ថាននរក ហើយក្រោយមកបានកើតជាអសុរកាយ ។ អ្នកត្រូវតែចៀសវាងកុំប្រើពាក្យអសុរោះ ។

Once an Ascetic scolded the Sangha in harsh words. And as a result he suffered in hell and was later born an Evil spirit. One must refrain from using harsh words.



ការបីបាច់រក្សាភិក្ខុសង្ឃ ឪពុកម្ដាយ គ្រូអាចារ្យ ចាស់ជរា និងជនពិការ

The care of Bhikkhus, Parents, Teachers, the Old, the Infirm

ការបីបាច់រក្សាភិក្ខុសង្ឃ ឪពុកម្ដាយ គ្រូបាធ្យាយ មនុស្សចាស់ជរា ជនពិការ មនុស្សពេញវ័យ និងអ្នកជម្ងឺ នឹងទទួលបាននូវសម្បត្តិសួគ៌ ។

The care of Bhikkhus, parents, teachers, the old, the infirm, the adults and the sick, earns heavenly comfort.



រឿងសូមយាចកម្នាក់ គ្រាន់តែដាក់បាត្របាយមួយស្លាបព្រា ចំពោះព្រះអនុរុទ្ធថេរ
Once a Begger gave just a spoonful of Rice to Anuruddha Thero

ម្តងនោះ មានសូមយាចកម្នាក់ បានយកបាយមួយស្លាបព្រាទៅប្រគេនព្រះអនុរុទ្ធថេរ ហើយបានទៅកើតជាព្រះឥន្ទ ។ នេះជាផលនៃការធ្វើទាន ។

Once a beggar gave just a spoonful of rice to Anuruddha Thero and was born the chief of Gods. This is the fruit of giving.



ស្ត្រីម្នាក់ ដែលបានកាន់សីលដ៏បរិសុទ្ធ បានតែមួយថ្ងៃប៉ុណ្ណោះ
A Woman who observed virtuous Sila just one day

ស្ត្រីម្នាក់ ដែលបានកាន់សីលបានតែមួយថ្ងៃប៉ុណ្ណោះ ដល់ពេលស្លាប់ទៅមានស្ត្រីទេពអប្សរមួយពាន់នាក់ជាបរិវារ និងសោយសុខនៅស្ថានសួគ៌ជាមួយព្រះឥន្ទ្ររហូត ។ ដូច្នេះ ចូរកុំរស់នៅដោយគ្មានសីលសោះនោះ ។

A woman who observed virtuous "Sila" just one day had a retinue of one thousand celestial maidens and is still enjoying heavenly pleasure in the company of the chief of gods. Therefore never lead a life devoid of sila.

សត្វកង្កែបកំពុងស្តាប់ធម៌របស់ព្រះពុទ្ធ

A Frog listening to the Word of the Buddha

សត្វកង្កែបមួយក្បាល ដែលងាប់ដោយសារគេច្រត់ឈើច្រត់ពីលើ ក្នុងពេលវាកំពុងស្តាប់ធម៌ព្រះពុទ្ធ បានទៅកើតជាទេព្តា នៅស្ថានសួគ៌ ។ ដូច្នេះ ចូរកុំស្ទាក់ស្ទើរនឹងស្តាប់ព្រះធម៌ ។

A frog listening to the word of the Buddha, died pierced by a walking stick and was born in Tidasa Heaven. Never be reluctant to listen to Dhamma.

ជនទុរគតម្នាក់ បានបូជាផ្កាព្រលិតមួយទងចំពោះព្រះចេតិយ
A poor person offered a humble water-flower to a Stupa

ជនទុរគតម្នាក់ បានថ្វាយផ្កាព្រលិតមួយទងចំពោះពុទ្ធចេតិយ ។ ដោយសារអំពើជាកុសលនោះ គាត់បានទៅកើតជាស្ដេចចក្រពត្តិប្រាំរយដង ។ បរមសុខ នឹងកើតមានពីតង្វាយបែបនេះ ។

A poor person offered a humble water flower to a Thupa. Due to that merit he was born as universal king 500 times. Bliss will come from such offerings.

ការបំពេញបារមី
PĀRAMITĀ
Perfections

ព្រះពោធិសត្វ ត្រូវមានការកសាងបារមីធម៌បានយ៉ាងបរិបូណ៌ ទើបបានសម្រេចនូវការត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ។ ឯបារមីធម៌នោះ មាន១០យ៉ាង ។ ព្រះពោធិសត្វ ប្រឹងប្រែងកសាងបារមីដោយការព្យាយាមមាំ មិនគិតពីអំណាច ឬកិត្តិស័ព្ទផ្ទាល់ព្រះអង្គឡើយ ។

បារមីទាំង១០នោះ គឺទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វិរិយបារមី ខន្តីបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និងឧបេក្ខាបារមី ។

The Aspirant Buddha, must practice ten supreme virtues, in order he may obtain Samma Sambodhi (Enlightenment). These ten are described as the Ten Paramis or Perfections. The Aspirant Buddha cultivates these, with absolute selflessness. He perfects these virtues, with no thought whatsoever of personal power or glory to himself.

The ten perfections are Dana (Generosity), Sila (Morality) Nekkhamma (Renunciation), Panna (Wisdom) Viriya (Unceasing effort), Khanti (Patience) Sacca (Truthfulness) Adhitthana (Determination) Metta (Loving kindness) and Upekkha (Equanimity).

ទានបារមី

(ព្រះវេស្សន្តរជាតក)

សម័យមួយ ព្រះពោធិសត្វនៃយើងបានកើតជាព្រះវេស្សន្តរ ពេលប្រសូត្រមកភ្លាម ទ្រង់លាព្រះហស្តសុំរាជទ្រព្យ ដើម្បីបរិច្ចាគទាន ។ កាលនៅជាកុមារព្រះវេស្សន្តរបានប្រទានគ្រឿងអលង្ការដែលមានតម្លៃដល់ស្រ្តីមេដោះព្រះអង្គផ្ទាល់ ។ ពេលចំរើនវ័យវឌ្ឍនាការឡើង ព្រះអង្គបានរៀបអភិសេកជាមួយព្រះនាង មទ្រី ក្រោយមកប្រសូត្របានព្រះរាជបុត្រមួយព្រះអង្គព្រះនាម ជាលី និងព្រះរាជធីតាមួយអង្គព្រះនាម ក្រិស្នា ។ ពេលព្រះអង្គឡើងគ្រងរាជសម្បត្តិជាស្តេចប្រចាំព្រះនគរជេតុត្តរ មាននគរមួយទៀតឈ្មោះ កលិង្គរាស្រ្ត កើតគ្រោះទុរ្ភិក្ស ព្រោះគ្មានភ្លៀងធ្លាក់ជាច្រើនឆ្នាំបានចាត់ព្រាហ្មណ៍ជាតំណាងឱ្យចូលគាល់ព្រះបាទវេស្សន្តរដើម្បីសុំដំរីឈ្មោះបច្ច័យនាគេន្ទ្រដែលជាដំរីមង្គលប្រចាំព្រះនគរ អាចធ្វើឱ្យភ្លៀងធ្លាក់ចុះបានតាមប្រាថ្នា យកទៅនគររបស់ខ្លួន ។ ព្រះវេស្សន្តរ បានឱ្យដំរីបច្ច័យនាគេន្ទ្រជាទានដល់ពួកព្រាហ្មណ៍ទាំងនោះ តាមសំណូមពរ ។ មនុស្សក្នុងព្រះនគរ មានការខឹងសម្បានឹងព្រះអង្គខ្លាំងណាស់ ហើយបាននាំគ្នាបណ្តេញព្រះអង្គចេញពីព្រះនគរឱ្យទៅរស់នៅក្នុងព្រៃ ។ ព្រះវេស្សន្តរ បានបួសជាតាបសអាស្រ័យនៅក្នុងព្រៃជាមួយព្រះនាងមទ្រី និងព្រះរាជកុមារទាំងពីរ ។ មានព្រាហ្មណ៍ចាស់ម្នាក់ឈ្មោះ ជូជក បានមកសុំព្រះរាជកុមារទាំងពីរធ្វើជាទាសាទាសី ព្រះអង្គបានឱ្យក្មេងទាំងពីរនោះជាទានទៀត ។ ក្រោយមកទៀត ព្រះឥន្ទបាននិមិត្តខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់ មកសុំយកព្រះនាងមទ្រីធ្វើជាទាសី ព្រះអង្គបានបរិច្ចាគព្រះនាងជាទានទៀត តែព្រះឥន្ទបានប្រែខ្លួនជារូបដើម ហើយថ្វាយព្រះនាងមទ្រីត្រឡប់ទៅព្រះអង្គវិញ ។ ព្រះរាជកុមារទាំងពីរត្រូវបានព្រះអយ្យកោអយ្យកា លោះពីតាជូជកយកមកព្រះនគរវិញ ។ ព្រះវេស្សន្តរ ត្រូវបានព្រះវររាជមាតាបិតា និងអ្នកនគរយាងត្រឡប់មកគ្រងរាជ្យក្នុងព្រះនគរវិញ ។ ព្រះអង្គបានបំពេញទានបារមី អស់រយៈពេល៧ខែ ។

The Perfection of Generosity (DÃNA)

Vessantara Birth Tale (Vessantara Jatake Story).

Once The Bodhisatva (The Aspirant Buddha) was born Prince Vessantara. Immediately after being born, he stretched his hand asking for something to be given as a gift. In his childhood, Prince Vessantara, gave all his costly ornaments to his wet nurses. When he grew up into youth he married Madri Devi and became king. They had two children son Jaliya and daugthter Krishnajina. When he was king representatives of Kalinga kingdom, where there had been no rain for a long spell, came to king Vessantara and asked him to donate them his Auspicious Elephant, that had the power to create rain. King Vessantara gave them the elephant. The people of the country became angry at that and he was sent into exile in the wildreness. There while he was practising austerities, with his queen and two children, and old Brahman called Jujaka came and asked the two children as a gift. The king gave them to the old Brahman. The chief of gods' determined to test the king's generosity came in the guise of an old man and asked that the queen be given to him. The king gifted the queen. The chief of gods, revealed his true identity and gave back the queen to the king. The two children were eventually rescued by their grand father and king Vessantara was brought back as king. For seven months he perfected generosity.







សីលបារមី

(ឆទ្ទន្តជាតក)

គ្រាមួយនោះ ព្រះពោធិសត្វកើតជាដំរីនៅជើងភ្នំហេមពាន្ត ជាស្តេចនៃដំរីហ្វូង ។ មានដំរីញីមួយឈ្មោះ ចុល្លសុភទ្រា បានងប់ស្រឡាញ់ស្តេចដំរី មានចិត្តប្រច័ណ្ឌហើយចងអាឃាតជាមួយស្តេចដំរីនោះដោយប្រាថ្នាថាសុំបានកើតជាបុត្រីរបស់ស្តេចក្នុងជាតិបន្ទាប់ ។

ពេលវេលាចេះតែកន្លងទៅ លុះអស់អាយុ នាងដំរីញីនោះបានមកកើតជាព្រះរាជបុត្រី ដូចដែលនាងបានប្រាថ្នាមែន ។ នាងបានជាស្នំឯករបស់ស្តេចនគរពារាណសី បានរំលឹកឃើញជាតិដែលកើតជាដំរីញី ហើយសម្រេចចិត្តធ្វើការសងសឹកស្តេចដំរីវិញ បានទូលអង្វរទៅព្រះស្វាមីថា នាងចង់បានភ្លុកទាំងពីររបស់ស្តេចដំរីខ្លាំងណាស់ ។ ព្រះចៅពារាណសីបញ្ជានាយព្រានព្រៃឈ្មោះ សោនុត្តរៈ ឱ្យចូលទៅក្នុងព្រៃដើម្បីបរបាញ់ ហើយនាំភ្លុកដំរីទាំងពីររបស់ស្តេចដំរី មកថ្វាយព្រះអង្គឱ្យបានឆាប់ ។ ព្រានព្រៃបានបាញ់ស្តេចដំរីឱ្យរបួសឯព្រះពោធិសត្វក៏មានបំណងបរិច្ចាគភ្លុកជាទានដល់ព្រានដែរ ។ ព្រានព្រៃបាននាំភ្លុកស្តេចដំរីថ្វាយដល់ព្រះស្នំឯក ។ ស្នំយល់ច្បាស់នូវភ្លុកដំរី ក៏កើតទុក្ខក្រៀមក្រំ ព្រោះកើតវិប្បដិសារីនឹងអំពើបាបដែលខ្លួនប្រព្រឹត្ត ហើយក៏ស្លាប់ទៅ ។

Perfection of Morality.

Chaddanta Jataka (Birth Story)

The Aspirant Buddha was once born in the Hinalayas as The leader of a herd of elephants. A she elephant by the name of Chulla Subadra, became jealous of the king elephant and decided to take revenge of him, when she would be born as a princess. As she wished, the she elephant, after her death was born as a princess and eventually became the chief consort of the king of Benares. Recalling her past birth, she decided to destroy the king elephant. She informed her husband the king that she desired very much to possess the two tusks of the elephant king. A forest chief, an able hunter – Sonuttara was sent to the wilderness to bring back the tusks. He laid a trap and wounded the king elephant. The Bodhisatva elephant himself, willingly donated his tusks to the Hunter. He brought the tusks to the queen. The queen realizing the gravity of the crime she committed, died of grief.



នេក្ខម្មបារមី

(មឃទេវជាតក)

ពេលមួយនោះ ព្រះពោធិសត្វនៃយើងកើតជាស្តេចឈ្មោះ មឃទេវៈ ក្នុងនគរវិទេហៈ ។ ព្រះអង្គស្ថិតនៅក្នុងភាពជាក្សត្របានគ្រប់គ្រងព្រះនគរប្រកបដោយធម៌ អស់កាលដ៏យូរ ។

ថ្ងៃមួយ ព្រះអង្គមានបន្ទូលទៅកាន់នាយខ្មាន់ព្រះកេសថា «ម្នាលខ្មាន់ព្រះកេស ! ពេលណាអ្នកឃើញសក់របស់យើងស្កូវ សូម្បីតែមួយសរសៃក៏ដោយ ចូរប្រញាប់ប្រាប់យើងឱ្យដឹងភ្លាម » ។ ក្រោយមក នាយខ្មាន់ព្រះកេសសង្កេតឃើញមានសក់មួយសរសៃស្កូវក្នុងចំណោមព្រះកេសារបស់ព្រះរាជា គាត់បានដកយកទៅដាក់លើព្រះហស្តព្រះរាជា ។ ព្រះអង្គពិចារណាឃើញសក់ស្កូវថាជាទូតរបស់មច្ចុរាជ ហើយក៏សម្រេចចិត្តលះបង់រាជសម្បត្តិ និងព្រះនគរ ចេញទៅបួសជាតាបសនៅក្នុងព្រៃស្ងាត់តែឯង ខិតខំប្រតិបត្តិធម៌យ៉ាងល្អអស់កាលជាយូរ លុះពេលអស់ព្រះជន្មបានទៅកើតក្នុងត្រកូលព្រហ្មលោក ។

Perfection of Renunciation

Makhadeva Jataka (Birth Story)

Once, the Aspirant Buddha was born as King Makhadeva of Videha. He ruled his country virtuously for quite a long while. He experienced the luxuries of kingly life for many years. One day, he summoned his barber and said to him: "Friend Barber, when you see a grey hair among my locks please let me know". After a long while the Barber noticed a grey hair among the King's locks. He placed the grey hairs on the King's palm. Considering these grey hairs as messengers of Death, he decided to renounce. He left his Kingdom, and took to the life of a wandering ascetic. After long years of ascetic life, he died and was born in the abode of Brahma.



បញ្ញាបារមី

(សាធុតន្ទជាតក)

ព្រះពោធិសត្វនៃយើង កើតជាបណ្ឌិតមានប្រាជ្ញាឈ្លាសវៃណាស់ ។ ពេលមួយនោះ មានព្រាហ្មណ៍ចាស់ម្នាក់បានទទួលនាងព្រាហ្មណី ក្រមុំម្នាក់មានវ័យក្មេង និងរូបស្អាត ជាថ្នូរនៃការកាត់បំណុលមកធ្វើជាភរិយា ។ ក្រោយមក ភរិយាក្មេងនោះបានលបលាក់មានសាហាយ ដើម្បីបំពេញបំណងតណ្ហាពេលប្ដីចាស់មិននៅផ្ទះ ។ ប្រពន្ធក្មេងនោះ បានបង្ខំព្រាហ្មណ៍ចាស់ឱ្យចេញទៅស្រុកឆ្ងាយដើម្បីសុំទាន ហើយទិញខ្ញុំប្រុសស្រីទុកគ្រាន់បំរើការងារក្នុងផ្ទះ ។ ព្រាហ្មណ៍ចាស់បានចេញដំណើរទៅ មានត្រឹមតែថង់អាហារមួយប៉ុណ្ណោះ ។ គាត់ដើរសុំទានគេគ្រប់ច្រកល្ហក ហើយសន្សំលុយបានច្រើន ក៏ចូលទៅទីក្រុងរកទិញខ្ញុំបំរើ ។ ពេលឃ្លានបាយ តាព្រាហ្មណ៍អង្គុយក្រោមម្លប់ឈើ ស្រាយមាត់ថង់យកកញ្ចប់បាយចេញដើម្បីហូប គាត់មិនទាន់បានចងមាត់ថង់បិទវិញទេ ហើយដើរចេញទៅរកទឹកផឹក ។ ពេលគាត់ចេញទៅឆ្ងាយ មានពស់កំណាចមួយលូនចូលថង់អាហារដើម្បីស៊ីចំណី ។ ព្រាហ្មណ៍ចាស់ត្រឡប់មកវិញ ក៏ចងមាត់ថង់បិទជិត ដោយមិនដឹងថាមានពស់កំណាចនៅក្នុងថង់ឡើយ ហើយស្ពាយថង់បន្តដំណើរទៅមុខទៀត ។

ទេវតាដែលអាស្រ័យលើដើមឈើ បានឃើញហេតុការណ៍នោះ បានសំដែងខ្លួនឱ្យព្រាហ្មណ៍ឃើញ ហើយពោលថា «ម្នាលព្រាហ្មណ៍ ! ប្រសិនបើអ្នកឈប់តាមផ្លូវអ្នកនឹងស្លាប់ តែបើអ្នកទៅដល់ផ្ទះប្រពន្ធអ្នកនឹងស្លាប់» ។ ព្រាហ្មណ៍មិនយល់ន័យដែលទេវតាបានប្រាប់នោះទេ ក៏កើតទុក្ខយ៉ាងខ្លាំងដើរផងយំផង ក៏បានជួបមនុស្សជាច្រើនដើរទៅកាន់ធម្មសភាព្រះពោធិសត្វ ដើម្បីស្ដាប់ធម៌ទេសនា ។ ព្រាហ្មណ៍ចាស់ក៏ទៅកាន់ទីនោះដែរ ហើយអង្គុយនៅចុងក្រោយនៃក្រុមមនុស្ស ។ ព្រះពោធិសត្វ បានឃើញព្រាហ្មណ៍ចាស់យំ ក៏សួររកហេតុផលដែលនាំឱ្យគាត់កើតទុក្ខ ។ ព្រាហ្មណ៍ចាស់បានរៀបរាប់នូវអ្វីដែលទេវតាបានប្រាប់គាត់ ។ ដោយប្រាជ្ញាគ្មានគូប្រៀប ព្រះពោធិសត្វបានយល់នូវអ្វីដែលបានកើតឡើង ហើយបានប្រាប់ទៅព្រាហ្មណ៍ពីពស់កំណាចនៅក្នុងថង់អាហារដែលគាត់កំពុងស្ពាយ ប្រសិនបើគាត់ឈប់តាមផ្លូវ ហើយស្រាយថង់លូកដៃយកអាហារ ពស់នឹងចឹកគាត់ស្លាប់មួយរំពេច ម៉្យាងវិញទៀតបើគាត់ទៅដល់ផ្ទះប្រពន្ធគាត់លូកដៃចូលថង់យករបស់ដែលប្ដីរកបានមក ក៏ពស់នឹងចឹកប្រពន្ធគាត់ស្លាប់ភ្លាមដែរ ។

មហាបណ្ឌិត សុំឱ្យព្រាហ្មណ៍ឈរជាមួយនឹងដំបងវែង ហើយបើកមាត់ថង់ ពេលនោះពស់កំណាចបានលូនចេញមកក្រៅថង់ ។ ហ្វូងមនុស្សបានស្រែកអបអរសាទរលាន់កងរំពង កោតសរសើរចំពោះប្រាជ្ញាព្រះពោធិសត្វ ។

ព្រះពោធិសត្វបានសាកសួរពីដំណើរព្រាហ្មណ៍ចាស់ហើយប្រាប់ថាប្រពន្ធក្មេងរបស់តាព្រាហ្មណ៍មានសាហាយលួចលាក់ ។ ព្រះពោធិ-សត្វប្រាប់ព្រាហ្មណ៍ឱ្យលាក់មាសទុកសិនសឹមទៅជួបប្រពន្ធ ហើយមិនឱ្យប្រាប់ប្រពន្ធពីមាស ឬកន្លែងលាក់មាសឡើយ ។ ព្រាហ្មណ៍ចាស់ទៅដល់ផ្ទះ នាងប្រពន្ធបានឱ្យសាហាយដែលនៅក្នុងផ្ទះចេញទៅក្រៅ ហើយសួររកមាសដែលរកបាន ។ ព្រាហ្មណ៍ចាស់មិនអាចលាក់អាថ៌កំបាំងបានឡើយ ក៏ប្រាប់កន្លែងលាក់មាសដល់ប្រពន្ធ ។ សាហាយបានលបស្ដាប់ដឹងរឿង ក៏ទៅលួចគាស់យកមាសនោះអស់ទៅ ។ ព្រឹកស្អែកឡើង ព្រាហ្មណ៍ចាស់ទៅរកមាសដែលខ្លួនបានលាក់ទុក តែរកមិនឃើញ គាត់បានត្រឡប់ទៅរកព្រះពោធិសត្វ ហើយបានប្រាប់ពីអ្វីដែលកើតឡើង ។

ព្រះពោធិសត្វ បានសុំឱ្យតាព្រាហ្មណ៍ដាក់ទានចំនួនប្រាំពីរថ្ងៃ ។ ថ្ងៃទីមួយសុំឱ្យគាត់អញ្ជើញព្រាហ្មណ៍ប្រាំពីររូប ហើយប្រពន្ធតាព្រាហ្មណ៍ ក៏សុំឱ្យអញ្ជើញប្រាំពីររូបដែរ ហើយនៅថ្ងៃបន្ទាប់តាព្រាហ្មណ៍ត្រូវនិមន្តបន្ថយម្នាក់ ឯនាងប្រពន្ធក៏ត្រូវបន្ថយម្នាក់រហូតរាល់ថ្ងៃ ដោយធ្វើបែបនេះ នៅថ្ងៃចុងក្រោយបំផុតនាងប្រពន្ធអញ្ជើញតែម្នាក់ប៉ុណ្ណោះ ។ ព្រះពោធិសត្វសុំឱ្យសង្កេតនៅថ្ងៃទីប្រាំពីរ តើព្រាហ្មណ៍ណាមួយដែលប្រពន្ធក្មេងរបស់តាព្រាហ្មណ៍អញ្ជើញមក និងផ្ដល់ព័ត៌មានអំពីបុគ្គលិកលក្ខណៈរបស់ព្រាហ្មណ៍ទៅព្រះអង្គ ។

ព្រាហ្មណ៍ចាស់បានធ្វើតាមព្រះពោធិសត្វបង្គាប់គ្រប់ប្រការ ហើយបានកត់សម្គាល់ឃើញនូវព្រាហ្មណ៍ដែលប្រពន្ធគាត់អញ្ជើញនៅថ្ងៃទីប្រាំពីរ រួចជូនដំណឹងទៅព្រះពោធិសត្វថាព្រាហ្មណ៍នេះជានរណា ។ ព្រះអង្គបានបញ្ជូនមនុស្សទៅនាំខ្លួនព្រាហ្មណ៍ដែលប្រពន្ធព្រាហ្មណ៍ចាស់អញ្ជើញនៅថ្ងៃទីប្រាំពីរនោះមកកាន់សំណាក់ព្រះអង្គ ។ នៅពេលព្រះពោធិសត្វសាកសួរ ព្រាហ្មណ៍នោះបានសារភាពថាគាត់បានប្រព្រឹត្តសាហាយស្មន់ជាមួយប្រពន្ធព្រាហ្មណ៍ចាស់មែន ព្រមទាំងបានលួចយកមាសតាព្រាហ្មណ៍ផងដែរ ។ ព្រះពោធិសត្វសុំឱ្យព្រាហ្មណ៍ក្មេងនោះយកមាសមកសងតាព្រាហ្មណ៍ជាម្ចាស់វិញ ។ មហាបណ្ឌិតសួរទៅព្រាហ្មណ៍ចាស់ថា តើចង់រួមរស់ជាមួយប្រពន្ធវិញទេ? នៅពេលតាព្រាហ្មណ៍ឆ្លើយថា គាត់ស្រឡាញ់ប្រពន្ធគាត់ និងចង់រស់នៅជាមួយគ្នាតទៅទៀត ព្រះពោធិសត្វបានឱ្យដំបូន្មានល្អៗដល់ព្រាហ្មណ៍ទាំងពីរនាក់ប្ដីប្រពន្ធ ដើម្បីឱ្យអ្នកទាំងពីរបានរួមរស់នៅជាមួយគ្នាដោយសុខដុមរមនាតរៀងទៅ ។

Perfection of Wisdom

Sattubhattha Jataka (Birth Tale)

Once the Aspirant Buddha (Bodhisatta) was born as a very wise Sage. At that time a very old Brahmin received as compensation for a debt a very young Brahmin girl. The old man took her home as wife. The young woman had illicit lovers. Desiring to dally freely with one of her illicit lovers, the young woman sent her old husband away to beg for gold with which he was asked to buy servants for the household. The old Brahmin set out on his journey, with food in his bag. He collected the necessary money, and was travelling to the City to buy servants. On his way he felt hungry. He sat at the foot of a tree opened the bag and ate food out of it. Without tying the bag he went to drink water. While he was away a ferocious Cobra smelling the food crept into the bag. The old man not knowing that a Cobra had got into the bag, tied it and went on carrying the bag. A deity dwelling in the tree saw this, and making himself half seen by the old Brahmin told him thus: "Oh Brahmin if you stopped on the way you will die. If you went home your wife will die". Not knowing what this meant the Brahmin, greatly disturbed, walked along crying. Seeing people going to Bodhisatta's preaching hall to listen to him, the old Brahmin too went there. He sat at the edge of the crowd, crying. Seeing the old Brahmin crying, the Bodhisatta asked him the reason for his grief. The old Brahmin, explained what the deity told him. With His immense wisdom, Bodhisatta the Sage understood what had happened. He told the Brahmin that a venomous Cobra had got into his travelling bag and if he stopped on the way and put his hand into the bag to get food, the Cobra would sting him to death. If on the other hand, he went home, his wife will put her hand in the bag to see what her husband brought and the Cobra will have her.

The wise Sage asked the Brahmin to untie the mouth of the bag and standing at a distance, to beat the bag with a long stick. When he did this the Cobra came out hissing. The masses cheered the Sage for His great wisdom.

The Bodhisatta enquired into the circumstances of the old Brahmin's trip and decided, that his young wife had an illicit lover. He instructed the old Brahmin to hide the gold and go home to his wife. He instructed that he should not inform the wife of the whereabouts of the gold. When the Brahmin went home, the illicit lover was inside the house. The wife let him out and asked the old Brahmin where the gold was. Unable to keep the secret the old Brahmin revealed where the gold was hidden. The illicit lover was told this. He went there and took the gold. Next morning when the old Brahmin went to the spot where he hid the gold he found that it was gone. He went back to the Bodhisatta and told Him what happened.

The Bodhisatta asked him to give alms to Brahmins for seven days. He was told that on the first day, he should invite seven Brahmins, and his wife should be asked to invite seven. On each succeeding day the old Brahmin should invite one less and wife too should do this. This way on the seventh day, the wife will invite one.

The Bodhisatta asked him to note the Brahmin invited by the wife on the seventh day and to inform Him his identity. As instructed the old Brahmin, noted the wife's guest on the seventh day and told the Bodhisatta who he was. The Bodhisatta sent His men and had that Brahmin arrested. When questioned by Bodhisatta the Sage, the Brahmin confessed that He was the young wife's paramour and that He stole the old Brahmin's gold. The Bodhisatta got him to return the gold. The Sage asked the old Brahmin whether he wants to live with his wife. When the old Brahmin said that he liked her and would live with her, the Bodhisatta provided the necessities for them to live happily together.

វីរិយបារមី

(បញ្ចាយុធជាតក)

ក្នុងកំណើតមួយនោះ ព្រះពោធិសត្វបានកើតជារាជបុត្រឈ្មោះបញ្ចាយុធៈ (ព្រះអង្គម្ចាស់មានអាវុធប្រាំ) មានជំនាញក្នុងការកាន់អាវុធ ។ បន្ទាប់ពីបានសិក្សាយុទ្ធសិល្ប៍យ៉ាងស្ទាត់ជំនាញ ក្នុងសំណាក់អាចារ្យទិសាបាមោក្ខហើយ ព្រះអង្គមានបំណងត្រឡប់វិលទៅព្រះនគរវិញ បានធ្វើដំណើរឆ្លងកាត់ព្រៃធំមួយ ដែលមានបិសាចកំណាចឈ្មោះ សិលេសលោមៈ រស់នៅទីនោះ ។ ព្រះពោធិសត្វ បានព្យាយាមបាញ់បិសាចនោះ ដោយសររហូតអស់ចំនួន៥០ព្រួញ ។ ផ្លែសរទាំងអស់បានដោតជាប់នឹងរោមរបស់បិសាចនោះ ប៉ុន្តែមិនបានធ្វើឱ្យមានគ្រោះថ្នាក់ដល់បិសាចនោះឡើយ ។ បញ្ចាយុធៈ បានច្បាំងតទល់ជាមួយបិសាចនោះ ដោយព្រះខ័នម្តង ។ ព្រះខ័នបានដោតជាប់ក្នុងរោមបិសាចនោះទៀត រួចបានប្រយុទ្ធដោយដំបងទៀតក៏មិនអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់បិសាចនោះដែរ ។ ដោយឃើញដូច្នោះ បញ្ចាយុធៈ បានតទល់ជាមួយបិសាចនោះដោយដៃ ដោយជើង និងដោយក្បាល ហើយបានជាប់នឹងរោមបិសាចទៀត ។ បិសាចនោះនៅតែមានកម្លាំងដដែល ព្រះអង្គបញ្ចាយុធៈ បានពោលទៅកាន់បិសាចនោះថា «ប្រសិនបើ ឯងស៊ីខ្ញុំ អាវុធមុតស្រួចដែលកប់នៅក្នុងខ្លួនខ្ញុំ នឹងកាត់ពោះវៀនអ្នកឯងជាកំណាត់តូចៗ ហើយខ្ញុំនិងអ្នកឯង ស្លាប់ទាំងអស់គ្នា» ។ តាមពិត ព្រះអង្គបញ្ចាយុធៈ ចង់និយាយដល់អាវុធគឺបញ្ញាមានក្នុងខ្លួនព្រះអង្គ ។ ដោយឮដូច្នោះ បិសាចភ័យតក់ស្លុត ហើយដោះលែងព្រះអង្គវិញ ។ ព្រះអង្គបានទេសនាទូន្មានធម៌ដល់បិសាច ធ្វើឱ្យបិសាចតាំងនៅក្នុងសេចក្តីល្អ ។ ចុងក្រោយ ព្រះអង្គបានត្រឡប់មកនគរ និងគ្រងរាជ្យជាស្តេចតរៀងមក ។

The Perfection of Effort

The Birth Story of Prince Pancayudha

Once the Bodhisatta (the Aspirant Buddha) was born, Prince Pancayudha (the Prince of Five-fold weapons). He was adept at wielding weapons. When he was returning to his Kingdom, after completing his studies at Disapamok Acariya, he had to travel through a thick forest. A ferocious demon named Silesaloma lived there. The Prince challenged him and shot fifty arrows at him. All arrows hung in the demon's body hair without harming him. The Prince attacked him with his sword. The sword too stuck in the Demon's hair. Next he attacked him with his cudgel. Even the cudgel did not harm the demon. Seeing this, the Prince attacked him with his two hands, two feet and his head. The Prince's hands, feet and head – all clung to the Demon's hair, without harming the demon. The Prince told the demon "If you ate me, the crystal weapon concealed within my body, will cut your inner body into pieces. Then both you and I will die together". The Prince, of course, referred to the weapon of wisdom, within him. The Demon got frightened and freed the Prince. The Prince, preached Dhamma to the Demon, and made him tread the path of righteousness. The Prince returned to his Kingdom and duly became King.

ខន្តីបារមី

(ខន្តីវាទិជាតក)

ក្នុងរជ្ជកាលព្រះបាទកាឡពុ គ្រងរាជសម្បត្តិនៅដែនកាសី ព្រះពោធិសត្វនៃយើង បួសជាតាបសឈ្មោះ សន្តិវាទិ ។ ថ្ងៃមួយស្តេចកាឡពុយាងចេញកំសាន្តក្នុងឧទ្យាន មួយអន្លើដោយមានពួកស្រីរបាំនិងស្រីបរិវារច្រើននាក់ទៀតហែហម ទ្រង់រីករាយហប្ញទ័យក្រៃលែងបានសោយសុរារហូតដល់ស្រវឹងជ្រុល ហើយក៏ផ្ទុលក់ស្កប់ស្កល់ទៅ ។ ឃើញព្រះរាជាផ្ទុំលក់ដូច្នោះ ក្រុមស្ត្រីទាំងនោះបាននាំគ្នាដើរចេញទៅកំសាន្តទីកន្លែងជិតៗនោះ ព្រោះចង់ស្គាល់ទំហំ និងសម្រស់នៃសួនឧទ្យាន រហូតដល់ទៅដល់អាស្រមតាបសឈ្មោះខន្តិវាទិ ។ ស្ត្រីទាំងនោះនាំគ្នាអង្គុយជុំវិញតាបស ដើម្បីស្តាប់ធម៌ទេសនា ។

លុះស្តេចតើនឡើង បានសួររកស្ត្រីទាំងនោះតើទៅទីណាអស់ ។ ព្រះអង្គទ្រង់ជ្រាបថា ពួកគេកំពុងតែស្តាប់ធម៌ទេសនានាសំណាក់តាបស ។ ស្តេចក៏យាង ទៅកាន់ទីនោះដែរ ហើយសួរតាបសថា តើយកអ្វីជាវត្តប្រតិបត្តិ ។ តាបសឆ្លើយថា «ខន្តិ» ។ ពេលឮតាបសឆ្លើយថា «ខន្តិ» ស្តេចបញ្ជាឱ្យពេជ្ឈឃាតកាត់ដៃទាំងពីរ ជើងទាំងពីរ ច្រមុះ ត្រចៀក របស់តាបសដើម្បីផ្ចាញ់ផ្ចាល ។ តាបសឆ្លើយថា «ខន្តិ» នៅក្នុងបេះដូង ស្តេចក៏ឱ្យគេពុះទ្រូងតាបសមើលក្នុងបេះដូងទៀត រហូតដល់តាបសស្លាប់ទៅ ។

ស្តេចបានចេញពីទីនោះ ដើម្បីកំសាន្តក្នុងឧទ្យានបន្តទៀត ផែនដីបានរហែកជាពីរ ហើយស្រូបយកស្តេចនោះ ទំលាក់ទៅស្ថាននរក ដោយមានអណ្តាតភ្លើងសន្ធោសន្ធៅឆាបឆេះផង ។

The Perfection of Patience

Kanthivadi Jataka (Birth Story)

Once in the days of king Kalabu of Kasi, the Aspirant one was born as ascetic Shanthivadi. One day the king was in the pleasure park with dancing women and a female retinue. The king slept in a drunken stupor. Seeing the king sleeping, the women wandered about the Park and came upon Ascetic Khantivadi. They, gathered round him and listened to his sermon. The king woke-up and asked where the women were. Hearing that they were listening to the Ascetic, the king went there and asked the Ascetic what his doctrine was. "Patience", the ascetic said. When the Ascetic repeated that his doctrine was Patience, the king ordered the executioner to cut off his hands, his feet his nose and his ears. Still the ascetic repeated that his doctrine was Patience and that it is in his heart. Then the king gave him a blow in the chest, and went off. While he was leaving the pleasure park the earth broke open and a flame emerged. The flames wrapped the king and dragged him down into Hell.






សច្ចៈបារមី

(សុតសោមជាតក)

កាលព្រះពោធិសត្វនៃយើង កើតជាស្តេចឈ្មោះសុតសោមៈ នៅក្នុងកុរុរដ្ឋ ។ កាលមិនទាន់បានសោយរាជ្យ បានទៅសិក្សានៅក្នុងសំណាក់គ្រូតែមួយ ជាមួយនឹងព្រះអង្គម្ចាស់ព្រហ្មទត្ត ។ ក្រោយមករាជបុត្រទាំងពីរអង្គនោះ បានគ្រងរាជ្យជាស្តេចក្នុងនគរដូចគ្នា ហើយនៅតែគោរពរាប់អានគ្នាជាមិត្តដដែល ។

អកុសលបានមកដល់ បណ្តាលឱ្យស្តេចព្រហ្មទត្តនឹកឃ្លានចង់សោយរសជាតិសាច់មនុស្ស ។ ពួកមនុស្សក្នុងនគរបានដឹងរឿងនោះ ក៏នាំគ្នាបណ្តេញព្រះអង្គចេញពីព្រះនគរ ។ ក្នុងព្រៃរហោស្ថាន ព្រហ្មទត្តឃ្លាំចាំស្ទាក់ចាប់មនុស្សណាដែលវង្វេងផ្លូវដើម្បីស៊ី ។ គ្រាមួយនោះ ព្រហ្មទត្តត្រូវរងរបួសជាទម្ងន់ស្ទើរតែក្ស័យ ហើយស្រាប់តែបានជាស្រាកស្រាន្តវិញដោយហេតុដ៏អស្ចារ្យ ។ ព្រះអង្គបានគិតថាអរោគ្យកម្មនេះ ពិតជាកើតឡើងដោយអំណាចនៃរុក្ខទេវតាពិតប្រាកដ ។ ព្រហ្មទត្តសប្បាយនឹងការរស់រានមានជីវិតនេះណាស់ ទើបសន្យាធ្វើពិធីបូជាយញ្ញនូវមនុស្សចំនួន១០០នាក់ ដើម្បីជាតង្វាយដល់ទេវតា ។ ដោយឃើញគ្រោះមហន្តរាយបំរុងនឹងកើតឡើងដូច្នោះ ទើបរុក្ខទេវតាសុំយោបល់ពីស្តេចទេវតាដើម្បីរកដំណោះស្រាយ ។ រុក្ខទេវតា បានមកបង្ហាញខ្លួននៅមុខបុរសស៊ីសាច់មនុស្ស ហើយពោលថា គ្រឿងពលិការនេះនៅមិនទាន់គ្រប់គ្រាន់ទេ លុះត្រាតែបានស្តេចសុតសោមៈមកទៀតទើបគ្រប់គ្រាន់ ។ ព្រហ្មទត្តព្យាយាមរហូតដល់ចាប់បានស្តេចសុតសោមៈ ដែលជាមិត្តធ្លាប់រស់នៅជាមួយគ្នាមកទៀត ។ ស្តេចសុតសោមៈ មានបន្ទូលប្រាប់ព្រហ្មទត្តថា ព្រះអង្គបានសន្យាចំពោះព្រាហ្មណ៍ម្នាក់ហើយមិនអាចកុហកបានទេ ហើយថាព្រះអង្គនឹងត្រឡប់មកធ្វើពលិកម្មវិញ បន្ទាប់ពីបានបំពេញកិច្ចសន្យានោះរួចរាល់ហើយ ។ ដោយគោរពពាក្យសច្ចៈ ស្តេចសុតសោមៈ បានយាងត្រឡប់មកវិញ ហើយបានទេសនាទូន្មានព្រហ្មទត្តឱ្យលះបង់នូវអំពើអាក្រក់មកជាមនុស្សធម្មតាវិញ ហើយបានមកជាស្តេចគ្រប់គ្រងនគរសាជាថ្មីម្តងទៀត ។

The Perfection of Truth

Sutasoma Jataka (Birth Tale)

Once upon a time the Bodhisatva was born king Sutasoma in the Kuru Kingdom. When as a Prince he studied under the teacher his class-mate was prince Brahma Datta. When the two of them became kings of their respective countries they were still good friends.

But, an unfortunate fate overcame King Brahmadatta. He developed a taste for human flesh. The people of his land discovered this, and he was banished from his kingdom. In the wilderness he waylaid unwary travellers and ate them up. Once he sustained an injury in the forest and it healed miraculously. He thought the cure was due to the power of the deity in the tree, beneath which he lived. Happy at his regaining his normal health he vowed to sacrifice 100 princes as an offering to the deity. Seeing the disaster that was going to happen, the deity sought the advice of the king of gods. In terms of that, the deity appeared before the man-eater and said that the sacrifice will not be complete unless king Sutasoma too was brought in as a sacrifice. The man-eater, promised to bring him. He caught king Sutasoma his intimate friend. King Sutasoma said that he has made a promise to a Brahmin and that he cannot break that promise. King Sutasoma said that he will come back to be sacrificed after he fulfilled his promise to the Brahmin. True to his word, king Sutasoma returned. After preaching to the man-eater king Sutasoma, converted him to normalcy. The man-eater gave up his evil ways and once again became the ruler of his land.



អធិដ្ឋានបារមី

(តេមិយជាតក)

ម្តងនោះ ព្រះពោធិសត្វនៃយើងមានឈ្មោះ តេមិយ ជាបុត្រនិងជាអ្នកស្នងរាជ្យនៃព្រះបាទកាសី ដែលសោយរាជ្យនគរពារាណសី ។ នៅជាតិខាងដើម ព្រះតេមិយកើតជាស្តេចគ្រប់គ្រងអំណាច បានប្រព្រឹត្តនូវបាបកម្មយ៉ាងច្រើន លុះអស់អាយុធ្លាក់ទៅកើតក្នុងនរក ត្រូវភ្លើងឆេះអស់ជាច្រើនឆ្នាំ ។ ពេលរួចពីនរកមក ព្រះតេមិយ ទ្រង់អធិដ្ឋានថា ជាតិនេះព្រះអង្គនឹងមិនសោយរាជ្យជាស្តេចទៀតឡើយ ។ ទេវតាបានឱ្យ ដំបូន្មានថាឱ្យធ្វើពុតជាថ្លង់ គ និងរលាក់រលើ ។ ព្រះមាតាបិតា និងសមាជិករាជបល្ល័ង្កបានព្យាយាមអស់ ១៦ឆ្នាំ ដើម្បីធ្វើឱ្យព្រះតេមិយមកជាកុមារធម្មតា ប៉ុន្តែមិនបានទទួលជោគជ័យសោះ ។ ដោយអស់សមត្ថភាពក្នុងការពិសោធន៍ និងការទួញសោករបស់ព្រះមាតាចំពោះព្រះតេមិយខ្លាំងពេក ស្តេចបញ្ជាឱ្យនាយពេជ្ឈឃាតឈ្មោះ សុនន្ទៈ នាំព្រះរាជកុមារទៅកាន់ព្រៃរហោស្ថាន ហើយឱ្យជីករណ្តៅកប់ចោលនៅទីនោះ ។ ពេលនាយពេជ្ឈឃាតកំពុងតែឈ្ងោកជីករណ្តៅ ព្រះតេមិយបានដើរចេញពីរាជរថ ហើយដោះគ្រឿងអលង្ការ និងសំលៀកបំពាក់ល្អៗចេញ រួចទៅឈរពីមុខនាយពេជ្ឈឃាត ។ ព្រះតេមិយកុមារ បានប្រាប់ពីដំណើររឿងពិតឱ្យនាយពេជ្ឈឃាតបានដឹងសព្វគ្រប់ ។ ឯនាយពេជ្ឈឃាតក៏សុំឱ្យព្រះរាជកុមារយាងទៅកាន់ព្រះបរមរាជវាំងវិញ តែព្រះតេមិយបានបដិសេធ ហើយប្រាប់ឱ្យនាយពេជ្ឈឃាតត្រឡប់ទៅកាន់ព្រះរាជវាំងវិញតែឯងចុះ រួចប្រាប់ដំណឹងនោះដល់ព្រះមាតាបិតា និងក្រុមរាជវង្សបានដឹងផង ។

ពេលបានដឹងយ៉ាងនេះ ព្រះមាតាបិតា ព្រមទាំងប្រជារាស្ត្រក្នុងព្រះនគរ បានយាងនិងធ្វើដំណើរមកជួបព្រះអង្គដោយផ្ទាល់ ។ ចុងក្រោយព្រះមាតាបិតា និងរាជវង្ស ព្រមទាំងអ្នកនគរបានចូលបួសជាតាបសទាំងអស់គ្នា ជាមួយព្រះតេមិយ ។

The Perfection of Determination

Themiya Jataka (The Birth Story)

Once upon a time the Bodhisatta (The Aspirant Buddha) was born as Prince Themiya – son and heir of King Kasi of Benares. In a previous birth he had been king. Due to the sins he committed as King he was born in Hell. Determined that he will avoid being King during this birth, Prince Themiya, with the advice of Gods, pretended to be deaf, dumb and half-witted. The parents and all the members of the court tried 16 years to make Prince Themiya a normal child, but failed. Then, resisting the protests and lamentations of the Queen – the mother of Prince Themiya – the King ordered charioteer Sunanda to take the child to the wilderness, dig a grave there and to crush the child's head and bury him. While the charioteer was busy digging the grave Prince Themiya stepped out of the chariot put on royal clothes and appeared before the charioteer. When Prince Themiya revealed his identity, the Charioteer requested the Prince to return to the palace with him. Refusing this request, Prince Themiya asked the charioteer to return to the palace and tell them what had happened.

On hearing this, the King the Queen and all the people in the Kingdom, came to see him. All of them decided to lead a life of asceticism along with Prince Themiya.



មេត្តាបារមី

(សុវណ្ណសាមជាតក)

ពីអតីតកាល ស្តេចបិលិយក្សគ្រប់គ្រងរាជសម្បត្តិនគរពារាណសី ។ នៅក្នុងព្រះរាជាណាចក្រនោះ មានត្រកូលអ្នកប្រមាញ់ពីររស់នៅត្រើយស្ទឹងម្ខាងម្នាក់ ។ ត្រកូលទាំងពីរនោះ រាប់អានគ្នាជាមិត្តដ៏ល្អ និងបានសន្យាគ្នាថា បើមានកូនហើយកូននោះប្រុសមួយស្រីមួយ ត្រូវផ្សំផ្គុំឱ្យជាប្តីប្រពន្ធ ។ ចំណេរខាងក្រោយមក ត្រកូលទាំងពីរនោះ កើតបានកូនម្នាក់មួយ ម្ខាងបានកូនប្រុស ម្ខាងទៀតបានកូនស្រី ។ កូនប្រុសមានឈ្មោះថា ទុកុលកុមារ កូនស្រីមានឈ្មោះ បារិកា ទាំងពីរនាក់បានរៀបការជាប្តីប្រពន្ធ ។ ទាំងពីរនាក់ប្តីប្រពន្ធបានចេញពីផ្ទះទៅបួសជាតាបស រស់នៅក្នុងអាស្រមតូចមួយ ។

ពេលវេលាកន្លងទៅ ព្រះឥន្ទ្រាធិរាជបានប្រាប់ទុកុល និងនាងបារិកាឱ្យជ្រាបថា ខាងមុខពួកគេនឹងងងឹតភ្នែកទាំងអស់គ្នា ដូច្នេះគេត្រូវតែមានកូនដើម្បីជួយថែរក្សា ។ ប៉ុន្តែ ទាំងពីរនាក់ប្តីប្រពន្ធប្រកែកមិនព្រមរួមបវេណីតាមធម៌លោកិយ ដូចមនុស្សធម្មតាឡើយ ។ ព្រះឥន្ទ្រសុំឱ្យទុកុលគ្រាន់តែយកបាតដៃស្ទាបត្រង់ផ្ចិតរបស់នាងបារិកាប៉ុណ្ណោះ ។ ប្តីប្រពន្ធនេះយល់ព្រមធ្វើតាម ។ ចាប់ពីពេលនោះមកនាងបារិកាមានផ្ទៃពោះ ហើយចុងក្រោយប្រសូត្របានបុត្រម្នាក់មានឈ្មោះថា សុវណ្ណសាម ។ ពេលកុមារសុវណ្ណសាម បានអាយុ១៦ឆ្នាំ ថ្ងៃមួយមាតាបិតាចូលទៅព្រៃ ដើម្បីបេះផ្លែឈើតាមធម្មតា មកធ្វើជាអាហារប្រចាំថ្ងៃ ក៏ស្រាប់តែមានពស់កំណាចមួយបានចេញមកព្រួសពិសដាក់ភ្នែកធ្វើឱ្យខ្វាក់មើលអ្វីមិនឃើញឡើយ ។ សុវណ្ណសាមកុមារបាត់មាតាបិតា បានចេញទៅតាមរក ក៏ជួបលោកទាំងពីរងងឹតភ្នែក ហើយបាននាំមកកាន់អាស្រមវិញដោយមេត្តាធម៌ ។

ថ្ងៃមួយ ស្តេចបិលិយក្សបានចេញប្រពាតព្រៃ ចំពេលសុវណ្ណសាមចេញទៅដងទឹកស្ទឹង ដោយមានសត្វម្រឹគជាច្រើនទៅជាមួយ ។ ស្តេចបានបាញ់ម្រឹគ តែផ្លែសរផ្លាតទៅត្រូវព្រះកុមារសុវណ្ណសាម ។ ព្រះកុមារសុវណ្ណសាម ដែលហៀបតែនឹងស្លាប់ទៅហើយបានទូលស្តេចថា លោកមិនខ្លាចសេចក្តីស្លាប់ទេ ប៉ុន្តែលោកបារម្ភដល់ម្តាយឪពុកចាស់ ហើយខ្វាក់ទាំងអស់គ្នាក៏ត្រូវស្លាប់ដែរ ពីព្រោះគ្មាននរណាមើលថែរក្សា ។ ស្តេចបានទៅកាន់អាស្រម ហើយនាំយាយតាខ្វាក់ទាំងពីរនោះមកជួបសុវណ្ណសាម ដែលជិតក្ស័យទៅហើយនោះ ។ ម្តាយឪពុកបានបួងសួងដល់ព្រះឥន្ទសុំឱ្យជួយពួកគេ ។ ដោយអំណាចនៃសច្ចវាចា សុវណ្ណសាមបានជាសះស្បើយមួយរំពេច ហើយមាតាបិតាក៏មានភ្នែកភ្លឺវិញដែរ ។

Perfection of Loving-kindness

Sama Jataka (Birth Tale)

Once upon a time King Piliyak ruled the Kingdom of Benares. In his Kingdom, on the two banks of a river, there lived two colonies of hunters. The two chieftains of these colonies were good friends. The two of them decided, that if the two of them got two children of the opposite sexes they should get married in due time. Eventually, a boy and a girl were born in the two families. The boy had the name Prince Dukula. The daughter was called Princess Parika. Both of them shunned lay life. Therefore together they left the household life and began to live as ascetics in the same hermitage. As time passed, the King of Gods appeared to them, and told them that the two of them are destined to lose their eye-sight. Therefore, they must have a son to look after them. But, the two of them did not want to live as husband and wife. The King of Gods suggested that Prince Dukula must caress Princess Parika's navel. They agreed to this. Eventually Princess Parika gave birth to a son. The parents looked after the son, who was called Prince Sama. When Prince Sama was 16 years old, one day the parents went out into the forest as usual for fruits and other forest yields. In the forest a fierce cobra attacked them with a poisonous fume. The parents lost their eye-sight because of that poisonous fume. Prince Sama, discovered what happened and from then on he looked after his blind parents with loving-kindness.

One day when the King of Benares, was out hunting in the forest Prince Sama went to the river, with his companions, the wild animals. The King felled Prince Sama with an arrow. The dying Prince revealed to the King who he was and said that his blind parents will not survive if he died, because, there is no one to look after them. The King went into the hermitage, and brought the blind parents to see their dying son. The parents prayed asking gods to help them because of the power of truth. Prince Sama recovered and the parents regained their eye-sight.




ឧបេក្ខាបារមី

លោមហង្សជាតក

ក្នុងកាលកន្លងហើយ ព្រះពោធិសត្វនៃយើង យោនកំណើតជាមនុស្សប្រុស បានចូលទៅបួសក្នុងក្រុមអចេលក៏ដែលប្រកាន់ការអាក្រាតកាយ ការមិនចង់ជួបមនុស្ស និងការភ័យរន្ធត់ពេលជួបមនុស្ស ជាវត្តប្រតិបត្តិដែលផ្ទុយពីសាសនារបស់ព្រះពុទ្ធបរមគ្រូនៃយើង ។ លុះចុងក្រោយទើបដឹងថា ការប្រតិបត្តិតាមលទ្ធិនោះជាការខុសឆ្គងខ្លាំងណាស់ ពិសេសដល់អស់អាយុពេលណានឹងសោយទុក្ខក្នុងនរកទៀតផង ក៏បានលះបង់ចោលការប្រតិបត្តិរបៀបនោះ ហើយងាកមកប្រតិបត្តិតាមផ្លូវត្រឹមត្រូវវិញ ។ ដោយផលនៃការប្រតិបត្តិត្រូវនោះ លុះតាបសនោះអស់អាយុទៅក៏បានទៅកើតនៅឋានតុសិតសួគ៌ ។

The Perfection of Equanimity

Lomahansa Jataka (Birth Tale)

Once the Bodhisatta (the Aspirant Buddha) in a previous birth, took to the life of an unclothed ascetic. He practised austerities that were outside the Buddhist system. He shunned the company of human beings. He was frightened of them. Towards the end of this wrong practice of asceticism, he knew that he would be born in hell, after death. Realizing the gravity of the situation he immediately gave up the misguided practices and started leading the life of proper asceticism. As a result of this he was born in Tusita Heaven after his death.



បរាភវសូត្រ

PARABHAVA SUTTA

ព្រះសូត្រស្តីអំពីប្រភព
នៃសេចក្តីវិនាស



ការមិនចូលចិត្តស្តាប់ព្រះធម៌

Disinclination either to listen to or to read the Doctrine.

បុគ្គលខ្លះសំដែងចេញនូវអាកប្បកិរិយា មិនចូលចិត្តស្តាប់ព្រះធម៌ មិនចង់ស្តាប់ព្រះធម៌ ។ ទម្លាប់បែបនេះ នាំឱ្យជនទាំងនោះធ្លាក់ទៅក្នុងសេចក្តីវិនាស ។

Some display a disinclination towards the Doctrine. They do not want to listen to it. Nor do they want to read it. This habit of mind leads to one's Downfall.

ការពេញចិត្តសេពគប់ជនអសប្បុរស

Preference for the company of the depraved and the dislike of the Virtuous.

បុគ្គលខ្លះពេញចិត្តសេពគប់តែជាមួយជនអសប្បុរស មិនពេញចិត្តសេពគប់ជនសប្បុរស គេចចេញពីពាក្យប្រៀនប្រដៅរបស់ជនសប្បុរស និងងាកចេញពីកុសលធម៌ ។ ទាំងនេះជាហេតុនាំទៅរកសេចក្ដីវិនាស ។

To some, the bad people are attractive. They do not take pleasure in the company of the Virtuous. While shunning those who teach righteousness, they turn to the Vicious. This is a cause for Downfall.

ភាពជាអ្នកខ្ជិលច្រអូស និងដេកច្រើន
Slothfulness and sleepiness

បុគ្គលដែលចូលចិត្តដេកច្រើន ចំណាយពេលចោលទទេ ជាអ្នកខ្ជិលច្រអូស មិនមានការប្រឹងប្រែង ។ អ្នកទាំងនេះជាប្រធាននៃសេចក្ដីវិនាស ។

If people tend to be sleepy, slothful, lethargic and are incapable of making an effort, they are on their way to their downfall.

ភាពជាអ្នកចូលចិត្តនិយាយពាក្យឥតប្រយោជន៍
Constant, fruitless talkativeness

បុគ្គលដែលខ្ជះខ្ជាយពេលវេលា ចូលចិត្តពោលពាក្យឥតប្រយោជន៍ ពាក្យឥតខ្លឹមសារ ប្រជុំគ្នានិយាយតែពាក្យប៉ប៉ាច់ប៉ប៉ោចគ្មានទីបញ្ចប់ មិនចូលចិត្តចូលរួមក្នុងសកម្មភាពដែលមានប្រយោជន៍ ។ ការពោលពាក្យឥតប្រយោជន៍បែបនេះជាប្រធាននៃសេចក្ដីវិនាស ។

There are those who waste their time away, in futile talkativeness. They get together and jabber endlessly without engaging in any constructive activity. Such useless talk is a cause of Downfall.

ការបណ្ដោយឱ្យចិត្តក្ដៅក្រហាយមិនចេះចប់

Leading a Life of unceasing irritation.

ភាពក្ដៅក្រហាយក្នុងចិត្ត និងសេចក្ដីក្រោធច្រើន នាំឱ្យអន្តរាយដល់សុភមង្គលក្នុងជីវិត ។ បុគ្គលខ្លះបណ្ដោយជីវិតឱ្យស្ថិតក្នុងភាពក្រៀមក្រំ ក្ដៅក្រហាយគ្មានទីបញ្ចប់ដូចជាភ្លើង និងផ្សែង ។ ទោសៈធ្វើឱ្យបាក់បែកគ្រួសារ និងមិត្តភាព ។ ការខឹងមិនចេះចប់នេះជាហេតុនាំឱ្យមានសេចក្ដីវិនាស ។

Irritation and Anger are qualities that destroy Harmony of Life. Some people lead a life of constant resentment, fuming endlessly like a smoking fire. Anger shatters family life and friendship. Such ceaseless Anger is a cause of one's Downfall.

ការមិនចិញ្ចឹមមាតាបិតាដែលចាស់ជរា

Disinclination to look after and support one's Parents even when one has the wherewithal.

បុគ្គលដែលមានទ្រព្យធនច្រើន មានរបស់ប្រណីតៗ រស់នៅក្នុងភាពសុខស្គម្ភ មិនបានចិញ្ចឹមមាតាបិតាដែលចាស់ជរា មិនយកចិត្តទុកដាក់លើតួនាទីខ្លួនជាកូន បុគ្គលនោះត្រូវបានទទួលការមាក់ងាយពីសង្គម ។ ការមិនចិញ្ចឹមមាតាបិតាដែលចាស់ជរានោះជាប្រធាននៃសេចក្ដីវិនាស ។

There are those who while leading a life of luxury neglect their old, helpless Parents. Such people have the means to support their aged Parents. But they neglect their Duty. Those bad people are looked down upon by Society. Such neglect of aged Parents is a cause of Downfall.

ការរកប្រាក់បានដោយទុច្ចរិត និងការបោកប្រាស់អ្នកដទៃ
Obtaining Money fraudulently, deceiving others.

បុគ្គលខ្លះរកស៊ីចិញ្ចឹមជីវិតដោយការភូតភរកុហក និងការបោកប្រាស់អ្នកដទៃ ។ មនុស្សពាលទាំងនោះ រមិលគុណអ្នកមានឧបការគុណលើខ្លួន បានកុហកយករបស់មានតម្លៃ និងមាសប្រាក់របស់មនុស្សស្លូតត្រង់ ។ សង្គមតែងតែតិះដៀលបុគ្គលប្រភេទនោះ ។ អំពើទាំងអស់នោះ ជាប្រធាននៃសេចក្តីវិនាស ។

Some earn a livelihood by Cheating and Deceiving others. Such bad men betray innocent people mercilessly and take their valuable possessions and their money. Society shuns such vicious men. Such behaviour is a cause of Downfall.

ការមិនចែករំលែកចំណីអាហារដែលមានរសជាតិឆ្ងាញ់ដល់អ្នកដទៃ

Partaking of tasty food, while others look on, without sharing it with them.

បុគ្គលមានអាហារដែលមានរសឆ្ងាញ់ពិសា ទោះបីអាចចែកអ្នកឯទៀតបាន តែគេមិនព្រមចែកឱ្យ គេលាក់ទុកសម្រាប់បរិភោគតែម្នាក់ឯង ។ នេះជាប្រធាននៃសេចក្ដីវិនាស ។

People of Means enjoy delicious Food and Drink. Although they can share these things with others they do not do so, but relish those all alone, even while others look on. This is a cause of Downfall.



ការមិនជួយដល់ញាតិក្រីក្រ និងការស្រវឹងក្នុងភាពស្ដុកស្ដម្ភ

Disregarding one's poor Relations, intoxicated with Wealth.

បុគ្គលខ្លះមានមោទនភាពនឹងទ្រព្យសម្បត្តិ ហើយមិនជួយរក្សាញាតិដែលក្រីក្រ ។ ចំពោះមនុស្សខ្លះ ដែលស្រវឹងនឹងទ្រព្យដែលគេមាន គេសំឡឹងមើលទៅញាតិមិត្តក្រីក្ររបស់ខ្លួនថាជាមនុស្សទាបថោកពុំគប្បីរាប់អានឡើយ ។ ការមិនអើពើដល់ញាតិមិត្តក្រីក្រនេះជាប្រធាននៃសេចក្ដីវិនាស ។

Some, proud of their riches, disregard their poor Relations. To such people, intoxicated with the Wealth they possess, their poor Relatives are an eyesore. This kind of neglect of one's poor relations is a source of Downfall.

ការងប់នឹងស្រី

Extreme fondness for Women.

បុរសខ្លះបានបង្ហាញនូវការងប់ចិត្តចំពោះល្បែងស្រី ដែលនាំឱ្យអន្តរាយទ្រព្យសម្បត្តិដែលមាន និងក្តៅក្រហាយក្នុងចិត្ត ។ ជាលទ្ធផលជីវិតរបស់គេក្លាយទៅជាមិនមានសេចក្តីស្ងប់ តែងជួបផលអាក្រក់ និងការវិនាសអន្តរាយ ។ ព្រោះហេតុនោះ ការងប់ក្នុងល្បែងស្រី ជាប្រធាននៃសេចក្តីវិនាស ។

There are some who display an extreme fondness for Women. This leads to loss of Wealth and to Worry. In consequence their Life becomes unsettled and blighted. Therefore such extreme attachment to various Women is a cause of downfall.



ការញៀននឹងគ្រឿងស្រវឹង

Desire for intoxicating Drinks.

មនុស្សប្រមឹក ត្រូវសង្គមតិះដៀល ។ មនុស្សអកុសល ចូលចិត្តសេពសុរាហួសប្រមាណ មិនយកចិត្តទុកដាក់ដល់ក្រុមគ្រួសារ ។ គេបានចំណាយទ្រព្យឥតប្រយោជន៍លើគ្រឿងស្រវឹង ។ ការញៀន និងសេពគ្រឿងស្រវឹង ជាប្រធាននៃសេចក្ដីវិនាស ។

Those who are addicted to Liquor are shunned by Society. These unfortunate people who have taken to excessive Drinking, neglect their Families. They waste all their Wealth on intoxicating Drinks. Desire for intoxicating Drinks is a cause of Downfall.

ការញៀននឹងល្បែងស៊ីសង

Desire for Gambling and delighting in winning Money through Gambling.

ល្បែងតែងបំផ្លាញទ្រព្យអ្នកដែលញៀនល្បែង ។ ចង់ឈ្នះល្បែងលើអ្នកឯទៀត គេយកទ្រព្យដែលមានទៅទាក់ទាញ ។ ប៉ុន្តែតាមពិតទៅ គេគ្រាន់តែបានឈ្មោះថាជាអ្នកបំផ្លាញសេចក្តីសុខនិងសុភមង្គលក្នុងគ្រួសាររបស់គេផ្ទាល់តែប៉ុណ្ណោះ ។ ល្បែងស៊ីសងជាប្រធាននៃសេចក្តីវិនាស ។

Gambling destroys those addicted to it. In the desire to Win through Gambling, they pursue elusive Wealth. But, they only squander away their own possessions,destroying the Happiness and Harmony of their Families. Gambling therefore is a source of Downfall.

ការចាយទ្រព្យមរតកដោយខ្ជះខ្ជាយ

Squandering away the Wealth and Property inherited from Ancestors.

ទ្រព្យសម្បត្តិជាកេរមរតកឪពុកម្តាយដូនតា ។ ឪពុកម្តាយដូនតាបានស្វែងរកទ្រព្យ និងថែរក្សាទ្រព្យដោយការប្រឹងប្រែងយ៉ាងខ្លាំង ។ ប៉ុន្តែ បុគ្គលជាកូនចៅ គ្រាន់តែទទួលទ្រព្យមរតកដែលមានស្រាប់ ជាទ្រព្យដែលដូនតាបន្សល់ទុកឱ្យ ដោយគ្មានការប្រឹងប្រែងរកថែម ហើយធ្វើឱ្យវិនាសអសារឥតការ ។ ការធ្វើដូច្នេះ ឈ្មោះថាជាប្រធាននៃសេចក្តីវិនាស ។

Some inherit Wealth from their Ancestors. Those Ancestors accumulated the Wealth, with great care and effort. But, the persons who inherit the Wealth effortlessly waste it away in vain pursuits. Such behaviour is a source of Downfall.

ការរងប់នឹងស្រីពេស្យា

Keeping constant company with Prostitutes.

បុរសខ្លះគប់មិត្តមិនល្អ នាំទៅរកការប្រេះស្រាំនៃជីវិតក្នុងគ្រួសារ ធ្វើទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះឱ្យសាបសូន្យ ព្រោះតែការសប្បាយខុសទំនងក្នុងផ្លូវកាមគុណ ដែលជាប្រធាននៃសេចក្តីវិនាស ។

Some Men keep the company of Courtesans, excessively. This leads to disruption of their family life. They deteriorate in Wealth and Social Prestige. This way, resorting to Courtesans excessively, is a source of Downfall.

បុរសវ័យចាស់ រៀបការជាមួយស្រីក្មេង

Marrying an extremely young woman even when one is old.

បុរសដែលមានវ័យចាស់ហួសពេក ហើយមានតម្រេករៀបការជាមួយស្រីក្មេង ។ គេទាំងពីរនាក់គ្មានសេចក្ដីសុខឡើយ ។ ស្រីក្មេងមិនពេញចិត្តរៀបការជាមួយបុរសចាស់ឡើយ ឯបុរសចាស់និទ្រាបានតិចតួចក្នុងពេលរាត្រី តែងព្រួយបារម្ភជានិច្ច ខ្លាចប្រពន្ធក្មេងរបស់គាត់លបលួចស្រឡាញ់ជាមួយបុរសក្មេងដទៃ ។ ស្ថានភាពបែបនេះជាប្រធាននៃសេចក្ដីវិនាស ។

When an aged person marries a young Woman, both are unhappy. The young Woman does not derive much pleasure out of the Marriage. The aged person spends sleepless nights worrying if his young Wife will think of a young Man. This situation is a source of Downfall.



ការភូតកុហក ចំពោះសមណព្រាហ្មណ៍

Deceiving the Clergy by telling them lies.

បុគ្គលខ្លះបានបញ្ឆោតសមណៈ អ្នកបួស និងព្រាហ្មណ៍ ដោយការពោលពាក្យមិនពិត ឬកុហកបោកប្រាស់ ។ ការប្រព្រឹត្តបែប នេះចំពោះសមណព្រាហ្មណ៍ ជាប្រធាននៃសេចក្តីវិនាស ។

Some people deceive Priests and Brahmins by giving false promises. They lie to them, and cheat those Religious persons. Adopting such an attitude to priests, Ascetics and Brahmins, is a source of Downfall.



ការមិនថ្វាយទានដល់ព្រះសង្ឃ និងអ្នកមានសីល

Not giving any Alms at all to Priests, Monks and Ascetics who come to one's door when one is taking Meals.

ជាអកុសលធំណាស់ចំពោះបុគ្គលដែលព្រះសង្ឃ និងសមណព្រាហ្មណ៍មកដល់គេហដ្ឋានដើម្បីបិណ្ឌបាត ហើយមិនយកចិត្តទុកដាក់ក្នុងការបំពេញទាន ជាពិសេសពេលគេកំពុងបរិភោគអាហារ ហើយមិនព្រមបរិច្ចាគ ។ នេះជាប្រធាននៃសេចក្ដីវិនាស ។

It is a Noble Human quality to treat Priests, Ascetics and Brahmins who come to one's door in their Almsround. If an individual neglects this duty, especially towards those Men of Religion who come to his door when he is taking his meals, it is a cause of Downfall.

ការគ្មានហិរិ និងឱត្តប្បៈ

Behaving without Shame and Fear.

ហិរិ គឺការខ្មាស់អំពើអាក្រក់ និងឱត្តប្បៈ គឺការខ្លាចបាប ដែលជាធមិរក្សាសណ្តាប់ធ្នាប់សង្គម ។ បុគ្គលមិនមានហិរិ និងឱត្តប្បៈ នឹងធ្វើឱ្យសង្គមមិនល្អ នាំឱ្យមានការច្របូកច្របល់កើតឡើង ។ ការគ្មានហិរិ និងឱត្តប្បៈ ជាប្រធាននៃសេចក្តីវិនាស ។

Shame and Fear are essential to ensure Social stability. When people have no regard whatsoever for Shame and Fear, Society deteriorates. Social disruption takes place. Individuals who behave without Fear or Shame demean themselves. Therefore, behaving with no regard for Fear and Shame is a source of Downfall.

សេចក្តីក្រោធខឹង និងសេចក្តីលោភ

Resorting to various Deceptions due to Anger and Extreme Greed.

ទោសៈ និងលោភៈ ខ្លាំងនាំឱ្យប្រព្រឹត្តអំពើថោកទាប ។ បុគ្គលនោះអាចធ្វើបានទាំងការបោកបំភាន់ ការបន្លំ ឬរហូតដល់សម្លាប់ក៏ហ៊ានដែរ ។ ទោសៈ និងលោភៈ នេះនឹងនាំបុគ្គលទៅរកសេចក្តីទុក្ខ ។ ទាំងនេះជាប្រធាននៃសេចក្តីវិនាស ។

Those in the grip of Anger and Extreme Greed will stoop to any low activity. Deception, Fraud and even Murder are not beyond such persons. These traits of Anger and Greed invariably lead them to Grief. Therefore, those Evils are a source of one's Downfall.



ការទិទៀន និងការមិនជឿការត្រាស់ដឹងរបស់ព្រះពុទ្ធ និងសាវ័ក

Constant censure and disapprobation of the Enlightened One and Disciples.

បុគ្គលដែលស្វែងរកទំនាស់ជាមួយព្រះពុទ្ធនិងអគ្គសាវ័ក គឺជាអំពើបាបយ៉ាងធំ ។ គេជាបុគ្គលគ្មានសទ្ធាងាយធ្លាក់ទៅផ្លូវខុស ។ ទាំងនេះជាប្រធាននៃសេចក្តីវិនាស ។

Those who find fault with the Enlightened One and the Disciples can resort to any sinful behaviour. They are unreliable and are easily led astray. Such unseemly behaviour is a source of Downfall.



មានលាភ និងបាត់លាភ, មានយស និងបាត់យស, សេចក្ដីសរសើរ និងការនិន្ទា, សេចក្ដីសុខ និងសេចក្ដីទុក្ខ

គឺ ជាធម៌ប្រាំបីយ៉ាង សម្រាប់រក្សាសណ្ដាប់ធ្នាប់របស់សត្វលោក

GAIN AND LOSS - FAME AND DEFAME PRAISE AND BLAME - HAPPINESS AND PAIN

"EIGHT WORLDLY CONDITIONS

ធម៌ប្រាំបីយ៉ាង
សម្រាប់ក្សោសណ្ដាប់ធ្នាប់របស់សត្វលោក
អដ្ឋលោកធម៌

ពិភពលោកដែលគ្មានតុល្យភាពនេះ មិនសុទ្ធតែល្អស្រស់ដូចផ្កាកុលាបទាំងស្រុងទេ ហើយក៏មិនសុទ្ធតែពិបាកស្អុតស្អាញទាំងអស់នោះដែរ ។ ផ្កាកុលាប វាទន់ភ្លន់ល្អស្អាត និងមានក្លិនក្រអូប ប៉ុន្តែទងរបស់វាមានសុទ្ធតែបន្លា ។ អ្វីដែលល្អស្រស់ គឺវាល្អស្រស់ អ្វីដែលស្មុគស្មាញ គឺវាស្មុគស្មាញ ។ ដោយសារចង់បានផ្កាកុលាប គេមិនត្រូវទោមនស្សនឹងបន្លាទេ ទាំងមិនត្រូវបង្អាប់បង្អោនផ្កាកុលាប ដោយសារតែបន្លាដែរ ។ ចំពោះអ្នកមានសុទិដ្ឋិនិយម ពិភពលោកនេះពិតជាស្រស់ប្រិមប្រិយដូចផ្កាកុលាប តែចំពោះមនុស្សទុទិដ្ឋិនិយមវិញ ពិភពលោកនេះពោរពេញទៅដោយបន្លាស្មុគស្មាញ ។ តែចំពោះអ្នកប្រាកដនិយម ពិភពលោកយើងនេះមិនសុទ្ធតែល្អដូចផ្កាកុលាប ហើយក៏មិនសុទ្ធតែស្មុគស្មាញដូចបន្លានោះទេ ។ តាមទស្សនប្រាកដនិយម ពិភពលោកនេះសម្បូរទៅដោយផ្កាកុលាបដ៏ស្រស់ស្អាត និងក៏មុតដោយបន្លាផងដែរ ។ ចំពោះអ្នកយល់បញ្ហា គាត់មិនស្រើបស្រាលនឹងសម្រស់របស់ផ្កាកុលាបទេ ប៉ុន្តែគាត់សម្លឹងមើលវាក្នុងន័យវាជាផ្កា ។ ដោយដឹងច្បាស់អំពីធម្មជាតិនៃបន្លា គាត់សម្លឹងមើលបន្លាក្នុងន័យជាបន្លា ហើយគាត់ប្រុងប្រយ័ត្ន ដើម្បីកុំឱ្យបន្លាមុត ។ ដូចជាប៉ោលនាឡិកា ដែលជានិច្ចជាកាលយោលទៅស្ដាំរួចទៅឆ្វេង ។ មានលក្ខណៈបួនប្រការដែលគេចង់បាន និងបួនប្រការមិនចង់បានកើតមាននៅក្នុងលោកនេះ ដែលមនុស្សទូទៅឥតមានលើកលែងនរណាម្នាក់ឡើយ សុទ្ធតែត្រូវប្រឈមមុខមិនអាចគេចផុតបាននៅក្នុងដំណើរជីវិតប្រចាំថ្ងៃរបស់ខ្លួន ។

លក្ខណៈទាំងនោះ គឺការបានលាភ និងការបាត់លាភ, ការមានយស និងការបាត់យស, ការសរសើរ និងការនិន្ទា, ការបានសេចក្ដីសុខ និងការបានទុក្ខ ។

ការបានលាភ និងការបាត់លាភ

ពួកអ្នកជំនួញជាក្រឹត្យក្រម សុទ្ធតែចំណុះទៅនឹងការបានលាភ និងការខាតបង់លាភ ។ វាជារឿងធម្មតាដែលត្រូវសប្បាយចិត្តនៅពេលទទួលបានលាភឬចំណេញ ។ នៅក្នុងការទទួលលាភនេះ មិនមានអ្វីខុសឆ្គងទេ ។ ចំណេញដែលបានដោយសុចរិត និងចំណេញមិនសុចរិត ទាំងនេះនាំមកនូវសេចក្ដីរីករាយចំពោះមនុស្សទូទៅ ដែលខំស្វែងរក ។ បើគ្មានពេលគួរឱ្យសប្បាយសោះ ទោះបីជីវិតយើងមិនឋិតថេរក៏ដោយ ក៏ជីវិតនោះឥតមានតម្លៃដែរ ។ នៅក្នុងពិភពលោកដែលពោរពេញទៅដោយការប្រកួតប្រជែង និងច្របូកច្របល់នេះ មានមនុស្សតិចណាស់ដែលមានសុភមង្គល ដែលធ្វើឱ្យបេះដូងរបស់ខ្លួនសប្បាយរីករាយ ។ សុភមង្គលទាំងនោះ តាមពិតទៅមានលក្ខណៈប្រាកដនិយម ដែលនាំឱ្យមានសុខភាពល្អ និងអាយុយឺនយូរ ។

បញ្ហាវាកើតឡើងក្នុងករណីមានការបាត់បង់ ។ ចំពោះការចំណេញ ម្នាក់ៗអាចទទួលយកដោយញញឹម ប៉ុន្តែចំពោះការបាត់បង់វិញនោះពុំដូច្នោះទេ ។ ជួនកាលនៅពេលដែលការបាត់បង់នោះ វាធ្ងន់ធ្ងរពុំអាចទ្រាំទ្របាន វាអាចនាំជននោះឱ្យឡប់សតិឬរហូតដល់ធ្វើអត្តឃាតក៏មាន ។ ស្ថិតនៅក្នុងស្ថានភាពមិនល្អបែបនេះ ម្នាក់ៗត្រូវបង្ហាញឱ្យឃើញនូវសេចក្ដីក្លាហានខាងចរិយាធម៌ និងរក្សាឱ្យបាននូវលំនឹងខាងផ្លូវចិត្ត ។ ទាំងអស់គ្នាសុទ្ធតែមានសំណាងល្អ និងអាក្រក់ក្នុងការតស៊ូក្នុងជីវិត ។ ដូច្នេះ ម្នាក់ៗគប្បីត្រៀមបង្ការជាពិសេសចំពោះសំណាងអាក្រក់ ។ បើធ្វើដូច្នេះបាននោះ ពេលមានសំណាងអាក្រក់ យើងមិនសូវខកចិត្តប៉ុន្មានទេ ។

ជាធម្មតានៅពេលវត្ថុអ្វីមួយត្រូវចោរលួចបាត់ ពេលនោះគេតែងព្រួយចិត្ត ។ ប៉ុន្តែការព្រួយចិត្តនោះពុំអាចរករបស់ដែលបាត់នោះបានមកវិញទេ «គេគប្បីគិតថា មានមនុស្សម្នាក់បានទទួលលាភពីការលួចនេះ ទោះបីលាភនោះបានមកដោយទុច្ចរិតក៏ដោយ ។ សូមឱ្យអ្នកនោះបានសុខសប្បាយចុះ!» ឬក៏គេអាចលួងលោមចិត្តខ្លួនឯងដោយគិតថា «នោះគឺជាការបាត់បង់ដ៏តូចតាចទេ» ។ អ្នកខ្លះអាចប្រកាន់យកនូវអាកប្បកិរិយាប្រកបដោយទស្សនៈខ្ពស់គឺថា «វាគ្មានសំខាន់អ្វីសោះ ដែលត្រូវហៅថានេះជាអាត្មាអញ ឬជារបស់អញ» ។

នៅក្នុងសម័យពុទ្ធកាល មានម្ដងនោះ មានស្ត្រីក្នុងត្រកូលខ្ពស់ម្នាក់បានថ្វាយចង្ហាន់ចំពោះព្រះភិក្ខុសារីបុត្ត និងភិក្ខុដទៃឯទៀត ។ ក្នុងពេលកំពុងប្រគេនចង្ហាន់ នារីនោះបានទទួលសំបុត្រមួយច្បាប់ប្រាប់ថា ស្វាមីរបស់នាង និងកូនៗរបស់នាងនាំគ្នាចេញទៅបង្ក្រាបជម្លោះ ហើយត្រូវគេពួនស្ទាក់វាយសម្លាប់អស់ហើយ ។ ដោយពុំបានខកចិត្តចំពោះដំណឹងនេះ គាត់បានញាត់សំបុត្រនោះទៅក្នុងថង់នៅចង្កេះគាត់ដោយស្ងប់ស្ងៀម រួចបន្តប្រគេនចង្ហាន់ដូចជាគ្មានរឿងអ្វីកើតឡើងដូច្នោះ ។

មានទាសីម្នាក់បាននាំយកទឹកដោះគោមួយថូទៅប្រគេនព្រះសង្ឃ តែរអិលដួលដោយមិនបានគិត ហើយធ្វើឱ្យបែកថូទឹកដោះនោះទៅ ។ ដោយគិតថា នារីនោះពិតជាស្ដាយចំពោះការបាត់បង់ទឹកដោះនោះ ព្រះសារីបុត្តមានដីកាទៅកាន់នាងទាសីនោះថា «វត្ថុទាំងឡាយណាដែលអាចបែក វារមែងតែនឹងបែកដូច្នេះឯង» ។ ស្ត្រីដ៏ឧត្ដមនោះពោលដោយឥតមានរំជួលក្នុងចិត្តថា «បពិត្រ ព្រះគុណម្ចាស់ តើអ្វីទៅដែលជាការបាត់បង់ឥតសំខាន់នោះ? ។ ខ្ញុំព្រះករុណាទើបបានទទួលសំបុត្រមួយច្បាប់ប្រាប់ថា ស្វាមីនិងកូនរបស់ខ្ញុំព្រះករុណាត្រូវឃាតករសម្លាប់ទៅហើយ ។ ខ្ញុំព្រះករុណាទុកសំបុត្រនេះក្នុងហោប៉ៅខ្ញុំដោយស្មារតីនឹងនដដែល ។ ខ្ញុំព្រះករុណាបានបំរើចង្ហាន់ព្រះករុណាគ្រប់ព្រះអង្គដដែល ទោះបីមានការបាត់បង់យ៉ាងនេះក៏ដោយ» ។

សេចក្ដីក្លាហាននៃស្ត្រីដ៏អង់អាចនេះ គួរឱ្យសរសើរខ្លាំងណាស់ ។ មានពេលមួយនោះព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅបិណ្ឌបាតនៅតាមភូមិ ។ ដោយសារមានពួកមារ (បិសាច) មកធ្វើអន្តរាគម ព្រះសម្មាសម្ពុទ្ធឥតទទួលបានចង្ហាន់បន្តិចសោះឡើយ ។ នៅពេលដែលមារសួរទៅព្រះសម្មាសម្ពុទ្ធដើម្បីចំអកបញ្ឈឺចិត្តព្រះពុទ្ធថា តើព្រះអង្គឃ្លានចង្ហាន់ឬក៏មិនឃ្លានទេ? ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ពន្យល់យ៉ាងម៉ឺងម៉ាត់អំពីអាកប្បកិរិយាខាងផ្លូវចិត្តរបស់ជនដែលបានរំដោះខ្លួនរួចផុតពីឧបសគ្គទាំងឡាយ និងមានបន្ទូលតបវិញថា «អី ! យើងរស់នៅដោយសុខសប្បាយ ចំពោះយើងដែលគ្មានឧបសគ្គអ្វីទាំងអស់នោះ យើងតែងតែជាអ្នកផ្ដល់សេចក្ដីសប្បាយរីករាយឱ្យគេ ដូចជាទេព្ដានៃអាណាចក្រដែលមានពន្លឺចាំងទៅគ្រប់ទិសទីដូច្នេះដែរ» ។

មានសម័យមួយនោះ ព្រះសម្មាសម្ពុទ្ធ និងព្រះសាវ័កទ្រង់គង់ចាំព្រះវស្សានៅក្នុងភូមិមួយតាមការអារាធនារបស់ព្រាហ្មណ៍ម្នាក់ ដែលខ្លួនគាត់បានភ្លេចឈឹងចំពោះភារកិច្ចដែលត្រូវទំនុកបំរុងចំពោះសេចក្ដីត្រូវការរបស់ព្រះសម្មាសម្ពុទ្ធ និងព្រះភិក្ខុសង្ឃក្នុងឱកាសនោះ ។ ក្នុងរយៈពេលបីខែនោះ ព្រះមោគ្គល្លានបានស្ម័គ្រចិត្តប្រើទិព្វញ្ញាណរបស់ព្រះអង្គដើម្បីរកចង្ហាន់ រីឯព្រះសម្មាសម្ពុទ្ធទ្រង់ពុំត្អូញត្អែរទាល់តែសោះ ទ្រង់ពេញ ព្រះហឫទ័យនឹងចំណីសេះ ដែលអ្នកលក់សេះម្នាក់បានថ្វាយព្រះអង្គ ។

នាងវិសាខា ជាប្រធានឧបាសិកាដ៏សប្បុរសចំពោះព្រះសម្មាសម្ពុទ្ធ ដែលតែងតែទៅវត្ត ដើម្បីផ្គត់ផ្គង់សេចក្ដីត្រូវការរបស់ព្រះសម្មាសម្ពុទ្ធនិងព្រះភិក្ខុសង្ឃ បានដណ្ដប់នូវសំពត់ស្បៃ ដែលមានដាំត្បូងដ៏មានតម្លៃ ។ នៅពេលចូលទៅក្នុងវត្ត នាងតែងតែដោះវាចេញ ហើយប្រគល់ឱ្យទាសីយកទៅរក្សាទុកកុំឱ្យបាត់ ។ ម្ដងនោះ ទាសីនោះបានត្រឡប់ទៅផ្ទះវិញ ដោយភ្លេចសំពត់ស្បៃនោះនៅក្នុងវត្តដោយអចេតនា ។ ព្រះអានន្ទបានឃើញដូច្នោះ ក៏យកសំពត់ស្បៃនោះទៅទុកនៅកន្លែងដ៏គត់មត់មួយ ដើម្បីទុកប្រគល់ឱ្យនាងវិសាខាវិញ នៅពេលនាងមកវត្ត ។ នាងវិសាខាបានដឹងអំពីការបាត់សំពត់ដណ្ដប់ ក៏បានប្រាប់ទៅនាងទាសីឱ្យទៅរកសំពត់នោះ ប៉ុន្តែកុំយកសំពត់នោះមក ប្រសិនបើភិក្ខុសង្ឃបានប៉ះពាល់វាហើយ ។ ក្នុងការសាកសួររកសំពត់នាងទាសីបានដឹងថា ព្រះអានន្ទបានរក្សាសំពត់នោះទុកក្នុងកន្លែងមានសុវត្ថិភាពហើយ ។ នៅពេលត្រឡប់មកដល់ផ្ទះវិញ នាងទាសីបានរាយការណ៍អំពីរឿងរ៉ាវទាំងអស់នោះ ។ នាងវិសាខាបានធ្វើដំណើរទៅវត្ត ហើយបានទូលសួរទៅព្រះពុទ្ធថា តើអ្វីជាអំពើកុសលដែលនាងគួរធ្វើ ដោយប្រើប្រាស់ប្រាក់ដែលនាងបានពីការលក់សំពត់ស្បៃដ៏មានតម្លៃនេះ ។ ព្រះពុទ្ធបានទូន្មាននាងថា គួរសាងវត្តមួយជាប្រយោជន៍ដល់ព្រះសង្ឃទាំងឡាយ ។ ដោយសារពុំមាននរណាម្នាក់ហ៊ានទិញសំពត់នោះ ព្រោះវាថ្លៃពេក ទើបនាងសម្រេចចិត្តទិញសំពត់នោះខ្លួនឯង

រួចបានសាងសង់វត្តមួយប្រគេនចំពោះព្រះសង្ឃ ។ ក្រោយពេលធ្វើបុណ្យវេរប្រគេនចំពោះព្រះសង្ឃរួច នាងវិសាខាបានសម្តែងការដឹងគុណចំពោះទាសីរបស់នាង ដោយនិយាយថា «ប្រសិនបើនាងមិនបានភ្លេចសំពត់ដណ្តប់របស់ខ្ញុំទេ នោះខ្ញុំពិតជាពុំមានឱកាសបានធ្វើអំពើជាកុសលនេះទេ ហេតុនេះចូរនាងទទួលយកចំណែកកុសលរបស់នាងចុះ» ។

ដោយមិនធ្វើឱ្យទាសីមានការពិបាកចិត្ត ព្រោះតែបានធ្វើឱ្យបាត់សំពត់មួយរយៈ និងមិនបានស្តីបន្ទោសនាងទាសីចំពោះការធ្វើប្រហែសរបស់ខ្លួន ផ្ទុយទៅវិញនាងវិសាខាថែមទាំងថ្លែងអំណរគុណចំពោះទាសី ដែលបានផ្តល់ឱកាសឱ្យនាងបានធ្វើអំពើជាកុសលនេះទៀតផង ។ អាកប្បកិរិយាជាគំរូនៃនាងវិសាខា ដែលប្រកបដោយការអប់រំនេះជាមេរៀនគួរឱ្យចងចាំមិនអាចបំភ្លេចបាន ចំពោះអ្នកផងទាំងឡាយដែលធាប់ច្រឡោតខឹង ចំពោះកំហុសឆ្គងនៃអ្នកបំរើដែលឥតទីពឹង ។ ចំពោះការបាត់បង់គេត្រូវតែប្រឹងប្រែងទ្រាំទ្រដោយរីករាយ និងប្រកបដោយពលសម្បទាជាមនុស្ស ។ ដោយមិនចង់ឱ្យមានរឿងបែបនេះកើតឡើងទេ តែជារឿយៗជនខ្លះបានប្រឈមនឹងការបាត់បង់នូវទ្រព្យសម្បត្តិដោយចំនួនច្រើន និងមិនមែនបាត់តែមួយមុខនោះទេ ។ គេត្រូវប្រឈមមុខចំពោះរឿងនេះដោយឧបេក្ខា និងគិតថានេះជាឱកាសដ៏ប្រពៃ ដើម្បីប្រតិបត្តិនូវគុណធម៌ដ៏កំពូលនោះ ។

ការមានយស និងការបាត់យស

ការមានយស និងការបាត់យស គឺជាលោកធម៌ដែលមិនអាចគេចផុតបានមួយគូ ទៀត ដែលប្រឈមមុខចំពោះយើងក្នុងដំណើរជីវិតប្រចាំថ្ងៃ ។

យើងស្វាគមន៍ចំពោះការបានយស តែយើងមិនចូលចិត្តការបាត់យសទេ ។ បានយសធ្វើឱ្យសប្បាយក្នុងចិត្ត បាត់យសធ្វើឱ្យយើងខកចិត្ត ។ យើងមានបំណងចង់មានកេរ្តិ៍ឈ្មោះល្បីល្បាញ ។ យើងចង់ឃើញឈ្មោះនិងរូបថតយើងនៅលើទំព័រសារព័ត៌មាន ។ យើងសប្បាយចិត្តខ្លាំងណាស់ កាលណាសកម្មភាពរបស់យើងត្រូវបានគេផ្សាយជាសាធារណៈ ទោះបីជាមិនសូវមានន័យប៉ុន្មានក៏ដោយ ។ ជួនកាលយើងប្រឹងប្រែងហួសហេតុក្នុងការឃោសនាទៀតផង ។ ដើម្បីឱ្យមានរូបយើងនៅក្នុងទស្សនាវដ្តី អ្នកខ្លះរហូតដល់ត្រៀមប្រាក់ចេញថ្លៃផ្សាយទៀតផង ។ ដើម្បីទទួលបានកិត្តិយស អ្នកខ្លះរៀបចំជូនសំណូកឬផ្តល់ជំនួយយ៉ាងក្រាស់ក្រែលចំពោះគណបក្សដែលកាន់អំណាច ។ ដើម្បីការងារឃោសនា អ្នកខ្លះបង្ហាញចិត្តសប្បុរសរបស់ខ្លួន ដោយប្រគេនចង្ហាន់បិណ្ឌបាតចំពោះព្រះសង្ឃមួយរយអង្គ ឬក៏ច្រើនជាងនេះទៀត ប៉ុន្តែគាត់មិនអាចរវល់អើពើចំពោះសេចក្តីទុក្ខវេទនារបស់អ្នកកំសត់ទុគ៌ត និងអ្នកត្រូវការជំនួយដែលនៅរស់នៅជិតខាងគាត់ក៏ទេដែរ ។ អ្នកខ្លះអាចពិន័យឱ្យបង់ប្រាក់និងផ្តន្ទាទោសចំពោះអ្នកអត់អាហារ ដែលព្រោះតែសេចក្តីស្រេកឃ្លានបានលួចផ្លែដូងមួយផ្លែ នៅក្នុងសួនច្បាររបស់គាត់ដើម្បីបរិភោគ ប៉ុន្តែគាត់មិនដែលស្ទាក់ស្ទើរក្នុងការធ្វើអំណោយផ្លែដូងរាប់ពាន់ផ្លែ ដើម្បីយកកេរ្តិ៍ឈ្មោះទេ ។ នេះហើយជាភាពទន់ខ្សោយរបស់មនុស្ស ។ មនុស្សភាគច្រើនរហូតដល់ធ្វើអំពើល្អមួយដោយសារមានបំណងចង់បានអ្វីមួយ ។ អ្នកមិនអាត្មានិយមដែលប្រព្រឹត្តអំពើមិនគិតពីប្រយោជន៍ខ្លួនមានចំនួនតិចណាស់ក្នុងលោកនេះ ។ ទោះបីមូលហេតុដែលជំរុញឱ្យធ្វើអំពើល្អនោះមិនសូវជាគួរឱ្យសរសើរក៏ដោយ ក៏អ្នកដែលបានធ្វើអំពើល្អទាំងប៉ុន្មាន គប្បីទទួលការសរសើរដោយសារបានធ្វើអំពើមានផលប្រយោជន៍ ។ មនុស្សភាគច្រើនដែលមានពិសោធន៍ក្នុងជីវិតនេះសុទ្ធតែមានគំនិត និងគម្រោងថានឹងធ្វើអ្វីមួយទៅថ្ងៃមុខ ។ ដូច្នេះតើមាននរណាល្អ១០០%ទេ? តើអ្នកមានភាពបរិសុទ្ធឥតខ្ចោះនៅក្នុងមូលហេតុរបស់ខ្លួនមានប៉ុន្មាននាក់ទៅ? តើមានប៉ុន្មាននាក់ទៅដែលគិតដល់អ្នកដទៃមែនទែននោះ?

យើងមិនចាំបាច់ស្វែងដេញចាប់យសទេ ។ យសនឹងមានដល់យើងដោយមិនបាច់រកវាទេ ។ សត្វឃ្មុំចាប់ចិត្តនឹងផ្កាដែលសម្បូរទៅដោយទឹកដម ។ តាមពិតទៅផ្កាពុំបានអញ្ជើញឃ្មុំឱ្យមកទេ ។

ជាការពិតណាស់ យើងតែងមានអារម្មណ៍រីករាយ តែមិនមែនរីករាយហួសហេតុទេ នៅពេលដែលកេរ្តិ៍ឈ្មោះយើងល្បីសាយភាយទៅឆ្ងាយ និងទូលំទូលាយនោះ ។ ប៉ុន្តែយើងត្រូវដឹងថាកេរ្តិ៍ឈ្មោះ កិត្តិយស និងកិត្តិគុណវាគ្រាន់តែនាំទៅកាន់ទីប៉ាឆាតែប៉ុណ្ណោះ ។ វានឹងរលាយបាត់សូន្យទៅតាមខ្យល់ ។ វាជាពាក្យដែលឥតន័យ ប៉ុន្តែវាធ្វើឱ្យពិរោះដល់ត្រចៀកតែប៉ុណ្ណោះ ។

ចុះតើការបាត់យស វាយ៉ាងដូចម្តេចដែរ?

វាមិនអាចល្មមនឹងទទួលបាន ទាំងតាមត្រចៀក ទាំងតាមផ្លូវចិត្ត ។ យើងពិតជាមានកង្វល់ក្នុងចិត្តដោយឥតសង្ស័យឡើយ នៅពេលពាក្យមួលបង្កាច់មិនពិរោះស្តាប់ បានឮដល់ត្រចៀកយើង ។ ការឈឺចាប់ខាងផ្លូវចិត្តកាន់តែខ្លាំងឡើង នៅពេលរបស់ដែលហៅថាសេចក្តីរាយការណ៍នោះវាមិនត្រឹមត្រូវ ឬក៏ខុសទាំងស្រុង ។

តាមធម្មតាគេត្រូវការពេលវេលារាប់ឆ្នាំ ដើម្បីស្ថាបនាអគារដ៏ប្រណីតមួយបាន ។ ប៉ុន្តែដោយប្រើអាវុធប្រល័យលោកយ៉ាងទំនើប គេអាចកំទេចអគារនោះឱ្យខ្ទេចបាន យ៉ាងងាយតែក្នុងរយៈមួយឬពីរនាទីប៉ុណ្ណោះ ។ ជួនកាលគេត្រូវចំណាយពេលរាប់ឆ្នាំ ឬក៏អស់មួយជីវិត ទើបកសាងបាននូវកេរ្តិ៍ឈ្មោះដ៏ល្បីល្បាញ ។ ប៉ុន្តែ មិនយូរប៉ុន្មានកេរ្តិ៍ឈ្មោះដែលយើងរកដោយពិបាកនោះ អាចនឹងរលាយបាត់ទៅវិញ ។ គ្មាននរណាម្នាក់អាចគេចផុតពីសេចក្តីសង្កេតប្រកបដោយសេចក្តីវិនាសអន្តរាយ ដែលផ្តើមសំណួរដោយពាក្យទុយិសមួយម៉ាត់គឺ "ប៉ុន្តែ" ទេ ។ មែនហើយគាត់នោះល្អណាស់ គាត់បានធ្វើនេះ គាត់បានធ្វើនោះ ប៉ុន្តែ. . . គឺថាបញ្ជីនៃអំពើល្អទាំងមូលរបស់គាត់ទាំងប៉ុន្មានត្រូវខូចតម្លៃដោយពាក្យ "ប៉ុន្តែ" នេះឯង ។ អ្នកអាចរស់នៅដូចជាព្រះពុទ្ធមួយអង្គបាន ប៉ុន្តែអ្នកមិនអាចគេចផុតពីការរិះគន់ និងការជេរប្រមាថបានឡើយ ។

ព្រះពុទ្ធជាសាស្តាចារ្យខាងសាសនាដ៏ឆ្នើមបំផុត និងត្រូវគេមួលបង្កាច់ជាងគេនៅក្នុងសម័យដែលព្រះពុទ្ធគង់ជាធរមាននៅឡើយ ។

មហាបុរស គេមិនសូវស្គាល់ទេ ហើយប្រសិនបើគេស្គាល់វិញក៏គេស្គាល់ក្នុងផ្លូវខុសដែរ ។

មានគូបដិបក្ខនឹងព្រះពុទ្ធបានផ្សព្វផ្សាយពាក្យចចាមអារ៉ាមថា មានស្ត្រីម្នាក់តែងតែទៅដេកនៅក្នុងវត្ត ។ ដោយបំណងដែលគាត់ប៉ុនប៉ងបន្ទាបបន្ថោកព្រះពុទ្ធមិនបានសម្រេច គាត់ក៏ខំព្យាយាមផ្សាយពាក្យចចាមអារ៉ាមមិនពិតទៀតទៅក្នុងចំណោមប្រជារាស្ត្រគ្រប់ជាន់ថ្នាក់ថា ព្រះពុទ្ធនិងសាវ័ករបស់ព្រះអង្គ បានសម្លាប់ស្ត្រីនោះ ហើយយកសាកសពនាងនោះ ទៅលាក់នៅក្នុងគំនរសំរាមនៃផ្កាស្វិតៗនៅក្នុងវត្ត ។ នៅពេលដែលព្រះរាជបេសកកម្មជាប្រវត្តិសាស្ត្ររបស់ព្រះអង្គបានសម្រេចជោគជ័យ ហើយនៅពេលមានមនុស្សជាច្រើនបានមកសុំបួសជាសាវ័ករបស់ព្រះអង្គ គូបដិបក្ខរបស់ព្រះអង្គនាំគ្នានិយាយបង្កាច់បង្ខូចព្រះអង្គថា បានលួចកូនពីម្តាយគេ បានធ្វើឱ្យស្ត្រីជាភរិយាបាត់បង់ប្តីសី ហើយថាព្រះអង្គបានរារាំងមិនឱ្យសង្គមជាតិរីកចំរើន ។

ដោយបរាជ័យក្នុងការប៉ុនប៉ងបំផ្លាញចរិតលក្ខណៈដ៏ថ្លៃថ្នូររបស់ព្រះអង្គ បងប្អូនជីដូនមួយរបស់ព្រះអង្គ និងជាសាវ័កមួយអង្គដែលពូកែខាងច្រណែននឹងព្រះអង្គបានប៉ុនប៉ងធ្វើគុតព្រះអង្គ ដោយច្រានដុំថ្មទម្លាក់មកលើព្រះអង្គ ។

ដោយទ្រង់បានត្រាស់ជាព្រះពុទ្ធរួចហើយ ព្រះអង្គមិនអាចត្រូវគេធ្វើគុតបានឡើយ ។ ប្រសិនបើវាសនាគួរឱ្យព្រួយរបស់អ្នកគ្មានកំហុស ដូចជាព្រះសម្មាសម្ពុទ្ធដ៏បរិសុទ្ធនេះ កើតមានចំពោះមនុស្សធម្មតាវិញ តើវានឹងទៅជាយ៉ាងណាទៅ? ។

នៅពេលអ្នកឡើងភ្នំកាន់តែខ្ពស់ទៅៗខ្លួនអ្នកកាន់តែលេចជ្រងោឡើង ហើយអ្នកផងមើលឃើញអ្នកកាន់តែតូចទៅៗ ។ ខ្នងរបស់អ្នកបង្ហាញឱ្យគេឃើញ តែមុខរបស់អ្នកគេមើលពុំឃើញទេ ។ ពិភពលោកដែលចាំតែរកកំហុសនេះ នឹងបង្ហាញអំពីកំហុសនិង អំពើខុសឆ្គងរបស់អ្នក ប៉ុន្តែបានបិទបាំងមិនបង្ហាញអំពីគុណសម្បត្តិដ៏លេចធ្លោរបស់អ្នកឡើយ ។ កង្ហារបក់ស្រូវ បក់យកអង្កាមចេញតែទុកអង្ករ ផ្ទុយទៅវិញប្រដាប់ច្រោះរក្សាទុកកាកសំបក ប៉ុន្តែបង្ហូរទឹកដមដែលមានរសផ្អែមចេញ ។ អ្នកមានការអប់រំទទួលយកអ្វីដែលសុខុម ហើយចោលអ្វីដែលគ្រោតគ្រាតតម្រាំងទាំងដុល ។ ចំណែកឯជនមិនមានការអប់រំរក្សាទុកនូវអ្វីជាដុលគ្រោតគ្រាត ហើយបោះចោលនូវអ្វីដែលសុខុម ។ នៅពេលអ្នកត្រូវគេរាយការណ៍មិនត្រឹមត្រូវ ដោយនិយាយផ្សេងខុសពីការពិតដោយចេតនា ឬដោយមិនបានគិតទុកជាមុន លោក **អេពិកតេតឹស** បានទូន្មានថាគឺមានតែជនប្រកប

ដោយគតិបណ្ឌិតទេ ដែលជាអ្នកគិតឬនិយាយថា «ដោយសារការមើលស្រាលរបស់គាត់និងការយល់ដឹងរបស់គាត់អំពីខ្ញុំបានតិចតួចពេក ទើបបានជាខ្ញុំត្រូវគាត់ទិទៀនបន្តិចបន្តួចយ៉ាងដូច្នេះ ។ ប៉ុន្តែប្រសិនបើខ្ញុំត្រូវគេស្គាល់កាន់តែច្បាស់ នោះការចោទប្រកាន់មកលើខ្ញុំនឹងកាន់តែធ្ងន់ធ្ងរ និងរឹតតែធំធេងថែមទៀត» ។

វាមិនចាំបាច់អ្វីទៅចំណាយពេលឥតប្រយោជន៍ ដើម្បីកែតម្រូវរបាយការណ៍ក្លែងក្លាយនោះទេ លុះត្រាតែកាលៈទេសៈបង្ខិតបង្ខំអ្នកឱ្យបង្ហាញសេចក្តីបំភ្លឺ ។ សត្រូវវាសប្បាយណាស់ពេលវាឃើញអ្នកមានការឈឺចាប់ ។ នោះគឺអ្វីដែលពេលនេះវាកំពុងសង្ឃឹមថាទទួលបាន ។ ប្រសិនបើអ្នកមិនរវល់អើពើ នោះការនិយាយមួលបង្កាច់ខុសពីការពិតនោះវានឹងគ្មាននរណាស្តាប់ទេ ។

ដោយមើលឃើញកំហុសរបស់អ្នកដទៃ យើងគប្បីប្រព្រឹត្តដូចជាមនុស្សខ្វាក់ ។ បើឮពាក្យរិះគន់មិនត្រឹមត្រូវចំពោះអ្នកដទៃ យើងគប្បីប្រព្រឹត្តដូចមនុស្សថ្លង់ ។ បើនិយាយអាក្រក់ពីអ្នកដទៃ យើងគប្បីប្រព្រឹត្តដូចជាមនុស្សគ ។ គេមិនអាចបញ្ឈប់ការចោទប្រកាន់មិនត្រឹមត្រូវ ការធ្វើរបាយការណ៍មិនត្រឹមត្រូវ និងការនិយាយពាក្យចចាមអារ៉ាមបានទេ ។ ពិភពលោកនេះពោរពេញទៅដោយបន្លានិងគ្រួស ។ គេមិនអាចយកវាចេញបានទេ ។ ប៉ុន្តែប្រសិនបើយើងត្រូវតែដើរថ្វីបើមានឧបសគ្គយ៉ាងនេះក៏ដោយជំនួសការប៉ុនប៉ងដើម្បីបំបាត់បន្លា និងគ្រួសដែលជាប្រការដែលគេមិនអាចធ្វើបាននោះ គេទូន្មានឱ្យយើងពាក់ស្បែកជើងវិញនោះយើងអាចដើរបានដោយឥតមានទុក្ខភ័យឡើយ ។

ព្រះធម៌បានបង្រៀនថាៈ

ចូរធ្វើឱ្យដូចសត្វសិង្ហ ដែលញ័រមិនមែនក៏ព្រោះតែស្នូរសម្លេង ។
ចូរធ្វើឱ្យដូចខ្យល់ ដែលមិនតោងជាប់នឹងក្រឡាសំណាញ់ ។
ចូរធ្វើឱ្យដូចផ្កាឈូក ដែលគ្មានប្រឡាក់ភក់ ដែលវាដុះចេញមក ។
ចូរត្រាច់ចរតែត្រាកទៅតែម្នាក់ឯងដូចសត្វរមាស ។

ជាស្តេចនៃព្រៃព្រឹក្សា សត្វសិង្ហឥតមានខ្លាចអ្វីទាំងអស់ ។ តាមធម្មជាតិសត្វសិង្ហមិនភ័យខ្លាចចំពោះសម្រែកនៃសត្វទាំងឡាយឡើយ ។ នៅក្នុងលោកនេះយើងអាចឮពាក្យរាយការណ៍មិនល្អ ឮការចោទប្រកាន់មិនត្រឹមត្រូវ ការតក់សម្គាល់ដោយបន្ទាបបន្ថោកនៃពួកមាត់ដាច ។ ដូចជាសត្វសិង្ហ យើងពុំគប្បីស្តាប់ពាក្យពួកអ្នកទាំងនោះទេ ។ ដូចជាដំបង **ប៊ូមេរ៉ាង**[១] ដែលគេចោលទៅហើយ វាតែងតែវិលត្រឡប់មករកកន្លែងដើមវិញដូច្នេះដែរ ។

សត្វឆ្កែចេះតែព្រួស ឯក្បួនរទេះចេះតែទៅមុខយ៉ាងសុខស្រួល ។ យើងកំពុងរស់នៅក្នុងលោកដែលប្រកបដោយភក់ល្បាប់ ។ មានឈូករាប់មិនអស់បានដុះចេញពីទីនោះ ។ ដោយឥតមានប្រឡាក់ភក់ ផ្កាឈូកបានលំអពិភពលោក ។ យើងគប្បីសាកល្បងដឹកនាំជីវិតដ៏ឧត្តមនិងឥតមានទោសរបស់យើង ដូចជាផ្កាឈូកដោយកុំខ្វល់រវល់យកចិត្តទុកដាក់ចំពោះភក់ដែលគេចោលមកលើយើង ។

យើងគប្បីសង្ឃឹមថា មានគេចោលភក់ច្រើនជាងចោលផ្កាឈូកមកលើយើង ។ ដូច្នេះយើងពុំមានការខកចិត្តឡើយ ។ ថ្វីបើមានការលំបាកយើងគប្បីសាកល្បងបណ្តុះអនុបាទាន (គឺការមិនជាប់ជំពាក់ចិត្ត) ។ មនុស្សយើងកើតមកតែម្នាក់ឯង ហើយស្លាប់ទៅវិញក៏តែម្នាក់ឯង ។ អនុបាទានជាសុភមង្គលនៅក្នុងលោកនេះ ។ ការមិនយកចិត្តទុកដាក់ចំពោះកូនសរពិស ដែលបាញ់ដោយអណ្តាតដែលចេះតែរលាស់គ្មានអ្វីទប់នេះអាចឱ្យយើងត្រាច់ទៅរកជួយអ្នកដទៃទៅតាមការប៉ិនប្រសប់ដ៏ល្អបំផុតរបស់យើង ។

ផ្ទុយទៅវិញ វាជារឿងចម្លែកណាស់ ដែលមហាបុរសទាំងឡាយត្រូវគេនិយាយមួលបង្កាច់ និយាយអាក្រក់ពីគាត់ បំពុលគាត់ ត្រូវគេចាប់យកទៅដោតឆ្កាង ឬបាញ់សម្លាប់ក៏មាន ។

មហាបុរស សូក្រាត ត្រូវគេបំពុល ។ ព្រះយេស៊ូដ៏ឧត្តមត្រូវគេចាប់យកទៅឆ្កាងដោយគ្មានមេត្តា ។ មហាត្មាគន្ធី ដែលឥតបានធ្វើទុក្ខបុកម្នេញនរណាម្នាក់សោះត្រូវគេបាញ់សម្លាប់ ។

ចុះវាមានគ្រោះថ្នាក់មែនទេ ក្នុងការចង់ធ្វើអ្វីឱ្យល្អជ្រុលនោះ? មែនហើយ ពេលដែលពួកគាត់រស់នៅ ពួកគាត់ត្រូវគេទិទៀន គេវាយប្រហារនិងសម្លាប់ ។ បន្ទាប់ពីគាត់ស្លាប់ទៅ គេទុកពួកគាត់ដូចជាទេព្តាហើយគោរពគាត់ ។

មហាបុរស មិនរវល់អើពើចំពោះការបានយស ឬបាត់យសទេ ។ ពួកគាត់មិនខូចចិត្តទេកាលណាមានគេទិទៀនគាត់ ឬនិយាយបង្កាច់គាត់ ពីព្រោះគាត់ធ្វើការមិនមែនដើម្បីយសឬកេរ្តិ៍ឈ្មោះទេ ។ ពួកគាត់មិនខ្វល់ពីអ្វីទាំងអស់ទោះបីអ្នកដទៃទទួលស្គាល់កិច្ចការរបស់គាត់ឬក៏អត់ ។ «ចំពោះការងារ គាត់មានសិទ្ធិនឹងធ្វើ ប៉ុន្តែមិនមែនដើម្បីទទួលផលពីការងារនេះទេ» ។

ការសរសើរ និងការនិន្ទា

ការសរសើរ និងការនិន្ទា គឺជាលោកធម៌ពីរទៀតដែលមានឥទ្ធិពលមកលើមនុស្សលោក ។ វាជាការធម្មតា ដែលត្រូវរីករាយនៅពេលគេសរសើរ និងធ្លាក់ទឹកចិត្តនៅពេលគេនិន្ទា ។ ឋិតនៅកណ្តាលសរសើរនិងនិន្ទា ព្រះសម្មាសម្ពុទ្ធទ្រង់មានដីកាថា «បណ្ឌិតមិនដែលបង្ហាញឱ្យឃើញទាំងសេចក្តីរីករាយ ទាំងការធ្លាក់ទឹកចិត្ត ។ ដូចជាថ្មសិលា ដែលមិនដែលរង្គើដោយសារខ្យល់ទេ ថ្មសិលានៅតែនឹងថ្កល់ដដែល» ។

ការសរសើរប្រសិនបើមានតម្លៃក៏ព្រោះតែវាធ្វើឱ្យពិរោះដល់ត្រចៀក តែបើវាគ្មានតម្លៃវិញ ដូចជាក្នុងករណីពោលពាក្យបញ្ជោរ ថ្វីបើពិរោះមែន តែវាជាការឆបោកទៅវិញទេ ។ ប៉ុន្តែ ទាំងពីរយ៉ាងគឺជាសម្លេងដែលពុំមានផលអ្វីទាំងអស់ ប្រសិនបើវាមិនឮដល់ត្រចៀក ។ ចេញពីទស្សនៈលោកិយ ពាក្យសរសើរមួយម៉ាត់វាមានន័យវែងឆ្ងាយណាស់ ។ ដោយពោលសរសើរតែបន្តិច គេអាចនឹងទទួលបាននូវការអនុគ្រោះមួយយ៉ាងងាយ ។ ពាក្យសរសើរដែលប្រកបដោយគុណសម្បត្តិ មានសារសំខាន់គ្រប់គ្រាន់សម្រាប់ទាក់ទាញអ្នកស្តាប់មុនពេលអ្នកនោះនិយាយ ។ ប្រសិនបើពីដើមដំបូង វាគ្មិនពោលសរសើរអ្នកស្តាប់ នោះអ្នកស្តាប់នឹងប្រុងត្រចៀកស្តាប់ ។ តែបើវាគ្មិន ពោលពាក្យទិតៀនរិះគន់អ្នកស្តាប់ចាប់ពីដំបូងទីហើយ នោះលទ្ធផលប្រាកដជាមិនបានជាទីពេញចិត្តឡើយ ។ ជនមានការអប់រំមិនពឹងលើការបញ្ជោរទេ ហើយក៏មិនចង់ឱ្យអ្នកដទៃបញ្ជោរខ្លួនដែរ ។ ដែលគួរឱ្យសរសើរ គេសរសើរដោយឥតមានការច្រណែនឈ្នានីស ។ ដែលគួរឱ្យនិន្ទា គេនិន្ទាដោយមិនស្អប់ខ្ពើម ប៉ុន្តែចេញពីសេចក្តីមេត្តាករុណាប្រកបដោយគោលបំណងដើម្បីកែលំអអ្នកទាំងនោះ ។

មហាបុរស បានទទួលសេចក្តីសរសើរច្រើនក្រៃលែងពីសំណាក់អ្នកធំ អ្នកតូចដែលបានស្គាល់គាត់ច្បាស់ ថ្វីបើគាត់មិនរវល់យកចិត្តទុកដាក់មែនទែនចំពោះពាក្យសរសើរទាំងនោះក៏ដោយ ។ មានមនុស្សជាច្រើនដែលបានស្គាល់ព្រះពុទ្ធយ៉ាងស្និទ្ធស្នាលបានពោលសរសើរ អំពីគុណធម៌របស់ព្រះសម្មាសម្ពុទ្ធ តាមការយល់ដឹងរបស់ខ្លួន ។

មានសេដ្ឋីម្នាក់ឈ្មោះ **ឧបាលិ** ដែលទើបថ្វាយខ្លួនជាពុទ្ធបរិស័ទបានសរសើរព្រះសម្មាសម្ពុទ្ធ ដោយរាប់ពុទ្ធគុណបានរាប់រយប្រការ ដែលព្រះអង្គមានពីមុនមក ។ គុណធម៌ចំនួន៩ប្រការរបស់ព្រះសម្មាសម្ពុទ្ធ ដែលគេបានដឹងនៅសម័យពុទ្ធកាល ឥឡូវនេះក៏ពុទ្ធសាសនិកនៅតែសូត្រក្នុងពេលថ្វាយបង្គំព្រះពុទ្ធរូបម្តងៗ រហូតដល់សព្វថ្ងៃ ។ នោះជាកម្មវត្ថុមួយនៃការធ្វើសមាធិសម្រាប់អ្នកមានជំនឿស៊ប់ចំពោះព្រះធម៌ ។ គុណធម៌ប្រកបដោយគុណសម្បត្តិល្អនេះ នៅតែជាការលើកទឹកចិត្តយ៉ាងធំធេងចំពោះពុទ្ធបរិស័ទ ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានបន្ទូលថា «អ្នកដែលនិយាយច្រើនក៏គេនិន្ទា អ្នកដែលនិយាយតិចពេកក៏គេនិន្ទា អ្នកនៅស្ងៀមមិននិយាយសោះក៏គេនិន្ទា ។ នៅក្នុងលោកនេះគ្មាននរណាម្នាក់ដែលគេមិននិន្ទាទេ» ។ ការនិន្ទាហាក់ដូចជាមរតកជាសកលទុកឱ្យមនុស្សជាតិ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានធ្វើការកត់សម្គាល់ថា មនុស្សភាគច្រើនលើសកលលោកមានវិន័យមិនសូវល្អ ។ ដូចដំរីដែលនៅក្នុងសមរភូមិ បានទ្រាំទ្រនឹងព្រួញដែលគេបាញ់មកលើខ្លួនដូច្នេះ ព្រះសម្មាសម្ពុទ្ធទ្រង់មានបន្ទូលថា តថាគតក៏ឥតឈឺចាប់នឹងពាក្យជេរប្រមាថដែរ ។

អ្នកចូលចិត្តបំភាន់បញ្ឆោតគេ និងជនកំណាចខំប្រឹងតែពីរកចំណុចអាក្រក់

[១] ដំបងរាងកោងជាអាវុធរបស់កុលសម្ព័ន្ធនៅប្រទេសអូស្ត្រាលីដែលចោលទៅហើយត្រឡប់មករកអ្នកចោលវិញ ។

របស់អ្នកដទៃ មិនមែនខំរកចំណុចត្រឹមត្រូវនិងចំណុចល្អទេ ។ គ្មាននរណាម្នាក់ល្អត្រឹមត្រូវ១០០%ទេ លើកលែងតែព្រះសម្មាសម្ពុទ្ធចេញ ហើយក៏គ្មាននរណាម្នាក់អាក្រក់ ១០០%ដែរ ។ នៅក្នុងខ្លួនយើងមានទាំងអ្វីដែលអាក្រក់បំផុត នៅក្នុងអ្វីដែលល្អបំផុត ។ យើងក៏មានអ្វីដែលល្អនៅក្នុងអ្វីដែលអាក្រក់បំផុតនៅក្នុងខ្លួនយើងដែរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានបន្ទូលថា «ជនដែលប្រកបដោយតុណ្ហីភាពប្រៀបដូចជាគងដែលបែកដូច្នោះ នៅពេលគេវាយប្រហារ គេប្រមាថឬគេរំលោភគាត់ ជននោះស្ថិតនៅចំពោះមុខនៃនិព្វាន ទោះបីគាត់មិនទាន់បានសម្រេចព្រះនិព្វានក៏ដោយ» ។

ម្នាក់ៗអាចធ្វើអ្វីមួយ នៅក្នុងបុព្វហេតុដ៏ល្អបំផុតរបស់ខ្លួន ។ ប៉ុន្តែពិភពលោកខាងក្រៅជាញឹកញយតែងតែគាត់យល់ខុស និងសន្មត់ថាជននោះមិនអាចនឹងសម្រេចបំណងរបស់ខ្លួនបានដូចប្រាថ្នាទេ ។

ម្នាក់ៗអាចបំរើ និងជួយអ្នកដទៃយ៉ាងអស់ពីចិត្តទៅតាមសមត្ថភាពរបស់ខ្លួន ជួនកាលរហូតដល់ជំពាក់បំណុលគេ ឬលក់របស់របរ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដើម្បីជួយសង្គ្រោះមិត្តដែលមានបញ្ហា ។ ប៉ុន្តែក្រោយមកពិភពលោកនេះបានបង្កើតមនុស្សរមិលគុណគេ បានធ្វើឱ្យជនដែលត្រូវគេជួយសង្គ្រោះនោះងាកទៅរកកំហុសអ្នកដែលជួយសង្គ្រោះខ្លួន តម្រោមរកប្រយោជន៍បង្ខូចកេរ្តិ៍ឈ្មោះអ្នកមានគុណលើខ្លួន ហើយទីបំផុតអ្នកនោះឯងបានធ្លាក់ទៅក្នុងសេចក្តីវិនាសសមតាមអំពើរបស់ខ្លួន ។

នៅក្នុងរឿងជាតកមានដំណាលថា តន្ត្រីករម្នាក់ឈ្មោះ គុត្តិលៈ បានបង្រៀននូវវិជ្ជាដែលខ្លួនចេះទាំងប៉ុន្មានដល់សិស្សរបស់គាត់ ដោយឥតមានលាក់លៀមអ្វីបន្តិចសោះ ។ ប៉ុន្តែជននោះជាជនអកតញ្ញូ គាត់ខំប្រឹងប្រណាំងប្រជែងជាមួយគ្រូគាត់ ហើយបំផ្លាញគ្រូគាត់ឱ្យវិនាសហិនហោច ។ តែអំពើនេះមិនបានសម្រេចជោគជ័យទេ ។

ភិក្ខុទេវទត្តជាសិស្ស និងជាបងប្អូនជីដូនមួយរបស់ព្រះសម្មាសម្ពុទ្ធ ដែលរៀនបានសម្រេចទិព្វញ្ញាណ មិនគ្រាន់តែបង្ខូចកិត្តិយសរបស់ព្រះពុទ្ធអង្គទេ ប៉ុន្តែថែមទាំងប៉ុនប៉ងធ្វើគុតព្រះពុទ្ធដោយច្រានដុំថ្មទម្លាក់ពីលើភ្នំមកលើព្រះពុទ្ធ ក្នុងគ្រាដែលព្រះពុទ្ធអង្គ កំពុងយាងចង្រ្កមចុះឡើងនៅក្រោមជើងភ្នំថែមទៀត ។ ប៉ុន្តែការប៉ុនប៉ងនេះមិនបានសម្រេចតាមបំណងទេ ។ ពុំមានសាស្តាចារ្យខាងសាសនាណាមួយដែលគេសរសើរជាទីបំផុត និងទិតៀនជាទីបំផុត ត្រូវគេជេរប្រមាថ និងនិន្ទាដូចព្រះសម្មាសម្ពុទ្ធទេ ។ នេះហើយជាវាសនានៃមហាបុរស ។ នៅក្នុងការប្រជុំជាសាធារណៈមួយ មានស្ត្រីអប្រិយម្នាក់ឈ្មោះនាង ចិញ្ចា បានក្លែងជាស្ត្រីមានផ្ទៃពោះចូលមកនិយាយបង្កាច់ព្រះសម្មាសម្ពុទ្ធ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់អត់ធន់ ខន្តីនឹងពាក្យជេរប្រមាថដោយព្រះភក្រ្តញញឹម ហើយភាពបរិសុទ្ធរបស់ព្រះសម្មាសម្ពុទ្ធត្រូវបានបង្ហាញឱ្យឃើញដោយមានភស្តុតាងយ៉ាងច្បាស់ ។ ព្រះសម្មាសម្ពុទ្ធ ត្រូវបានគេចោទថា បានសម្លាប់ស្ត្រីម្នាក់ដោយមានទាំងពួកសាវ័កជួយក្នុងឃាតកម្មនេះផង ។ ពួកអ្នកមិនកាន់ពុទ្ធសាសនា បានទិតៀនព្រះសម្មាសម្ពុទ្ធនិងសាវ័កព្រះអង្គ យ៉ាងធ្ងន់ធ្ងរបំផុត រហូតដល់ព្រះអានន្ទសុំអារាធនាយាងព្រះសម្មាសម្ពុទ្ធចេញទៅគង់នៅភូមិផ្សេងទៀត ។

«ម្នាលអានន្ទ ! ចុះបើមនុស្សនៅក្នុងភូមិនោះក៏ប្រមាថយើងដែរ តើយើងធ្វើដូចម្តេចទៅ?» ។ «ដូច្នេះ ម្នាលអានន្ទ ប្រទេសឥណ្ឌាទាំងមូលនេះឥតមានកន្លែងសម្រាប់ពួកយើងស្នាក់នៅទេ ចូរអ្នកខន្តីអត់ធ្មត់ ។ ពាក្យជៀលត្មះនេះវានឹងសាបរលាបទៅជាស្វ័យប្រវត្ត» ។

នាងមាគន្ទិយា ជាស្ត្រីស្អំម្នាក់បានចងកំហឹងចំពោះព្រះសម្មាសម្ពុទ្ធដោយខឹងនឹងព្រះពុទ្ធពោលបង្អាប់មុខមាត់ដ៏ល្អស្រស់របស់នាង នៅពេលដែលឪពុកនាងចង់ឱ្យនាងរៀបការជាមួយព្រះពុទ្ធ ដោយសារតែសេចក្តីល្ងង់ខ្លៅ ។ នាងនោះបានជួលមនុស្សប្រមឹកឱ្យទៅជេរប្រមាថព្រះសម្មាសម្ពុទ្ធ នៅចំពោះមុខសាធារណៈជន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ខន្តីនឹងការជេរប្រមាថនោះដោយឧបេក្ខាយ៉ាងសុក្រឹត ។ ប៉ុន្តែនាងមាគន្ទិយា បានរងទុក្ខវេទនាដោយសារទោសកំហុសរបស់ខ្លួន ។ ការជេរប្រមាថគឺជាចំណែកមួយរបស់មនុស្សទូទៅ ។ កាលណាអ្នកធ្វើការកាន់តែច្រើន អ្នកកាន់តែមានឋានៈខ្ពស់ អ្នកកាន់តែក្លាយជាគោលដៅនៃការជេរប្រមាថ និងការធ្វើឱ្យ អាម៉ាស់មុខ ។

ព្រះយេស៊ូ ត្រូវគេជេរប្រមាថធ្វើឱ្យអាម៉ាស់មុខ និងត្រូវគេយកទៅឆ្កាង ។

លោកសូក្រាត ត្រូវជេរប្រមាថដោយភរិយារបស់គាត់ ។ រាល់ពេលដែលគាត់ចេញទៅខាងក្រៅដើម្បីជួយអ្នកដទៃ ភរិយាដែលឥតមានខន្តីរបស់គាត់តែងតែស្តីបន្ទោសគាត់ជានិច្ច ។ ថ្ងៃមួយនាងប្រពន្ធមានជម្ងឺ ដូច្នេះនាងពុំអាចស្តីបន្ទោសប្តីនាងបាន ។ នៅពេលនោះ លោកសូក្រាតបានចេញពីផ្ទះដោយទឹកមុខក្រៀមក្រំ ។ មិត្តសម្លាញ់របស់គាត់បានសួរគាត់ថា ហេតុអ្វីបានជាអ្នកព្រួយដូច្នេះ ។ គាត់ឆ្លើយថា ថ្ងៃនេះប្រពន្ធគាត់មិនបានស្តីបន្ទោសគាត់ ទេ ពីព្រោះនាងមានជម្ងឺ ។

ពេលនោះសម្លាញ់គាត់និយាយថា «ដូច្នេះអ្នកត្រូវតែសប្បាយរីករាយដោយសារអ្នកពុំបានទទួលពាក្យស្តីបន្ទោស ដែលអ្នកមិនស្វាគមន៍នោះ» ។

ប៉ុន្តែទស្សនវិទូនោះឆ្លើយថា «ទេ ! មិនដូច្នោះទេ ពីព្រោះថាពេលនាងស្តីបន្ទោសខ្ញុំ គឺពេលនោះហើយជាឱកាសដែលធ្វើឱ្យខ្ញុំអាចអនុវត្តធម៌ខន្តី ។ ថ្ងៃនេះខ្ញុំខកខានមិនបានធ្វើការអនុវត្តន៍ខន្តីនោះទេ ដោយហេតុនោះហើយបានជាខ្ញុំព្រួយ» ។ នេះគឺជាមេរៀនគួរចងចាំសំរាប់យើងទាំងអស់គ្នា ។

នៅពេលគេជេរប្រមាថយើង យើងគប្បីគិតថានោះជាឱកាសដែលគេផ្តល់ឱ្យយើងអនុវត្តធម៌ខន្តីហើយ ។ ជំនួសឱ្យការអត់ធ្មត់សង្កត់ចិត្តចំពោះសត្រូវដែលបានបំពានមកលើយើង យើងគប្បីអរគុណចំពោះគូសត្រូវយើងទៅវិញ ។

សេចក្តីសុខ និងសេចក្តីទុក្ខ

សេចក្តីសុខ និងសេចក្តីទុក្ខ ជាសភាវពីរផ្ទុយគ្នា ។ សភាវទាំងពីរនេះជាកត្តាប្រកបដោយពលានុភាពខ្លាំងបំផុត ដែលប៉ះពាល់ដល់មនុស្សទូទៅ ។ អ្វីដែលយើងទ្រាំទ្របានដោយស្រួលហៅថា សុខៈឬសេចក្តីសុខ អ្វីដែលពិបាកទ្រាំ គឺទុក្ខឬការឈឺចាប់ ។ តាមធម្មតាសេចក្តីសុខ គឺជាការធ្វើឱ្យឆ្អែតនូវចំណង់ ។ មិនយូរប៉ុន្មានបន្ទាប់ពីយើងទទួលបានវត្ថុដែលយើងបានហើយ យើងក៏ចង់បានសេចក្តីសុខផ្សេងទៀត ។ ដូច្នេះចំណង់ដែលយើងចង់បានផ្ទាល់ខ្លួននោះ មិនដែលស្កប់ស្កល់ឡើយ ។ ការត្រេកត្រអាលនឹងកាមរាគៈវាគ្រាន់តែជាសុភមង្គល ដែលមានកំរិតខ្ពស់បំផុតរបស់មនុស្សទូទៅ ។ ដោយឥតសង្ស័យឡើយ នោះគឺជាសេចក្តីសុខតែមួយរយៈខ្លីនៅក្នុងការរង់ចាំដោយរំភើបដោយការពេញចិត្តនិងការនឹកឃើញឡើងវិញនូវសេចក្តីសប្បាយខាងសម្ភារៈនោះ ហើយដែលអ្នកត្រេកត្រអាលនឹងកាមរាគៈបានឱ្យតម្លៃខ្ពស់ ប៉ុន្តែតាមពិតសេចក្តីសប្បាយនោះវាជាកលមាយាបំភាន់វិញ្ញាណនិងមានរយៈដ៏ខ្លីប៉ុណ្ណោះ ។ តើការមានទ្រព្យសម្បត្តិជាសម្ភារៈអាចផ្តល់នូវសេចក្តីសុខមែនទែនដល់អ្នកនោះឬទេ? បើដូច្នេះមែន អ្នកមានប្រាក់រាប់លានមិនគប្បីគិតដល់ការធ្វើអត្តឃាតទេ ។ នៅក្នុងប្រទេសខ្លះ ដែលការរីកចំរើនខាងសម្ភារៈបានឈានដល់កំពូលនោះ មានមនុស្សប្រហែល១០%មានជម្ងឺខាងផ្លូវចិត្ត ។ ហេតុអ្វីបានជាដូច្នេះ បើការមានទ្រព្យ សម្ភារៈ តែឯងអាចផ្តល់នូវសេចក្តីសុខមែនទែនហើយនោះ? តើអំណាចដែលអាច ត្រួតត្រាពិភពលោកទាំងមូលអាចបង្កើតសេចក្តីសុខពិតប្រាកដបានឬទេ? លោក អាឡិចហ្សង់ ដែលបានធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌា ប្រកបដោយជាញជ័យ ដោយច្បាំងដណ្តើមយកទឹកដីនៅតាមផ្លូវបាននិយាយដោយដកដង្ហើមធំថា គ្មានដីនៅសល់ដើម្បីច្បាំងយកទៀតទេ ។ តើព្រះចៅអធិរាជ និងមហាក្សត្រដែលពាក់មកុដសប្បាយព្រះហឫទ័យជានិច្ចឬទេ? ជាញឹកញយជីវិតនៃរដ្ឋបុរសដែលកាន់អំណាចអាចនឹងមានផលអាក្រក់ ។ ករណីគួរឱ្យអាណិតរបស់មហាត្មាគន្ធី និងលោកកេណេឌី គឺជាឧទាហរណ៍ស្រាប់ ។ សេចក្តីសុខពិតមាននៅក្នុងចិត្តនិងមិនមែនមានន័យថា មានទ្រព្យសម្បត្តិ មានអំណាច មានកិត្តិយសឬមានសញ្ជ័យនោះទេ ។ ប្រសិនបើទ្រព្យលោកិយនេះបានមកដោយប្រើកម្លាំងសង្កត់សង្កិនគេដោយអយុត្តិធម៌ ឬប្រើប្រាស់វាក្នុង ផ្លូវខុសឬក៏មានទស្សនៈជាប់ជំពាក់យ៉ាងខ្លាំងនឹងវា ទ្រព្យនឹងក្លាយទៅជាប្រភពនៃសេចក្តីទុក្ខព្រួយសម្រាប់ម្ចាស់ទ្រព្យនោះ ។ អ្វីជាសេចក្តីសុខរបស់មនុស្សម្នាក់អាចមិនមែនជាសេចក្តីសុខរបស់មនុស្សម្នាក់ទៀតទេ ។ អ្វីជាសាច់ និងភេសជ្ជៈរបស់ម្នាក់ អាចជាថ្នាំពុលចំពោះអ្នកឯទៀត ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីការៀបរាប់ថាមានសេចក្តីសុខ បួនប្រភេទសម្រាប់មនុស្សធម្មតា ។ នោះគឺសេចក្តីសុខព្រោះមានជារបស់ខ្លួន ដូចជាមានសុខភាព មានទ្រព្យធន មានអាយុវែង មានរូបសម្បត្តិល្អ

មានសេចក្តីរីករាយ មានកម្មសិទ្ធ មានកម្លាំងពលំ មានកូនច្រើន ។ល។

ប្រភពទីពីរនៃសេចក្តីសុខ បានមកពីការប្រើប្រាស់ទ្រព្យដែលខ្លួនមាននោះ ។ តាមធម្មតាបុរស និងស្ត្រីទាំងឡាយប្រាថ្នាចង់ឱ្យខ្លួនឯងបានសុខស្រួល ។ ព្រះសម្មាសម្ពុទ្ធពុំបានទូន្មានឱ្យមនុស្សទូទៅលះបង់ការសប្បាយលោកិយ ហើយថយទៅរស់នៅតែម្នាក់ឯងឆ្ងាយពីគេនោះទេ ។

ការសប្បាយនឹងទ្រព្យធន មិនស្ថិតនៅលើការប្រើប្រាស់វាសម្រាប់តែខ្លួនយើងទេ ប៉ុន្តែនៅលើការធ្វើទានសម្រាប់សុខុមាលភាពរបស់អ្នកដទៃផងដែរ ។ អ្វីដែលយើងហូបវាឆ្អែតបានតែមួយរយៈពេលដ៏ខ្លីប៉ុណ្ណោះ ។ អ្វីដែលយើងរក្សាទុក យើងឥតបាននៅជាមួយវាហើយយើងទៅចោលវាទៀត ។ អ្វីដែលយើងឱ្យគេ គឺយើងយកទៅជាមួយយើង ។ គេនឹងនឹកដល់យើងជានិច្ច ដោយសារតែអំពើល្អដែលយើងបានធ្វើដោយប្រើទ្រព្យលោកិយដែលយើងមាន ។

ការគ្មានជំពាក់បំណុលគេ ជាប្រភពនៃសេចក្តីសុខមួយទៀត ។ ប្រសិនបើយើងសប្បាយនឹងអ្វីដែលយើងមាន ហើយប្រសិនបើយើងមានការសន្សំសំចៃ នោះយើងនឹងមិនជំពាក់បំណុលគេទេ ។ អ្នកជំពាក់បំណុលគេ រស់នៅមានការឈឺចាប់ខាងផ្លូវចិត្តខ្លាំងណាស់ ហើយត្រូវស្ថិតនៅក្រោមការបង្ខិតបង្ខំរបស់ម្ចាស់បំណុល ។ ថ្វីបើក្រមែនតែកាលណាគ្មានជំពាក់បំណុលគេ អ្នកប្រាកដជាមានអារម្មណ៍ធូរស្រាល និងមានការសប្បាយខាងផ្លូវចិត្ត ។

ការរស់នៅក្នុងជីវិតគ្មានការនិន្ទា គឺជាប្រភពដ៏ល្អបំផុតមួយនៃសេចក្តីសុខសម្រាប់បុគ្គលជាគ្រហស្ថ ។ បុគ្គលឥតមានការនិន្ទា គឺជាការប្រសិទ្ធិពរចំពោះខ្លួនឯង និងចំពោះអ្នកដទៃ ។ ជននោះត្រូវបានគេគ្រប់គ្នាកោតសរសើរ និងមានអារម្មណ៍សប្បាយរីករាយជាងគេ ដោយគាត់ទទួលបាននូវទំនាក់ទំនងសន្តិភាពពីអ្នកដទៃ ។ យ៉ាងណាក៏ដោយ ក៏គេអាចនិយាយបានថា វាជាការពិបាកខ្លាំងណាស់ ដើម្បីរកឱ្យបានមនុស្សល្អក្នុងចំណោមមនុស្សទាំងឡាយ ។ បុគ្គលដែលមានសតិល្អបរិសុទ្ធ យកចិត្តទុកដាក់តែចំពោះជីវិតឥតនិន្ទា ហើយមិនរវល់អើពើនឹងការទទួលស្គាល់ពីសង្គមខាងក្រៅទេ ។ មនុស្សភាគច្រើននៅក្នុងលោកនេះ ធ្វើឱ្យខ្លួនឯងបានរីករាយដោយត្រេកត្រអាលនឹងសេចក្តីសប្បាយលោកិយ នៅពេលដែលអ្នកខ្លះទៀតខំធ្វើឱ្យខ្លួនគេរីករាយ ដោយលះបង់ការសប្បាយលោកិយ ។ ការមិនជាប់ជំពាក់ឬការមិនឱ្យតម្លៃចំពោះការសប្បាយខាងសម្ភារៈ គឺជាសេចក្តីសុខខាងស្មារតី ។ និព្វានសុខគឺជាបរមសុខដែលរួចផុតទុក្ខវេទនា ។ នោះហើយជាសុខដ៏កំពូល ។

តាមធម្មតាយើងស្វាគមន៍ចំពោះសេចក្តីសុខ តែយើងមិនស្វាគមន៍ចំពោះសេចក្តីទុក្ខទេ ព្រោះវាពិបាកទ្រាំទ្រណាស់ ។ សេចក្តីទុក្ខ ឬការឈឺចាប់កើតចេញជាអាការៈផ្សេងៗគ្នា ។ យើងរងទុក្ខពេលយើងចាស់ជរា ដែលនេះជាការធម្មតាសម្រាប់មនុស្សទូទៅ ។ ដោយឧបេក្ខា យើងត្រូវតែទ្រាំទ្រនឹងការឈឺចាប់នៃចាស់ជរា ។ កាន់តែឈឺចាប់ជាងជរាទុក្ខទៅទៀតនោះ គឺសេចក្តីទុក្ខដោយសារមានរោគាព្យាធិ ។ ចំពោះជម្ងឺនេះ បើវាពុំរ៉ៃយើងមានអារម្មណ៍ថាសេចក្តីស្លាប់ពិតជាចៀសមិនរួចទេ ។ សូម្បីគ្រាន់តែឈឺធ្មេញបន្តិចបន្តួច ឬឈឺក្បាលក៏ជួនកាលយើងពុំអាចទ្រាំបានផង ។ នៅពេលយើងធ្លាក់ខ្លួនឈឺ យើងមិនបាច់បារម្ភទេ គឺយើងគប្បីតែអាចទ្រាំទ្រវាឱ្យអស់ពីលទ្ធភាព ។ មែនហើយយើងត្រូវលើកទឹកចិត្តខ្លួនឯងដោយគិតថា យើងនឹងបានជាសះស្បើយពីជម្ងឺដ៏ធ្ងន់នោះ ។ ជាញឹកញយ យើងត្រូវឃ្លាតឆ្ងាយពីអ្នកជិតស្និទ្ធ និងអ្នកជាទីស្រឡាញ់របស់យើង ។ ការព្រាត់ប្រាស់និរាសបែបនេះជាហេតុនាំឱ្យមានទុក្ខខាងផ្លូវចិត្តធំធេងណាស់ ។ យើងគប្បីយល់ថា ការរស់នៅជាក្រុមញាតិត្រូវបញ្ចប់ដោយសារការ និរាសប្រាស់ព្រាត់គ្នា ។ នេះក៏ជាឱកាសដ៏ល្អសម្រាប់យើងអនុវត្តធម៌ឧបេក្ខាដែរ ។ ជាញឹកញយ យើងត្រូវបង្ខំឱ្យរួមរស់ជាមួយអ្វីដែលយើងមិនពេញចិត្ត ដែលយើងស្អប់ខ្ពើម ។ យើងគប្បីតែអាចទទួលទ្រាំទ្រវាបានដោយគិតថា ប្រហែលជាយើងកំពុងប្រមូលផលនៃអំពើដែលយើងបានធ្វើពីអតីតកាល និងក្នុងបច្ចុប្បន្នកាលនេះ ។ យើងគប្បីតែខំសម្របសម្រួលចិត្តយើងទៅនឹងស្ថានភាពថ្មី ឬក៏ខិតខំជំនះលើឧបសគ្គដោយ មធ្យោបាយផ្សេងៗ ។

ទោះបីព្រះសម្មាសម្ពុទ្ធ ជាសត្វលោកដ៏បរិសុទ្ធឥតខ្ចោះមួយអង្គ ដែលបានបំផ្លាញកិលេសអស់រលីងហើយក៏ដោយ ក៏គង់ទទួលនូវសេចក្តីទុក្ខខាងផ្លូវកាយដែលបណ្តាលមកពីជម្ងឺព្យាធិ និងគ្រោះថ្នាក់ដែរ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់អាពាធព្រះកេសជាប្រចាំ ។ ជម្ងឺចុងក្រោយបំផុតរបស់ព្រះអង្គ បណ្តាលឱ្យព្រះអង្គមានការឈឺចាប់ខាងរាងកាយយ៉ាងខ្លាំង ។ ដូចជាលទ្ធផលនៃការទម្លាក់ដុំថ្ម ដែលភិក្ខុទេវទត្តប៉ុនប៉ងធ្វើគុតព្រះអង្គ គឺព្រះបាទារបស់ព្រះអង្គមានរបួសដោយកំទេចថ្ម ដែលតម្រូវឱ្យធ្វើការវះកាត់ ។ ជួនកាលព្រះអង្គត្រូវបង្ខំឱ្យអត់អាហារទៀតផង ។ ក្នុងពេលនោះ ព្រះអង្គទ្រង់ពេញព្រះហឫទ័យនឹងចំណីសេះ ។ ដោយមកពីសិស្សរបស់ព្រះអង្គមិនស្តាប់បង្គាប់ព្រះអង្គ ព្រះអង្គត្រូវតែបង្ខំព្រះហឫទ័យយាងចេញទៅគង់នៅក្នុងព្រៃអស់បីខែ ។ នៅក្នុងព្រៃមានតែកម្រាលស្លឹកឈើក្រាលផ្ទាល់លើព្រះធរណី និងប្រឈមនឹងភាពរងាដោយខ្យល់ត្រជាក់ តែព្រះអង្គទ្រង់នៅតែថ្នឹងធ្លាក់ដោយធម៌ឧបេក្ខាយ៉ាងសុក្រឹត ។ នៅចន្លោះទុក្ខនិងសុខ ព្រះអង្គសម្រួលជីវិតព្រះអង្គដោយមានតុល្យភាពខាងស្មារតី ។

សេចក្តីស្លាប់ គឺជាទុក្ខសោកដ៏ធ្ងន់ធ្ងរបំផុត ដែលបង្ខំឱ្យយើងទទួលនៅក្នុងដំណើរគ្មានទីបញ្ចប់របស់យើងនៅក្នុងវដ្តសង្សារ ។ មរណភាពជួនកាលមិនមែនកើតមានចំពោះតែមនុស្សម្នាក់ទេ តែចំពោះមនុស្សច្រើននាក់ក្នុងពេលជាមួយគ្នា ដែលអាចរហូតដល់នាំឱ្យឆ្កួតវង្វេងស្មារតី ។ នាងបដាចារា បានបាត់បង់សាច់ញាតិជិតស្និទ្ធ និងជាទីស្រឡាញ់របស់នាង គឺឪពុកម្តាយ ស្វាមី បងប្រុសនិងកូនទាំងពីរនាក់ ហើយនាងបានក្លាយទៅជាមនុស្សឆ្កួត ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានលួងលោមនាងឱ្យមានស្មារតីឡើងវិញ ។ នាងកិសាគោតមី បានបាត់បង់កូនប្រុសតែម្នាក់គត់របស់នាង ។ នាងបានបីសាកសពកូនដែលស្លាប់ទៅហើយនោះដើរស្វែងរកថ្នាំដើម្បីព្យាបាលកូននាងឱ្យរស់ឡើងវិញ ។ នាងបានចូលទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ហើយទូលសុំថ្នាំពីព្រះអង្គ ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីកាថា «ម្នាលនាងគោតមី តើនាងអាចរកគ្រាប់ស្ពៃខៀវបានទេ?» ។ នាងឆ្លើយថា «បពិត្រព្រះអង្គ ទូលព្រះបង្គំរកបាន» ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទៀតថា «ប៉ុន្តែ ចូរនាងទៅរកគ្រាប់ស្ពៃនោះពីផ្ទះណាដែលគ្មានមនុស្សស្លាប់សោះ» ។ នាងរកគ្រាប់ស្ពៃបាន ប៉ុន្តែពុំមែនបានពីកន្លែងដែលគ្មានមនុស្សស្លាប់ទេ ។ ពេលនោះទើបនាងយល់ច្បាស់អំពីធម្មជាតិនៃជីវិត ។ នៅពេលដែលគេសួរស្ត្រីជាម្តាយម្នាក់ថា ហេតុអ្វីបានជាអ្នកមិនយំចំពោះមរណភាពនៃកូនប្រុសតែម្នាក់គត់របស់អ្នកយ៉ាងនេះ? ។ នាងនោះឆ្លើយថា «កូនខ្ញុំ កាលគេមកក៏គ្មាននរណាហៅឱ្យមក ដល់គេទៅវិញ គេក៏មិនឱ្យដំណឹងមុន» ។ ដោយសារគេកើតទើបគេស្លាប់ទៅវិញ ហេតុអ្វីបានជាយើងត្រូវយំ? តើការយំសោកឱ្យប្រយោជន៍អ្វីខ្លះទៅ? ដូចជាផ្លែឈើដែលធ្លាក់ពីដើម មានខ្ចី ទុំ ឬចាស់ ដូចគ្នានេះដែរ យើងក៏អាចស្លាប់ក្នុងពេលដែលយើងនៅក្មេង ពេលពេញវ័យឬក៏ដល់ពេលចាស់ ។ ព្រះអាទិត្យរះនៅទិសបូព៌ា គឺដើម្បីទៅលិចនៅទិសបស្ចិម ។ បុប្ផារីកនៅពេលព្រឹក ដើម្បីស្រពោននៅពេលល្ងាច ។ សេចក្តីស្លាប់ដែលចៀសមិនរួច តែងកើតមានដល់ជនគ្រប់រូបឥតមានលើកលែងនរណាម្នាក់ឡើយ ដូច្នេះយើងត្រូវតែទទួលស្គាល់ដោយធម៌ឧបេក្ខា ដ៏សុក្រឹតបំផុត ។

ដូចជាព្រះធរណី ដែលមិនខ្វល់ចំពោះអ្វីដែលគេបោះចោលទៅលើឡើយ មិនថាផ្អែមឬស្អុយ ឧបេក្ខាជាធម៌សម្រាប់យើងទាំងអស់គ្នាក៏ដូច្នោះដែរ គឺមិនត្រូវសម្តែងការស្អប់ហើយក៏មិនត្រូវសម្តែងការស្រឡាញ់ដែរ ។ ដូច្នេះមនុស្សយើងក៏ដូចគ្នាទោះបីសុខសប្បាយឬមានជម្ងឺ យើងត្រូវតែមានស្មារតីស្ថិតក្នុងតុល្យភាពដែលយើងធ្លាប់តែមានរហូតមក ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា «នៅពេលជួបប្រទះនឹងលោកធម៌ទាំងឡាយ ស្មារតីរបស់ព្រះអរហន្តមិនដែលកម្រើកសោះឡើយ ។ នៅចន្លោះបានលាភ និងបាត់លាភ, មានយសនិងបាត់យស, សរសើរនិងនិន្ទា, សុខនិងទុក្ខ ចូរយើងខិតខំរក្សាឱ្យបាននូវតុល្យភាពខាងស្មារតី » ។

អំពីប្រាសាទនានា

TEMPLES



មហិយង្គណៈ ស្រីលង្កា

នៅក្នុងសម័យពុទ្ធកាល មានដំណាលថា ព្រះពុទ្ធបានយាងមកដល់ប្រទេសស្រីលង្កាយ៉ាងហោចណាស់ក៏បីដងក្នុងឱកាសខុសៗគ្នា ដើម្បីមកទតកន្លែងដ៏ពិសិដ្ឋទាំងឡាយ គឺមហិយង្គណៈ នាគទីប និងកេលនិយៈ ។

មហាចេតិយបុរាណមហិយង្គណៈ គឺជាប្រាសាទពុទ្ធសាសនាដ៏វិសុទ្ធមួយនៃកោះលង្កា ។ អ្នកមានជំនឿចំពោះពុទ្ធសាសនាជឿថា ប្រាសាទនេះត្រូវបានគេសាងសង់ឡើង ដើម្បីតម្កល់ព្រះកេសារបស់ព្រះពុទ្ធ តាំងពីមុនព្រះអង្គបរិនិព្វានម្ល៉េះ ។ បើតាមគម្ពីរមហាវង្ស ដែលជាកាលប្បវត្តបុរាណរបស់ពុទ្ធសាសនិកសីហឡៈ បានឱ្យដឹងថា ព្រះសម្មាសម្ពុទ្ធបានយាងមកកាន់ទីនេះក្នុងឱកាសបុណ្យវេទ្ធ ទ្រង់បានហោះឡើងទៅលើអាកាស ធ្វើឱ្យពួកយក្សភិតភ័យយ៉ាងខ្លាំង ហើយបានប្រមូលអ្នកកោះទាំងឡាយឱ្យកាន់ពុទ្ធសាសនា ។

គេនិយាយថា ក្រោយមកគេបានយកឆ្អឹងដងកាំបិតដែលគេគាយរកឃើញនៅកន្លែងបូជាព្រះសពរបស់ព្រះពុទ្ធមកតម្កល់នៅក្នុងមហាចេតិយ ដែលគេពង្រីកបន្ថែមនេះ ។ អ្នកគ្រប់គ្រងប្រទេសបន្តបន្ទាប់មក ចាប់តាំងពីព្រះបាទទុតុគេមុនុ នៅសតវត្សទី២ មុនគ្រិស្តសករាជរហូតដល់សព្វថ្ងៃនេះ បានកែលំអមហាចេតិយនេះបន្ថែមទៀតដោយបូកពីលើគ្នាមួយជាន់ហើយមួយជាន់ទៀត ដូចជាស្រទាប់មើមខ្ទឹមបារាំង រហូតដល់មានរូបរាងគួរឱ្យចាប់អារម្មណ៍ដូចសព្វថ្ងៃនេះ ។

នាគទីប ស្រីលង្កា

មួយឆ្នាំពេញមួយឆ្នាំ អ្នកមានសទ្ធាចំពោះពុទ្ធសាសនា បាននាំគ្នាយ៉ាងច្រើនកុះករទៅប្រជុំគ្នានៅវិហារនាគទីបដែលជាកន្លែងមួយក្នុងចំណោមកន្លែងទាំងបី ដែលគេនិទានថាជាកន្លែងដែលព្រះសម្មាសម្ពុទ្ធ បានយាងមកដើម្បីទស្សនាកោះលង្កា ។ រឿងដែលល្បីល្បាញនោះដោយសារតែចេតិយ និងព្រះវិហារនេះមានឈ្មោះថា នាគទីបដែលតាមគម្ពីរមហាវង្ស នាគទីបសំដៅឧបទ្វីបជាហ្វណាទាំងមូល ។

ចេតិយ ជាទីសក្ការៈនៅនាគទីបដែលស្ថិតនៅកោះ ណៃនតិវុ ដែលនៅខាងមុខឆ្នេរសមុទ្រជាហ្វណា គឺជាគំរូដ៏ល្អមួយនៃចេតិយជាប្រពៃណី ដែលមានរាងដូចកណ្ដឹង ។

រាជមហាវិហារ កេលនិយៈ ស្រីលង្កា

មជ្ឈមណ្ឌលខាងជំនឿដ៏សំខាន់បំផុតនៃពុទ្ធសាសនិកនៅក្រុងកូឡុំបូ គឺវិហារកេលនិយៈ ដែលស្ថិតនៅចម្ងាយដប់មួយគីឡូម៉ែត្រពីបន្ទាយទៅទិសឦសាន និងបែកចេញបន្តិចពីផ្លូវទៅក្រុងកាន្ឌី ។ ពិតមែនហើយ រាជមហាវិហារកេលនិយៈ គឺជាកន្លែងមួយក្នុងចំណោមកន្លែងទាំងបីនៃកោះលង្កា ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានជ្រើសយកជាកន្លែងពិសេសសម្រាប់ទស្សនកិច្ចរបស់ព្រះអង្គ ។

តាមគម្ពីរមហាវង្ស ចេតិយដែលមានរាងប្លែកពីគេ គឺរាងដូចគំនរស្រូវនៅកេលនិយៈនេះបញ្ជាក់នូវកន្លែងដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់លើបល្ល័ង្កដាំត្បូង តាមការយាងនិមន្តរបស់ស្តេចនាគរាជ ដើម្បីសម្តែងធម្មទេសនាដល់ប្រជារាស្ត្រ និងប្រោសប្រជារាស្ត្រទាំងនោះ ។ គេសន្និដ្ឋានថា នោះជាស្នាដៃរបស់ព្រះបាទយតាលតិស្សៈ នៅរវាងសតវត្ស ទី៣មុនគ្រិស្តសករាជ ។

ព្រះវិហារថ្មី ដែលទើបកសាងនៅដើមសតវត្សនេះ មានលក្ខណៈល្អប្រណីតប្លែកពីគេ ។ រូបចម្លាក់លំអជញ្ជាំងរៀបរាប់អំពីពុទ្ធប្បវត្តិ អំពីព្រះពុទ្ធសាសនានៅលង្កា និងប្រវត្តិរបស់ព្រះវិហារកេលនិយៈ ។ ផ្ទាំងគំនូរលើពិដាន ដែលយកគំរូតាមគំនូរបែបរេខាគណិតនៃព្រះវិហារធំនេះមើលទៅគួរឱ្យចាប់ចិត្តខ្លាំងណាស់ ។ នៅក្នុងទីនោះមានពុទ្ធបដិមាសំខាន់ៗ បីអង្គ មួយអង្គទ្រង់ផ្ទំ ពីរអង្គទ្រង់គង់ ។ ផ្នែកខាងក្រៅនៃជញ្ជាំងមានលំអទៅដោយផ្ទាំងរឿងកំប្លែងនៃមនុស្សតឿ និងដំរី ដែលគេចម្លងតាមចម្លាក់នៃប្រាសាទតិវង្កនៅក្រុងប៉ូឡូណារុវ៉ា ។

ក្បួនដង្ហែប្រចាំឆ្នាំនៅកេលនិយៈប្រព្រឹត្តទៅ នៅថ្ងៃពេញបូរមីក្នុងខែមករា ដើម្បីរំលឹកដល់ដំណើរមកដល់កោះលង្ការបស់ព្រះពុទ្ធ ។ បើនិយាយពីទស្សនិយភាពវិញ ក្បួនដង្ហែនៅកេលនិយៈជាក្បួនដង្ហែទី២ បន្ទាប់ពីក្បួនដង្ហែនៅក្រុងកាន្ឌី ។



ស្រីបាទៈ ស្រីលង្កា

សាសនាធំៗទាំងបួននៅស្រីលង្កា សុទ្ធតែចាត់ទុកថាកំពូលភ្នំអាដាំជាកន្លែងសក្ការៈបូជារបស់ខ្លួន ។ អ្នកកាន់ព្រះពុទ្ធសាសនាហៅភ្នំនោះថា ស្រីបាទៈ «ស្នាមព្រះបាទដ៏ពិសិដ្ឋ» ហើយថាព្រះសមណគោតម បានយាងមកកាន់ទីនោះដោយព្រះអង្គឯង ។ ចំពោះពួកឥណ្ឌូវិញ កំពូលភ្នំដែលគេឱ្យឈ្មោះថា សិវនាទិបាទំ «របាំប្រឌិតញាណរបស់ព្រះសីវៈ» ជាកន្លែងរក្សាទុកនូវស្នាមព្រះបាទរបស់ព្រះសិវៈ ។ ពួកមូស្លីមទទួចចង់បានថាទីនោះជាកន្លែងដែលអាដាំបានដាក់ជើងលើផែនដីមុនគេ ។ ឯពួករ៉ូម៉ាំងកាតូលិកជាច្រើននិយាយថា ស្នាមព្រះបាទដែលជិតជាប់លើថ្មាំងថ្មលើកំពូលភ្នំនោះ គឺជាស្នាមព្រះបាទរបស់ព្រះសន្តថូម៉ាស ដែលជាគ្រិស្តសាវ័កដំបូងគេបង្អស់ បើតាមប្រពៃណីថាជាអ្នកមកផ្សព្វផ្សាយគ្រិស្តសាសនា នៅភាគខាងត្បូងនៃប្រទេសឥណ្ឌា ។

ឈ្មោះដើមដំបូងបង្អស់របស់ភ្នំនេះ គឺសមនលៈកន្ទ ឬភ្នំសមន ។ តាំងពីមុនពេលដែល ព្រះពុទ្ធសាសនាបានមកប្រតិស្ឋាននៅលើកោះនេះ ទេវៈសមន ត្រូវបានគេគោរពជាទេវៈកំពូលនៅទីនេះ ។ ហ្វូងមេអំបៅពណ៌លឿងដែលហើរមកជួបជុំគ្នាក្នុងរយៈពេលដ៏ខ្លី មួយឆ្នាំម្តងនៅលើកំពូលភ្នំនេះគេហៅថា សមនលយោ ។

យ៉ាងហោចណាស់ ចាប់តាំងពីសតវត្សទី១១រហូតមក ភ្នំនេះបានក្លាយទៅជាគោលដៅនៃពួកអ្នកធ្វើធម្មយាត្រា ។ ព្រះបាទវិជ័យពាហុទី១ និងព្រះបាទនិស្សង្កមល្លៈនៃរដ្ឋប៉ូឡូណារុវ៉ា ទាំងពីរព្រះអង្គសុទ្ធតែបានធ្វើធម្មយាត្រាទៅកាន់ទីនោះ ។ គម្ពីរមហាវង្ស ក៏មាននិយាយយោងទៅដល់ព្រះពុទ្ធសាសនានៅលើកំពូលភ្នំនោះដែរ ។

រដូវធម្មយាត្រាចាប់ផ្តើមពីខែធ្នូ និងបន្តរហូតដល់ថ្ងៃពិសាខបូជា ក្នុងខែឧសភា ។ អ្នកធ្វើធម្មយាត្រាច្រើនបំផុតទៅទីនោះ ក្នុងខែមីនា ។ នៅក្នុងពេលផ្សេងពីនេះ កំពូលភ្នំមានសភាពអាប់អួរ និងមានភ្លៀងធ្លាក់ ធ្វើឱ្យផ្លូវឡើងប្រកបដោយគ្រោះថ្នាក់ ។ រៀងរាល់ឆ្នាំមានបូជនីយេសក៍រាប់ម៉ឺននាក់បានធ្វើដំណើរទៅកាន់ទីនោះ ។ ភាគច្រើននៃជនទាំងនោះ ធ្វើដំណើរនៅពេលយប់ដោយឡើងតាមជណ្តើរដែលបំភ្លឺដោយចង្កៀងអគ្គិសនី ។ មានដំណាក់សម្រាប់អ្នកដំណើរសម្រាក និងកន្លែងលក់ភេសជ្ជៈជាច្រើននៅតាមបណ្តោយផ្លូវធ្វើឱ្យដំណើរឡើងភ្នំមានភាពងាយស្រួល ។ ជនណាដែលឡើងទៅដល់កំពូលភ្នំពេលថ្ងៃរះនឹងបានឃើញនូវទស្សនិយភាពដ៏ល្អបំផុតមួយ គឺម្លប់រាងត្រីកោណដែលជាស្រមោលដ៏ធំសម្បើមនៃកំពូលភ្នំ គ្របទៅលើជនបទស្រែចំការដែលទើបភ្ញាក់ពីដំណេក ។ នៅពេលដ៏កម្រខ្លះ គេអាចមើលឃើញស្រមោលខ្លួនឯង ដែលរីកយ៉ាងធំមហិមា ជិតលើអ័ព្ទនៅឯទីឆ្ងាយ ដោយមានឥន្ទធនូព័ទ្ធជុំវិញផង ។

បូជនិយេសក៍ឡើងកំពូលភ្នំអាដាំ តែងគោរពតាមពិធីនៃប្រពៃណីខ្លះក្នុងដំណើរឡើងភ្នំរបស់ខ្លួន ។ តាមទម្លាប់អ្នកឡើងដំបូងត្រូវជូតក្បាលនឹងឈ្នួតយ៉ាងធំមួយ ។ នៅតាមផ្លូវសំខាន់ៗទាំងឡើងទាំងចុះ មានកន្លែងបោះម្ជុលដែលនៅទីនោះគេសុំឱ្យបូជនិយេសក៍ឈប់ និងបញ្ចេញម្ជុលដែលមានដោតអំបោះ ទៅក្នុងគុម្ពោតព្រៃនៅសងខាងផ្លូវ ដើម្បីបញ្ជាក់ឱ្យដឹងនូវកន្លែងដែលគេនិយាយថាព្រះសម្មាសម្ពុទ្ធបានឈប់សំរាកដើម្បីប៉ះស្បង់ចីពររបស់ព្រះអង្គ ។ នៅឯកំពូលភ្នំ សម្លេងជួងបន្លឺឥតឈប់ឈរដោយសារមនុស្សចាស់ និងកុមារតូចៗផងដែរ ដើម្បីបញ្ជាក់ថាការធ្វើធម្មយាត្រាបានចប់បរិបូរណ៍ហើយ ។ ការធ្វើដំណើរបែបនេះអាចថាមិនទាន់គ្រប់គ្រាន់ទេ ព្រោះថាការធ្វើធម្មយាត្រាចប់បរិបូរណ៍ លុះត្រាតែយើងត្រឡប់មកដល់ផ្ទះវិញ ។ នៅតាមផ្លូវ ការសួរចង់ដឹងថាកំពូលភ្នំនៅឆ្ងាយប៉ុន្មានទៀតទើបដល់ជាប្រការមិនល្អទេ ផ្ទុយទៅវិញគេតប្បីផ្លាស់ប្តូរទៅវិញទៅមកនូវការគោរពគ្នាដោយករុណាធម៌ គឺ "សន្តិភាព" ។

និវាគុហា ស្រីលង្កា

នៅក្នុងឆ្នាំទីប្រាំបី បន្ទាប់ពីព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ និងក្នុងឱកាសដែលព្រះអង្គទ្រង់គង់នៅក្នុងវត្តជេតពន ព្រះអង្គទ្រង់យាងឆ្ពោះទៅតំបន់កល្យាណីដោយមានព្រះភិក្ខុចំនួន៥០០អង្គនិមន្តទៅជាមួយ (នេះជាដំណើរយាងលើកទីបីទៅស្រីលង្កា) ។ កល្យាណីជាលំនៅរបស់ មនិអក្ខិក ដែលជាស្តេចនាគរាជ ។ នៅក្រោមបារាំ ដែលរំលេចដោយត្បូងមានតម្លៃ ដែលគេតម្កើងនៅត្រង់កន្លែងដែលក្រោយមកគេបានសង់ចេតិយកល្យាណី ព្រះអង្គទ្រង់គង់លើរតនបល្ល័ង្កជាមួយព្រះភិក្ខុជាព្រះរាជសាវ័ក ។ ហើយទ្រង់បានធ្វើឱ្យស្តេចនាគរាជសប្បាយរីករាយយ៉ាងខ្លាំង ដោយទ្រង់ទទួលភត្តាហារទិព្វ ទាំងរឹង ទាំងទន់ ដែលស្តេចនាគរាជបានរៀបចំថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ និងព្រះសាវ័កទាំងអស់អង្គ ។ នៅពេលព្រះសម្មាសម្ពុទ្ធប្រទានធម្មទេសនានៅទីនោះរួចហើយ ព្រះអង្គទ្រង់ក្រោកឈរឡើង និងបន្សល់ទុកនៅស្នាមជំហានរបស់ព្រះអង្គនៅកណ្តាលវាលត្រង់សុមនកូត ។ ហើយបន្ទាប់ពីព្រះអង្គទ្រង់គង់អស់ជាច្រើនថ្ងៃតាមព្រះរាជហឫទ័យនៅជើងភ្នំទិវាគុហា* ជាមួយព្រះរាជសាវ័កមក ព្រះអង្គទ្រង់យាងបន្តទៅកាន់ ទីឃវាបិ ទៀត ។

---

* (បច្ចុប្បន្ននេះ គេពុំដឹងថា ទិវាគុហា ស្ថិតនៅត្រង់ទីណាទេ)

មុតិយង្គណៈ ស្រីលង្កា

ព្រះវិហារមុតិយង្គណៈ ត្រូវបានគេចាត់ទុកថាជាពុទ្ធស្ថាន ជាទីសក្ការៈទី១៦ នៅស្រីលង្កា ។ ប្រវត្តិដើមក៏ដូចជាស្លាកស្នាមនៃសំណង់បុរាណ បានបាត់បង់អស់ទៅហើយ ប៉ុន្តែតាមប្រពៃណីបានសន្មត់ថាជាស្នាព្រះហស្តរបស់ព្រះរាជា ទេវានម្បិយតិស្សៈ នៅសតវត្សទី៣មុនគ្រិស្តសករាជ ។



តិស្សមហាវិហារ ស្រីលង្កា

តិស្សមហារាម ដែលស្ថិតនៅលើច្រាំងទន្លេតិស្សវេវៈ គឺជាធានីបុរាណនៃខេត្តរុហុនៈ ដែលអ្នកស្នេហាជាតិស្រីលង្កាបានប្រមូលផ្តុំគ្នាគាំទ្រចំពោះការប្រឆាំងតទល់នឹងពួកឈ្លានពានឥណ្ឌា ធ្វើឱ្យពួកនេះបរាជ័យរាល់លើក ។ ពុំមានការធ្វើកំណាយខាងបុរាណវិទ្យាជាយថាក្រមណាមួយបានធ្វើឡើងនៅលើទីតាំងដែលគេស្គាល់ច្បាស់ និងមិនច្បាស់នៅតំបន់រុហុនៈនៅឡើយទេ ។ មានគម្រោងធ្វើកំណាយដ៏តូចតាចមួយនៅមហាថូបៈ ក្នុងតិស្សមហារាម ។ ប្រាសាទនេះកសាងឡើងចាប់តាំងពីសតវត្សទីពីរមុនគ្រិស្តសករាជឬមុនពេលនេះទៀត ហើយត្រូវបានគេចាត់ទុកថាជាប្រាសាទដ៏ធំជាងគេបំផុតនៅស្រីលង្កានៅសម័យនោះ ។ ព្រះរាជវាំង ឬក៏ប្រហែលជាកុដិរបស់គណៈសង្ឃនៅក្នុងវត្តមួយត្រូវបានគេធ្វើកំណាយនៅជិតឆ្នេរទន្លេតិស្សវេវៈ ។

មហាពោធិ ស្រីលង្កា

មានព្រឹត្តិការណ៍សំខាន់ពីរក្នុងប្រវត្តិសាស្ត្រស្រីលង្កាបុរាណ ដែលគេបានដឹងឮពាសពេញកោះ តាំងពីយូរមកហើយ គឺព្រះពុទ្ធសាសនា និងគំរូនៃការគោរពសក្ការៈជាពិសេសមួយ ។

រឿងទីមួយកើតឡើងក្នុងពេលដែលព្រះមហិន្ទ គង់នៅក្នុងក្រុងអនុរាធបុរៈ ។ ពេលនោះព្រះវរបិតាព្រះអង្គ គឺព្រះបាទអសោកបានកាត់មែកពោធិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់នៅពីក្រោមដើមនោះ ដើម្បីផ្ញើទៅកោះលង្កា ទុកជានិមិត្តរូបនៃព្រះសម្មាសម្ពុទ្ធ ចំពោះពុទ្ធសាសនិកដែលទើបថ្វាយខ្លួនថ្មីៗ ។ ព្រះអង្គបានដាំកូនពោធិនោះនៅក្នុងភាជន៍មាសហើយទ្រង់ប្រគល់ឱ្យព្រះរាជបុត្រីព្រះអង្គ (ព្រះអនុជរបស់ព្រះមហិន្ទ) គឺព្រះភិក្ខុនីសង្ឃមិតាឱ្យនាំយកមែកពោធិនោះតាមសំពៅទៅកាន់កោះលង្កា ។ មែកពោធិនោះត្រូវបានប្រជាជននៅអនុរាធបុរៈ ធ្វើបុណ្យទទួលយ៉ាងមហោឡារិក ។ ព្រះបាទទេវានម្បិយតិស្សៈ ព្រះអង្គឯងបានទ្រង់ទតមើលការដាំដើមពោធិនោះនៅក្នុងសួនរបស់ព្រះអង្គ ដែលរហូតដល់សព្វថ្ងៃដើមពោធិនោះនៅតែជាវត្ថុជាទីគោរពសក្ការៈបំផុតសំរាប់ពុទ្ធសាសនិករាប់លាននាក់ ។ ដោយសារដើមពោធិដែលព្រះពុទ្ធបានត្រាស់នោះបានងាប់បាត់ទៅហើយ ដូច្នេះមែកពោធិដែលគេបានរក្សាទុកជាកេរនេះ ត្រូវបានគេចាត់ទុកថាជាដើមឈើដ៏ពិសិដ្ឋបំផុត ក្នុងចំណោមដើមឈើដ៏ពិសិដ្ឋទាំងឡាយ ។

ព្រះទន្តប្រាសាទ ស្រីលង្កា

ប្រមាណជាប្រាំសតវត្សក្រោយមក គឺនៅដើមសតវត្សទី៤ នៃគ្រិស្តសករាជ រតនវត្ថុដ៏មានតម្លៃមួយទៀត បានមកដល់កោះលង្កា ។ នោះគឺជាព្រះចង្កូមកែវខាងឆ្វេងរបស់ព្រះសម្មាសម្ពុទ្ធ ។ ព្រះចង្កូមកែវ ត្រូវបានគេគោរពបូជារហូតដល់ក្នុងសតវត្សខាងក្រោយៗមក មានកើតសង្គ្រាមក្នុងការដណ្តើមយកព្រះចង្កូមកែវនេះធ្វើជាសម្បត្តិតែរៀងខ្លួន ។ ជាមួយគ្នានឹងបាត្រដ៏ពិសិដ្ឋរបស់ព្រះពុទ្ធ ដែលទទួលបានក្នុងរាជព្រះបាទទេវានម្បិយតិស្សៈ ព្រះទន្តធាតុបានក្លាយទៅជានិមិត្តរូបនៃភាពរឹងមាំ និងឯករាជ្យភាពរបស់ប្រជាជាតិសីហឡៈ ។ ចាប់តាំងពីដើមដំបូងរហូតដល់បច្ចុប្បន្នកាលនេះ ព្រះទន្តត្រូវបានគេតម្កល់ទុកក្នុងប្រអប់ធ្វើពីមាស នៅក្នុងព្រះទន្តប្រាសាទនៃរាជធានី ឈ្មោះប្រាសាទទលទាមាលិគាវៈ សព្វថ្ងៃនេះស្ថិតនៅក្នុងទីក្រុងកាន្ឌី ។ ព្រះធាតុនៃព្រះចង្កូម

កែវនេះត្រូវបានគេយកមកហែប្រទក្សិណទីក្រុងក្នុងរយៈពេលពីរសប្ដាហ៍ នៅរៀងរាល់ខែសីហាក្នុងពិធីបុណ្យ ដង្ហែក្បួន ឈ្មោះអេសាលៈ បេរៈហេរៈ យ៉ាងគគ្រឹកគគ្រេង ។

នៅក្នុងពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វានទៅ ព្រះអដ្ឋិធាតុត្រូវបានគេចែកទៅគ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា នៅអាស៊ីអាគ្នេយ៍ទាំងមូល ។ ព្រះទន្តស្ថិតនៅក្នុងការថែរក្សាទុករបស់ស្ដេចកលិង្គ នៃប្រទេសឥណ្ឌាអស់ជាច្រើនសតវត្ស ។ នៅពេលដែលរាជបល្ល័ង្ករបស់ព្រះអង្គ ត្រូវវង្សអ្នកមិនកាន់ពុទ្ធសាសនាគម្រាមកំហែង ព្រះបាទគុហសីវៈ បានប្រគល់ទន្តធាតុនេះទៅឱ្យបុត្រីរបស់ព្រះអង្គឈ្មោះ ហេមមាលា ដោយទ្រង់ផ្ដែផ្ដាំថា ប្រសិនបើព្រះអង្គទ្រង់បរាជ័យក្នុងសង្គ្រាមសូមឱ្យព្រះនាង និងព្រះស្វាមី ឈ្មោះទន្តកុមារ នាំយកព្រះទន្តនេះទៅតម្កល់ទុកនៅកន្លែងមានសុវត្ថិភាពនៅកោះស្រីលង្កាជាទីដែលព្រះបាទសិរីមេឃវណ្ណៈទ្រង់សោយរាជ្យ ។

ដូច្នេះបានជានៅពេលព្រះបាទគុហសីវៈ ទ្រង់បរាជ័យដូចទ្រង់បានគិតនោះ ព្រះនាងហេមមាលា បានភៀសខ្លួនដោយនាំយកនូវព្រះទន្តធាតុដោយលាក់ក្នុងភ្នួងសក់ នៅពេលដែលព្រះនាង និងស្វាមីទន្តកុមារក្លែងខ្លួនធ្វើជាបួជនិយេសក៍ ។

ព្រះបាទ សិរីមេឃវណ្ណៈ បានទទួលយកព្រះចង្កូមកែវ ដោយសេចក្ដីគោរពយ៉ាងជ្រាលជ្រៅ ហើយបានរក្សាទុកជាមួយវត្ថុដ៏មានតម្លៃទាំងឡាយនៃព្រះរាជវាំងរបស់ព្រះអង្គរហូតដល់ប្រាសាទដ៏សមរម្យថ្មីមួយសម្រាប់តម្កល់ព្រះទន្តធាតុនោះ ត្រូវបានសាងសង់រួច ។



មិរិសវតិមហាចេតិយ ស្រីលង្កា

ព្រះបាទ ទុត្ថគាមិនិ (ឆ្នាំ១៦១-១៣៧ មុនគ្រិស្តសករាជ) ទ្រង់បានធ្វើពិធីបុណ្យ៧ថ្ងៃ បន្ទាប់ពីថ្ងៃជ័យជំនះរបស់ព្រះអង្គ ដោយមានពិធីបុណ្យអុំទូកនៅក្នុងបារាយណ៍ទឹកមួយកន្លែង ឈ្មោះតិស្សៈ ។ នៅជិតនោះទ្រង់បានដោតលំពែងរបស់ព្រះអង្គនៅលើមាត់ច្រាំង (លំពែងរបស់ព្រះរាជា ជាទូទៅមានបញ្ចុះព្រះពុទ្ធអដ្ឋិធាតុ គឺជាទង់តំណាងព្រះរាជាក្នុងចំបាំង) ហើយទ្រង់ដោះសម្លៀកបំពាក់នៅទីនោះ ។ នៅទីនោះព្រះអង្គបានស្ថាបនាព្រះមហាចេតិយទីមួយរបស់ព្រះអង្គ ដោយតម្កល់ព្រះលំពែងដែលមានបញ្ចុះព្រះពុទ្ធអដ្ឋិធាតុ ដោយព្រះអង្គបានពន្យល់ថា ដើម្បីលាងបាបកម្មដែលកើតពីចិត្តអសទ្ធា ដោយមានម្ដងនោះទ្រង់បានសោយអាហារដោយមិនបានគិតដល់ព្រះភិក្ខុសង្ឃ ។ ក្បាច់លំអខាងមុខប្រាសាទនោះគួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ ។



សុវណ្ណមាលីមហាចេតិយ ស្រីលង្កា

កំពូលចេតិយ មិហិន្តាលេ កន្ទុះ ដែលគេអាចមើលឃើញយ៉ាងច្បាស់ពីគ្រប់ទិសគឺជាប្រាសាទមហាសេយៈ ដែលកសាងតាំងពីសតវត្សទី១មុនគ្រិស្តសករាជ ។ គេនិយាយថាគេតម្កល់ព្រះកេសាព្រះពុទ្ធមួយសរសៃនៅក្នុងចេតិយនេះ ។ ពីទីនោះទៅគេមើលឃើញទេសភាពយ៉ាងល្អ រហូតដល់មហាចេតិយនៃអនុរាធបុរៈ ។

ថូបារាម ស្រីលង្កា

ចេតិយថូបារាម គឺជាចេតិយដ៏ចាស់ជាងគេនៃប្រទេស និងត្រូវបានគេជឿថាជាចេតិយ ដែលតម្កល់ឆ្អឹងដងកាំបិតរបស់ព្រះម្ចាសម្ពុទ្ធ ដែលព្រះបាទអសោកបានផ្ញើមក បន្ទាប់ពីព្រះមហិន្ទបានណែនាំអ្នកក្រុងអនុរាធបុរៈ ឱ្យកាន់ព្រះពុទ្ធសាសនារួចមក ។ ព្រះទិវានម្បិយតិស្សៈ ទ្រង់បានស្ថាបនាចេតិយនេះ នៅក្នុងសតវត្សទី៣ មុនគ្រិស្តសករាជ ហើយបានហៅចេតិយនេះថា «ថូបារាម ឬអារាមមានស្តូប» ។ ចេតិយនោះមានសណ្ឋានដូចគំនរស្រូវនិងធ្វើពីដីសុទ្ធនៅសតវត្សទី២មុនគ្រិស្តសករាជ ។ ព្រះបាទលញ្ជតិស្សៈ ហ៊ុំព័ទ្ធចេតិយនេះដោយសសរឈើធ្វើជារបៀង ។ នៅក្នុងសតវត្សទី៧ ព្រះបាទអគ្គោទី២

បានពង្រឹងរបៀងនោះ ដោយប្រើសសរថ្ម និងសង់ដំបូលរាងមូលដូចសាជី ។ ឥឡូវនេះសសរថ្មខ្លះនៅឈរនៅឡើយ ។ តួចេតិយមានសណ្ឋានដូចកណ្តឹង ដែលគេឃើញសព្វថ្ងៃនេះ គឺជាលទ្ធផលនៃការជួសជុលកាលពីឆ្នាំ១៨៦២ ។

អភយគិរី ស្រីលង្កា

ក្សត្រដំបូងបង្អស់ដែលសោយរាជ្យនៅក្រុង អនុរាធបុរៈ គឺព្រះបាទវត្តគាមនី អភយ វលគមពាហ៍ (១០៣និង៨៩-៧៧ មុនគ្រិស្តសករាជ) ។ នៅឆ្នាំទីមួយនៃរាជរបស់ព្រះអង្គពួកឈ្លានពានចូឡៈ (ព្រះរាជាណាចក្រចូឡៈ នៅភាគខាងត្បូងឥណ្ឌា) បានលេចមុខមកម្តងទៀត និងជំរុញឱ្យព្រះអង្គលាក់ខ្លួនជាបណ្តោះអាសន្ន ។ អស់រយៈពេល១៤ឆ្នាំ នៅពេលដែលស្តេចទមិឡឡើងសោយរាជ្យជំនួសព្រះអង្គ ព្រះអង្គទ្រង់យាងត្រាកត្រាំគ្មានទីកំណត់ដើម្បីរកកន្លែងពួននៅតាមរូងភ្នំក្នុងព្រៃជ្រៅ ។ មានកំណត់ត្រាថា ក្នុងគ្រាដែលព្រះអង្គភៀសខ្លួនចេញពីនគរនេះ ទ្រង់បានជួបនឹងសំណាក់តាបសពួកជេនបុរាណឈ្មោះ គិរី ដែលបានពោលពាក្យឡកឡឺយចំពោះព្រះអង្គថា «មហាសិង្ហខ្មៅកំពុងរត់ភៀសខ្លួនហើយ»។ ក្នុងពេលនិរទេសរបស់ព្រះអង្គ ការជេរប្រមាថនេះធ្វើឱ្យព្រះអង្គឈឺចាប់យ៉ាងខ្លាំង ។ ចុងបំផុត នៅពេលព្រះអង្គដណ្តើមយកជ័យជំនះលើព្រះរាជាណាចក្រព្រះអង្គវិញ ព្រះអង្គបានកំទេចសំណាក់តាបសគិរីចោល ហើយបានសង់វត្តអភ័យគិរីនៅលើកន្លែងនោះ ។ ឈ្មោះនេះ គឺជាពាក្យថ្លែងបំភ្លៃទៅរកព្រះនាមរបស់ព្រះអង្គផ្ទាល់ និងឈ្មោះតាបសដែលមិនចេះទាក់ទងនឹងមនុស្សឯទៀតផងដែរ (ដែលមានន័យថា ភ្នំដែលគ្មានសេចក្តីភ័យខ្លាច) ដែលជាពាក្យបដិសេធនូវសេចក្តីភ័យខ្លាចរបស់ព្រះអង្គ ។ ចេតិយដែលគេឃើញនៅកន្លែងសព្វថ្ងៃនេះ កសាងឡើងនៅដើមសតវត្សទី២មុនគ្រិស្តសករាជ ដោយព្រះបាទគជពាហុ ។ ដោយមានកម្ពស់ ១១៣ម៉ែត្រ មានវិជ្ឈមាត្រស្មើរតែស្មើនឹងកំពស់គឺ ១១០ម៉ែត្រ ចេតិយនេះជាចេតិយធំជាងគេទី២ នៅលើលោកនេះ បន្ទាប់ពីចេតិយនៅវត្តជេតពនារាម ។ សព្វថ្ងៃនេះកំពូលខាងលើបានបាក់បែកអស់ហើយ ប៉ុន្តែទោះបីជាយ៉ាងណា ក៏ចេតិយនេះមានលក្ខណៈមាំទាំរហូតដល់កំពស់ ៧៦ម៉ែត្រដែរ ។



ជេតពន ស្រីលង្កា

វត្តជេតពនារាម ចាប់ផ្តើមកសាងដោយព្រះបាទមហាសេនៈ នៅចុងសតវត្សទី៣នៃគ្រិស្តសករាជក្នុងរយៈពេលដែលមានជម្លោះរវាងនិកាយផ្សេងៗ ។ នៅក្នុងថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨២ ក្នុងពេលដែលពួកបុរាណវិទូធ្វើកំណាយនៅទីនោះ គេបានរកឃើញបន្ទះមាសមួយសន្លឹកដែលមានចំណាស់រាប់សតវត្សមកហើយ ហើយដែលនៅលើសន្លឹកមាសនោះមានចារអត្ថបទក្នុងគម្ពីរមហាយានជាភាសាសំស្ក្រឹត ។

ចេតិយជេតពនារាម គឺជាប្រាសាទដែលមានសណ្ឋានទាំងដុល រឹងមាំជាងគេបំផុតក្នុងចំណោមចេតិយដូចគ្នានេះ ។ ពីដំបូងប្រាសាទនេះមានកំពស់ជាង១២២ ម៉ែត្រ តែក្រោយពេលធ្វើការជួសជុលជាថ្មី ត្បូងត្រីស្តាលដែលគេដាក់លើកំពូលបានចាំងពន្លឺនៅលើកំពស់ដល់ទៅ១៥២ម៉ែត្រពីដី ។ បាតក្រោមនៃចេតិយនេះ ដែលមានវិជ្ឈមាត្រប្រវែង១១៣ម៉ែត្រ ស្ថិតនៅពីលើគ្រឹះធ្វើអំពីឥដ្ឋកម្រាស់៨ម៉ែត្រ ។ គ្រឹះនេះទៀតស្ថិតនៅលើគ្រឹះដីរឹងមាំជាច្រើនជាន់ទៀត ។ ប្រាសាទទាំងមូលប្រើអស់ផ្ទៃដីចំនួនប្រមាណ ៣២ ៣៧៦ ម៉ែត្រក្រឡា ។ វាមានទំហំធំជាងប្រាសាទនានា ប៉ុន្តែប៉ុនប្រាសាទពីរ៉ាមីតពីរផង ។



គិរិវេហេរៈ ស្រីលង្កា

គិរិវេហេរៈ គឺជាចេតិយដ៏ធំមួយដែលគេនិយាយថា ព្រះសម្មាសម្ពុទ្ធទ្រង់បានគង់ធ្វើវិបស្សនានៅទីនោះ ក្នុងដំណើរលើកទីបី និងជាលើកចុងក្រោយរបស់ព្រះអង្គទៅស្រីលង្កា ។

សេលៈចេតិយ ស្រីលង្កា

ប្រាសាទអម្ពស្ថាលៈ គឺជាចេតិយដ៏ស្រស់ស្អាត តាមរឿងនិទានថាជាកន្លែងដែលព្រះបាទទេវានម្បិយតិស្សៈបានប្រទះឃើញព្រះមហិន្ទ ក្នុងពេលដែលព្រះអង្គតាមរកសត្វប្រើសដែលព្រះអង្គបានបាញ់ត្រូវ ។ ឈ្មោះប្រាសាទរំឭកឡើងវិញនូវពាក្យអម្ព ឬស្វាយគឺដើមឈើដែលព្រះអង្គទាំងពីរទ្រង់បានសន្ទនាគ្នា ។ ប្រាសាទនេះអាចនឹងត្រូវបានកសាងឡើង ក្រោយពេលព្រះបាទទេវានម្បិយតិស្សៈ ចូលទិវង្គតទៅបន្តិច ។ ចេតិយនេះបានប្តូរទៅតាមរចនាបទវតទាគេ នៅក្នុងសតវត្សទី៣នៃគ្រិស្តសករាជ ។ នៅជិតចេតិយនេះមានចេតិយមួយទៀតឈ្មោះអារាធនាគល ឬ «ដុំសិលានៃការកោះប្រជុំ» គឺជាទីដែលព្រះមហិន្ទបានសម្តែងធម្មទេសនាលើកដំបូង ។



ទីឃវាបិចេតិយ ស្រីលង្កា

ទីឃវាបិចេតិយ ជាចេតិយជាទីសក្ការៈមួយក្នុងចំណោមចេតិយដ៏ពិសិដ្ឋទាំង ១៦កន្លែងនៅស្រីលង្កា ។ គម្ពីរមហាវង្សសរសេរថា ព្រះសម្មាសម្ពុទ្ធទ្រង់បានធ្វើវិបស្សនានៅទីនេះ បន្ទាប់ពីបានទុកស្នាមព្រះបាទនៅលើកំពូលភ្នំអាដាំ ។ តាមនិទានពី បុរាណថាចេតិយនេះត្រូវបានកសាងឡើងដោយព្រះបាទសទ្ធាតិស្សៈ ដែលជាព្រះរាជបុត្រពៅរបស់ព្រះបាទកាវន្តិស្សៈ នៃរដ្ឋរុហុនៈនៅក្នុងសតវត្សទី៣ មុនគ្រិស្តសករាជ ដើម្បីបញ្ចុះព្រះនខានៃព្រះហស្តរបស់ព្រះសម្មាសម្ពុទ្ធ ។ ប្រាសាទនេះស្ថិតនៅខាងត្បូងនៃស្ទឹងគាលោយៈ ចម្ងាយប្រហែល១៦គីឡូម៉ែត្របែកពីផ្លូវទៅឧទ្យានជាតិ ។

សារនាថ ឥណ្ឌា

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធបានត្រាស់នៅគយាមក ព្រះអង្គទ្រង់យាងទៅកាន់ក្រុងពារាណសី ដែលពេលនោះជាមជ្ឈមណ្ឌលនៃការសិក្សា ដើម្បីសម្តែងព្រះធម៌ប្រោសបញ្ចវគ្គិយ៍ ដែលពីមុននេះភិក្ខុទាំងអស់នោះធ្លាប់ជាសាវ័ករបស់ព្រះអង្គ ហើយក្រោយមកបានចាកចេញពីព្រះអង្គដោយសេចក្តីអស់សង្ឃឹម ។ ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅកាន់ព្រៃមិគទា នៅឥសិបតន (សារនាថ) ជាទីដែលពួកបញ្ចវគ្គិយ៍អាស្រ័យនៅ ហើយទ្រង់

បានសម្តែងអំពីធម៌មជ្ឈិមប្បដិបទាជាលើកទីមួយ នោះគឺជាការបង្វិលចលនាធម្មចក្ករបស់ព្រះអង្គ ។ ជាអ្នកបួសត្រូវតែលះបង់អំពើហួសហេតុពីរយ៉ាង គឺការត្រេកត្រអាលញៀននឹងកាមសុខនិងការធ្វើទារុណកម្មចំពោះខ្លួនឯង ហើយគប្បីដើរតាមផ្លូវកណ្តាល ។ បន្ទាប់ពីបានស្តាប់ធម្មទេសនាដ៏វែងនោះមក បញ្ចវគ្គីយ៍ទាំងប្រាំអង្គបានបួសជាភិក្ខុ ។ នោះគឺជាការចាប់ផ្តើមបង្កើតគណៈសង្ឃរបស់ព្រះពុទ្ធ ។

សារនាថ បញ្ជាក់នូវកំណើតនៃសាសនារបស់ព្រះសមណគោតម ។ សិលាចារឹកបង្ហាញថាកន្លែងនោះជាធម្មចក្កប្បវត្តនវិហារ ។ ដោយសារឈ្មោះនេះ ទើបកន្លែងដ៏ពិសិដ្ឋត្រូវបានអ្នកនិពន្ធខាងពុទ្ធសាសនាពីបុរាណស្គាល់យ៉ាងច្បាស់ ។ ទោះបីយ៉ាងណាក៏នៅដើមពុទ្ធសតវត្ស គេបានដឹងដ៏តិចតួចណាស់អំពីប្រវត្តិរបស់ព្រៃមិគទានេះ ប៉ុន្តែកន្លែងនោះមានឈ្មោះល្បីល្បាញដូចជាពុទ្ធដ្ឋានផ្សេងៗទៀត ចាប់តាំងពីសម័យព្រះបាទអសោកមក ។ ក្សត្រដ៏វិសុទ្ធអង្គនេះ បានកសាងប្រាសាទជាច្រើនរាប់ទាំងសសរស្តម្ភដែលមានចារឹកនូវបញ្ញត្តិ ដើម្បីព្រមានចំពោះភិក្ខុ និងភិក្ខុនី កុំឱ្យបង្កជម្លោះនាំបែកបាក់គ្នាជាពួក ជានិកាយនៅក្នុងវត្ត ។ ចេតិយធមេខ ស្ថិតនៅប៉ែកអគ្នេយ៍នៃសារនាថ ។ ពិតមែនតែមានការបែកបាក់ខ្លះ ប៉ុន្តែប្រាសាទនេះនៅមានកំពស់រហូតដល់៤៧ម៉ែត្រគិតពីគ្រឹះក្រោមរបស់វា ។ មែនទែនទៅប្រាសាទនេះមានសភាពមាំទាំណាស់ កសាងឡើងដោយថ្មទាំងដុលៗនៅផ្នែកខាងក្រោម ហើយប៉ែកខាងលើគេប្រើ ឥដ្ឋពីក្នុង និងរៀបថ្មពីក្រៅ ។ កំពូលមានរាងមូល ហើយផ្នែកខាងក្រោមមានរាងប្រាំបីជ្រុង ក្នុងមួយជ្រុងៗមានអង្កែយ៉ាងធំដែលពីមុនគេមានតម្កល់បដិមានៅក្នុងនោះ ។ ផ្នែកខាងក្រោមនេះមានក្បាច់មួយខ្សែយ៉ាងធំព័ទ្ធជុំវិញ ដែលមានចម្លាក់បែបគំនូររេខាគណិតនៅកណ្តាលនិងមានក្បាច់ភ្ញីនៅអមពីខាងលើ និងពីខាងក្រោម ។ ឈ្មោះថ្មីដែលហៅថា «ធមេខ» នេះទំនងជាក្លាយពីពាក្យសំស្ក្រឹត «ធមេក្ស» ដែលមានន័យថា «ការធ្វើធម្មភាវនា» ហើយដោយ សារប្រាសាទនេះស្ថិតនៅក្នុងជួរជាមួយនឹងប្រាសាទធម្មរាជិករបស់ព្រះបាទអសោក ដែលស្ថិតនៅទិសខាងលិចនៃប្រាសាទនេះ ទើបគេសន្និដ្ឋានថាកាលនោះប្រាសាទនេះជាប្រាសាទដ៏សំខាន់មួយ ។ ទម្រង់ដើមនៃប្រាសាទនៅទីនោះអាចសន្មត់បានថាត្រូវបានគេកសាងតាំងពីសម័យកាលនៃព្រះបាទអសោកមកម្ល៉េះ ។

វត្តស្វេឌគុន ប្រទេសភូមា

ព្រះបាទឧក្កបាល នៃដែនសុវណ្ណភូមិរបស់ជនជាតិតាឡាំង បានរស់នៅក្នុងតំបន់មួយជិតភ្នំសិង្គុត្តរ ក្នុងភាគទំនាបនៃប្រទេសភូមា ក្នុងសម័យដែលព្រះសិទ្ធត្ថគោតមនៅជាយុវជនមួយព្រះអង្គក្នុងភាគខាងជើងនៃប្រទេសឥណ្ឌានៅឡើយ ។ កូនភ្នំនោះគឺជាទីសក្ការៈបូជា ពីព្រោះវត្ថុធាតុបីយ៉ាងរបស់ព្រះពុទ្ធបីព្រះអង្គកន្លងទៅមាន ឈើច្រត់ ហោយដងទឹក និងចំណែកមួយនៃស្បង់ចីពរ ត្រូវបានគេតម្កល់ទុកនៅលើកំពូលភ្នំនោះ ។ ម្យ៉ាងទៀត ដោយសារជិតប្រាំពាន់ឆ្នាំបានកន្លងផុតទៅហើយ ចាប់តាំងពីព្រះពុទ្ធចុងក្រោយបានត្រាស់ដឹងលើដែនដីនេះ ហេតុនេះភ្នំនោះនឹងបាត់បង់នូវការគោរពបូជារហូតដល់ព្រះពុទ្ធមួយអង្គទៀតបានត្រាស់ និងធ្វើអំណោយដល់ទីនោះផង ។ ហេតុដូច្នេះព្រះបាទឧក្កបាលបានចំណាយពេលអស់ជាច្រើនម៉ោងនៅលើកំពូលភ្នំនេះ ដើម្បីធ្វើវិបស្សនា និងបន់ស្រន់សុំឱ្យទទួលបានវត្ថុទាំងបីយ៉ាងមកវិញ ។

ក្នុងពេលនោះ នៅប្រទេសឥណ្ឌាឯណោះវិញ ព្រះសមណគោតមទ្រង់បានត្រាស់ដឹងជាព្រះពុទ្ធ នៅក្រោមដើមពោធិព្រឹក្សនៅពោធិគយា ។ រំពេចនោះព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញព្រះអង្គដោយទិព្វញ្ញាណ នៅចំពោះព្រះភក្ត្រព្រះបាទឧក្កបាល និងទ្រង់បានសន្យាថា ព្រះអង្គនឹងប្រទាននូវវត្ថុទាំងប៉ុន្មានដែលស្តេចអង្គនោះប្រាថ្នាចង់បាន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ចំរើនភាវនា នៅក្រោមដើមពោធិព្រឹក្សអស់ចំនួន៤៩ថ្ងៃមុននឹងទទួលតង្វាយទីមួយ ដែលគេថ្វាយព្រះអង្គ នោះគឺនំធ្វើអំពីទឹកឃ្មុំ ដែលតបស្សុ និងភល្លុកៈជាឈ្មួញនៅស្រុកឧក្កល បានថ្វាយព្រះអង្គដើម្បីសម្តែងនូវកតញ្ញូតាធម៌ចំពោះព្រះអង្គ ។ ព្រះសមណគោតម បានបោចព្រះកេសាប្រាំបីសរសៃពីព្រះកេសរបស់ព្រះអង្គ ហើយប្រគល់ទៅឱ្យឈ្មួញទាំងពីរនាក់នោះ ។ ដំណើរត្រឡប់ទៅផ្ទះវិញរបស់ឈ្មួញនោះបានជួបបញ្ហាជាច្រើន ។ ក្នុងការធ្វើដំណើរតាមជើងគោក ស្តេចអជេត្តបានលួចព្រះពុទ្ធកេសាអស់ពីរសរសៃទៅ ។ នៅពេលពួកគាត់ឆ្លងឈូងសមុទ្របង់ហ្គាល ស្តេចនាគនៅបាតសមុទ្របានយកអស់ពីរសរសៃទៀត ។ ប៉ុន្តែ នៅពេលពួកគាត់មកដល់ស្រុកឧក្កល ស្តេចឧក្កបាល ទ្រង់បានឱ្យគេរៀបចំធ្វើពិធីបុណ្យដ៏ធំមួយ ។ ទេវភូមិក៏បានចូលរួម ហើយទាំងអស់គ្នាសម្រេចជ្រើសរើសយកកន្លែងមួយ ដើម្បីស្ថាបនាចេតិយមួយ ដើម្បីតម្កល់ព្រះធាតុ ទាំងអស់របស់ព្រះពុទ្ធ ។

នៅពេលដែលព្រះបាទឧក្កបាល ទ្រង់បើកប្រអប់ដាក់ព្រះកេសាព្រះពុទ្ធ ព្រះអង្គទ្រង់ទតឃើញហេតុដ៏អស្ចារ្យមួយ គឺព្រះកេសាទាំងប្រាំបីសរសៃនោះស្រាប់តែមកនៅក្នុងប្រអប់នោះ ទោះបីព្រះកេសាចំនួនពាក់កណ្តាលត្រូវបានគេលួចបាត់ក៏ដោយ ។ នៅពេលព្រះអង្គបើកប្រអប់យ៉ាងនោះ ស្រាប់តែមានពន្លឺចាំងរន្ទាលអណ្តែតឡើងកំពស់ចុងត្នោត ហើយជះរស្មីទៅគ្រប់ទិសទី ។ រំពេចនោះពួកអ្នកមានភ្នែកខ្វាក់ ក្លាយទៅជាភ្លឺ អ្នកមានត្រចៀកថ្លង់ ក្លាយជាស្តាប់ឮ មនុស្សគត្រឡប់ជាចេះនិយាយ ហើយមនុស្សពិការត្រឡប់ជាដើរបាន ។ ព្រះធរណីញ័រកក្រើកឡើង ផ្គរបន្ទោរចាំងចិញ្ចាញ ដើមឈើផងទាំងឡាយចេញផ្កា និងមានផ្លែពេញដើម ហើយភ្លៀងនៃត្បូងរតនៈក៏ធ្លាក់ចុះមកក្រាលលើដែនដី ។

ចេតិយមាសមួយដែលមានកំពស់២០ម៉ែត្រ ត្រូវបានគេកសាងឡើងនៅពីលើស្តូប ដែលមានតម្កល់ព្រះកេសានោះ ។ មានប្រាសាទតូចៗធ្វើអំពីប្រាក់ សំណប៉ាហាំង ស្ពាន់ សំណ ថ្មកែវ ដែក និងឥដ្ឋ ត្រូវបានគេសង់ជាន់ពីលើគ្នាមួយហើយមួយទៀតនៅខាងក្នុងចេតិយនោះ ដើម្បីតម្កល់ព្រះសារីរិកធាតុនោះ ។

ប្រាសាទបុរូបួឌួ ប្រទេសឥណ្ឌូណេស៊ី

នៅចន្លោះភ្នំ និងវាលរាបនៃកោះជ្វារបស់ប្រទេសឥណ្ឌូណេស៊ីភាគកណ្តាលមានប្រាសាទពុទ្ធសាសនាដ៏បុរាណមួយឈ្មោះ បុរូបួឌួ ដែលជាប្រាសាទពុទ្ធសាសនាដ៏ធំបង្អស់មួយ ដែលស្ថិតស្ទើរដល់សព្វថ្ងៃ ។ សឹងថាអាចធំជាងប្រាសាទអង្គរវត្តនៅប្រទេសកម្ពុជា បុរូបួឌួ ប្រហែលជាប្រាសាទរបស់ប្រទេសឥណ្ឌូណេស៊ី ដែលល្បីជាងគេ និងជាប្រាសាទដែលសង់ពីថ្មធំជាងគេ នៅអឌ្ឍគោលប៉ែកខាំងត្បូង ។

អំពីប្រវត្តិរបស់ប្រាសាទ

គេមិនបានដឹងអំពីប្រវត្តិដើមរបស់ប្រាសាទនេះទេ ប៉ុន្តែ គេគិតថាឈ្មោះ បុរូបួឌួ នេះមកពីពាក្យសំស្ក្រឹត «វិហារពុទ្ធឧហ្រ» ដែលមានន័យថា «វត្តព្រះពុទ្ធសាសនា

នៅលើភ្នំ» ។ ស្ថិតនៅក្នុងវាលរាបភាគខាងត្បូងនៃកោះជ្វាផ្នែកកណ្តាល ប្រាសាទនេះជាប្រាសាទមួយក្នុងចំណោមប្រាសាទពុទ្ធសាសនា ដែលគេកសាងឡើងនៅចន្លោះសតវត្សទី៨ និងទី១០ នៃគ្រិស្តសករាជ ក្នុងសម័យដែលមានសន្តតិវង្សធំៗពីរគ្រប់គ្រងកោះជ្វា គឺវង្សពុទ្ធសាសនិកសៃលេន្ទ្រ និងវង្សឥណ្ឌូជញ៉ូយ ។ បន្ទាប់ពីការរលំរលាយខាងគំនិតច្នៃប្រឌិត និងសកម្មភាពដែលធ្លាប់មានជាងពីរសតវត្សមក តំបន់វាលរាបនោះត្រូវបានគេបោះបង់ចោល ។ រាជធានីរបស់ស្តេចហិណ្ឌូ- ពុទ្ធសាសនិក ត្រូវបានប្តូរទៅទិសខាងកើតកោះជ្វាវិញ ដែលនៅទីនោះមានការបញ្ចូលជាមួយគ្នានូវធាតុខ្លះនៃជំនឿអធិធម្មជាតិរបស់ប្រជាជាតិឥណ្ឌូណេស៊ីដើម ដើម្បីពង្រីកនិកាយសាសនាចំរុះមួយ ដោយរួមមានទាំងប្រាសាទផ្សេងៗនៅទីនោះ ។

ប្រាសាទប៊ួរបួឌួ ត្រូវបានគេបោះបង់ចោលរាប់រយឆ្នាំ ។ ដោយពុំមានទឹកនាដល់ និងបំភ្លេចចោល ដូច្នេះប្រាសាទនេះត្រូវកប់បាត់នៅក្នុងគំនរកម្ទេចថ្ម និងផេះភ្នំភ្លើង ។ ប្រជាជននៅទីនោះមានអប្បិយជំនឿហើយនិយាយរឿងផ្តេសផ្តាស់អំពីខ្មោចលងដែលស្ថិតនៅក្នុងរូបមនុស្សជិះសេះដ៏ចម្លែកនៅលើភ្នំនោះ ។ ប្រាសាទនេះ ត្រូវបានរកឃើញដោយលោក ស្តាមហ្វ៊ត រ៉ាហ្វ៊ល ។ នៅក្នុងសម័យចុងក្រោយនៃរជ្ជកាលរបស់ណាប៉ូឡេអុង កោះជ្វាត្រូវបានកាន់កាប់ដោយពួកអង់គ្លេសហើយលោក រ៉ាហ្វ៊ីលជាអនុសេនីយទោនៃអគ្គទេសាភិបាល ។ លោកបានចាប់អារម្មណ៍ចំពោះប្រវត្តិនៃកោះជ្វាហើយបានចំណាយពេលជាច្រើនក្នុងការធ្វើដំណើរទស្សនាកោះនេះ ដើម្បីប្រមូលយកនូវពត៌មានអំពីវប្បធម៌ និងប្រវត្តសាស្ត្ររបស់កោះ ។ នៅឆ្នាំ១៨១៤ គេបាននិយាយប្រាប់គាត់អំពីកន្លែងអស្ចារ្យនៅតំបន់កណ្តាលនៃកោះជ្វានេះ ។ ដោយសារលោកមានភារកិច្ចរវល់នឹងកិច្ចការច្រើន លោកបានបញ្ជូនបេសកជនម្នាក់ជាជនជាតិហុលឡង់ឈ្មោះគ័រណេលីយ៉ីស ដែលជាអ្នករកឃើញនូវប្រាសាទដ៏សំខាន់ជាងគេបំផុតនៅលើសកលលោកនេះ ។

លោកគ័រណេលីយ៉ីស បានធ្វើការពិនិត្យស្រាវជ្រាវមួយ ។ គាត់បានប្រមូលអ្នកស្រុកចំនួន២០០នាក់ ដើម្បីត្រួសត្រាយគំនរថ្ម និងកាប់ព្រៃឈើដែលដុះគ្របលើប្រាសាទ ។ ដោយគេចាប់ផ្តើមសំអាតទីកន្លែងនោះ គេបានឃើញច្បាស់ថាមានវត្ថុដែលមានសារសំខាន់សម្បើមណាស់នៅទីនោះ ។ នៅពេលដែលផ្នែកនៃទីលានប្រកបដោយចម្លាក់បានលេចរូបរាងឡើង គេអាចមើលឃើញថានៅទីនោះមានសំណង់សិល្បៈដ៏ប្រណីតមួយ ។ នោះគឺជាស្នាដៃនៃសិល្បករប្រកបដោយទេពកោសល្យ ដែលបានបំពេញការងារដោយសេចក្តីស្រឡាញ់ក្នុងការឆ្លាក់ក្បាច់យ៉ាងល្អិត នៅលើថ្មពណ៌ប្រផេះ ។ គេត្រូវចំណាយពេលអស់ច្រើនឆ្នាំសម្រាប់សិល្បករ និងពលករទាំងនោះ ក្នុងការផ្គុំថ្មឱ្យកើតជាតង្វាយដ៏កំពូលនេះ ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធ ដែលបានកសាងឡើងដោយផ្ចិតផ្ចង់ និងឆ្លាក់លើដុំថ្មដល់ទៅជាងមួយលានពីរសែនដុំឯណោះ ។

សេចក្តីពណ៌នា

ប្រាសាទប៊ួរបួឌួ ត្រូវបានកសាងឡើងទុកដូចជាពុទ្ធមណ្ឌលមួយដែលជារូបសណ្ឋានមួយដើម្បីជួយដល់ការធ្វើសមាធិ និងដែលមានរាងជាពីរ៉ាមីតយ៉ាងធំសម្បើមសង់ដោយមានសមប្បមាណ និងជានិមិត្តរូបនៃជំហានទាំង១០នៃលោកធាតុ តាមទស្សនវិស័យនៃលទ្ធិសាសនាមហាយាន ។ ព័ទ្ធជុំវិញដោយដីទួលតូចមួយ ប្រាសាទនេះស្ថិតនៅលើផ្ទៃបាតទំហំ ១២៣ម៉ែត្រការ៉េ ។ មានលានរោងទងធ្វើអំពីថ្មប្រកបដោយចម្លាក់ចំនួនបីថ្នាក់ព័ទ្ធជុំវិញប្រាសាទនោះ ។ មានជណ្តើរបួនប្រកបដោយចម្លាក់ក្បូរក្បាច់ឡើងឆ្ពោះទៅរកទីលានទាំងនោះ និងទៅរកចេតិយនៅខាងលើនៃប្រាសាទ ។ គេនិយាយថា មានម្តងនោះថ្មពណ៌ប្រផេះនេះត្រូវបានគេលាបទឹកមាស ឬទឹកប្រាក់ ដែលធ្វើឱ្យប្រាសាទទាំងមូលមានពន្លឺភ្លឺរន្ទាលដូចត្បូងរតនៈយ៉ាងធំលើផែនដី នៅពេលវាទទួលពន្លឺព្រះអាទិត្យ ។ នៅថ្នាក់ក្រោមបំផុត អ្នកផងទូទៅគេស្គាល់ថាជាកាមធាតុដោយសារមាន រឿងស្តីអំពីការត្រេកត្រអាលក្នុងធម៌លោកិយនិងតណ្ហា ដែលពណ៌នាប្រកបដោយ ប្រាកដនិយមនៅលើចម្លាក់រាបតាមជញ្ជាំង ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ផ្ទាំងរូបត្រូវបានគេបិទបាំងដោយជញ្ជាំងដែលគេតម្លើងថ្មី ទុកតែកន្លែងខ្លះសម្រាប់តែបង្ហាញទេសចរណ៍តែប៉ុណ្ណោះ ។ ថ្នាក់បន្តបន្ទាប់បួនជាន់ទៀតនិយាយអំពីរូបធាតុ ។ ផ្នែកនោះពណ៌នាអំពីពិភពលោកដែលមនុស្សទោះបីខំប្រយុទ្ធនឹងចំណង់តណ្ហារបស់ខ្លួន ក៏នៅតែជាប់ជំពាក់នឹងពិភពសម្ភារៈដែរ ។ វត្ថុខ្លះនៃពុទ្ធប្បវត្តិក៏ត្រូវបានរំលេចដោយមានលាយឡំទៅនឹងការរស់នៅរបស់អ្នកកោះជ្វាក្នុងសតវត្សទី៨នៃគ្រិស្តសករាជ ដែលអាចឆ្លុះបញ្ចាំងឱ្យឃើញនូវជីវភាពរស់នៅរបស់មនុស្សជំនាន់នោះ ។ ទីលានព័ទ្ធជុំវិញកំពូលខាងលើបីថ្នាក់ទៀត ពណ៌នាអំពីអរូបធាតុ ឬនិព្វាន ដែលជាគីរីតខ្ពស់បំផុតដែលមនុស្សអាចទៅដល់ ។ នៅលើលានទាំងនោះពុំមានការតុបតែងលំអទេ ហើយអ្វីដែលមាននោះ គឺគេអាចគយគន់មើលទៅសកលលោកទាំងមូល ។ មានចេតិយចំនួន៧២ ដែលក្នុងចេតិយនីមួយៗមានតម្កល់ព្រះពុទ្ធរូបមួយអង្គ ។ គេនិយាយថា ការពាល់ព្រះបាទ ឬព្រះហស្តនៃពុទ្ធរូបនោះនឹងនាំមកនូវលាភសក្ការៈ ។ លាននោះបន្ទុបដោយចេតិយយ៉ាងធំមួយនៅចំកណ្តាល ដែលតំណាងឱ្យព្រះនិព្វានជានិមិត្តរូបនៃសុញ្ញភាព ។

ខុសប្លែកពីប្រាសាទនានា ប្រាសាទប៊ួរបួឌួ ពុំមានបន្ទប់សម្រាប់ធ្វើការគោរពបូជាទេ ប៉ុន្តែគេប្រើធម្មជាតិនៅជុំវិញ ។ ពេលដែលគេបានទៅដល់ថ្នាក់ខ្ពស់បំផុតគេឃើញមេឃ ឃើញទេសភាពកំពូលភ្នំនៅឯនាយ និងទេសភាពស្រុកស្រែ ដែលទុកដូចជាជំបូលនៃប្រាសាទ ។

ជញ្ជាំងខាងក្រៅនៃរោងទង មានរចនាជាអង្កែចំនួន ៤៣២ ដែលក្នុងអង្កែនីមួយៗ មានពុទ្ធរូបមួយអង្គប៉ុនរូបមនុស្សមែនទែន ។ ចំណែកនៅលើលានខាងលើ មានចេតិយចំនួន ៧២ ដែលក្នុងនោះក៏មានតម្កល់ព្រះពុទ្ធរូបដែរ ។ បូករួមទាំងអស់មានព្រះពុទ្ធរូបចំនួន ៥០៤ អង្គ ។ នៅតាមបណ្តោយលានមានក្បាច់រាប និងចម្លាក់ថ្មពណ៌នាអំពីពិភពលោកធាតុមានប្រវែងជិតបីគីឡូម៉ែត្រ ។ ប្រសិនបើគេដើរប្រទក្សិណជុំវិញលានយើងនឹងបានឃើញថា ក្បាច់ចម្លាក់នៅលើថ្មនៅតែច្បាស់ល្អ និងប្រកបដោយទេពកោសល្យយ៉ាងផ្ចិតផ្ចង់ ទោះបីពេលវេលាបានកន្លងទៅរាប់ពាន់ឆ្នាំហើយក៏ដោយ ។

ប្រាសាទប៊ួរបួឌួ ត្រូវបានគេកសាងមុនប្រាសាទអង្គរវត្តបីសតវត្ស និងពីរសតវត្សមុនប្រាសាទណោត្រដាម ។ គេគិតថាប្រាសាទប៊ួរបួឌួ មានតួនាទីដូចជាប្រាសាទចន្ទី គឺជាកន្លែងធ្វើពិធីបុណ្យខាងពុទ្ធសាសនាដែលមានមហាថេរទាំងឡាយទៅចូលរួម ។ វាអាចជាមជ្ឈមណ្ឌលនៃសរណដ្ឋាន ដោយមានប្រាសាទតូចៗពង្រាយនៅជុំវិញ ក្នុងចំណោមនោះមាន ប្រាសាទតូចៗពីរនៅសេសសល់ដល់សព្វថ្ងៃ គឺប្រាសាទចន្ទី មេនឌុត

និងប្រាសាទប៉ាវុន ដែលស្ថិតនៅចម្ងាយប្រហែលមួយគីឡូម៉ែត្រពីប្រាសាទធំ ។ ប្រាសាទទាំងពីរនេះតូចជាង ប៉ុន្តែវាជាចំណែកមួយនៃក្រុមប្រាសាទនោះ ដែលទំនងជាមានទាំងវត្តមួយផង ។ ប្រាសាទ ចន្ទីមេនឌុត ជាប្រាសាទចាស់ជាងគេបំផុតក្នុងចំណោមប្រាសាទបីដែលមានតម្កល់ព្រះពុទ្ធរូបកំពស់បីម៉ែត្រ ដែលគេឆ្លាក់លើថ្មដុលតែមួយដុំ ។ គេគិតថាប្រាសាទប៉ាវុន ជាប្រាសាទដើម្បីធ្វើចិត្តឱ្យបរិសុទ្ធ មុននឹងដើរចូលទៅក្នុងប្រាសាទបុរូបួឌួ ។ ប្រាសាទទាំងបីសង់លើបន្ទាត់មួយត្រង់ជួរគ្នា ដែលបង្កើតបានជាផ្លូវមួយសម្រាប់បូជនិយេសក៍ ។

ពិធីបុណ្យផ្សេងៗ

ប្រាសាទទាំងនេះស្ថិតនៅជាកន្លែងធ្វើពិធីបុណ្យធម្មយាត្រាប្រចាំឆ្នាំ ។ ក្នុងមួយឆ្នាំម្តង នៅខែឧសភា មុនថ្ងៃពេញបូរមី គេបានធ្វើពិធីបុណ្យមួយឈ្មោះ បុណ្យពិសាខបូជា ដើម្បីរំឭកដល់ពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត្រ ទ្រង់បានត្រាស់ និងទ្រង់បរិនិព្វាន ។ មុនពេលព្រះចន្ទរះ ព្រះភិក្ខុសង្ឃទាំងឡាយ បាននិមន្តមកជួបជុំគ្នានៅប្រាសាទចន្ទីមេនឌុត ដើម្បីធ្វើពិធីបន្សុទ្ធកាយចិត្តដោយលាងទឹកមន្ត រួចបាននិមន្តជាក្បួនយឺតៗឆ្ពោះទៅកាន់ប្រាសាទប៉ាវុនហើយទីបញ្ចប់ទៅដល់ប្រាសាទបុរូបួឌួ ។ នៅពេលក្បួនដង្ហែបានទៅដល់ថ្នាក់កំពូល និងបាននិមន្តប្រទក្សិណគាត់តាមរោងទងនានា ហើយគេបានអុជទៀននិងបាចផ្កាក្នុងពេលព្រះសង្ឃនាំគ្នាសូត្រធ្យាយព្រះធម៌និងធ្វើការបួងសួង។

ការជួសជុល

នៅដើមសតវត្សទី២០ ពួកហុលឡង់បានចាប់ផ្តើមធ្វើគម្រោងជួសជុលហើយបានរកឃើញជំនួសដុំថ្មមាំៗនោះ នូវប្រាសាទដែលធ្វើអំពីដុំសិលាតម្រួតគ្នាដោយឥតមានប្រើបាយអព៌ទ្ធជុំវិញដីទួលមួយដុំ ។ មួយឆ្នាំពេញមួយឆ្នាំ កូនភ្នំនោះស្ថិតនៅក្រោមដំណក់ទឹកភ្លៀងយ៉ាងជោគជាំ ហើយតួប្រាសាទទាំងមូលចាប់ផ្តើមរលំមួយចំណែកនៅជ្រុងទោលដោយសារដីស្រុត ។ ប្រាសាទបុរូបួឌួស្ថិតក្នុងគ្រោះថ្នាក់នៃការដួលរលំទៅហើយ ។ ទើបតែថ្មីៗនេះទេ ដែលការជួសជុលទាំងស្រុងជាលើកទី២នៃប្រាសាទនេះត្រូវបានបញ្ចប់ ។ តម្លៃខាងវប្បធម៌ ដែលមិនអាចកាត់ថ្លៃបាននៃប្រាសាទបុរូបួឌួ ត្រូវបានគេទទួលស្គាល់ហើយការជួសជុលជាថ្មីបានចាប់ផ្តើមពីឆ្នាំ១៩៧៣ ។ រដ្ឋាភិបាលឥណ្ឌូណេស៊ីអង្គការយូណេស្កូ ព្រមទាំងវិភាគទានពីគ្រប់ប្រទេសទូទាំងសកលលោក បានចូលរួមផ្គត់ផ្គង់ថវិកាដល់គម្រោង ដែលមានទឹកប្រាក់រហូតដល់ម្ភៃមួយលានដុល្លាអាមេរិក ។ គម្រោងផែនការជួសជុលដ៏ធំនេះប្រើពេលវេលាអស់១០ឆ្នាំ ។ ការជួសជុលដែលបានបញ្ចប់នៅដើមឆ្នាំ១៩៨៣ និងធ្វើពិធីសម្ពោធក្រោមអធិតីភាពរបស់លោកប្រធានាធិបតីស៊ូហាតូ អាចធានាថាប្រាសាទបុរូបួឌួ អាចមានអាយុរាប់ពាន់ឆ្នាំទៀត ។ ដើម្បីយល់ឱ្យបានច្បាស់អំពីព្រលឹងនៃប្រាសាទបុរូបួឌួ ប្រហែលជាត្រូវជ្រើសរើសពេលវេលាទៅទស្សនាប្រាសាទនេះនៅពេលព្រឹកព្រលឹមមុនពេលពួកទេសចរណ៍ចូលទៅដល់ ។ ដោយសារនៅពេលថ្ងៃរះ អាកាសដែលនៅមានអ័ព្ទ និងមានសភាពស្ងប់ស្ងាត់នៅឡើយ នោះគេអាចនឹងទទួលអារម្មណ៍សន្តិភាព និងបរិសុទ្ធ ដែលមាននៅក្នុងពេលដែលភាពច្របូកច្របល់មានតិចតួចបំផុត ។

ពិធីសម្ពោធពុទ្ធមណ្ឌលស្រីលង្កា - ជប៉ុន

នៅក្នុងឆ្នាំ១៩៨៤

Japan Sri Lanka Buddhist Centre

OPENING CEREMONY IN 1984

FOUNDER MEMBERS
OF JAPAN SRI LANKA BUDDHIST CENTRE, JAPAN

Seated front row from left :

Ven. Banagala Upatissa Thero, Chief Abbot (Secretary)
Ven. Weragoda Sarada Maha Thero (General Secretary)
Ven. Mapalagama Vipulasara Maha Thero (President)
Ven. H. Pannatissa Nayaka Thero
H.E. Ex-President of Sri Lanka, J.R. Jayawardene

Seated 2nd row 6th from right :

Mr. Sri Lal Sathischandra (Committee)
Mr. K.A. Samantilak (Hon. Treasurer)

Seated back row 4th from right :

Mr. Ajanta Dinamitra (Committee)

Seated 2nd row 5th from right :

Mrs. Takiko Yoshida (Patron)

In conjunction of the *10th Anniversary of the JAPAN SRI LANKA BUDDHIST CENTRE, and my 55th Birthday* I would like to present 200 copies of *LIFE OF THE BUDDHA (in pictures)* to all members participating in this ceremony.

VENERABLE W. SARADA MAHA THERO
Chief Monk, The Singapore Buddhist Meditation Centre, Singapore

THESE PUBLICATIONS ARE FREELY AVAILABLE.
PLEASE WRITE TO:

VEN. SARADA
THE SINGAPORE BUDDHIST MEDITATION CENTRE
342-D Pasir Panjang Road, Singapore 0511
Tel: 7783330 Fax: 7730150

SPONSORS TO DEFRAY THE PRINTING COST ARE WELCOME.

NAME AND AUTHOR	DONATED BY
TREASURY OF TRUTH By Ven. Sarada Thero	The Corporate Body of the Buddha Educational Foundation
THE PATH OF PURIFICATION By Bhadantacariya Buddhaghosa	SBMC - Devotee
THE GLOBAL PHILOSOPHY by. W.V. Zinn	Mr. W. V. Zinn
BUDDHISM FOR BEGINNERS compiled by Ven. Sarada Thero	Mr Lee Beng Huat & Mr Miss Chan Gim Ai
PHENOMENA AND NOUMENA by W.V. Zinn	Mr Tay Boon Soo & Mr Tay Yong Hong
REFLECTION ON DEATH compiled by Ven. Sarada Thero	Mr Robert Ang Chee Soong
BUDDHISM EXPLAINED by Bikkhu Kantipala	Mrs Piyasena
THE BUDDHIST WAY OF MEDITATION compiled by Ven. Sarada Thero	Datin Lau Khoo Gueh Noi
AN INTRODUCTION OF THE TEACHING OF THE BUDDHA GOTAMA (A BUDDHIST CATECHISM) by Subhadra Bhikshu	In memory of the late G. A. Podisingho by his children
WHAT THE BUDDHA TAUGHT (CHINESE) by Walpola Rahula	Capt. Swee Lim Guan & Mdm. Chan Fong Lim
MEDITATION ON LOVING-KINDNESS (KARANIYA METTA SUTTA) by Ven. Sarada Thero	Mr Alahendra
A YOUNG PEOPLE'S LIFE OF THE BUDDHA by Bhikkhu Silacara	Mrs. Niciju Okada
WHY WORRY by Ven. Dr. K. Sri Dhammananda	Mr & Mrs. A. P. Palliyaguru
THE BUDDHA'S TEACHING ITS ESSENTIAL MEANING by R.G. de S Wettimuny	Singapore Buddhist Meditation Centre
THE WAY OF MINDFULNESS THE SATIPATTHANA SUTTA & COMMENTARY by Soma Thera	Mr Kua Chong Siang of Brunei
THE THIRTY-ONE STATES OF BEING & BECOMING by Egerton C. Baptist	Singapore Buddhist Meditation Centre
THE BUDDHA'S TEACHING & THE AMBIGUITY OF EXISTENCE by S. Wettimuny	Mdm Wee Teek Kim & family Singapore
HALO'D TRIUMPHS JAYA MANGALA GATHA by Acharya Buddharakkhita	Mr Chan Chee Seng
THE LIFE OF BUDDHA FOR YOUNG PEOPLE by Ven. Balangoda Ananda Maitreya Maha Nayaka Thera	Mrs Takiko Yoshida in memory of her late husband Mr Kishi Yoshida
LIFE OF THE BUDDHA IN PICTURES by Ven. Balangoda Ananda Maitreya Maha Nayaka Thera	Miss Adeline Ang Miss Indra Ang Miss Eileen Ang
THE WAY TO PEACE & HAPPINESS compiled by Yogavacara Rahula	Mr Than Myint & Mdm Daw Than Yiin Memory of the late Mr Sein Yin & Mdm Daw Lai Shwe
THE BUDDHA WORD by Weragoda Sarada Kondanna Edwin Ariyadasa	Singapore Buddhist Meditation Centre
MEDITATION IN THERAVADA & ZEN by Bhikkhu Ananda	Mr Peter Lai
THE KALAMA SUTTA	Mr Kio Guan Heng & Family
BUDDHIST RULES FOR THE LAITY by D.J. Subasingha	Mdm Ho Yuk Ying
THE FIVE PRECEPTS by Dr. Paul Dahlke	Mr Freddie Leong
THOUGHTS FOR THE DAY by Egerton C. Baptist	Mis Chew Beng Suan

THE SEVEN STAGES OF PURIFICATION & THE INSIGHT KNOWLEDGE by Ven. Matara Sri Nanarama Mahathera	Mr & Mrs Lim Ah Swan & children Miss Goh Hwee Kiat Miss Rhoda Ow Yeong
THE MIRROR OF THE DHAMMA by Venerables Narada Maha Thera and Kassapa Thera	In memory of the late Mrs Margaret Ranaweere by her daughters Rose & Lily & their children
A MANUAL OF BUDDHISM by Narada Thera	Mrs Lim Ah Swan & children
BUDDHISM FOR BEGINNERS by Ven. Narada	Mrs Lim Ah Swan & children
WHY WORRY (REPRINT) by Ven. Dr. K. Sri Dhammananda	Mdm Lim Guat Eng Miss Khoo Hui Joo Miss L. Khoo
VANDANA BUDDHIST DEVOTIONS compiled by Ven. Ratana Siri	Ven. K. Wimalajothi in memory of the late Mr Loke Wan Yat
MEDITATION ON BREATHING by Ven. Balangoda Ananda Maitreya Maha Nayaka Thera	In memory of the late Mdm Koh Saw Tin & Mdm Yeoh Siew Eng
DO YOU BELIEVE IN REBIRTH? by Ven. Dr. K. Sri Dhammananda	Mdm Pek Boh Lan
SUPREME SCIENCE OF THE BUDDHA by Egerton C. Baptist	In memory of the late Mdm Lim Ah Sah & Mr Koh Keng Chia by their children & grandchildren
BUDDHISM FOR EVERY MAN by W.G. Weeraratne	Mr. & Mrs Lim Ah Swan & children
THE WORD OF THE BUDDHA by Ven Nyanatiloka	Mr & Mrs Seng Joo How
SIGALOVADA SUTTA by Pandit. P. Pemaratana Nayaka Thero	Mr & Mrs Lim Ah Swan & children
THE BUDDHA AND HIS TEACHING by Ven. Narada Maha Thera	Mr & Mrs Lim Ah Swan & children
A MANUAL OF ABHIDHAMMA by Ven. Narada Maha Thera	Mr & Mrs Lim Ah Swan & children
WHY WORRY (REPRINT) by Ven. Dr. K. Sri Dhammananda	Mdm Wong Seng Yee
THE RELIGIOUS SIGNIFICANCE OF THE FULL MOONS by Alec Robertson	Mr & Mrs Lim Ah Swan & children
ANAPANA SATHI BHAVANA by Ven. Nauyane Ariyadhamma	Mrs K.R. William & children
MEDITATION ON LOVING KINDNESS by Ven. W. Sarada	In memory of the Late Mdm Ng Tah Ing by her beloved children
PORTRAIN OF THE BUDDHA by Jayasena Jayakody	Mr Vincent Warnakulasuriya and Mrs P.L.P Warnakulasuriya
WHY WORRY (REPRINT) by K. Sri Dhammananda	Mdm. Lim Guat Eng
MANUAL OF BUDDHISM	In memory of the Late
A HAPPY MARRIED LIFE by Dr. K. Sri Dhammananda	In Loving Memory of Mdm Foo Kim Swee & Mr Ee Tham Poh Sponsored by Mr. Ee Fook Choy & Family
ABHIDHAMMA FOR BEGINNER by Egerton C. Baptist	Miss Ang Poh Tin

MY CONTRIBUTION TOWARDS THE REPRINTING OF BUDDHIST LITERATURE FOR FREE DISTRIBUTION

To. Date..

SINGAPORE BUDDHIST MEDITATION CENTRE
342-D Pasir Panjang Road, Singapore 0511.
Tel: 7783330 Fax: 7730150

I would wholeheartedly like to join in making this Dhamma gift and herewith is my personal contribution of S$/M$......................Cheque/Money order.

NAME..

ADDRESS ....

....

....

....

MONEYORDERNO ....

CHEQUENO ....

N.B.
All contributions are to be made payable to

"SINGAPORE BUDDHIST MEDITATION CENTRE PRINTING FUND"
342-D Pasir Panjang Road, Singapore 0511.
Tel: 7783330 Fax: 7730150

Yours in the Dhamma

....

සීවලී මහ රහතන් වහන්සේ
SIVALI ARAHATH

Singapore Buddhist Meditation Centre